

ឯកសារគម្ពីរព្រះត្រៃបិដកស្កេននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដើម ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កេនដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងថ្លៃថ្លាអំពីៈ

- ឧបាសិកា កាំង ហ៊ុចហ៊ែណ (ភ្នំពេញ)
- ឧបាសក ដុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា រ៉ាវី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ដុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្ដីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក
# ខុទ្ទកនិកាយ ជាតក
## ទសមភាគ
# ៦១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៣

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។

ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។

ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន" ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | | |
|---|---|---|---|---|
| 世話人代表 | 無着　成恭 | 世話人 | 松永　然道 | 有馬　実成 |
| 事務局長 | 篠原　鋭一 | | 伊藤　佳通 | 渡井　奎一 |
| | | | 杉谷　義純 | 茂田　真澄 |
| | | | 前田　利勝 | 中島　教之 |
| | | | 永　六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ជាតក

## ទសមភាគ

៦១

ព.ស. ២៥០៣

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស ជាតកំ

# ទសមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បញ្ញាសនិបាតជាតកំ

## និឡិនិកាជាតកំ

(១) ឧទ្ទយ្ហតេ ជនបទោ រដ្ឋញ្ចាបិ វិនស្សតិ

ឯហិ និឡិនិកេ គច្ឆ តំ មេ ព្រាហ្មណមានយ ។

(២) នាហំ ទុក្ខក្ខមា រាជ នាហំ អទ្ធានកោវិទា

កថំ អហំ គមិស្សាមិ វនំ កុញ្ជរសេវិតំ ។

(៣) ផីតំ ជនបទំ គន្ត្វា ហត្ថិនា ច រថេន ច

ទារុសង្ឃាដយានេន ឯវំ គច្ឆ និឡិនិកេ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ជាតក

# ទសមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## បញ្ញាសនិបាតជាតក

## នឡិនិកាជាតក

(១) (ព្រះបាទព្រហ្មទត្ត ត្រាស់ថា) ម្នាលនាងនឡិនិកា ជនបទក្តៅស្ងួត ទាំងដែនក៏វិនាស ចូរនាងមក ចូរនាងទៅញុំាងព្រាហ្មណ៍ (អ្នកធ្វើនូវសេចក្តីវិនាស) ដល់អញនោះ ឲ្យមកលុះអំណាចរបស់ខ្លួន ។

(២) (នាងនឡិនិកា ក្រាបទូលថា) បពិត្រព្រះរាជា ខ្ញុំម្ចាស់អត់ទ្រាំសេចក្តីលំបាកពុំបាន ខ្ញុំម្ចាស់មិនស្ទាត់ផ្លូវឆ្ងាយ ខ្ញុំម្ចាស់នឹងទៅកាន់ព្រៃ ដែលមានដំរីនៅអាស្រ័យ ដូចម្តេចបាន ។

(៣) (ព្រះរាជា...) ម្នាលនាងនឡិនិកា នាងចូរទៅកាន់ជនបទដ៏ស្តុកស្តម្ភ ហើយទៅដោយដំរីផង ដោយរថផង ដោយយាន (ទូក) ដែលគេគាបដោយឈើផង យ៉ាងនេះចុះ ។

ហត្ថី អស្សា រថា បត្តី គច្ឆេវាទាយ ខត្តិយេ
តវេវ វណ្ណរូបេន វសំ តមានយិស្សសិ ។

(៤) កទលីធជបញ្ញាណោ អាភុជិបរិវារិតោ[១]
ឯសោ បទិស្សតិ រម្មោ ឥសិសិង្គស្ស អស្សមោ ។
ឯសោ អគ្គិស្ស សង្ខាតោ ឯសោ ធូមោ បទិស្សតិ
មញ្ញេ នោ អគ្គិ ហាបេតិ ឥសិសិង្គោ មហិទ្ធិកោ ។

(៥) តញ្ច ទិស្វាន អាយន្តឹ អាមុត្តមណិកុណ្ឌលឹ
ឥសិសិង្គោ បាវិសិ ភីតោ អស្សមំ បណ្ណឆាទនំ ។
អស្សមស្ស ច សា ទ្វារេ គេណ្ឌុកេនស្ស កីឡតិ
វិទំសយន្តី អង្គានិ គុយ្ហំ បកាសិតានិ ច ។

(៦) តញ្ច ទិស្វាន កីឡន្តឹ បណ្ណសាលគតោ ជដី
អស្សមា និក្ខមិត្វាន ឥទំ វចនមព្រវិ ។

---

១ ឱ. អាភុជិបរិវារណោ ។

ម្នាលខត្តិយានី ចូរនាងយកដំរី សេះ រថ និងពលថ្មើរជើង ទៅចុះ ចូរនាងនាំព្រាហ្មណ៍ឥសិសិង្គៈនោះមកកាន់អំណាច (ខ្លួន) ដោយសម្ផស្សនិងរូបឆោមរបស់នាង ។

(៤) (ពួកព្រានព្រៃបង្ហាញថា) នុ៎ះ ប្រាកដជាអាស្រមរបស់តាបសឈ្មោះឥសិសិង្គៈជាទីគួររីករាយ មានដើមចេកជាទង់ ជាគ្រឿងសំគាល់ មានដើមស្មាច់ដុះព័ទ្ធជុំវិញ ។ នុ៎ះ ភ្លើងដែលឥសិសិង្គៈនោះតាក់តែង (ដោយឈាន) នុ៎ះ ផ្សែងដែលឃើញប្រាកដ ខ្ញុំសំគាល់ថា ឥសិសិង្គៈ អ្នកមានឫទ្ធិច្រើន មិនញុំាងភ្លើងឲ្យសាបសូន្យទេ ។

(៥) (អភិសម្ពុទ្ធគាថា) ឥសិសិង្គៈ បានឃើញនាងនឡិនិកានោះពាក់កុណ្ឌលកែវមណី កំពុងដើរមក ក៏ភិតភ័យ ចូលទៅកាន់អាស្រមដែលប្រក់ដោយស្លឹក ។ ឯនាងនឡិនិកានោះ ក៏បង្ហាញនូវអវយវៈទាំងឡាយផង បញ្ចេញនូវកេរ្តិ៍ខ្មាសដ៏កំបាំងផង ហើយលេងកូនឃ្លីក្បែរទ្វារអាស្រមនៃឥសិសិង្គៈនោះ ។

(៦) អ្នកមានជដា (ឥសិសិង្គៈ) នៅក្នុងបណ្ណសាលា ឃើញនាងនឡិនិកានោះ កំពុងលេង ចេញអំពីអាស្រមមកនិយាយពាក្យនេះថា

## បញ្ញាសនិបាតេ បឋមំ នឡិនិកាជាតកំ

អម្ភោ កោ នាម សោ រុក្ខោ យស្ស តេវំ គតំ ផលំ
ទូរេបិ ខិត្តំ បច្ចេតិ ន តំ ឱហាយ គច្ឆតិ ។
(៧) អស្សមស្ស មម ព្រហ្មេ សមីបេ គន្ធមាទនេ
ពហវោ តាទិសា រុក្ខា យស្ស តេវំ គតំ ផលំ
ទូរេបិ ខិត្តំ បច្ចេតិ ន មំ ឱហាយ គច្ឆតិ ។
(៨) ឯតុ ភវំ អស្សមិមំ អទេតុ
បជ្ជញ្ច ភក្ខញ្ច បដិច្ឆ ទម្មិ
ឥទមាសនំ អត្រ ភវំ និសីទតុ
ឥតោ ភវំ មូលផលានិ ភុញ្ជតុ ។
(៩) កិន្តេ ឥទំ ឩរូនមន្តរស្មឹ
សុបិច្ឆិតំ កណ្ហរិវប្បកាសតិ
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ
កោសេ នុ តេ ឧត្តមង្គំ បវិដ្ឋំ ។
(១០) អហំ វនេ មូលផលេសនំ ចរំ
អសាទយឹ អច្ឆំ សុឃោររូបំ
សោ មំ បតិត្វា សហសជ្ឈប្បត្តោ
បនុជ្ជ មំ អព្ពហិ ឧត្តមង្គំ ។

ម្នាលអ្នកដ៏ចំរើន ឈើរបស់អ្នកនោះឈ្មោះអ្វី ដែលមានផ្លែបែបនេះ សូម្បីអ្នកបោះទៅក្នុងទីឆ្ងាយហើយ ក៏វិលត្រឡប់មកវិញ មិនទៅបោលអ្នក ។

(៧) (នាងនឡិនិកា...) បពិត្រតាបសដ៏ប្រសើរ ផ្លែបែបនេះនៃឈើណា សូម្បីខ្ញុំបោះទៅក្នុងទីឆ្ងាយក៏ត្រឡប់មកវិញ មិនទៅបោលខ្ញុំទេ ឈើបែបនោះមានក្នុងទីជិតអាស្រមនៃខ្ញុំ នាភ្នំគន្ធមាទន៍ ។

(៨) (ឥសិសិង្គៈ...) អ្នកដ៏ចំរើន ចូរមកកាន់អាស្រមនេះចុះ ចូរបរិភោគអាហារចុះ ចូរទទួលថ្នាំសម្រាប់លាបជើងផង កក្យា–ហារផង ខ្ញុំជូន(ដល់អ្នក) នេះអាសនៈ អ្នកដ៏ចំរើន ចូរអង្គុយលើអាសនៈនេះ អ្នកដ៏ចំរើន ចូរពិសាមើមឈើនិងផ្លែឈើក្នុងទីនេះចុះ ។

(៩) (ឥសិសិង្គៈសួរថា) អ្វីនេះកំពុងល្អ (ដូចមាត់ខ្យងបៀ) នៅត្រង់ចន្លោះភ្លៅរបស់អ្នក ប្រាកដដូចជាវត្ថុមានពណ៌ខ្មៅ ។ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនុះ អវយវៈដ៏ឧត្តម(លិង្គ)របស់អ្នកលិចចូលទៅក្នុងស្រោម (សរីរៈ) ឬ ។

(១០) (នាងនឡិនិកា...) ខ្ញុំត្រាច់ទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើក្នុងព្រៃ បានបោលខ្លាឃ្មុំមានរូបដ៏សម្បើម ខ្លាឃ្មុំនោះស្ទុះមកសង្គ្រប ខ្ញុំដោយរហ័ស ផ្តួលខ្ញុំហើយខាំដកយកអវយវៈដ៏ឧត្តមទៅ ។

ស្វាយំ វណោ ឧជ្ជតិ កណ្ហាភាយតិ
សព្វញ្ញុ កាលំ ន លភាមិ សភតំ
បហោ ភវំ កណ្ហមិមំ វិនេតុំ
កុរុតំ ភវំ យាចិតោ ព្រាហ្មណត្តំ ។

(១១) គម្ភីររូឡោ តេ វណោ សណោហិតោ
អប្បតិកោ បន្នគន្ធោ(១) មហា ច
ករោមិ តេ កិញ្ចិ កសាយយោគំ
យថា ភវំ បរមសុខី ភវេយ្យ ។

(១២) ន មន្តយោគា ន កសាយយោគា
ន ឱសធា ព្រហ្មចារី កមន្តិ
យំ តេ មុទុ តេន អង្គេន វិនេហិ កណ្ហំ(២)
យថា អហំ បរមសុខី ភវេយ្យំ ។

(១៣) ឥតោ នុ ភោតោ កតមេន អស្សមោ
កច្ចិ ភវំ អភិរមសិ អរញ្ញេ
កច្ចិ នុ តេ មូលផលំ បហូតំ
កច្ចិ ភវន្តំ ន វិហឹសន្តិ វាឡា ។

---

១ ម. វណោគន្ធោ ។ បក្កគន្ធោតិ អដ្ឋកថា យំ ទិស្សតិ ។ ២ ម. យន្តេ មុទុកេន វិនេហិ កណ្ហំ ។ យន្តេ មុទុកេន អង្គេន វិនេហិ កណ្ហន្តិបិ បាឋោ ។

ដំបៅនោះឯង ឈឺពេកផង រមាស់ផង ខ្ញុំមិនបានសេចក្ដីសុខ សព្វៗកាលទេ អ្នកដ៏ចំរើនអាចនាំចេញនូវរោគរមាស់នេះចេញ បាន អ្នកដ៏ចំរើនដែលខ្ញុំអង្វរហើយ សូមធ្វើនូវប្រយោជន៍ដល់ ព្រាហ្មណ៍ ។

[១១] (ឥសិសិង្គ:...) ដំបៅរបស់អ្នកមានសភាពដ៏ជ្រៅ មានសម្បុរ ក្រហម មិនស្អុយទេ គ្រាន់តែមានក្លិនខ្លោះ (បន្តិចៗ) ហើយ ថែមទាំងធំផង ខ្ញុំនឹងប្រកបដោយថ្នាំផុស លាបឲ្យអ្នកបន្តិច មើល ដើម្បីនឹងឲ្យអ្នកដ៏ចំរើន បានសេចក្ដីសុខស្រួល ។

[១២] (នាឡិនិកា...) បពិត្រតាបសដ៏ប្រសើរ ការប្រកបដោយ មន្តទាំងឡាយក៏មិនត្រូវ ការប្រកបដោយថ្នាំផុសទាំងឡាយក៏ មិនត្រូវ ឱសថទាំងឡាយក៏មិនត្រូវ អវយវៈណារបស់លោក ដ៏ទន់ៗ ប្ដូរលោកនាំចេញនូវរោគរមាស់ដោយអវយវៈនោះ ទើប ខ្ញុំមានសេចក្ដីសុខស្រួលតទៅ ។

[១៣] (ឥសិសិង្គ:...) អាស្រមរបស់អ្នកដ៏ចំរើននៅខាងណាអំពីទីនេះ ម្នាលអ្នកដ៏ចំរើន អ្នកអភិរម្យ ក្នុងព្រៃដែរឬ អ្នកមានមើមឈើ ផ្លែឈើច្រើនដែរឬ សត្វសាហាវទាំងឡាយ មិនបៀតបៀនអ្នក ដ៏ចំរើនទេឬ ។

## បញ្ញាសនិបាតេ បឋមំ នឡិនិកាជាតកំ

(១៤) ឥតោ ឧជុំ ឧត្តរាយំ ទិសាយំ
ខេមា នទី ហិមវន្តា បភាតិ[1]
តស្សា តីរេ អស្សមោ មយ្ហ រម្មោ
អហោ ភវំ អស្សមំ មយ្ហ បស្សេ ។
អម្ពា ច សាលា តិលកា[2] ច ជម្ពុយោ
ឧទ្ទាលកា បាដលិយោ ច ផុល្លា
សមន្តតោ កិម្បុរិសាភិគីតំ
អហោ ភវំ អស្សមំ មយ្ហ បស្សេ ។
តាលា ច មូលា ច ផលា ច មេត្ថ
វណ្ណេន គន្ធេន ឧបេតរូបំ
តំ ភូមិភាគេហិ ឧបេតរូបំ
អហោ ភវំ អស្សមំ មយ្ហ បស្សេ ។
ផលា ច មូលា ច បហូតមេត្ថ
វណ្ណេន គន្ធេន រសេនុបេតា
អាយន្តិ ច លុទ្ទកា តំ បទេសំ
មា មេ តតោ មូលផលំ អហាសុំ ។

---

១ ម. ហិមវតា បភាវី ។ ២ តិណ្ឌុកាតិ អដ្ឋកថាយំ ទិស្សតិ ។

(១៨) (នាងនឡិនិកា...) អាស្រមរបស់ខ្ញុំជាទីគួររីករាយ (នៅ) ក្បែរឆ្នេរនៃស្ទឹងឈ្មោះខេមា ដែលហូរទៅអំពីព្រៃហិមវន្ត នាំទិសខាងជើងត្រង់អំពីទីនេះ ធ្វើដូចម្តេចហ្ន៎ អ្នកដ៏ចំរើន គប្បីឃើញអាស្រមរបស់ខ្ញុំ ។ (ទៀបអាស្រមរបស់ខ្ញុំ) មានដើមស្វាយ រាំងភ្នំ ទន្លាប់ ព្រីង រាជព្រឹក្ស ប្រទៀង មានផ្ការីកស្គុះស្គាយ ធ្វើដូចម្តេចហ្ន៎ អ្នកដ៏ចំរើន គប្បីឃើញអាស្រមរបស់ខ្ញុំ ដែលមានកិន្នរ ច្រៀងពីរោះដោយជុំវិញ ។ ក្នុងទីជិតអាស្រមរបស់ខ្ញុំនុ៎ះ មានដើមត្នោតទាំងឡាយផង មើមឈើទាំងឡាយផង ផ្លែឈើទាំងឡាយផង ធ្វើដូចម្តេចហ្ន៎ ទើបអ្នកដ៏ចំរើន គប្បីឃើញនូវអាស្រមរបស់ខ្ញុំ ដែលប្រកបដោយពណ៌និងក្លិន ដែលប្រកបដោយភូមិភាគទាំងឡាយ (ដ៏រាបស្មើ) នោះ ។ ផ្លែឈើទាំងឡាយផង មើមឈើទាំងឡាយផង មានគរគោកក្នុងអាស្រមនេះ ប្រកបដោយពណ៌ ក្លិន និងរស តែពួកព្រានព្រៃ តែងមកកាន់ប្រទេសនោះ កុំឲ្យពួកវាលួចមើមឈើនិងផ្លែឈើរបស់ខ្ញុំអំពីអាស្រមនោះឡើយ ។

(១៥) បិតា មម មូលផលេសនំ គតោ

ឥទានិ អាគច្ឆតិ សាយកាលេ

ឧភោវ គច្ឆាមសេ អស្សមន្តំ

យាវ បិតា មូលផលតោ ឯតុ ។

(១៦) អញ្ញេ ពហូ ឥសយោ សាធុរូបា

រាជីសយោ អនុមគ្គេ វសន្តិ

តេយេវ បុច្ឆេសិ មមស្សមន្តំ

តេ តំ នយិស្សន្តិ មមំ សកាសេ ។

(១៧) ន តេ កដ្ឋានិ ភិន្នានិ ន តេ ឧទកមាភតំ

អគ្គិបិ តេ ន ហាសិតោ កិន្នុ មន្ទោវ ឈាយសិ ។

ភិន្នានិ កដ្ឋានិ ហុតោ ច អគ្គិ

តបនីបិ តេ សមិតា សព្រហ្មចារី

បីឋញ្ច មយ្ហំ ឧទកញ្ច ហោតិ

រមសិ តុវំ ព្រហ្មភូតោ បុរត្ថា ។

១៥) (ឥសិសិង្គ:...) បិតារបស់ខ្ញុំ ទៅកាន់ទីស្ងួតរកមើមឈើ ផ្លែឈើនឹងមកក្នុងកាលល្ងាច ឥឡូវនេះចាំបិតា មកអំពីទីស្ងួត រកមើមឈើនឹងផ្លែឈើសិន សឹមយើងទាំងពីរនាក់ ទៅកាន់អាស្រមនោះ ។

(១៦) (នាងនឡិនិកា ...) មានពួកព្រាហ្មណ៍ជាឥសី នឹងពួកព្រះរាជាជាឥសីដទៃទៀតជាច្រើន ដែលជាមនុស្សត្រឹមត្រូវនៅក្បែរផ្លូវជាលំដាប់ ចូរអ្នកសួររកអាស្រមខ្ញុំនឹងឥសីទាំងនោះចុះ ឥសីទាំងនោះនឹងនាំអ្នកទៅឯសំណាក់ខ្ញុំ (មិនខាន) ។

(១៧) (ពោធិសត្វ ជាបិតាសួរថា) ឧសក៏អ្នកមិនពុះ ទឹកក៏អ្នកមិនដង ទាំងភ្លើងក៏អ្នកមិនបង្កាត់ ហេតុអ្វីបានជាអ្នកជ្រប់ស្រពោន ។ ម្នាលកូនសព្រហ្មចារី ឧសទាំងឡាយអ្នកធ្លាប់តែពុះ ភ្លើងអ្នកធ្លាប់តែបង្កាត់ ទាំងភ្លើងសម្រាប់អាំងក៏អ្នកធ្លាប់ចាត់ចែង តាំងក៏អ្នកធ្លាប់រៀបចំសម្រាប់អញ ទឹកក៏អ្នកធ្លាប់តែដកល់ទុកសម្រាប់អញ កាលពីមុន អ្នកជាមនុស្សប្រសើរ តែងរីករាយ (ក្នុងអាស្រមនេះ) ។

## បញ្ញាសនិបាតេ បឋមំ នឡិនិកាជាតកំ

អភិន្នកដ្ឋោសិ អនាភតោទកោ
អហាសិតគ្គីសិ អសិទ្ធភោជនោ[(១)]
ន មេ តុវំ អាលបសិ មមជ្ជ
នដ្ឋំ នុ កឹ ចេតសិកញ្ច ទុក្ខំ ។

(១៨) ឥធាគមា ជដិលោ ព្រហ្មចារី
សុទស្សនេយ្យោ សុតនូ វិនេតិ
នេវាតិទីឃោ ន បនាតិរស្សោ
សុកណ្ហកណ្ហច្ឆទនេហិ ភោតោ ។
អមស្សុជាតោ អបុរាណវណ្ណី
អាធាររូបញ្ច បនស្ស កណ្ឋេ
ទ្វេ យមា គណ្ឌា ឧរេ សុជាតា
សុវណ្ណតិណ្ឌុសន្និភា បភស្សរា ។
មុខញ្ច តស្ស ភុសទស្សនេយ្យំ
កណ្ណេសុ លម្ពន្តិ ច កុញ្ចិតគ្គា
តេ ជោតរេ ចរតោ មាណវស្ស
សុត្តញ្ច យំ សំយមនំ ជដានំ ។

---

១ ឱ. អហាបិតគ្គីសិ អសិទ្ធភោជនោ ។ ម. អហាបិតគ្គីបិ អសិទ្ធភោជនោ ។

បញ្ញាសនិបាត នឡិនិកាជាតក

(ឥឡូវនេះ) អ្នកមិនពុះអុស មិនដងទឹក មិនបង្កាត់ភ្លើង មិនស្ងោរ
វត្ថុសម្រាប់បរិភោគ នៃកូនរបស់អញ ថ្ងៃនេះអ្នកមិនហៅរកអញ
អ្នកបាត់របស់អ្វី ឬក៏អ្នកកើតទុក្ខ ក្នុងចិត្តដូចម្ដេច ។

[១៨] (ឥសិសិង្គ:...) ជដិលជាអ្នកប្រព្រឹត្តធម៌ប្រសើរមកក្នុងទីនេះ ជា
មនុស្សគួរគេយកគន់ មានដងខ្លួនទ្រទេសទ្រទន់ មិនខ្ពស់ពេក មិន
ទាបពេក ញុំាងអាស្រមបទឲ្យភ្លឺសាយពាសពេញ ដោយសក់
ទាំងឡាយដែលខ្មៅស្រិលដូចជាពណ៌នៃស្លាបកន្ទុំ របស់ជដិល
ដ៏ចំរើន (នោះ) ។ (ជដិលនោះ) មិនទាន់ដុះពុកមាត់នៅ
ឡើយទេ ទើបនឹងបួសថ្មី ៗ មានទាំងរបស់មានសណ្ឋានដូចដើម
ហ្គ្រ ពាក់ត្រង់ករបស់គាត់ មានពកពីរជាគូ ភ្លឺបំព្រង ដូចជា
ផ្លែទន្លាប់មាស ដុះក្បាលត្រង់ទ្រូង ។ មុខជដិលនោះ គួរគេយ
គន់ក្រៃពេក មានកំពូល នៃគ្រឿងប្រដាប់ត្រចៀកទាំងឡាយ
សំយុងចុះ ឭដ៏ត្រចៀកទាំងឡាយ កាលមាណព (នោះ)
ត្រាប់ទៅ គ្រឿងប្រដាប់ នៃត្រចៀកទាំងនោះ ក៏រុងរឿង
ផ្លេកៗ ផងមានទាំងខ្សែស្រយ រុំព័ទ្ធផ្ទង់សក់ទាំងឡាយផង ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

អញ្ញា ច តស្ស សំយមានិ ចតស្សោ
នីលា បីតា លោហិតកា ច សេតា
តា សំសរេ ចរតោ មាណវស្ស
តិរិដិសង្ឃារិវ ភាវុសម្ហិ ។
ន មេខលំ មុញ្ជមយំ ធារេតិ
ន សន្ថរេ នោ បន បព្ពជស្ស
តា ជោតរេ ជឃនន្តរេ វិលគ្គា
សតេរិតា វិជ្ជុរិវន្តលិក្ខេ ។
អឌីលកានិ ច អវណ្ដកានិ ។
ហេដ្ឋា នភ្យា កដិសមោហិតានិ
អយន្តិតា និច្ចកីឡំ ករោន្តិ
ហន្ទាន កឹ រុក្ខជលានិ តានិ ។
ជដា ច តស្ស កុសនស្សធេយ្យា
បកេសតំ វេល្លិតគ្គា សុគន្ធា
ទ្វេធាសិរោ សាធុវិភត្តរូបោ
អហោ នុខោ មយ្ហ តថា ជដាស្សុ ។

មាណពនោះ មានគ្រឿងប្រដាប់ដៃទៀតមានពន្លឺ៤ ពណ៌គឺ ព័ណ៌ខៀវលឿង ក្រហម ស កាលបើមាណព(នោះ) ដើរទៅគ្រឿងប្រដាប់ទាំងនោះញ័រ ៗ ដូចជាពួកនៃសត្វមេភ្លៀង ក្នុងពេលកំពុងភ្លៀង ៗ (មាណពនោះ) មិនពាក់សង្វារស្មៅយាប្លងទេ មិនប្រើប្រាស់សំពត់សំបកឈើទេ មិនប្រើប្រាស់សំពត់ដែលត្បាញដោយស្មៅដំណេកទន្សាយទេ គ្រឿងប្រដាប់ទាំងនោះ ជាប់នៅត្រង់ចន្លោះនៃស្តន ភ្លឺដូចជាផ្លេកបន្ទោរ ដែលចាំងព្វង់អាកាស ៗ (មាណពនោះមានគ្រឿងប្រដាប់ដេរដោយសូត្រ) មិនមានស្នាមគ្រោតគ្រាតផង មិនមានទង (អាចម៍ដង្កូវ) ផង ចង់ព័ទ្ធត្រង់ចង្កេះពីត្រឹមផ្ចិតចុះទៅខាងក្រោម គ្រឿងប្រដាប់ទាំងនោះ ទុកជាឥតមានអ្វីប៉ះពាល់សោះ ក៏ធ្វើនូវល្បែងជានិច្ច គឺញ័ររវិចជាប្រក្រតី បពិត្របិតាដ៏ចំរើន គ្រឿងប្រដាប់ទាំងនោះឈ្មោះថាផ្លែឈើអ្វី ៗ ផ្នួងសក់របស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក (បើមើល) ជាងមួយរយដង (ក៏មិនអស់ចិត្ត) មានចុងងខ្វង់ មានក្លិនក្រអូប (មាណពនោះ) មានសក់ក្បាលញែកជាពីរ សិតញែកស្អាតបាត ធ្វើដូចម្តេចហ្ន៎ នឹងបានឲ្យផ្នួងសក់របស់ខ្ញុំល្អដូច្នោះផង ៗ

## បញ្ញាសនិបាតេ បឋមំ នឡិនិកាជាតកំ

យទា ច សោ បកិរតិ តា ជដាយោ
វណ្ណេន គន្ធេន ឧបេតរូបា
នីលុប្បលំ វាតសមេរិតំវ
តថេវ សំវាយតិ បនស្សមោ អយំ ។
បង្កោ ច តស្ស ភុសទស្សនេយ្យោ
នេតាទិសោ យាទិសោ មយ្ហ កាយោ
សោ វាយតិ ឯរិតោ មាលុតេន
វនំ យថា អគ្គគិម្ហេ សុផុល្លំ ។
និហន្តិ សោ រុក្ខផលំ បថព្យា
សុចិត្តរូបំ រុចិរំ ទស្សនេយ្យំ
ខិត្តញ្ច តស្ស បុនរេតិ ហត្ថំ
ហន្ទាត កឹ រុក្ខផលំ នុ ខោ តំ ។
ទន្តា ច តស្ស ភុសទស្សនេយ្យា
សុទ្ធា សមា សង្ខវរូបបន្នា
មនោ បសាទេន្តិ វិវរិយមានា
ន ហិ នូន សោ សាកមខាទិ តេហិ ។

មាណពនោះវាសាយសក់ក្នុងកាលណា ផ្នូងសក់ទាំងឡាយនោះក៏ប្រកបដោយពណ៌ ដោយក្លិន ក្នុងកាលនោះ អាស្រមនេះក៏ផ្សព្វផ្សាយទៅ ( ដោយក្លិន ) ដូចជាផ្កាឧប្បលខៀវ ដែលខ្យល់បក់ត្រូវដូច្នោះ ។ សម្បុររបស់មាណពនោះ គួរឲ្យចង់មើលក្រៃពេក កាយរបស់មាណពនោះ មិនដូចជាកាយរបស់ខ្ញុំឡើយ កាយរបស់មាណពនោះ កាលបើត្រូវខ្យល់បក់មកផ្សព្វផ្សាយក្លិន ដូចជាព្រៃឈើដែលមានផ្ការីកស្គុះស្គាយ ក្នុងខាងចុងនៃគិម្ហរដូវ ។ មាណពនោះ តែងទះនូវផ្លែឈើ មានសភាពដ៏វិចិត្រល្អរុងរឿង គួរឲ្យចង់មើល បោះទៅលើផែនដី ផ្លែឈើនោះវិលត្រឡប់មករកដៃរបស់មាណពនោះវិញ បពិត្រឫសីដ៏ចំរើន នោះជាផ្លែឈើអ្វី ។ ធ្មេញទាំងឡាយរបស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ស្អាតស្មើដូចជាស័ង្ខ ដែលគេខាត់យ៉ាងសំខាន់ កាលដែលគាត់ហាមាត់ឡើង តែងញាំងចិត្តឲ្យជ្រះថ្លា ដ្បិតមាណពនោះ មិនទំពាស៊ីនូវបន្លែ ដោយធ្មេញទាំងឡាយនោះទេ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

អកក្កសំ អគ្គឡិតំ មុហុំ មុហុំ
ឧជុំ អនុទ្ធតំ អចបលមស្ស ភាសិតំ
រុទំ មនុញ្ញំ ករវីកសុស្សរំ
ហទយង្គមំ រញ្ជយតេវ មេ មនោ ។
ពិន្ទុស្សរោ នាតិវិសដ្ឋវាក្យោ
ន នូន សជ្ឈាយមតិប្បយុត្តោ
ឥច្ឆាមិ ខោ តំ បុនទេវ ទដ្ឋុំ
មិត្តញ្ហិ មេ មាណវហុ បុរត្តា ។
សុសន្ធិ សព្វត្ថ វិមដ្ឋិមំ វណំ
បុថុ សុជាតំ ខរបត្តសន្និភំ
តេនេវ មំ ឧត្តរិយាន មាណវោ
វិវរិយ ឩរុំ ជឃនេន បីឡយិ ។
តបន្តិ អាភន្តិ វិរោចរេ ច
សតេរតា វិជ្ជុរិវន្តលិក្ខេ
ពាហា មុទូ អញ្ជនលោមសាទិសា
វិចិត្រវដ្ដង្គុលិកាស្ស សោភរេ ។

សំដីរបស់មាណពនោះ និយាយឡើង មិនជាសំដីអាក្រក់ មិនក្អាត់
ពីរោះ ស្រទន់ ត្រង់ ៗ មិនពាយមាយ មិនព្រកោកកាក ជាសំដី
ញុំាងចិត្តឲ្យរីករាយ គួរចាប់ចិត្តដូចជាសំឡេងនៃសត្វករវិកយាស
យំ ចិត្តរបស់ខ្ញុំត្រេកអរខ្លាំងណាស់ ៗ ( មាណពនោះ)មានសំ-
ឡេងមូល មានពាក្យមិនស្ងួវក្បោះក្បាយពេកទេ មិនមែនជាអ្នក
ខ្វល់ខ្វាយក្នុងការស្វាធ្យាយ(មន្ត)ដោយពិត ខ្ញុំចង់ឃើញមាណព
នោះម្តងទៀត ដ្បិតមាណព(នោះ)ជាមិត្តរបស់ខ្ញុំតាំងពីមុនដម្បូង
មក ៗ ដំបៅ ( ត្រង់ចន្លោះភ្លៅរបស់មាណពនោះ) ជិតស្និទ្ធល្អ
លើងស្អាតសព្វអន្លើ ក្រាស់ក្បំល្អដូចជាផ្កាឈូកក្រពុំ មាណព
( នោះ) គ្របសង្កត់ខ្ញុំដោយដំបៅនោះឯង សើយភ្លៅហើយគាប
ខ្ញុំដោយស្មុន ៗ ( រស្មីដូចមាសដែលផ្សាយចេញអំពីសរីរៈកាយនៃ
មាណពនោះ) ភ្លឺត្រចះត្រចង់ ភ្លឺស្វាង រុងរឿងភ្លឺផ្លេក ៗ ដូចជាផ្លេក
បន្ទោរធ្លៀលធ្លាក់លើអាកាស ដើមដៃទាំងពីរទន់ក្អន់មានរោមប្រ-
ហែលកេសផ្កាអញ្ជ័ន មាណពនោះមានម្រាមដៃមូល ៗ ដ៏វិចិត្រល្អ ៗ

## បញ្ញាសនិបាតេ បឋមំ នឡិនិកាជាតកំ

អកក្កសង្គោ ន ច ទីឃលោមោ
នខស្ស ទីឃា អបិ លោហិតគ្គា
មុទូហិ ពាហាហិ បលិស្សជន្តោ
កល្យាណរូបោ រមយំ(១) ឧបដ្ឋហិ ។

ទុមស្ស តូលូបនិភា បភស្សរា
សុវណ្ណកម្ពុតលវដ្ដសុច្ឆវី
ហត្ថា មុទូ តេហិ មំ សំផុសិត្វា
ឥតោ គតោ តេន មំ ទហន្តិ តាត ។

ន នូន សោ ខារិវិធំ អហាសិ
ន នូន សោ កដ្ឋានិ សយំ អភញ្ជិ
ន នូន សោ ហន្តិ ទុមេ កុឋារិយា
នហិស្ស ហត្ថេសុ ខិលានិ អត្ថិ ។

អច្ឆាច ខោ តស្ស វណំ អកាសិ
សោ មំ ព្រវី សុខិតំ មំ ករោហិ
តាហំ ករឹ តេន មមាសិ(២) សោខ្យំ
សោ ច ព្រវី សុខិតោស្មីតិ ព្រហ្មេ ។

---

១ ម. មយ្ហំ ។ ២ ម. មហតិ ។

ម្យ៉ាងទៀត (មាណពនោះ) មានអវយវៈតូចធំ មិនរដិបរដុប (ដោយមុននឹងបួសជាដើម)ទេ មានរោមមិនវែងពេកទេ ឯក្រចករបស់មាណពនោះវែង ៗ មានចុងក្រហម ៗ (មាណពនោះ) មានរូបល្អ ឱបរឹត (ខ្ញុំ) ដោយដើមដៃទាំងពីរដ៏ទន់ល្វន់ (ផ្គាប់ផ្គុន) (ខ្ញុំ)ឲ្យរីករាយ ៗ ដៃទាំងពីររបស់មាណពនោះ ដូចជាប៉ុយឈើ មានស្ទីផ្តុក ៗ មានបាតដៃមូលនឹងធរីណ្ណស្រស់បំព្រង ដូចផ្លែកញ្ចក់ជាវិការៈនៃមាស មាណពនោះពាល់ខ្ញុំ ដោយដៃទាំងពីរនោះហើយ ទៅពីទីនេះទៅ បពិត្របិតា មាណពនោះដុតរោលខ្ញុំ (ឲ្យក្តៅក្រហាយ) ដោយសម្ផស្សនៃដៃនោះ ៗ មាណពនោះប្រហែលជាមិនដែលនាំទៅនូវវត្ថុមានទម្ងន់មួយខារី (មួយអំរែក) ទេ មាណពនោះ មិនដែលពុះឧសទាំងឡាយខ្លួនឯងទេ មាណពនោះ មិនដែលកាប់ឈើទាំងឡាយ ដោយកាំបិតទេ បានជាដៃរបស់មាណពនោះមិនក្រិនសោះ ៗ មានខ្លាឃ្មុំមួយធ្វើមាណពនោះឲ្យមានដំបៅ គេបាននិយាយនឹងខ្ញុំថា សូមឲ្យអ្នកធ្វើខ្ញុំឲ្យបានសេចក្តីសុខស្រួល ខ្ញុំក៏បានធ្វើគាត់ឲ្យបានសុខស្រួល ដោយអវយវៈដ៏ឧត្តមនោះរបស់ខ្ញុំ បពិត្របិតាដ៏ប្រសើរ មាណពនោះបាននិយាយប្រាប់ខ្ញុំថា ខ្ញុំបានសេចក្តីសុខស្រួលហើយ ៗ

អយញ្ច តេ មាលុវបណ្ណសន្ថតា
វិកិណ្ណរូបាវ មយា ច តេន ច
កិលន្តរូបា ឧទកេ រមិត្វា
បុនប្បុនំ បណ្ណកុដឹ វជាម ។
ន មជ្ជ អន្តា បដិភន្តិ តាត
ន អគ្គិហុត្តំ នបិ យញ្ញតន្ត្រ
ន ចាបិ តេ មូលផលានិ ភុញ្ជេ
យាវ ន បស្សាមិ តំ ព្រហ្មចារឹ ។
អទ្ធា បជានាសិ តុវំបិ តាត
យស្មឹ ទិសាភាគំ វសតេ ព្រហ្មចារី
តំ មំ ទិសំ បាបយ តាត ខិប្បំ
មា តេ អហំ អមរិមស្សមម្ហិ
វិចិត្រផុល្លញ្ហិ(១) វនំ សុតំ មយា
ទិជាភិឃុដ្ឋំ ទិជសង្ឃសេវិតំ
តំ មំ វនំ បាបយ តាត ខិប្បំ
បុរា តេ បាណំ វិជហាមិ អស្សមេ ។

១ ឱ. វិចិត្របុប្ផំ ហិ ។

នេះគម្រោលនៃស្លឹកឈើទាល មានសភាពពក់ពាយ ដែលខ្ញុំនឹងគេដេក ប្រកៀកប្រទុបលើគ្នា យើងទាំងពីរនាក់នោះអស់កម្លាំងក៏ចុះងូតទឹក ហើយចូលទៅកាន់បណ្ណកុដិរៀង ៗ ។ បពិត្របិតា ខ្ញុំមិនបានជួបនឹងព្រហ្មចារីនោះ ដរាបណា មន្តទាំងឡាយមិនជាក់ច្បាស់ដល់ខ្ញុំក្នុងថ្ងៃនេះផង ខ្ញុំមិនពេញចិត្តនឹងការបូជាភ្លើងផង មិនពេញចិត្តនឹងការបូជាយ័ញ្ញផង ទាំងមិនបរិភោគមើមឈើនឹងផ្លែឈើរបស់លោកផង ដរាបនោះ ។ បពិត្របិតា ចំណែកលោកជ្រាបច្បាស់ប្រាកដ ព្រហ្មចារី (នោះ) នៅក្នុងទិសណា បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ទិសនោះយ៉ាងឆាប់ កុំឲ្យខ្ញុំស្លាប់ក្នុងអាស្រមរបស់លោកឡើយ ដ្បិតខ្ញុំបានឮថា ព្រៃ ( ជាទីនៅនៃព្រហ្មចារីនោះ ) មានផ្ការីកស្គុះស្គាយដ៏វិចិត្រ ហើយជាទីគឹកកងដោយបក្សី ជាទីដែលពួកបក្សីនៅអាស្រ័យ (ជានិច្ច) បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ព្រៃនោះឆាប់ ៗ មុនខ្ញុំនឹងលះជីវិតក្នុងអាស្រមរបស់លោក ។

បញ្ញាសនិបាតេ បឋមំ នឡិនិកាជាតកំ

(១៩) ឥមស្មា ហិ ជោតិរសេ វនម្ហិ
គន្ធព្វទេវច្ឆរសង្ឃសេវិតេ
ឥសីនមាវាសេ សនន្តនម្ហិ
នេតាទិសំ អរតិ បាតុរហោសិ ។
ភវន្តិ មិត្តានិ អថោ ន ហោន្តិ
ញាតីសុ មិត្តេសុ ករោន្តិ បេមំ
អយញ្ច ជម្មោ កិស្ស ឥធ(១) និវិដ្ឋោ
យោ នេវ ជានាតិ កុតោម្ហិ អាគតោ ។
សំវាសេន ហិ មិត្តានិ សន្ធិយន្តិ បុនប្បុនំ
ស្វេវ មិត្តោ អសង្គន្តុ អសំវាសេន ជីរតិ ។
សចេ តុវំ ទក្ខសិ ព្រហ្មចារី
សចេ តុវំ សល្លបេ ព្រហ្មចារិនា
សម្បន្នសស្សំវ មហោទកេន
តបោគុណំ ខិប្បមិមំ បហស្សសិ ។

---
១ ឱ.ម. វា ។

(១៩) (ព្រះមហាសត្វ...) សេចក្ដីពិតថា បុគ្គលមិនគួរដល់នូវ
សេចក្ដីអផ្សុកបែបនេះ ក្នុងព្រៃដែលរុងរឿងដោយពន្លឺ ជាទីគឹកកង
ដោយពួកគន្ធព្វ និងស្រីទេពអប្សរ ជាទីនៅនៃឥសីទាំងឡាយ
ជាព្រៃមានតាំងពីយូរយារណាស់ហើយនេះឡើយ ៗ មិត្រ
ទាំងឡាយ មានខ្លះ មិនមានខ្លះ ជនទាំងឡាយគួរធ្វើនូវសេចក្ដី
ស្រឡាញ់ចំពោះញាតិនិងមិត្រ មនុស្សណាមិនដឹងថា អាត្មា
អញកើតមកពីណា មនុស្សនេះគម្រក់ ត្រូវមាតុគ្រាមបង្ខឹកបាន
ទាំងថ្ងៃ ដោយហេតុអ្វី ៗ ធម្មតាមិត្រទាំងឡាយ រមែងជាប់គ្នា
ដោយការនៅរួមរឿយ ៗ មិត្រនោះឯង រមែងលាកចិត្តដោយ
ការមិនបាននៅរួមគ្នា របស់បុរសដែលមិនបានទៅមករកគ្នា ៗ

បុនបិ ចេ ទក្ខសិ ព្រហ្មចារឹ
បុនបិ ចេ សល្លបេ ព្រហ្មចារិនា
សម្បន្នសស្សំវ មហោទកេន
ឧស្មាគតំ ទិប្បមិមំ បហាស្សសិ ។
ភូតានិ ហេតានិ ចរន្តិ តាត
វិរូបរូបេន មនុស្សលោកេ
ន តានិ សេវេថ នរោ សបញ្ញោ
អាសជ្ជនំ នស្សតិ ព្រហ្មចារីតិ ។

នឡិនិកាជាតកំ បឋមំ ។

---

## ឧម្មាទន្តីជាតកំ

(២០) និវេសនំ កស្ស នុទំ សុនន្ទ
បាការេន បណ្ឌុមយេន គុត្តំ
កា ទិស្សតិ អគ្គិសិខាវ ទូរេ
វេហាយសំ បព្វតគ្គេវ អច្ចិ ។

បើអ្នកឃើញនូវព្រហ្មចារី (នោះទៀត) បើអ្នកបរិភោគជាមួយនឹងព្រហ្មចារី (នោះទៀត) អ្នកនឹងបំផ្លាញនូវគេហគុណនេះយ៉ាងឆាប់មិនខាន ដូចជាសន្ទូងដ៏ល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ ។ បើអ្នកនឹងឃើញនូវព្រហ្មចារី (នោះ) ទៀត បើអ្នកបរិភោគជាមួយនឹងព្រហ្មចារី (នោះ) ទៀត អ្នកនឹងបំផ្លាញនូវតេជះរបស់សមណៈនេះ យ៉ាងឆាប់មិនខាន ដូចជាសន្ទូងល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ ។ នែកូន កូតទាំងឡាយនេះតែងត្រាច់ទៅក្នុងមនុស្សលោក ដោយបែបភាពនៃរូបផ្សេងៗ ដល់អ្នកមានប្រាជ្ញា មិនត្រូវគប់រកនឹងកូតទាំងឡាយនោះឡើយ បុគ្គលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែងវិនាសទៅ (ព្រោះដល់) នូវការជាប់ចំពាក់ (នឹងកូតបែបនោះឯង) ។

ចប់ នឡិនិកាជាតក ទី ១ ។

# ឧម្មាទន្តីជាតក

[៦០] (ព្រះបាទសិវិ ត្រាស់សួរសារថីថា) ហៃសុនន្ទៈ នេះជាទីលំនៅរបស់នរណាហ្ន៎ ដែលព័ទ្ធព័ទ្ធ ដោយកំពែង ធ្វើដោយឥដ្ឋពណ៌ក្រហម ស្រ្តីអ៊ីប្រាកដ ដូចអណ្តាតភ្លើង ក្នុងទីឆ្ងាយ ឬដូចជាអណ្តាតភ្លើង ព្លង់អាកាសលើកំពូលភ្នំ ។

ធីតា ត្វយំ កស្ស សុនន្ទ ហោតិ
សុណិសា ត្វយំ កស្ស អថោបិ ភរិយា
អក្ខាហិ មេ វិប្បមិធេវ បុដ្ឋា
អភាវតា យទិ វា អត្ថិ ភត្តា ។

(២១) អហំ ហិ ជានាមិ ជនិន្ទ ឯតំ
មត្យា ច បេត្យា ច អថោបិ អស្សា
តតោ សោ បុរិសោ ភូមិបាល
រត្តិន្ទិវំ អប្បមត្តោ តវត្ថេ ។

ឥទ្ធោ ច ផីតោ ច សុវឌ្ឍិតោ ច
អមច្ចោ ច តេ អញ្ញតរោ ជនិន្ទ
តស្សេសា ភរិយា អភិបារកស្ស
ឧម្មាទន្តីតិ នាមធេយ្យេន រាជ ។

ម្នាលសុនន្ទៈ ស្ត្រីនេះជាធីតា របស់នរណាហ្ន៎ ស្ត្រីនេះជាកូនប្រសារ របស់នរណាហ្ន៎ ឬជាភរិយារបស់នរណា ប្រសិនបើ (ស្ត្រីនេះ) មិនទាន់មានគេហួងហែងក្តី មានភស្តាក្តី ខ្ញុំសួរហើយ ចូរអ្នកប្រាប់យ៉ាងឆាប់ ក្នុងកាលឥឡូវនេះកុំខាន ។

(២១) (សារថីក្រាបបង្គំទូលថា) បពិត្រព្រះជនិន្ទៈ ខ្ញុំព្រះអង្គស្គាល់ស្ត្រីនុ៎ះជាក់លាក់ អំពីចំណែកខាងមាតាផង អំពីចំណែកខាងបិតាផង ទាំងស្វាមីរបស់ស្ត្រីនោះក៏ខ្ញុំព្រះអង្គស្គាល់ បពិត្រព្រះភូមិបាល ស្វាមីនោះជាបុរសរបស់ព្រះអង្គហ្នឹងឯង ជាអ្នកមិនប្រហែសធ្វេសក្នុងប្រយោជន៍របស់ព្រះអង្គ ទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះជនិន្ទៈ ព្រះអង្គមានអាមាត្យម្នាក់ ជាអ្នកស្តុកស្តម្ភមាំមួន ថ្កុំថ្កើង បពិត្រព្រះរាជា ស្ត្រីនោះឈ្មោះនាង ឧម្មាទន្តី ជាប្រពន្ធរបស់អាមាត្យ ឈ្មោះអភិបារកៈនោះឯង ។

(២២) អម្ភោ អម្ភោ នាមមិទំ ឥមិស្សា
មត្យា ច បេត្យា ច កតំ សុសាធុ
តទាហិ មយ្ហំ អវលោកយន្តី
ឧម្មត្តកំ ឧម្មាទន្តី អកាសិ ។

(២៣) យា បុណ្ណមាសេ មិគមន្ទលោចនា
ឧបាវិសី បុណ្ឌរីកត្តចង្គី
ទ្វេ បុណ្ណមាយោ តទហូ អមញ្ញឹ(១)
ទិស្វាន បារាវតរត្តវាសិនឹ ។
អឡារបម្ហេហិ សុភេហិ វគ្គុភិ
បលោភយន្តី មំ យទា ឧទិក្ខតិ
វិជម្ភមានា ហរតេវ មេ មនោ
ជាតា វនេ កឹបុរិសីវ បព្វតេ ។
តទា ហិ ព្រហតី សាមា អាមុត្តមណិកុណ្ឌលា
ឯកច្ចវសនា នារី មិគី ភន្តាវុទិក្ខតិ ។
កទាស្សុ មំ តម្ពនខា សុលោមា
ពាហា មុទូ ចន្ទនសារលិត្តា

---

១ ឱ. អមញ្ញំ ។ ម. អមញ្ញហំ ។

[២២] (ព្រះរាជា...) រ៉ឺយ រ៉ឺយ ឈ្មោះនេះដែលមាតាបិតាបានឱ្យដល់នាងនេះ ត្រូវល្អណាស់ បានជាថាដូច្នោះ ព្រោះនាងឧម្មាទន្តី កាលក្រឡេកមើលអញ ធ្វើអញឱ្យឆ្កួត ។

[២៣] ស្ត្រីណាមានភ្នែកស្រទន់ដូចភ្នែកម្រឹគ មានសរីរៈសម្បុរដូចផ្កាឈូកក្រហម អង្គុយអែប (ក្បែរបង្អួច) ក្នុងរាត្រីដែលមានព្រះចន្ទពេញវង់ អញបានឃើញស្រីនោះ ដែលមានសំលៀកបំពាក់ក្រហមដូចជាដើមព្រាប កំស្មានថាជាព្រះចន្ទពេញវង់ពីរ ។ (នាងឧម្មាទន្តី) ប្រលោមអញដោយអាការទ្រទេសទ្រទន់ល្អស្រស់ ជាប្រធាននៃការដ៏វិសេស មុឹកម៉ក់ក្រឡេកមើលអញ ចិត្តរបស់អញក៏រវើរវាយ ដូចជាក្នុងកាលដែលកិន្នរញីកើតក្នុងព្រៃភ្នំ (ហិមពាន្តៈធ្វើកិន្នរឈ្មោលឱ្យមានចិត្តរវើរវាយដូច្នោះ) ។ ដ្បិតក្នុងកាលនោះ នាងនារីមានសម្បុរលឿង ពាក់កុណ្ឌលកែវមណី មានសំលៀកបំពាក់តែមួយ ក្រឡេកមើល (អញ) ដូចជាមេម្រឹគផ្អើល ។ កាលណាហ្ន៎ នឹងបាននារី មានក្រចកក្រហមទុំ មានរោមល្អ មានដើមដៃទន់ក្ងន់ លាបស្រឡាបដោយខ្លឹមចន្ទន៍

វដ្ដង្គុលី សន្នតធីរកុត្តិយា
នារី ឧបញ្ញិស្សតិ សីសតោ សុភា ។
កទាស្សុ មំ កញ្ចនជាលុរច្ឆទា
ធីតា តិរីដិស្ស វិលាកមជ្ឈា
មុទូហិ ពាហាហិ បលិស្សជិស្សតិ
ព្រហាវនេ ជាតទុមំវ មាលុវា ។
កទាស្សុ មំ លាខារសរត្តសុច្ឆវី
ពិន្ទុត្ថនី បុណ្ឌរីកត្តចង្គី
មុខំ មុខេន ឧបនាមយិស្សតិ
សោណ្ឌោវ សោណ្ឌស្ស សុរាយ ថាលំ ។

យទាទ្ទសំ តំ តិដ្ឋន្តិំ សព្វគត្តំ(១) មនោរមំ
តតោ សកស្ស ចិត្តស្ស នាវពោធាមិ កញ្ចិនំ ។
ឧម្មាទន្តី មយា ទិដ្ឋា អាមុត្តមណិកុណ្ឌលា(២)
ន សុប្បាមិ ទិវារត្តិំ សហស្សំវ បរាជិតោ ។
សក្កោ ចេ មេ វរំ ទជ្ជា សោ ច លព្ភេថ មេ វរោ
ឯករត្តំ ទ្វិរត្តំ វា ភវេយ្យំ អភិបារកោ
ឧម្មាទន្ត្យា រមិត្វាន សិវិរាជា តតោ សិយា ។

---

១ ម. សព្វភទ្ទំ ។ ២ ម. ឧម្មាទន្តិមហំ ទិដ្ឋា អាមុត្តមណិកុណ្ឌលំ ។

មានម្រាមដៃមូល ប្រសប់ខាងផ្ទើម្រឹកម៉ាក់ ល្អផុតបុងសក់ មកឱប
អង្អែលអញ ។ កាលណាហ្ន៎ អញនឹងបានធីតារបស់សេដ្ឋីឈ្មោះ
តិរិដិ ដែលមានគ្រឿងប្រដាប់ទ្រូងជាវិការៈនៃមាស មានដង
ខ្លួនវៀវ មកឱបរិតអញដោយដើមដៃទាំងពីរដ៏ទន់ភ្លន់ ដូចជា
ពួរជ្រៃដែលរួបរឹតដើមឈើដុះក្នុងព្រៃធំ ។ កាលណាហ្ន៎ អញនឹង
បាន( នារី ) ដែលមានសម្បុរល្អស្រស់ ដូចជាទឹកល័ក្តក្រហម
មានដោះកំរ្យូដូចជាពពុះទឹក មានសរីរៈសម្បុរដូចផ្កាឈូកក្រហម
បង្អោនមុខមកប៉ះនឹងមុខ (អញ) ដូចជាអ្នកលេង (ដែលហុច)កែវ
សុរា ឲ្យដល់អ្នកលេងផងគ្នា ។ អញបានឃើញនារីនោះមានខ្លួន
សមរម្យសព្វអន្លើ ជាតម្រេកនៃចិត្ត កំពុងឈរក្នុងកាលណា
អញមិនបានជាឥស្សរៈ (លើចិត្តរបស់ខ្លួន) មិនស្គាល់នារីនោះជា
ជាអ្វីឡើយ ក្នុងកាលនោះ ។ អញបានឃើញនាងឧម្មាទន្តី ដែល
ពាក់កុណ្ឌលជាវិការៈនៃកែវមណី ក៏ដេកមិនលក់ទាំងថ្ងៃទាំងយប់
ដូចជាគេផ្ចាញ់អស់មួយពាន់ដង ។ បើសក្កទេវរាជប្រទានពរ
ដល់អញ សូមឲ្យអញបានពរនោះជាអភិបារកសេនាបតី សូម
ត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តីតែមួយយប់ពីរយប់ប៉ុណ្ណោះ
ចុះ តពីនោះទៅ សូមព្រះបាទសិវិរាជ (ត្រេកត្រអាលជាមួយ
នឹងនាងឧម្មាទន្តីវិញ ) ។

(២៤) ភូតានិ មេ ភូតបតី នមស្សតោ
អាគម្ម យក្ខោ ឥទមេតទព្រវិ
រញ្ញោ មនោ ឧម្មាទន្ត្យា និវិដ្ឋោ
ទទាមិ តេ តំ បរិចារយស្សុ ។

(២៥) បុញ្ញា ច ធំសេ អមរោ ន ចម្ហិ
ជនោ ច មេ បាបមិទញ្ច ជញ្ញា
ភុសោ ច ត្យស្ស មនសោ វិឃាតោ
ទត្វា បិយំ ឧម្មាទន្តឹ អទិដ្ឋា ។

(២៦) ជនិន្ទ នាញ្ញត្រ តយា មយា វា
សព្វាបិ កម្មស្ស កតស្ស ជញ្ញា
យន្តេ មយា ឧម្មាទន្តី បទិន្នា
ភុសេហិ រាជា វនថំ សជាហិ ។

(២៧) យោ បាបកំ កម្មករំ មនុស្សោ
សោ មញ្ញតិ មាយិទំ មញ្ញឹសុ អញ្ញេ
បស្សន្តិ ភូតានិ ករោន្តមេតំ
យុត្តា ច យេ ហោន្តិ នរា បថព្យា ។

[២៤] (អភិបារកសេនាបតី ..) បពិត្រព្រះអង្គជាម្ចាស់នៃជន កាលដែលទូលព្រះបង្គំជាខ្ញុំសំពះទេវតាទាំងឡាយ មានទេវតា (មួយអង្គ) មកពោលពាក្យដូច្នេះថា ព្រះទ័យរបស់ព្រះរាជាជាប់បំពាក់នឹងនាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយព្រះអង្គ សូមព្រះអង្គឲ្យនាងឧម្មាទន្តីនោះបំរើចុះ ។

[២៥] (ព្រះរាជា..) ខ្ញុំគប្បីឃ្លាតចាកបុណ្យផង ខ្ញុំមិនមែនជាមិនស្លាប់ផង អ្នកផងដឹងនូវអំពើអាក្រក់ របស់ខ្ញុំនេះផង សេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យ (នាងឧម្មាទន្តី) ជាទីស្រឡាញ់ហើយមិនបានឃើញទៀតផង ។

[២៦] (អភិបារក ..) បពិត្រព្រះជនិន្ទៈ លើកលែងតែព្រះអង្គនឹងទូលព្រះបង្គំជាខ្ញុំចេញ អ្នកទាំងពួងមិនគប្បីដឹងនូវអំពើដែលទូលព្រះបង្គំជាខ្ញុំថ្វាយនាងឧម្មាទន្តី ដល់ព្រះអង្គទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យខ្លាំងក្លាចូរ (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យហើយ សូមលះបង់ចុះ) ។

[២៧] (ព្រះរាជា...) មនុស្សណា ធ្វើអំពើអាក្រក់ មនុស្សនោះតែងសំគាល់ថា ជនទាំងឡាយដទៃ ពុំដឹងនូវអំពើអញនេះឡើយ តែពួកភូតនឹងពួកនរជនដែលប្រកប (ដោយឫទ្ធិ) លើផែនដី រមែងឃើញបុគ្គល ដែលធ្វើបាបកម្មនុ៎ះ ។

អញ្ញោ នុ តេ កោចិ នរោ បថព្យា
សទ្ធេយ្យ លោកស្មិំ ន មេ បិយោតិ
ភុសោ ច ត្យស្ស មនសោ វិឃាតោ
ឥត្វា បិយំ ឧម្មាទន្តី អនិដ្ឋា ។

(២៨) អត្តា បិយា មយ្ហ ជនិន្ទ ឯសា
ន សា មមំ អប្បិយា ភូមិបាល
គច្ឆេវ ត្វំ ឧម្មាទន្តី ភទ្ទន្តេ
សីហោវ សេលស្ស គុហំ ឧបេតិ ។

(២៩) ន បីឡិតា អត្តទុក្ខេន ធីរា
សុខប្ផលំ កម្ម បរិច្ចជន្តិ
សម្មោហិតា វាបិ សុខេន មត្តា
ន បាបកម្មញ្ច សមាចរន្តិ ។

(៣០) តុវញ្ហិ មាតា ច បិតា ច មយ្ហំ
ភត្តា បតី បោសកោ ទេវតា ច
ទាសោ អហំ តុយ្ហ សបុត្តទារោ
យថាសុខំ សីវិ(១) ករោហិ កាមំ ។

១ ម. សាមិ ។ ឱ. សិព្វ ។

ជនដទៃណាហ្ន៎+ លើផែនដីក្នុងលោក គប្បីជឿចិត្តអ្នកថា នាង (ឧម្មាទន្តី) មិនជាទីស្រឡាញ់របស់អញ ដូច្នេះ ទាំងសេចក្តីបង្អៀតបង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀត ។

[២៨] (អកិបារក... ) បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ+ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះ មិនមែនមិនជាទីស្រឡាញ់ របស់ទូលព្រះបង្គំជាខ្ញុំទេ សូមសេចក្តីចំរើនចូរមានដល់ព្រះអង្គ សូមព្រះអង្គយាងទៅកាន់សំណាក់នាងឧម្មាទន្តីកុំខាន ដូចជាសីហៈឈ្មោលចូលទៅកាន់គុហាកែវមណី (ជាលំនៅរបស់សីហៈញី) ដូច្នោះ ។

[២៩] (ព្រះរាជា... ) អ្នកប្រាជ្ញទាំងឡាយ (បើទុកជា) ត្រូវសេចក្តីទុក្ខក្នុងខ្លួនបៀតបៀនហើយ ក៏មិនលះបង់នូវអំពើដែលមានផលជាសុខឡើយ ឬនោះបី វង្វេងជ្រុលជ្រប់ក្តី ស្រវឹងដោយសេចក្តីសុខក្តី ក៏គង់មិនប្រព្រឹត្តធ្វើបាបកម្មទេ ។

[៣០] (អកិបារក... ) ព្រះអង្គដូចជាមាតាបិតា ជាអ្នកចិញ្ចឹម ជាម្ចាស់ ជាអ្នកបីបាច់រក្សា ទាំងជាទេវតារបស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះបាទសិវិ ខ្ញុំព្រះអង្គព្រមទាំងកូនប្រពន្ធជាទាសៈរបស់ព្រះអង្គ សូមទ្រង់ធ្វើសេចក្តីប្រាថ្នាតាមសប្បាយចុះ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

(៣១) យោ ឥស្សរោម្ហីតិ ករោតិ បាបំ
កត្វា ច សោ នុត្តបតេ បរេសំ
ន តេន សោ ជីវតិ ទីឃមាយុំ
ទេវាបិ បាបេន សមេក្ខរេ នំ ។

(៣២) អញ្ញាតកំ សាមិកេហិ បទិន្នំ
ធម្មេ ឋិតា យេ បដិច្ឆន្តិ ទានំ
បដិច្ឆកា ទាយកា ចាបិ តត្ថ
សុខប្ផលញ្ញេវ ករោន្តិ កម្មំ ។

(៣៣) អញ្ញេ នុ តេ កោចិ នរេ បឋព្យា
សទ្ធេយ្យ លោកស្មិំ ន មេ បិយាតិ
កុសោ ច តស្ស មនសោ បិយោ តោ
ឧត្វា បិយំ ឧម្មាទន្តី អតិដ្ឋា ។

(៣៤) អន្វា បិយា មយ្ហំ ជនិន្ទ ឯសា
ន សា មមំ អប្បិយា ភូមិបាល
យន្តេ មយា ឧម្មាទន្តី បទិន្នា

(៣១)(ព្រះរាជា...)បុគ្គលណាអាងថា អាត្មាអញជាធំដូច្នេះហើយ ធ្វើនូវអំពើអាក្រក់ បុគ្គលនោះលុះបានធ្វើរួចហើយក៏មិនរអែងនឹងពួកជនដទៃ ព្រោះអំពើនោះបុគ្គលនោះមិនរស់នៅអស់កាលជាអង្វែង ទាំងពួកទេវតាក៏តែងរំពៃមើលបុគ្គលនោះ ដោយអំពើអាក្រក់ ។

(៣២)(អភិបារក...) បុគ្គលទាំងឡាយណា តាំងនៅក្នុងធម៌ ទទួលយកនូវទានដែលគេមិនស្គាល់ ដែលម្ចាស់ទាំងឡាយ ប្រគល់ឲ្យហើយ បុគ្គលជាអ្នកទទួលទាំងឡាយ(នោះ)ផង អ្នកឲ្យទាំងឡាយផង ឈ្មោះថាធ្វើនូវអំពើមានផលជាសុខក្នុងហេតុនោះ ។

(៣៣)(ព្រះរាជា...)បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា (នាងឧម្មាទន្តី) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្តគប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង ។

(៣៤)(អភិបារក... )បពិត្រព្រះជនិន្ទ: នាងឧម្មាទន្តីនុ៎ះជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ នាងឧម្មាទន្តីទូលព្រះបង្គំជាខ្ញុំបានថ្វាយហើយ ចំពោះព្រះអង្គដោយហេតុណា

## បញ្ញាសនិបាតេ ទុតិយំ ឧម្មាទន្តីជាតកំ

ភុសេហិ រាជា វនថំ សជាហិ ។

(៣៥) យោ អត្តទុក្ខេន បរស្ស ទុក្ខំ
សុខេន វា អត្តសុខំ ទហាតិ
យថេវិទំ មយ្ហ តថា បរេសំ
យោ ឯវំ បជានាតិ ស វេទិ ធម្មំ ។

(៣៦) អញ្ញោ នុ តេ កោចិ បរោ បជញ្ញា
សទ្ធេយ្យ លោកស្មិំ ន មេ បិយាតិ
ភុសោ ច តស្ស មនសោ វិឃាតោ
ទត្វា បិយំ ឧម្មាទន្តឹ អទិដ្ឋា ។

(៣៧) ជនិន្ទ ជានាសិ បិយា មមេសា
ន សា មមំ អប្បិយា ភូមិបាល
បិយេន តេ ទម្មិ បិយំ ជនិន្ទ
បិយទាយិនោ ទេវ បិយំ លភន្តិ ។

បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យខ្ទាំងកាប់ចុះ (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យ)សូមលះបង់ចុះ ។

(៣៥) (ព្រះរាជា....) បុគ្គលណាឲ្យទុក្ខដល់ជនដទៃ ដោយទុក្ខរបស់ខ្លួន ឬដណ្ដើមសុខដើម្បីខ្លួន អំពីសុខ (របស់ជនដទៃ) (បុគ្គលនោះឈ្មោះថាមិនស្គាល់ធម៌) លុះតែបុគ្គលណាដឹងច្បាស់យ៉ាងនេះថា សុខទុក្ខរបស់អញនេះយ៉ាងណា សុខទុក្ខរបស់ជនដទៃក៏យ៉ាងនោះដែរ បុគ្គលនោះទើបឈ្មោះថា អ្នកដឹងធម៌ ។

(៣៦) បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា (នាងឧម្មាទន្តី) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្ដីបង្អៀតបង្អល់ចិត្តគប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀតផង ។

(៣៧) (អភិបារក...) បពិត្រព្រះជនិន្ទៈ ព្រះអង្គគង់ជ្រាបថា នាងឧម្មាទន្តីនុ៎ះជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ បពិត្រព្រះជនិន្ទៈ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនាងឧម្មាទន្តីជាទីស្រឡាញ់ចំពោះព្រះអង្គ ដោយចិត្តជាទីស្រឡាញ់ បពិត្រព្រះសម្មតិទេព បុគ្គលអ្នកឲ្យនូវវត្ថុជាទីស្រឡាញ់ទាំងឡាយ រមែងបាននូវវត្ថុជាទីស្រឡាញ់វិញ ។

(៣៨) សោ ទូរតោហំ វធិស្សាមិ អត្តានំ កាមហេតុកំ

នហិ នម្ពុំ អនម្ពេន អហំ វធិតុមុស្សហោ ។

(៣៩) សចេ តុំ មយ្ហ សតី ជនិន្ទ

ន កាមយាសិ នរវីរសេដ្ឋ

ចជាមិ នំ សព្វជនស្ស មជ្ឈេ

មយា បមុត្តំ តតោ អវ្ហយេសិនំ ។

(៤០) អទូសិយញ្ចេ អភិចារកា តុវំ

ចជាសិ កត្តេ អហិតាយ ត្យស្ស

មហា ច តេ ឧបវាទោបិ អស្ស

ន ចាបិ ត្យស្ស នគរម្ហិ បក្ខោ ។

(៤១) អហំ សហិស្សំ ឧបវាទមេតំ

និន្ទំ បសំសំ គរហញ្ច សព្វំ

មមេតមាគច្ឆតុ ភូមិបាល

យថាសុខំ សិវិ ករោហិ កាមំ ។

(៣៨) (ព្រះរាជា...) អញនោះមុខជានឹងសម្លាប់ខ្លួន ព្រោះមានកាមជាហេតុ ដោយពិត អញនឹងមិនអាចដើម្បីសម្លាប់នូវធម៌ដោយអធម៌ឡើយ ។

(៣៩) (អកិត្តាបារក...) បពិត្រព្រះជនិន្ទៈ ទ្រង់មានព្យាយាមក្នុងពួកជនដ៏ប្រសើរ បើព្រះអង្គមិនសប់ព្រះរាជហឫទ័យនឹងនាងឧម្មាទន្តី ដែលជារបស់ទូលព្រះបង្គំជាខ្ញុំទេ ទូលព្រះបង្គំជាខ្ញុំនឹងលះបង់នាងនាកណ្ដាលជនទាំងពួង តពីនោះទៅ ព្រះអង្គគប្បីនាំយកនាងឧម្មាទន្តីនោះ ដែលទូលព្រះបង្គំជាខ្ញុំលះបង់ហើយ ។

(៤០) (ព្រះរាជា...)នែអកិត្តាបារកៈ បើអ្នកលះបង់ (នាងឧម្មាទន្តី)ដែលមិនមានទោស នៃអ្នកធ្វើ(ប្រយោជន៍ដល់ខ្ញុំ)ការលះបង់នោះគប្បីមិនជាប្រយោជន៍ដល់អ្នកផង ពាក្យតំណះតំនៀលយ៉ាងច្រើនគប្បីមានដល់អ្នកផង បក្ខពួករបស់អ្នកក្នុងនគរ មិនគប្បីមានផង ។

(៤១) (អកិត្តាបារក...)បពិត្រព្រះភូមិបាល ទូលព្រះបង្គំជាខ្ញុំនឹងអត់ទ្រាំនូវពាក្យតំណះតំនៀលទុះផង នូវនិន្ទាផង នូវសេចក្ដីសរសើរផង នឹងការពោលទោសគ្រប់យ៉ាងថា ហេតុទាំងនុ៎ះ ចូរមកដល់ទូលព្រះបង្គំជាខ្ញុំចុះ បពិត្រព្រះបាទសិវិ សូមទ្រង់ធ្វើនូវសេចក្ដីប្រាថ្នាតាមសប្បាយចុះ ។

## បញ្ញាសនិបាតេ ទុតិយំ ឧម្មាទន្តីជាតកំ

យោ ទេវ និន្ទំ ន បុនប្បសំសំ
អាទិយតិ គរហំ នោបិ បូជំ
សិរី ច លក្ខី ច អបេតិ តម្ហា
អាបោ សុវុដ្ឋីវ យថា ថលម្ហា ។
យង្កិញ្ចិ ទុក្ខញ្ច សុខញ្ច ឯត្តោ
ធម្មាតិសារញ្ច មនោវិឃាតំ
ឧរសា អហំ បដិច្ឆិស្សាមិ[1] សព្វំ
បថវី យថា ថាវរានំ តសានំ ។
(៤២) ធម្មាតិសារញ្ច មនោវិឃាតំ
ទុក្ខញ្ច និច្ឆាមិ អហំ បរេសំ
ឯកោបិមំ តារយិស្សាមិ ភារំ
ធម្មេ ឋិតោ កិញ្ចិ អហាបយន្តោ ។
(៤៣) សគ្គូបគំ បុញ្ញកម្មំ ជនិន្ទ
មា មេ តុវំ អន្តរាយំ អកាសិ
ទទាមិ តេ ឧម្មាទន្តីំ បសន្នោ
រាជាវ យញ្ញេ ធនំ ព្រាហ្មណានំ ។

---

១ ឱ. បច្ចុបទិស្សាមិ ។ ម. បច្ចុត្តរិស្សាមិ ។

បុគ្គលណា មិនអើពើនឹងនិន្ទា មិនអើពើនឹងសេចក្ដីសរសើរ មិនអើពើនឹងពាក្យពោលទោស មិនអើពើនឹងការបូជា សេចក្ដីបញ្ញាក្ដី រមែងទៅប្រាសចាកបុគ្គលនោះដូចជាទឹក គឺទឹកភ្លៀងយ៉ាងស្រួល ដែលទៅប្រាសចាកទីទួលដូច្នោះ ។ ទូលព្រះបង្គំជាខ្ញុំនឹងទទួលនូវសេចក្ដីទុក្ខផង នូវសេចក្ដីសុខផង នូវអំពើអាក្រក់ហួសផ្លូវធម៌ផង នូវសេចក្ដីបង្អៀតបង្អល់ចិត្ត គ្រប់យ៉ាងតាមតែយ៉ាងណាក៏ដោយ អំពីដំណើរនេះ ដោយផ្ទាល់ទ្រូងដូចជាផែនដី (ដែលទទួលនូវវត្ថុណាមួយ) របស់ពួកជនអ្នកមាំមួន គឺព្រះអរហន្ត និងរបស់ពួកជនអ្នកតក់ស្លុត គឺបុថុជ្ជន ។

(៤២) (ព្រះរាជា...) ខ្ញុំមិនប្រាថ្នាអំពើអាក្រក់ហួសផ្លូវធម៌ផង សេចក្ដីទុក្ខជាគ្រឿងបង្អៀតបង្អល់ចិត្តផង ដល់ជនទាំងឡាយដទៃទេ ខ្ញុំតែម្នាក់ឯង ឋិតនៅក្នុងធម៌ មិនញុំាងប្រយោជន៍បន្តិចបន្តួចឲ្យសាបសូន្យទៅទេ ហើយនឹងធ្ងន់នូវភារៈ គឺសេចក្ដីទុក្ខនេះ ។

(៤៣) (អភិបារកៈ...) បពិត្រព្រះជនិន្ទៈ ព្រះអង្គកុំធ្វើនូវបុញ្ញកម្មជាគ្រឿងញុំាងសត្វឲ្យកើតក្នុងឋានសួគ៌របស់ទូលព្រះបង្គំជាខ្ញុំឲ្យអន្តរាយឡើយ ទូលព្រះបង្គំជាខ្ញុំជ្រះថ្លា ថ្វាយនាងឧម្មាទន្តីបំពោះព្រះអង្គ ដូចជាព្រះរាជា (ដែលទ្រង់ព្រះរាជទាន) នូវទ្រព្យក្នុងការបូជា ដល់ពួកព្រាហ្មណ៍ ។

(៤៤) អទ្ធា តុវំ កត្តេ ហិតោសិ មយ្ហំ
សខា មមំ ឧម្មាទន្តី តុវញ្ច
និន្ទេយ្យុ ទេវា បិតរោ ច សព្វេ
បាបញ្ច បស្សំ អភិសម្បរាយំ ។

(៤៥) នហេតំ ធម្មំ សីវិរាជ វជ្ជុំ
សនេគមា ជានបទា ច សព្វេ
យន្តេ មយា ឧម្មាទន្តី បទិន្នា
កុសេហិ រាជ វនថំ សជាហិ ។

(៤៦) អទ្ធា តុវំ កត្តេ ហិតោសិ មយ្ហំ
សខា មមំ ឧម្មាទន្តី តុវញ្ច
សព្វានិ ធម្មានិ សុកិត្តិតានិ
សមុទ្ទវេលាវ ទុរច្ចយានិ ។

(៤៧) អាហុនេយ្យោ មេសិ ហិតានុកម្បី
ធាតា វិធាតា ចសិ កាមបាលោ

(៤៤) (ព្រះរាជា...) ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមាន ប្រយោជន៍ដល់ខ្ញុំ ដោយពិត នាងខុម្មាទន្តី នឹងអ្នកជាសំឡាញ់ របស់ខ្ញុំ ពួកទេវតានឹងទេវតាជាបិតា នឹងអ្នក ទាំងអស់ មុខជានឹង ទាំងខ្ញុំក៏មុខជានឹងឃើញនូវបាបកម្មអកុសលប្បាយកត ពុំខាន ។

(៤៥) (អភិបារកៈ...) បពិត្រព្រះបាទសិវិ ពួកអ្នកនិគម នឹងពួក អ្នកជនបទទាំងអស់គ្នា មិនគប្បីពោលនូវអំពើ ដែលទូលព្រះបង្គំ ជាខ្ញុំ បានថ្វាយនាងខុម្មាទន្តីចំពោះព្រះអង្គនុះថាជាធម៌ទេ បពិត្រ ព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ (តណ្ហា) ឲ្យខ្ចាំងក្លា (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យហើយ) សូមលះបង់ចុះ ។

(៤៦) (ព្រះរាជា...) ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមាន ប្រយោជន៍ដល់ខ្ញុំ ដោយពិត នាងខុម្មាទន្តី នឹងអ្នកជាសំឡាញ់របស់ខ្ញុំ ធម៌ទាំងឡាយ ដែលពួកសប្បុរសបានសំដែងល្អ ហើយ ខ្ញុំប្រព្រឹត្តកន្លងបានដោយកម្រ ដូចជាសមុទ្រនឹងច្រាំង ។

(៤៧) (អភិបារកៈ...) ព្រះអង្គជាអាហុនេយ្យបុគ្គល ជាអ្នកអនុគ្រោះ ដោយប្រយោជន៍ ជាអ្នកទ្រទ្រង់ ជាអ្នកចាត់ចែង (ឥស្សរិយសុខ) នឹងជាអ្នករក្សានូវសេចក្តីប្រាថ្នា របស់ទូលព្រះបង្គំជាខ្ញុំ

## បញ្ញាសនិបាតេ ទុតិយំ ឧម្មាទន្តីជាតកំ

តយី ហុតា រាជ មហាប្ផលា ហិ
កាមេន មេ ឧម្មាទន្តី បដិច្ឆ ។

(៤៨) អទ្ធា ហិ សព្វំ អភិបារក ត្វំ
ធម្មំ អចារី មម កត្តុបុត្ត
អញ្ញោ នុ តេ កោ ឥធ សោត្ថិកត្តា
ទ្វិបទោ នរោ អរុណោ ជីវលោកេ ។

(៤៩) ត្វំ នុ សេដ្ឋោ ត្វមនុត្តរោសិ
ត្វំ ធម្មគុ ធម្មវិទូ សុមេធោ
សោ ធម្មគុត្តោ ចិរមេវ ជីវ
ធម្មញ្ច មេ ទេសយ ធម្មបាល ។

(៥០) តទិង្ឃ អភិបារក សុណោហិ វចនំ មម
ធម្មន្តេ ទេសយិស្សាមិ សតំ អាសេវិតំ អហំ ។
សាធុ ធម្មរុចី រាជា សាធុ បញ្ញាណវា នរោ
សាធុ មិត្តានមទ្ទុព្ភោ បាបស្សាករណំ សុខំ ។

បពិត្រព្រះរាជា នាងឧម្មាទន្តីដែលទូលព្រះបង្គំជាខ្ញុំ បានថ្វាយព្រះអង្គនឹងមានផលច្រើន សូមទ្រង់ទទួលយកនាងឧម្មាទន្តីតាមសេចក្តីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ ។

(៤៨) (ព្រះរាជា...) ម្នាលអភិបារកៈជាកូនរបស់សេនាបតី ជាអ្នកធ្វើនូវប្រយោជន៍ អ្នកមិនមែនជាបុគ្គលប្រព្រឹត្តនូវធម៌ទាំងអស់ដល់ខ្ញុំដោយពិត ជនមានជើងពីរដទៃ តើរូបណាក្នុងជីវលោកនេះ ជាអ្នកធ្វើនូវសួស្តីដល់អ្នក ក្នុងពេលអរុណរះ ។

(៤៩) (អភិបារកៈ...) ព្រះអង្គជាបុគ្គលប្រសើរផុត ព្រះអង្គជាបុគ្គលខ្ពង់ខ្ពស់ផុត ព្រះអង្គជាអ្នកដល់នូវធម៌ ជ្រាបច្បាស់នូវធម៌ មានព្រះប្រាជ្ញាប្រពៃ ទ្រង់ជាអ្នកគ្រប់គ្រងនូវធម៌ សូមទ្រង់មានព្រះជន្មាយុអស់កាលដ៏អង្វែង បពិត្រព្រះធម្មបាល សូមទ្រង់សំដែងធម៌ដល់ទូលព្រះបង្គំជាខ្ញុំ ។

(៥០) (ព្រះរាជា...) បើដូច្នោះ ម្នាលអភិបារកៈ អ្នកចូរស្តាប់ពាក្យខ្ញុំ ខ្ញុំនឹងសំដែងធម៌ដែលពួកសប្បុរសធ្លាប់សេព ដល់អ្នក ៗ ព្រះរាជា ជាអ្នកគាប់ចិត្តដោយធម៌ ទើបល្អ ជនមានប្រាជ្ញា ទើបល្អ ការមិនប្រទូស្តមិត្ត ទើបល្អ កិរិយាមិនធ្វើបាប ទើបសុខ ។

អក្កោធនស្ស វិជិតេ ឋិតធម្មស្ស រាជិនោ
សុខំ មនុស្សា អាសេថ សីតច្ឆាយាយ សង្ឃរេ ។
ន ចាហមេតំ អភិរោចយាមិ
កម្មំ អសមេក្ខកតំ អសាធុ
យេ ចាបិ ញត្វា ន សយំ ករោន្តិ
ឧបមា ឥមា មយ្ហំ តុវំ សុណោហិ ។
គវំ ចេ តរមានានំ ជិម្ហំ គច្ឆតិ បុង្គវោ
សព្វា តា ជិម្ហំ គច្ឆន្តិ នេត្តេ ជិម្ហំ គតេ សតិ ។
ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេ អធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ ទុក្ខំ សេតិ រាជា ចេ ហោតិ អធម្មិកោ ។
គវំ ចេ តរមានានំ ឧជុំ គច្ឆតិ បុង្គវោ
សព្វា តា ឧជុំ គច្ឆន្តិ នេត្តេ ឧជុំ គតេ សតិ ។
ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេបិ ធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោ ។

មនុស្សទាំងឡាយ គប្បីនៅជាសុខក្នុងផ្ទះរបស់ខ្លួន ក្នុងម្លប់ដ៏ត្រជាក់ ក្នុងដែននៃស្ដេចដែលមិនមានក្រោធ មានច្បាប់ឋិតថេរ ។ ខ្ញុំមិនគាប់ចិត្តនឹងអំពើដែលមិនពិចារណាហើយធ្វើ ដែលធ្វើមិនប្រពៃនុ៎ះទេ ម្យ៉ាងទៀត ជនទាំងឡាយណាដឹងថា (មិនប្រពៃ) ហើយមិនធ្វើដោយខ្លួនឯង ( អំពើរបស់ជនទាំងឡាយនោះ ទើបខ្ញុំពេញចិត្ត ) អ្នកស្ដាប់ពាក្យប្រៀបធៀបនេះរបស់ខ្ញុំចុះ ។ កាលគោទាំងឡាយកំពុងឆ្លងទៅ បើគោបាទៅវៀចផ្លូវ កាលបើគោអ្នកនាំផ្លូវទៅវៀចហើយ ពួកមេគោទាំងអស់នោះក៏ដើរវៀចដែរ ។ បណ្ដាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត បើជននោះប្រព្រឹត្តនូវអធម៌ទៅហើយ នឹងចាំបាច់និយាយទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់ តែងដេកជាទុក្ខ ។ កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោបាទៅត្រង់ កាលបើគោអ្នកនាំផ្លូវទៅត្រង់ហើយ ពួកមេគោទាំងអស់នោះក៏ដើរទៅត្រង់ ។ បណ្ដាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត បើជននោះប្រព្រឹត្តធម៌ នឹងចាំបាច់ពោលទៅថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាទ្រង់ប្រកបដោយធម៌ រាស្ត្រទាំងអស់ រមែងដេកជាសុខ ។

## បញ្ញាសនិបាតេ ទុតិយំ ឧម្មាទន្តីជាតកំ

ន ចាបាហំ អធម្មេន អមរត្តមភិបត្ថយេ
ឥមំ វា បថវឹ សព្វំ វិជេតុំ អភិបារកា ៗ
យញ្ហិ កិញ្ចិ មនុស្សេសុ រតនំ ឥធ វិជ្ជតិ
គាវោ ទាសោ ហិរញ្ញញ្ច វត្ថិយំ ហរិចន្ទនំ ៗ
អស្សិត្ថិយោ រតនំ មណិកញ្ច
យញ្ចាបិ មេ ចន្ទសុរិយា អភិបាលយន្តិ
ន តស្ស ហេតុ វិសមំ ចរេយ្យ
មជ្ឈេ សិវីនំ ឧសភោស្មិ ជាតោ ៗ
នេតា ហិតា ឧគ្គតោ រដ្ឋបាលោ
ធម្មំ សិវីនំ អបចាយមានោ
សោ ធម្មមេវានុវិចិន្តយន្តោ
តស្មា សកេ ចិត្តវសេ ន វត្តោ ៗ
(៥១) អទ្ធា តុវំ មហារាជ និច្ចំ អព្យសនំ សិវំ
ករិស្សសិ ចិរំ រជ្ជំ បញ្ញា ហិ តវ តាទិសី ៗ

មាលអភិបារកៈ ខ្ញុំមិនប្រាថ្នានូវភាពនៃខ្លួនជាទេវតា ដោយអធម៌ទេ ម្យ៉ាងទៀត (ខ្ញុំមិនប្រាថ្នា) ដើម្បីឈ្នះនូវផែនដីទាំងមូលនេះ (ដោយអធម៌ទេ) ។ ប៉ុន្តែបើក្នុងមនុស្សលោកនេះ មានគេនរណាមួយ គឺគោពាំងឡាយ ខ្ញុំ ប្រាក់ សំពត់ និងខ្ញុំមបន្ទន់ក្រហមដោយពិតដូច្នោះ ។ ព្រះចន្ទនឹងព្រះអាទិត្យទាំងឡាយនេះ គេក្ដុកនូវគេនៈណាមួយ គឺសេះនឹងស្ត្រីទាំងឡាយ តែមែណ៎ បុគ្គលមិនគួរប្រព្រឹត្តនូវធម៌មិនស្មើ ព្រោះហេតុនៃគេនរណានោះ ៗ ទេ យើងដូចជាគោឧសភ កើតក្នុងបំណោមនៃពួកជនអ្នកនៅក្នុងដែនសិវិ ។ ខ្ញុំនោះជាអ្នកដឹកនាំជាអ្នកស្វែងរកប្រយោជន៍ ល្បីល្បាញក្នុងនូវដែន លំអុតលំទ្ទនបំពោះប្រពៃណី (របស់ស្ដេចជាន់មុន) នៃអ្នកសិវិក្រស្ត្រទាំងឡាយ ជាអ្នកត្រិះរិះតែធម៌ ព្រោះហេតុនោះ ខ្ញុំមិនលុះក្នុងអំណាចនៃចិត្តរបស់ខ្លួនទេ ។

[៤១] (អភិបារកៈ...) បពិត្រមហារាជ ព្រះអង្គនឹងសោយរាជសម្បត្តិ ទៀងទាត់ មិនវិនាស គ្រប់គ្រាន់ បានយូរយារ ដោយពិត ដ្បិតប្រាជ្ញា របស់ព្រះអង្គប្រាកដដូច្នោះ ។

ឃនន្ទ អនុមោទាម យំ ធម្មំ នប្បមជ្ជសិ
ធម្មំ បមជ្ជ ខត្តិយោ រដ្ឋា ចវតិ ឥស្សរោ ។
ធម្មញ្ចរ មហារាជ មាតាបិតូសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ បុត្តទារេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ វាហនេសុ ពលេសុ ច
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ គាមេសុ និគមេសុ ច
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ រដ្ឋេសុ ជនបទេសុ ច
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ព្រះអង្គមិនប្រមាទបំពោះធម៌ណា ទូលព្រះបង្គំជាខ្ញុំសូមអនុមោទនាបំពោះធម៌នុ៎ះរបស់ព្រះអង្គ ក្សត្រជាឥស្សរៈប្រមាទបំពោះធម៌ហើយ រមែងឃ្លាតចាកដែន ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងមាតាបិតាទាំងឡាយ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងព្រះរាជបុត្រនិងអគ្គមហេសី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកមិត្រនិងអាមាត្យ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកវាហនៈផង ក្នុងពួកពលផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកស្រុកផង ក្នុងពួកអ្នកនិគមផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មញ្ចរ មហារាជ សមណេ ព្រាហ្មណេសុ ច
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ មិគបក្ខីសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ ធម្មោ ចិណ្ណោ[1] សុខាវហោ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ ឥន្ទា ទេវា សព្រហ្មកា
សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បមាទោតិ ។

ឧម្មាទន្តីជាតកំ ទុតិយំ ។

---

១ ម. សុចិណ្ណោ ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកដែនផង ក្នុងពួកអ្នកជនបទផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងសមណៈផង ក្នុងពួកព្រាហ្មណ៍ផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកម្រឹគនិងបក្សី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ ( ដ្បិត ) ធម៌ដែលគេសន្សំហើយ តែងនាំមកនូវសេចក្ដីសុខ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ទឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ ( ដ្បិត ) ព្រះឥន្ទ្រទាំងឡាយ ទេវតាទាំងឡាយ ព្រមទាំងព្រហ្ម បានដល់នូវអត្តភាព ជាទិព្វ ដោយសារធម៌ដែលគេបានសន្សំទុកល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រមាទចំពោះធម៌ឡើយ ។

ចប់ ឧម្មាទន្តីជាតក ទី ២ ។

# មហាពោធិជាតកំ

(៥២) កិន្នុ ទណ្ឌំ កិមាជិនំ កឹ ឆត្តំ កឹ ឧបាហនំ
កឹ អង្កុសញ្ច បត្តញ្ច សង្ឃាដិញ្ចាបិ ព្រាហ្មណ
តរមានរូបោ គណ្ហាសិ កិន្នុ បត្ថយសេ ទិសំ ។

(៥៣) ទ្វាទសេតានិ វស្សានិ វុសិតានិ តវន្តិកេ
នាភិជានាមិ សោណេន បិង្គលេនាភិកូជិតំ ។
ស្វាយំ ទត្តោវ នទតិ សុក្កទាឋំ វិទំសយំ
តវ សុត្វា សភរិយស្ស វីតសទ្ធស្ស មំ បតិ ។

(៥៤) អហុ ឯស កតោ ទោសោ យថាភាសសិ ព្រាហ្មណ
ឯស ភិយ្យោ បសីទាមិ វស ព្រាហ្មណ មាគមា ។

(៥៥) សព្វសេតោ បុរេ អាសិ តតោបិ សពលោ អហុ
សព្វលោហិតកោ ទានិ កាលោ បក្កមិតុំ មម ។

# មហាពោធិជាតក

(៥២) (ព្រះបាទព្រហ្មទត្តត្រាស់សួរថា) បពិត្រព្រាហ្មណ៍ ហេតុអ្វីក៏លោកប្រញាប់ប្រញាល់កាន់យកឈើច្រត់ផង ស្បែកខ្លាឃ្មុំផង ឆ័ត្រផង ស្បែកជើងផង ទំពក់ផង បាត្រផង សង្ឃាដិផង លោកប្រាថ្នា (ដើម្បីទៅ) កាន់ទិសណាហ្ន៎ ។

(៥៣) (ព្រះមហាសត្វឆ្លើយថា) អាត្មាភាពនៅក្នុងសំណាក់ព្រះអង្គអស់ ១២ ឆ្នាំនេះហើយ មិនដែលស្គាល់សំឡេងដែលឆ្កែក្រហមព្រុះម្តងឡើយ ។ ឆ្កែនោះបញ្ចេញបង្កួមសស្វាប ព្រុះដូចជាសាហាវព្រោះឮ (ព្រះបន្ទូល) របស់ព្រះអង្គព្រមទាំងអគ្គមហេសីដែលមានជំនឿទៅប្រាសហើយ ក្នុងរវាងអាត្មាភាព ។

(៥៤) (ព្រះរាជា...) បពិត្រព្រាហ្មណ៍ ទោសនុ៎ះខ្ញុំបានធ្វើហើយដូចជាលោកពោល ខ្ញុំនោះជ្រះថ្លាលើសដើម បពិត្រព្រាហ្មណ៍សូមលោកគង់នៅ ចូរកុំទៅ ។

(៥៥) (ព្រះមហាសត្វ...) កាលពីដើម បាយសសុទ្ធ តពីនោះមក បាយពព្រុះ ឥឡូវនេះ បាយក្រហមសុទ្ធ (កាលនេះ) ជាកាលគួរ អាត្មាភាពចៀសចេញទៅហើយ ។

## បញ្ញាសនិបាតេ តតិយំ មហាពោធិជាតកំ

អព្ភន្តរំ បុរេ អាសិ តតោ មជ្ឈេ តតោ ពហិ
បុរា និទ្ធមនា ហោតិ សយមេវ វជាមហំ ។
វិតសន្ធំ ន សេវេយ្យ ឧទបានំវនោទកំ
សចេបិ នំ អនុខណេ វារិកទ្ទមគន្ធិកំ ។
បសន្នមេវ សេវេយ្យ អប្បសន្នំ វិវជ្ជយេ
បសន្នំ បយិរុបាសេយ្យ រហទំ វុទកត្ថិកោ ។
ភជេ ភជន្តំ បុរិសំ អភជន្តំ ន ភជ្ជយេ
អសប្បុរិសធម្មោ សោ យោ ភជន្តំ ន ភជ្ជតិ ។
យោ ភជន្តំ ន ភជតិ សេវមានំ ន សេវតិ
ស វេ មនុស្សបាបិដ្ឋោ មិគោ សាខស្សិតោ យថា ។
អច្ចាភិក្ខណសំសគ្គា អសមោសរណេន ច
ឯតេន មិត្តា ជីរន្តិ អកាលេ យាចនាយ ច ។

ពីដើមអាសនៈរបស់ (អាត្មាភាព) ទៅខាងក្នុង (ប្រាសាទ) តមក ទៅកណ្តាល (ក្បាលដំណើរ) តពីនោះមកទៀត ទៅខាងក្រៅ អាត្មាភាពនឹងចេញទៅខ្លួនឯង មុនការបណ្តេញ ។ បុគ្គលមិនត្រូវសេពគប់បុគ្គលប្រាសចាកសទ្ធា ដែលទុកដូចអណ្តូងមិនមានទឹក ប្រសិនបើ បុគ្គលកកាយអណ្តូងនោះ (ទឹកដែលចេញអំពីអណ្តូងនោះ) មុខជាប្រកបដោយក្លិនភក់ពុំខាន ។ បុគ្គលត្រូវសេពគប់ចំពោះតែជនដែលជ្រះថ្លា ត្រូវវៀរចាកជនដែលមិនជ្រះថ្លា ត្រូវចូលទៅអង្គុយជិតជនដែលជ្រះថ្លា ដូចជាបុគ្គលត្រូវការដោយទឹក(ចូលទៅរក) អន្លង់ទឹកដូច្នោះ ។ បុគ្គលគួរគប់រកបុរសដែលគប់រក (ខ្លួន) មិនគួរគប់រកបុរសដែលមិនគប់រក (ខ្លួន) ទេ បុគ្គលណា មិនគប់រកបុគ្គល ដែលគប់រក (ខ្លួន) បុគ្គលនោះឈ្មោះថាកាន់ធម៌របស់អសប្បុរស ។ បុគ្គលណាមិនគប់រកបុគ្គលដែលគប់រក (ខ្លួន) មិនសេពគប់ចំពោះបុគ្គល ដែលសេពគប់ (នឹងខ្លួន) បុគ្គលនោះឯង ជាមនុស្សអាក្រក់ផុត ដូចជាម្រឹគដែលអាស្រ័យនៅលើមែកឈើ (ស្វា) ។ មិត្រទាំងឡាយលាកចិត្តពីគ្នាដោយហេតុនេះគឺ ដោយនៅប្រឡូកប្រឡំគ្នាញឹកពេក ១ ដោយការមិនជួបគ្នាសោះ ១ ដោយការសូមក្នុងកាលមិនគួរ ១ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

តស្មា ជាតិក្ខណំ គព្ភេ ន ច គព្ភេ ចិរាចិរំ

(១)

កាលេន យាចំ យាចេយ្យ ឯវំ មិត្តា ន ជីររេ ។

អតិចិរំ និវាសេន បិយោ ភវតិ អប្បិយោ

អាមន្ត ខោ តំ គច្ឆាម បុរា តេ ហោម អប្បិយា ។

(៤៦) ឯវំ ចេ យាចមានានំ អញ្ជលឹ នាវពុជ្ឈសិ

បរិចារិកានំ សត្តានំ វចនំ ន ករោសិ នោ

ឯវន្តំ អភិយាចាម បុន កយិរាសិ បរិយាយំ ។

(៤៧) ឯវញ្ចេ នោ វិហរតំ អន្តរាយោ ន ហេស្សតិ

តុយ្ហំ វាបិ មហារាជ មយ្ហំ វា រដ្ឋវឌ្ឍន

អប្បេវ នាម បស្សេម អហោរត្តានមច្ចយេ ។

(៤៨) ឧទីរណា ចេ សង្គត្យា ភាវាយ មនុវត្តតិ

---

១ ម. ន ជីយរេ។

ព្រោះហេតុនោះ បុគ្គលមិនត្រូវទៅញឹក ៗ ផង មិនត្រូវទៅ (ឃ្លាតគ្នា)យូរពេកផង គប្បីសូមនូវរបស់ដែលគួរសូមតាមកាលផង យ៉ាងនេះទើបមិត្រទាំងឡាយមិនលាកបិត្តពីគ្នា ៗ បុគ្គលធ្លាប់ជាទីស្រឡាញ់ ទៅជាមិនជាទីស្រឡាញ់វិញ ព្រោះនៅរួមគ្នាយូរពេក អាត្មាភាពសូមលាព្រះអង្គទៅមុន យើងទាំងឡាយនោះ មិនជាទីស្រឡាញ់គ្នាទេ ៗ

[៤៦] (ព្រះរាជា... )បើលោកម្ចាស់ មិនទទួលដឹងនូវអញ្ជលីរបស់យើងទាំងឡាយ ដែលអង្វរយ៉ាងនេះ មិនធ្វើតាមពាក្យយើងដែលជាសត្វបំរើទេ យើងខ្ញុំសូមអង្វរលោកម្ចាស់យ៉ាងនេះ សូមលោកម្ចាស់ធ្វើនូវសេចក្តីប្រាថ្នា (ដើម្បីមកកន្លែងនេះ) ម្តង ៗ ៗ

[៤៧] (ពោធិសត្ត...) បពិត្រមហារាជ ទ្រង់មានសេចក្តីចំរើនក្នុងដែន កាលបើយើងទាំងឡាយនៅ(ផ្សេងគ្នា)យ៉ាងនេះ អន្តរាយនឹងមិនមានដល់ព្រះអង្គផង ដល់អាត្មាភាពផង សូមយើងទាំងឡាយ ជួបគ្នាក្នុង កាលកន្លងទៅមួយថ្ងៃមួយយប់ ៗ

[៤៨] (ព្រះមហាសត្វទំលាយនូវវាទ.របស់អាមាត្យជាអហេតុកវាទីថា)

## បញ្ញាសនិបាតេ តតិយំ មហាពោធិជាតកំ

អកាមា អករណីយំ វា ករណីយំ វាបិ កុព្វតិ

អកាមករណីយស្មឹ កុវិធ បាបេន លិប្បតិ ។

សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច បាបកោ

ភោតោ ចេ វចនំ សច្ចំ សុហតោ វានរោ មយា ។

អត្តនោ ចេ ហិ វាទស្ស អបរាធំ វិជានិយ

ន មំ ត្វំ គរហេយ្យាសិ ភោតោ វាទោ ហិ តាទិសោ ។

បើពាក្យ ( របស់អ្នកថា ) សត្វប្រព្រឹត្តទៅតាមសង្គតិ[1] ( នៃអភិជាតិទាំង ៦ ) និងសភាវៈសត្វធ្វើនូវអំពើ ដែលមិនគួរធ្វើ ( បាប ) ឬអំពើដែលគួរធ្វើ ( បុណ្យ ) តើនរណា ក្នុងលោកនេះ ប្រឡាក់ដោយបាប ព្រោះអំពើដែលធ្វើដោយការមិនចង់ ។ បើ ( សេចក្តីនៃភាសិតរបស់អ្នក គឺអះហេតុកវាទ ) នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើន ជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងនូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើន បែបនោះ ។

---

១ នេះជាសេចក្តីយល់របស់ជនជាអហេតុកវាទី ។ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ មានសេចក្តីពន្យល់ថា អភិជាតិទាំង ៦ នោះគឺ កណ្ហាភិជាតិ (ជាតិខ្មៅ)បានដល់ព្រានម្រឹគ ព្រានបក្សីជាដើម ១ នីលាភិជាតិ (ជាតិខៀវ) បានដល់ភិក្ខុក្នុងព្រះពុទ្ធសាសនា ១ លោហិតាភិជាតិ (ជាតិក្រហម)បានដល់ពួកនិគ្រន្ថ ១ ហលិទ្ទាភិជាតិ(ជាតិលឿងដូចរមៀត) បានដល់ពួកអចេលកសាវ័ក ១ សុក្កាភិជាតិ(ជាតិស)បានដល់ពួកអាជីវក ១ បរមសុក្កាភិជាតិ(ជាតិសណាស់) បានដល់ពួកជនជានន្ទគោត្រនឹងវច្ឆគោត្រជាដើម ១ ។ ការព្រាច់ទៅក្នុងអភិជាតិទាំង៦ឈ្មោះថា សង្គតិ ។ ធម្មតាដែលកើតឡើងដូចៗគ្នា ឈ្មោះថាសភាវៈប្រៀបដូចបន្លាដែលស្រួចឯង ផ្លែខ្វិតមានសណ្ឋានមូលដោយខ្លួនឯង សត្វម្រឹគបក្សីមានសណ្ឋានរូបរាងវិចិត្រផ្សេង ដោយធម្មតាឯងយ៉ាងណាមិញ លោកទាំងអស់មានសេចក្តីប្រែប្រួលទៅជាយ៉ាងដូច្នោះ មិនបាច់អាស្រ័យហេតុបច្ច័យឡើយ ប្រៀបដូចបន្លាជាដើម យ៉ាងនោះឯង ឈ្មោះថា សភាវៈ ។

(៤៩) ឥស្សរោ សព្វលោកស្ស សចេ កប្បេតិ ជីវិតំ

ឥទ្ធឹ ព្យសនភាវញ្ច កម្មំ កល្យាណបាបកំ

និទ្ទេសការី បុរិសោ ឥស្សរោ តេន លិប្បតិ ។

សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច បាបកោ

ភោតោ ចេ វចនំ សច្ចំ សុហតោ វានរោ មយា ។

អត្តនោ ចេ ហិ វាទស្ស អបរាធំ វិជានិយ

ន មំ ត្វំ គរហេយ្យាសិ ភោតោ វាទោ ហិ តាទិសោ ។

(៥០) សចេ បុព្វេកតហេតុ សុខទុក្ខំ និគច្ឆតិ

បោរាណកំ កតំ បាបំ តមេសោ មុញ្ចតេ ឥណំ

បោរាណកឥណមោក្ខោ ក្វិធ បាបេន លិប្បតិ ។

(៥៩) ( ព្រះមហាសត្វទំលាយនូវវាទៈរបស់អាមាត្យ ជាឥស្សរករណ-វាទីថា ) ប្រសិនបើព្រះឥស្សរ ចាត់ចែងជីវិតរបស់សត្វលោកទាំងអស់ផង ចាត់ចែងនូវឫទ្ធិ គឺឥស្សរិយយសផង នូវភាពនៃសេចក្ដីវិនាសផង នូវកម្មល្អនឹងអាក្រក់ផង មានបុរស ( ណាមួយ ) ជាអ្នកធ្វើតាមបង្គាប់ ( របស់ព្រះឥស្សរនោះ ) ព្រះឥស្សរទេតើ តែងប្រឡាក់ជិតជាម ដោយអំពើអាក្រក់នោះ ( ដោយខ្លួនឯង ) ។ បើ ( សេចក្ដីនៃភាសិតរបស់អ្នក ) នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើន ជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើន បែបនោះ ។

(៦០) (ព្រះមហាសត្វទម្លាយនូវវាទៈ នៃអាមាត្យដែលជាបុព្វេកត-ហេតុវាទីថា ) បើបុគ្គលដល់នូវសុខទុក្ខ ព្រោះហេតុនៃអំពើដែលខ្លួនធ្វើក្នុងកាលមុន បុគ្គលនោះឯង រមែងរួចចាកបំណុលនោះ ដែលជាអំពើអាក្រក់ គឺខ្លួនធ្វើពីដើមមក ( កាលបើយ៉ាងនេះ ) អាត្មាក៏ឈ្មោះថា បានរួចចាកបំណុលចាស់ តើនរណា ក្នុងលោកនេះប្រឡាក់ដោយបាប ។

សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច បាបកោ
ភោតោ ចេ វចនំ សច្ចំ សុហតោ វានរោ មយា ។
អត្តនោ ចេ ហិ វាទស្ស អបរាធំ វិជានិយ
ន មំ ត្វំ គរហេយ្យាសិ ភោតោ វាទោ ហិ តាទិសោ ។

(៦១) ចតុន្នំយេវុបាទាយ រូបំ សម្ភោតិ បាណិនំ
យតោ ច រូបំ សម្ភោតិ តត្ថេវានុបគច្ឆតិ ។
ឥធេវ ជីវតិ ជីវោ បេច្ច បេច្ច វិនស្សតិ
ឧច្ឆិជ្ជតិ អយំ លោកោ យេ ពាលា យេ ច បណ្ឌិតា
ឧច្ឆិជ្ជមានេ លោកស្មឹ កិញ្ចិ បាបេន លិម្បតិ ។
សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច បាបកោ
ភោតោ ចេ វចនំ សច្ចំ សុហតោ វានរោ មយា ។
អត្តនោ ចេ ហិ វាទស្ស អបរាធំ វិជានិយ
ន មំ ត្វំ គរហេយ្យាសិ ភោតោ វាទោ ហិ តាទិសោ ។

បើ ( សេចក្ដីនៃភាសិតរបស់អ្នក ) នោះជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើន ជាពាក្យពិត ពានរក៏ឈ្មោះជាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើន បែបនោះ ។

(៦១) ( ព្រះមហាសត្វទំលាយនូវវាទៈរបស់អាមាត្យជាឧច្ឆេទវាទីថា ) រូបក្ខន្ធរបស់សត្វទាំងឡាយ តែងកើតឡើង ព្រោះអាស្រ័យនូវភូតរូបទាំង ៤ ( មានដីជាដើម ) ឯរូប ( នោះ ) ក៏កើតឡើងអំពីភូតរូបណា(ដល់ពេលរលត់) ក៏ត្រឡប់ទៅក្នុងភូតរូបនោះវិញ ។ ជីវៈរស់នៅក្នុងលោកនេះ លុះរំលាងខន្ធទៅហើយនឹងសាបសូន្យក្នុងបរលោក លោកនេះដាច់សូន្យ ជនទាំងឡាយ ទាំងពាល ទាំងបណ្ឌិត ( រមែងសូន្យដូចគ្នា ) កាលបើលោកនេះដាច់សូន្យហើយ តើនរណា ក្នុងលោកនេះ ប្រឡាក់ដោយបាប ។ បើ ( សេចក្ដីនៃភាសិតរបស់អ្នក ) នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើន ជាពាក្យពិត ពានរក៏ឈ្មោះជាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើន បែបនោះ ។

(១)

(៦២) អាហុ ខត្តវិធា លោកេ ពាលា បណ្ឌិតមានិនោ

មាតរំ បិតរំ ហន្ត្វា អថោ ជេដ្ឋម្បិ ភាតរំ

ហនេយ្យ បុត្តទារេ ច អត្តា ចេ តាទិសោ សិយា ។

(៦៣) យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា

ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ ។

អថ អត្ថេ សមុប្បន្នេ សមូលមបិ អព្វហេ

អត្ថោ មេ សម្ពលេនាបិ សុហតោ វានរោ មយា ។

សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច បាបកោ

ភោតោ ចេ វចនំ សច្ចំ សុហតោ វានរោ មយា ។

អត្តនោ ចេ ហិ វាទស្ស អបរាធំ វិជានិយ

ន មំ ត្វំ គរហេយ្យាសិ ភោតោ វាទោ ហិ តាទិសោ ។

---

១ ម. អាហុ ខត្តវិទា ។

(៦២) ( ព្រះមហាសត្វទំលាយនូវវាទៈរបស់អាមាត្យជាខត្តវិជ្ជវាទីថា) ជនទាំងឡាយអ្នកមានខត្តវិជ្ជា ( វិជ្ជាខាងការគាស់រំលើង ) ក្នុងលោក ជាជនពាលសោះទេ តែមានមានះថាជាបណ្ឌិត ពោលថា បុគ្គលសម្លាប់មាតាក៏បាន បិតាក៏បាន ពុំនោះសោតទេ សម្លាប់បងប្អូន ឬកូនប្រពន្ធក៏បាន ប្រសិនបើមានប្រយោជន៍បែបនោះ ។

(៦៣) (មហាសត្វប្រកាសនូវលទ្ធិរបស់ខ្លួនថា ) បុគ្គលអង្គុយក្តី ដេកក្តី ក្រោមម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះទេ ដ្បិតបុគ្គលប្រទូស្តមិត្រ ជាមនុស្សអាក្រក់ ។ ( ចំណែកខាងអ្នក ពោលថា ) កាលបើប្រយោជន៍កើតឡើង (ចំពោះខ្លួន) ហើយ បុគ្គលគប្បីគាស់រំលើង សូម្បីទាំងឫសក៏បាន ( ដូច្នេះ ) ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ព្រោះអាត្មាត្រូវការដោយស្បៀង ។ បើសេចក្តីនៃភាសិតរបស់អ្នកនោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើន ជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើន បែបនោះ ។

## បញ្ញាសនិបាតេ តតិយំ មហាពោធិជាតកំ

(៦៤) អហេតុវាទោ បុរិសោ យោ ច ឥស្សរកុត្តិកោ
បុព្វេកតី ច ឧច្ឆេទី យោ ច ខត្តវិទោ នរោ ។
ឯតេ អសប្បុរិសា លោកេ ពាលា បណ្ឌិតមានិនោ
ករេយ្យ តាទិសោ បាបំ អថោ អញ្ញម្បិ ការយេ
អសប្បុរិសសំសគ្គោ ទុក្ខន្តោ កដុកុទ្រយោ ។

(៦៥) ឧរព្ភរូបេន ពកាសុ បុព្វេ
អសង្កិតោ អជយូថំ ឧបេតិ
ហន្ត្វា ឧរណឹ អជិយំ អជញ្ច
ហន្ត្វា[១] សយិត្វា យេន កាមំ បលេតិ ។
តថាវិធេកេ សមណព្រាហ្មណាសេ
ឆទនំ កត្វា វញ្ចយន្តិ មនុស្សេ
អនាសកា ថណ្ឌិលសេយ្យកា ច
រជោជល្លំ ឧក្កុដិកប្បធានំ
បរិយាយភត្តញ្ច អបានកត្តា
បាបាចារា អរហន្តោ វទានា ។

---
១ ឧ. បិត្រា ។ ម. ឧត្រា ។

(៦៨) ( ព្រះមហាសត្វ សំដែងធម៌ដល់ព្រះរាជាថា ) ( បុរសអ្នកលុះក្នុងអំណាចនៃទិដ្ឋិ ៥ នាក់គឺ ) បុរសជាអហេតុវាទ ១ ជា ឥស្សរកតវាទ ១ ជា បុព្វេកតវាទ ១ ជា ឧច្ឆេទវាទ ១ ជា ខត្តវិជ្ជវាទ ១ នេះជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនជាបណ្ឌិត បុរសបែបនោះធ្វើបាប (ខ្លួនឯង) ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំនឹងអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រៃ ។

(៦៩) កាលពីដើម មានសត្វកុកមួយមានរូបដូចចៀម កាលបើឥតគេសង្ស័យ ក៏ចូលទៅរកហ្វូងពពែ សម្លាប់មេចៀមផង មេពពែផង ពពែឈ្មោលផង លុះសម្លាប់បានហើយ ក៏ហើរទៅតាមបំណងរបស់ខ្លួន ។ សមណព្រាហ្មណ៍ពួកខ្លះ ក៏បែបនោះដែរ ធ្វើនូវគ្រឿងបិទបាំង ហើយបញ្ឆោតមនុស្សទាំងឡាយ ( ពួកខ្លះ) ជាអ្នកមិនបរិភោគអាហារ ( ពួកខ្លះ ) ជាអ្នកដេកលើផែនដី ( ពួកខ្លះ ) ទុកក្អែល ( ពួកខ្លះ ) ព្យាយាមអង្គុយប្រហោង ( ពួកខ្លះ) បរិភោគបាយ ដោយកំណត់ថ្ងៃ ( ពួកខ្លះ ) មិនផឹកទឹក មានមារយាទអាក្រក់ នាំគ្នាពោលថា ខ្លួនជាអរហន្ត ។

ឯតេ អសប្បុរិសា លោកេ ពាលា បណ្ឌិតមានិនោ
ការេយ្យ តាទិសោ បាបំ អថោ អញ្ញម្បិ ការយេ
អសប្បុរិសសំសគ្គោ ទុក្ខន្តោ កដុកុទ្រយោ ។
យមាហុ នត្ថិ វីរិយន្តិ ហេតុញ្ច អបវទន្តិ យេ
បរការំ អត្តការញ្ច យេ តុច្ឆំ សមវណ្ណយុំ ។
ឯតេ អសប្បុរិសា លោកេ ពាលា បណ្ឌិតមានិនោ
ការេយ្យ តាទិសោ បាបំ អថោ អញ្ញម្បិ ការយេ
អសប្បុរិសសំសគ្គោ ទុក្ខន្តោ កដុកុទ្រយោ ។
សចេ ហិ វីរិយំ នាស្ស កម្មំ កល្យាណបាបកំ
ន ភរេ វឌ្ឍកី រាជា នបិ យន្តានិ ការយេ ។
យស្មា ច វីរិយំ អត្ថិ កម្មំ កល្យាណបាបកំ
តស្មា យន្តានិ ការេតិ រាជា ភរតិ វឌ្ឍកី ។
យទិ វស្សសតំ ទេវោ ន វស្សេ ន ហិមំ បតេ
ឧច្ឆិជ្ជេយ្យ អយំ លោកោ វិនស្សេយ្យ អយំ បជា ។

ជនទាំងនុ៎ះ ជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុគ្គលបែបនោះធ្វើបាប (ខ្លួនឯង) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំដោយអសប្បុរសមានទុក្ខជាទីបំផុត មានសេចក្ដីក្ដៅក្រហាយជាកម្រៃ ។

ពួកជនណា ពោលថា ព្យាយាមឥតអំពើផង មិនពោលអាងហេតុផង ពណ៌នានូវអំពើរបស់បុគ្គលដទៃ នឹងអំពើរបស់ខ្លួនថាជាអំពើសូន្យទទេផង ។ ពួកជននុ៎ះជាអសប្បុរស ក្នុងលោកជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុរសបែបនោះធ្វើបាប ( ខ្លួនឯង ) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំដោយអសប្បុរស មានទុក្ខជាទីបំផុតមានសេចក្ដីក្ដៅក្រហាយជាកម្រៃ ប្រសិនបើការព្យាយាមឥតអំពើ មិនមានអំពើល្អនឹងអាក្រក់ទេ ព្រះរាជាមិនគប្បីបញ្ចឹមនូវជាងឈើ ទាំងមិនគប្បីឲ្យគេធ្វើ នូវយន្តទាំងឡាយឡើយ ។ ព្រោះហេតុតែការព្យាយាមមានផង អំពើល្អនឹងអាក្រក់មានផងបានជា ព្រះរាជាតែងចាត់ឲ្យធ្វើ នូវយន្តទាំងឡាយ តែងបញ្ចឹមនូវជាងឈើ ។ ប្រសិនបើភ្លៀងខានបង្អុរចុះ រហូតមួយរយឆ្នាំ ទាំងទឹកសន្សើម ក៏មិនធ្លាក់ចុះសោះ មុខជាលោកនេះ នឹងសូន្យឈឹង ពពួកសត្វនេះ នឹងវិនាស ។

## បញ្ញាសនិបាតេ តតិយំ មហាពោធិជាតកំ

យស្មា ច វស្សតិ ទេវោ ហិមញ្ញានុទុសីយតិ
តស្មា សស្សានិ បច្ចន្តិ រដ្ឋញ្ច បាលយតេ ចិរំ ។
គវញ្ចេ តរមាណានំ ជិម្ហំ គច្ឆតិ បុង្គវោ
សព្វា តា ជិម្ហំ គច្ឆន្តិ នេត្តេ ជិម្ហំ គតេ សតិ ។
ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេ អធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ ទុក្ខំ សេតិ រាជា ចេ ហោតិ អធម្មិកោ ។
គវញ្ចេ តរមានានំ ឧជុំ គច្ឆតិ បុង្គវោ
សព្វា តា ឧជុំ គច្ឆន្តិ នេត្តេ ឧជុំ គតេ សតិ ។
ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេបិ ធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោ ។
មហារុក្ខស្ស ផលិនោ អាមំ ឆិន្ទតិ យោ ផលំ
រសញ្ចស្ស ន ជានាតិ ពីជញ្ចស្ស វិនស្សតិ ។

ព្រោះហេតុតែភ្លៀង បង្អុរចុះផង ទាំងទឹកសន្សើម ក៏ផ្សើមហើយ ៗ ផង បានជាសន្ទូងទាំងឡាយ លូតលាស់ល្អ ទាំងអ្នកដែន ក៏ព្រះរាជាទ្រង់រក្សា អស់កាលជាអង្វែងផង ។ កាលពួកគោ កំពុងឆ្លងទៅ ( កាន់ទីណាមួយ ) បើគោបាទៅវៀច កាលបើគោបា នាំពួកគោទៅវៀច មេគោទាំងអស់នោះក៏ទៅវៀច ។ បណ្ដាពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថា ប្រសើរផុត បើបុគ្គលនោះប្រព្រឹត្តអធម៌ហើយ ទឹងចាំបាច់និយាយថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាទុក្ខ ។ កាលពួកគោ កំពុងឆ្លងទៅ បើគោបាទៅត្រង់ កាលបើគោបានាំគេទៅត្រង់ មេគោទាំងអស់នោះក៏ទៅត្រង់ ។ ពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថា ប្រសើរផុត ប្រសិនបើ បុគ្គលនោះប្រព្រឹត្តធម៌ ទឹងចាំបាច់និយាយថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាសុខ ។ បុគ្គលណា បេះផ្លែខ្ចី នៃឈើធំដែលមានផ្លែ ( បុគ្គលនោះ ) រមែងមិនដឹងនូវរស នៃផ្លែឈើនោះផង ទាំងពូជ នៃផ្លែឈើនោះ ក៏វិនាសទៅផង ។

មហារុក្ខូបមំ រដ្ឋំ   អធម្មេន (យោ) បសាសតិ
រសញ្ចស្ស ន ជានាតិ   រដ្ឋញ្ចស្ស វិនស្សតិ ។

មហារុក្ខស្ស ផលិនោ   បក្កំ ឆិន្ទតិ យោ ផលំ
រសញ្ចស្ស វិជានាតិ   ពីជញ្ចស្ស ន នស្សតិ ។

មហារុក្ខូបមំ រដ្ឋំ   ធម្មេន យោ បសាសតិ
រសញ្ចស្ស វិជានាតិ   រដ្ឋញ្ចស្ស ន នស្សតិ ។

យោ ច រាជា ជនបទំ   អធម្មេន បសាសតិ
សព្វោសធីហិ សោ រាជា   វិរុទ្ធោ ហោតិ ខត្តិយោ ។

តថេវ នេគមេ ហិំសំ   យេ យុត្តា កយវិក្កយេ
ឱជទានពលីការេ   ស កោសេន វិរុជ្ឈតិ ។

បហារវរខេត្តញ្ញូ   សង្គាមេ កតនិស្សមេ
ឧស្សិតេ ហិំសយំ រាជា   ស ពលេន វិរុជ្ឈតិ ។

ព្រះរាជាណាគ្រប់គ្រងផែនដីដែលប្រៀបដូចដើមឈើធំ ដោយអធម៌ (ព្រះរាជានោះ) ឈ្មោះថា មិនជ្រាបនូវរសរបស់ផែនដីនោះផង ទាំងផែនដីរបស់ព្រះរាជានោះក៏វិនាសផង ៗ បុគ្គលណាបេះផ្លែឈើទុំនៃដើមឈើធំដែលមានផ្លែ បុគ្គលនោះរមែងដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជរបស់ផ្លែឈើនោះក៏មិនវិនាសផង ៗ ព្រះរាជាណាគ្រប់គ្រងផែន ដែលប្រៀបដូចជាដើមឈើធំដោយធម៌ (ព្រះរាជានោះ) ឈ្មោះថាបានជ្រាបនូវរសរបស់ផែនដីនោះផង ទាំងផែនរបស់ព្រះរាជានោះក៏មិនវិនាសផង ៗ ព្រះរាជាណាមួយ គ្រប់គ្រងជនបទដោយអធម៌ ( លុះអំណាចអគតិ ) ព្រះរាជាជាខត្តិយៈនោះ ឈ្មោះថា សាបសូន្យជាតដើមឈើ ដែលត្រូវជាទុសងទាំងអស់ ៗ មួយទៀត ( ព្រះរាជាអង្គណា ) បៀតបៀនពួកកុដុម្ពិក ដែលនៅក្នុងនិគម ( ផង ) បៀតបៀនពួកពាណិជដែលប្រកបក្នុងការលក់ចេញទិញចូល ជាអ្នកធ្វើនូវការថ្វាយពន្ធដារនឹងពលិការ ( ផង ) ព្រះរាជានោះ ឈ្មោះថាសាបសូន្យជាតឃ្លាំង ៗ ព្រះរាជាណា បៀតបៀននូវខ្មាន់ធ្នូ ដែលជាអ្នកដឹងនូវកន្លែងយ៉ាងតំណំ ដែលគួរប្រហារ នឹងពួកទាហានធំ ដែលជាអ្នកពិចារណាធ្វើការក្នុងសង្គ្រាម នឹងមហាមាត្យដែលមានស័ក្តិធំ ៗ ព្រះរាជានោះ ឈ្មោះថា សាបសូន្យជាតពល ៗ

នចេវ ទស្សយោ ហិំសំ សំយមេ ព្រហ្មចារិយេ
អនច្ចចារី ឧត្តិយោ សោ សក្កេន វិរុជ្ឈតិ ៗ
យោ ច បជា អនច្ចេដ្ឋា ករិយំ ហន្តិ អត្ថសត្តំ
លុទ្ធំ បសវតេ ហាឆំ បុត្តេហិ ច វិរុជ្ឈតិ ៗ
ធម្មំ ចរេ ជានបទេ នេគមេសុ ពលេសុ ច
ឥសយោ ច ន ហិំសេយ្យ បុត្តទារេ សមញ្ញរេ ៗ
ស តាទិសោ ភូមិបតិ រដ្ឋបាលោ អកោធនោ
សាមន្តេ សម្បកម្បេតិ ឥន្ទោវ អសុរាធិបោតិ ៗ

មហាពោធិជាតកំ តតិយំ ។

## តស្សុទ្ទានំ

សនិឡីនិកមវ្ហយនោ បឋមោ
ទុតិយោ បន សឡម្មទន្តិវរោ
តតិយោ បន ពោធិសិរីវ្ហយនោ
កថិតា បន តីណិ ជិនេន សុភា ៗ

បញ្ញាសនិបាតំ និដ្ឋិតំ ។

ក្សត្រណាប្រព្រឹត្តនូវអធម៌ បៀតបៀនពួកឥសីអ្នកសង្រួម ប្រព្រឹត្ត ធម៌ដ៏ប្រសើរ ដូចជាបៀតបៀននូវពួកអ្នកនិគមដូច្នោះ ក្សត្រនោះ ឈ្មោះថា សាបសូន្យចាកឋានសួគ៌ ។ មួយវិញទៀត ព្រះរាជា ណាមិនឋិតនៅក្នុងធម៌ សម្លាប់អគ្គមហេសីដែលជាអ្នកមិនប្រទូស្ត ព្រះរាជានោះឈ្មោះថា បានបួបប្រទះនូវឋានៈដ៏អាក្រក់ផង ឈ្មោះ ជាសាបសូន្យចាកកូនចៅផង ។ ព្រះរាជាត្រូវតែប្រព្រឹត្តធម៌ ផង មិនត្រូវបៀតបៀនអ្នកជនបទនិងអ្នកនិគមផង ពួកពល ផង-ពួកឥសីផង គប្បីប្រព្រឹត្តស្មោះស្ម័គ្រចំពោះកូននិងប្រពន្ធផង ។ ព្រះរាជានោះ ទើបឈ្មោះថាជាម្ចាស់នៃផែនដី ឈ្មោះថា អ្នក គ្រប់គ្រងនូវដែន ឈ្មោះថាជាអ្នកមិនក្រោធ រមែងញាំញីពួកអ្នក ដែនជិតខាងឲ្យកើតញាប់ញ័រ ដូចព្រះឥន្ទ្រជាធំជាងអសុរ ។

ចប់ មហាពោធិជាតក ទី ៣ ។

## ឧទ្ទាននៃបញ្ចាសនិបាតនោះ គឺ

និទ្ទេសទី ១ ប្រកបដោយនាងរាជធីតាព្រះនាម នឡិនិកា ១

និទ្ទេសទី ២ ប្រកបដោយសេដ្ឋីធីតាឈ្មោះឧម្មាទន្តីដ៏ប្រសើរ ១

និទ្ទេសទី ៣ ប្រកបដោយតាបសមានសិរីឈ្មោះ ពោធិ ១

និទ្ទេសទាំង ៣ ដ៏ល្អ (នេះ) ព្រះជិនស្រីទ្រង់សំដែងទុកមកហើយ ។

ចប់ បញ្ចាសនិបាត ។

# សត្តតិនិបាតេ បឋមំ សោណកជាតកំ

## សត្តតិនិបាតជាតកំ

## សោណកជាតកំ

(៦៦) កស្ស(១) សុត្វា សតំ ទម្មិ សហស្សំ ទិដ្ឋ សោណកំ
កោ មេ សោណកមក្ខាតិ សហាយំ បំសុកីឡិតំ ។
អថព្រវិ មាណវកោ ទហរោ បញ្ចចូឡកោ
មយ្ហំ សុត្វា សតំ ទេហិ សហស្សំ ទិដ្ឋ សោណកំ
អហំ តេ សោណកមក្ខិស្សំ សហាយំ បំសុកីឡិតំ ។
(៦៧) កតរស្មឹ សោ ជនបទេ រដ្ឋេសុ និគមេសុ ច
កត្ថ សោណកមទ្ទក្ខិ(២) តំ មេ អក្ខាហិ បុច្ឆិតោ ។
(៦៨) តវេវ ទេវ វិជិតេ តវេវុយ្យានភូមិយា
ឧជុវំសា មហាសាលា នីលោភាសា មនោរមា ។
តិដ្ឋន្តិ មេឃសមានា រម្មា អញ្ញោញ្ញនិស្សិតា

---

១ ម. តស្ស ។ ២ ឱ. កត្ថ តេ សោណកោ ទិដ្ឋោ ។

# សត្តិនិបាត សោណកជាតក ទី ១

## សត្តិនិបាតជាតក

## សោណកជាតក

(៦៦) (ព្រះរាជាព្រះនាមអរិន្ទមៈ ទ្រង់ត្រាស់ថា) អ្នកណាបានឮ អញនឹងឲ្យទ្រព្យមួយរយ អ្នកណាបានឃើញសោណកៈ អញនឹងឲ្យទ្រព្យមួយពាន់ អ្នកណានឹងប្រាប់អញនូវសោណកៈជាសំឡាញ់ ដែលលេងដីជាមួយគ្នា ។

(អភិសម្ពុទ្ធគាថា) គ្រានោះ មាណពក្មេងមានជុក ៥ បានក្រាបបង្គំទូលថាទូលព្រះបង្គំជាខ្ញុំបានឮ សូមព្រះអង្គប្រទានទ្រព្យមួយរយ ទូលព្រះបង្គំជាខ្ញុំបានឃើញសោណកៈ សូមព្រះអង្គប្រទានទ្រព្យមួយពាន់ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គ នូវសោណកៈជាសំឡាញ់ ដែលលេងដីជាមួយគ្នា ។

(៦៧) (ព្រះរាជា...) សោណកៈនោះ នៅក្នុងជនបទណា ក្នុងដែនណា ក្នុងនិគមណា ឯងបានឃើញសោណកៈ ក្នុងទីណា អញសួរហើយ ឯងចូរប្រាប់ពីសោណកៈនោះ ។

(៦៨) (កុមារ...) បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គ ក្នុងដែនរបស់ព្រះអង្គហ្នឹងឯង មានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវ ជាគេប្រមែកនៃចិត្ត ពួកឈើទាំងនោះ មានពណ៌ដូចផ្កាមេឃ គួរឲ្យត្រេកអរ ដុះទាក់ទងគ្នាទៅវិញទៅមក

## សត្តតិនិបាតេ បឋមំ សោណកជាតកំ

តេសំ មូលស្មិំ សោណកោ ឈាយតិ អនុបាទនោ
ឧបាទានេសុ លោកេសុ ឌយ្ហមានេសុ និព្វុតោ ។

(៦៩)តតោ ច រាជា អាយាសិ សេនាយ ចតុរង្គិយា
ការាបេត្វា សមំ មគ្គំ អគមា យេន សោណកោ ។

ឧយ្យានភូមឹ គន្ត្វាន វិចរន្តោ ព្រហាវនេ
អាសីនំ សោណកំ ទក្ខិ ឌយ្ហមានេសុ និព្វុតំ ។

(៧០)កបណោ វតាយំ ភិក្ខុ មុណ្ឌោ សង្ឃាដិបារុតោ
អមាតិកោ អបិតិកោ រុក្ខមូលស្មិំ ឈាយតិ ។

(៧១)ឥមំ វាក្យំ និសាមេត្វា សោណកោ ឯតទព្រវិ
ន រាជ កបណោ ហោតិ ធម្មំ កាយេន ផស្សយំ ។

យោ ច ធម្មំ និរង្កត្វា អធម្មំ អនុវត្តតិ
ស រាជ កបណោ ហោតិ បាបោ បាបបរាយណោ ។

កាលពួកសត្វលោកមានគ្រឿងឆេះ កំពុងត្រូវភ្លើងឆេះ សោណកៈ មិនមានគ្រឿងឆេះ ជាបុគ្គលរលត់ហើយ កំពុងបំរើនឈានជិត គល់ឈើទាំងនោះ ។

(៦៩) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះរាជាទ្រង់ប្រើបំរើឲ្យចាត់ចែងធ្វើផ្លូវរាបស្មើ យាងចេញទៅដោយសេនាមានអង្គ៤ សំដៅទៅត្រង់កន្លែងដែលព្រះបច្ចេកពុទ្ធព្រះនាមសោណកៈគង់នៅ ។ លុះព្រះរាជាទ្រង់យាងទៅដល់ទីឧទ្យានហើយ ទ្រង់ត្រាច់ទៅក្នុងព្រៃធំ បានទតឃើញព្រះសោណកបច្ចេកពុទ្ធ កាលដែលពួកសត្វលោកកំពុងត្រូវភ្លើងឆេះ លោកជាបុគ្គលរលត់គង់នៅហើយ ។

(៧០) (ព្រះរាជា...) ភិក្ខុត្រកោលដណ្តប់សង្ឃាដិ មិនមានមាតា នេះ កំព្រាណាស់តែ ស្ងួតស្ងប់ជិតគល់ឈើ ។

(៧១) (អភិសម្ពុទ្ធគាថា) ព្រះសោណកបច្ចេកពុទ្ធ ស្តាប់ព្រះបន្ទូលនេះហើយ បានថ្វាយព្រះពរយ៉ាងនេះថា បពិត្រព្រះរាជា បុគ្គលដែលពាល់ត្រូវនូវធម៌ដោយកាយ មិនមែនឈ្មោះថា កំព្រាទេ ។ បុគ្គលណា ក្នុងលោកនេះ លះធម៌ចោលហើយ ប្រព្រឹត្តតាមអធម៌វិញ បពិត្រព្រះរាជា បុគ្គលនោះ ទើបឈ្មោះថា កំព្រា ជាបុគ្គលអាក្រក់ ជាទីសង្ឃឹមរបស់បុគ្គលអាក្រក់ ។

(៧២)អរិន្ទមោតិ មេ នាមំ កាសិរាជាតិ មំ វិទូ

កច្ចិ ភោតោ សុខា សេយ្យា ឥធ បត្តស្ស សោណក ។

(៧៣)សទាបិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ

ន តេសំ កោដ្ឋេ ឱបេន្តិ ន កុម្ភេ ន កឡោបិយា

បរនិដ្ឋិតមេសានា តេន យាបេន្តិ សុព្វតា ។

ទុតិយម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ

អនវជ្ជបិណ្ឌោ ភោតព្វោ ន ច កោចូបរោធតិ ។

តតិយម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ

និព្វុតោ បិណ្ឌោ ភោតព្វោ ន ច កោចូបរោធតិ ។

ចតុត្ថម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ

មុត្តស្ស រដ្ឋេ ចរតោ សង្គោ យស្ស ន វិជ្ជតិ ។

បញ្ចមម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ

នគរម្ហិ ឌយ្ហមានម្ហិ នាស្ស កិញ្ចិ អឌយ្ហថ[១] ។

---

១ ម. អឌយ្ហតិ ។

(៧២) (ព្រះរាជា...) ខ្ញុំឈ្មោះអរិន្ទមៈ អ្នកផងស្គាល់ខ្ញុំថា កាសិរាជ បពិត្រព្រះសោណកៈ លោកដ៏ចំរើនមកដល់ក្នុងទីនេះសិនទៅ ជាសុខទេឬ ។

(៧៣) (ព្រះបច្ចេកពុទ្ធ...) សេចក្ដីចំរើន (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ សព្វកាល គឺ (ទ្រព្យនិងធញ្ញជាតិទាំងឡាយ) របស់ភិក្ខុទាំងនោះ លែងចូលទៅក្នុងជង្រុក លែងចូលទៅក្នុងឆ្នាំង លែងចូលទៅក្នុងក្រឡប់ទៀតហើយ លោកមានវត្តល្អ មានការស្វែងរកសម្រេចហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ ។ សេចក្ដីចំរើនទីពីរ (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺបរិភោគដុំបាយ ដែលមិនមានទោស កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្ដីចំរើនទីបី (តែងមាន) ដល់ភិក្ខុ មិនមាទ្រព្យ មិនមានផ្ទះ គឺឆាន់ដុំបាយដ៏ត្រជាក់ (មិនជាថេយ្យបរិភោគជាដើម) កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្ដីចំរើនទីបួន (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺសេចក្ដីជាប់ចំពាក់ មិនមានដល់ភិក្ខុដែលផុតស្រឡះ (ចាកត្រកូល) ត្រាច់ទៅក្នុងដែន ។ សេចក្ដីចំរើនទីប្រាំ (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺកាលបើនគរកំពុងត្រូវភ្លើងឆេះ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះក៏ភ្លើងមិនឆេះទេ ។

## សត្តតិនិបាតេ បឋមំ សោណកជាតកំ

ឆដ្ឋម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ
រដ្ឋេ វិលុម្បមានម្ហិ នាស្ស កិញ្ចិ អហារថ(១) ។
សត្តមម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ
ចោរេហិ រក្ខិតំ មគ្គំ យេ ចញ្ញេ បរិបន្ថិកា
បត្តចីវរមាទាយ សោត្ថឹ គច្ឆតិ សុព្វតោ ។
អដ្ឋមម្បិ ភទ្រមធនស្ស អនាគារស្ស ភិក្ខុនោ
យំ យំ ទិសំ បក្កមតិ អនបេក្ខោវ គច្ឆតិ ។
(៧៤) ពហូបិ ភទ្រា ឯតេសំ យោ ត្វំ ភិក្ខុ បសំសសិ
អហញ្ច គិទ្ធោ កាមេសុ កថំ កាហាមិ សោណក ។
បិយា មេ មានុសា កាមា អថោ ទិព្យាបិ មេ បិយា
អថ កេន នុ វណ្ណេន ឧភោ លោកេ លភាមសេ ។
(៧៥) កាមេ គិទ្ធា កាមរតា កាមេសុ អធិមុច្ឆិតា
នរា បាបានិ កត្វាន ឧបបជ្ជន្តិ ទុគ្គតឹ ។

---

១ ឱ. អហីរថ ។ ម. អាហរថ ។

សេចក្ដីចំរើនទីប្រាំមួយ (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ កាលបើដែនកំពុងត្រូវចោរប្លន់ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ចោរមិនលួចទេ ។ សេចក្ដីចំរើនទីប្រាំពីរ(តែងមាន)ដល់ភិក្ខុ មិនមានទ្រព្យមិនមានផ្ទះ គឺភិក្ខុមានវត្តល្អ នាំយកបាត្រនិងចីវរ ដើរទៅកាន់ផ្លូវដែលពួកចោរនិងពួកគយដទៃរក្សាដោយស្រួល ។ សេចក្ដីចំរើនទីប្រាំបី(តែងមាន)ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុនោះដើរទៅកាន់ទិសណា ៗ ទៅបានដោយមិនមាននឹកនា ។

[៧៤] ( ព្រះរាជា... ) បពិត្រភិក្ខុ លោកសរសើរនូវសេចក្ដីចំរើនរបស់ភិក្ខុទាំងនោះច្រើនមែន បពិត្រព្រះសោណកៈ តែខ្ញុំជក់ចិត្តក្នុងកាមទាំងឡាយ តើនឹងធ្វើយ៉ាងណា ៗ កាមទាំងឡាយជារបស់មនុស្ស ជាទីស្រឡាញ់របស់ខ្ញុំ មួយទៀត កាមជាទិព្វក៏ជាទីស្រឡាញ់របស់ខ្ញុំ បើដូច្នេះ តើយើងនឹងបាននូវកាមទាំងពីរក្នុងលោក ដោយហេតុដូចម្ដេច ។

[៧៥] (ព្រះបច្ចេកពុទ្ធ....)ពួកជនអ្នកជក់ចិត្តក្នុងកាម ត្រេកអរក្នុងកាម ងប់ក្នុងកាម រមែងធ្វើបាបទាំងឡាយ ហើយទៅកាន់ទុគ្គតិ ៗ

យេ ច កាមេ បហាត្វាន និក្ខន្តា អកុតោភយា
ឯកោទិភាវាធិគតា ន តេ គច្ឆន្តិ ទុគ្គតឹ ។
ឧបមន្តេ ករិស្សាមិ តំ សុណោហិ អរិន្ទម
ឧបមាយ មិធេកច្ចេ អត្ថំ ជានន្តិ បណ្ឌិតា ។
គង្គាយ កុណបំ ទិស្វា វុយ្ហមានំ មហណ្ណវេ
វាយសោ សមចិន្តេសិ អប្បបញ្ញោ អចេតសោ ។
យានញ្ច វតិទំ លទ្ធំ ភក្ខោ ចាយំ អនប្បកោ
តត្ថ រត្តឹ តត្ថ ទិវា តត្ថេវ និរតោ មនោ ។
ខាទំ នាគស្ស មំសានិ បិវំ ភាគីរសោទកំ
សម្បស្សំ វនចេត្យានិ ន បលេត្ថ វិហង្គមោ ។
តញ្ច ឱតរណី គង្គា បមត្តំ កុណបេ រតំ
សមុទ្ទំ អជ្ឈគាហាសិ អគតី យត្ថ បក្ខិនំ ។
សោ ច ភក្ខបរិក្ខីណោ ឧទបត្វា (១) វិហង្គមោ
ន បច្ឆតោ ន បុរតោ នុត្តរំ នោបិ ទក្ខិណំ ។
ទីបំ សោ នជ្ឈគាគញ្ឆិ អគតី យត្ថ បក្ខិនំ
សោ ច តត្ថេវ បាបត្ថ យថា ទុព្វលកោ តថា ។

---

១ ឧប្បតិត្វាតិ អត្ថកថាយំ ទិស្សតិ ។

ចំណែកពួកជនណា លះបង់កាម ហើយចេញទៅ មិនមានភ័យអំពីកិលេសណាមួយ បាននូវភាពជាបុគ្គលឯក ពួកជននោះ មិនទៅកាន់ទុគ្គតិ ។ បពិត្រព្រះអរិន្ទមៈ អាត្មាភាពនឹងធ្វើសេចក្ដីឧបមាថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់សេចក្ដីឧបមានោះ ព្រោះពួកបណ្ឌិតខ្លះក្នុងលោកនេះ តែងយល់សេចក្ដីដោយសារឧបមា ។ ក្អែកឥតប្រាជ្ញាឥតសេចក្ដីគួរគាន់ ឃើញសាកសព( ដំរី )កំពុងអណ្ដែតតាមទន្លេគង្គាទៅក្នុងសមុទ្រ ហើយគិតថា អែយ៉ា! អញបានយាននេះហើយផង ដំរីនេះនឹងបានជាចំណីអញយ៉ាងច្រើនផង ចិត្តរបស់ក្អែកនោះក៏ត្រេកអរក្នុងដំរីនោះទាំងថ្ងៃទាំងយប់ ។ ក្អែកចិកស៊ីសាច់ដំរី ផឹកទឹកទន្លេគង្គា ឃើញព្រៃដែលគេសន្មតថា ចេតិយ ក៏មិនហើរទៅ ។ ទន្លេគង្គាហូរទៅបាននាំក្អែកនោះ ដែលប្រហែសធ្វេសត្រេកអរក្នុងសាកសព ទៅកាន់សមុទ្រដែលមិនមែនជាទីទៅនៃបក្សី ។ សត្វហើរនោះអស់ចំណីរលីងហើយ ក៏ហើរឡើងទៅទិសខាងលិចមិនរួច ទៅទិសខាងកើតមិនរួច ទៅទិសខាងជើងមិនរួច ទៅទិសខាងត្បូងមិនរួច ។ ក្អែកនោះទៅកាន់សមុទ្រ ដែលមិនមែនជាទីទៅនៃពួកបក្សី ក៏មិនបាននូវទីពឹង ធ្លាក់ទៅក្នុងសមុទ្រ នោះឯង ដូចជាបុគ្គល មានកំឡាំងថយ ។

តញ្ច សាមុទ្ទិកា មច្ឆា កុម្ភីលា មករា សុសូ
បសយ្ហការា ខាទិំសុ ផន្ទមានំ វិបក្ខិនំ ។
ឯវមេវ តុវំ រាជ យេ ចញ្ញេ កាមភោគិនោ
គិទ្ធា ចេ ន វមិស្សន្តិ កាកបញ្ញាយ តេ វិទូ ។
ឯសា តេ ឧបមា រាជ អត្ថសន្ទស្សនី កតា
ត្វញ្ច បញ្ញាយសេ តេន យទិ កាហសិ វា ន វា ។
(៧៦) ឯកវាចំបិ ទ្វិវាចំ ភណេយ្យ អនុកម្បកោ
តតុត្តរឹ ន ភាសេយ្យ ទាសោវយ្យស្ស សន្តិកេ ។
(៧៧) ឥទំ វត្វាន បក្កាមិ សោណកោ អមិតពុទ្ធិមា
វេហាសេ អន្តលិក្ខស្មឹ អនុសាសិត្វាន ខត្តិយំ ។
(៧៨) កោ នុមេ រាជកត្តារោ សូតា វេយ្យត្តិមាគតា
រថំ និយ្យាទយិស្សាមិ នាហំ រជ្ជេន មត្ថិកោ ។

ពួកត្រី ក្រពើ មករ ឆ្លាម ដែលកើតក្នុងសមុទ្រ ក៏ហែកខាំក្អែកនោះ ដែលមានស្លាបរបោចហើយ កំពុងបម្រះ ( យ៉ាងណាមិញ ) ។ បពិត្រព្រះរាជា ព្រះអង្គនឹងពួកជនដទៃអ្នកបរិភោគកាមក៏យ៉ាងនោះដែរ បើពួកជនដែលដក់ចិត្តហើយមិនខ្ជាក់ (កាម) ចោលចេញទេ បណ្ឌិតទាំងឡាយ (ស្គាល់) ពួកជននោះ(ថាមានប្រាជ្ញាស្មើ) ដោយប្រាជ្ញារបស់ក្អែក ។ បពិត្រព្រះរាជា ឧបមាជាគ្រឿងបំភ្លឺនូវសេចក្តីនេះ អាត្មាភាពបានធ្វើថ្វាយព្រះអង្គហើយ បើព្រះអង្គធ្វើឬមិនធ្វើ ព្រះអង្គនឹងប្រាកដតាមហេតុនោះ ។

(៧៦) បុគ្គលអ្នកឈឺឆ្អាល គប្បីនិយាយត្រឹមតែមួយម៉ាត់ ឬពីរម៉ាត់ មិនគប្បីនិយាយ ឲ្យលើសហួសពីនោះទៅ ដូចទាសៈនិយាយក្នុងសំណាក់នៃម្ចាស់ ។

(៧៧) ( អភិសម្ពុទ្ធគាថា ) លុះព្រះសោណកបច្ចេកពុទ្ធ មានប្រាជ្ញារាប់មិនបាន ពោលពាក្យនេះប្រៀនប្រដៅក្សត្រិយ៍ហើយ ទើបចៀសចេញទៅឰដ៏អាកាសវេហាស៍ ។

(៧៨) (ព្រះរាជា...) ពួកជនអ្នករៀបចំអភិសេកបុគ្គល ដែលគួរដល់រាជ្យ ជាអ្នកបង្កក់ប្រសិទ្ធនេះ ចាំស្ងាត់ នៅក្នុងទីណា អញនឹងប្រគល់រាជ្យឲ្យ អញមិនត្រូវការដោយរាជ្យទេ ។

អជ្ជេវ បព្វជិស្សាមិ  កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ  កាមានំ វសមន្វគា ។

(៧៩) អត្ថិ តេ ទហរោ បុត្តោ  ទីឃាវុ រដ្ឋវឌ្ឍនោ
តំ រជ្ជេ អភិសិញ្ចស្សុ  សោ នោ រាជា ភវិស្សតិ ។

(៨០) ខិប្បំ កុមារំ អានេថ  ទីឃាវុំ រដ្ឋវឌ្ឍនំ
តំ រជ្ជេ អភិសិញ្ចិស្សំ  សោ វោ រាជា ភវិស្សតិ ។

(៨១) តតោ កុមារមានេសុំ  ទីឃាវុំ រដ្ឋវឌ្ឍនំ
តំ ទិស្វា អាលបិ រាជា  ឯកបុត្តំ មនោរមំ ។

សដ្ឋី គាមសហស្សានិ  បរិបុណ្ណានិ សព្វសោ
តេ បុត្ត បដិបជ្ជស្សុ  រជ្ជំ និយ្យាទយាមិ តេ ។

អជ្ជេវ បព្វជិស្សាមិ  កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ  កាមានំ វសមន្វគំ ។

អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹង មានក្នុងថ្ងៃស្អែក អញលែងលុះ ក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកនោតហើយ ។

(៧៩) (ពួកអាមាត្យ...) ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមទីឃាវុ នៅក្មេង ជាអ្នកញុំាងផែនឲ្យចំរើន សូមព្រះអង្គអភិសេក ព្រះរាជបុត្រនោះក្នុងរាជ្យចុះ ព្រះរាជបុត្រនោះនឹងបានជាព្រះរាជា របស់យើងខ្ញុំ ។

(៨០) (ព្រះរាជា...) អ្នកទាំងឡាយ ចូរនាំយកកុមារឈ្មោះទីឃាវុ អ្នកញុំាងផែនឲ្យចំរើនមកឲ្យឆាប់ អញនឹងអភិសេកកុមារនោះក្នុង រាជ្យ កុមារនោះនឹងជាព្រះរាជារបស់អ្នកទាំងឡាយ ។

(៨១) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ពួកអាមាត្យក៏បាននាំកុមារ ឈ្មោះទីឃាវុ អ្នកញុំាងផែនឲ្យចំរើនមកថ្វាយ ព្រះរាជាទត ឃើញទីឃាវុកុមារនោះ ជាបុត្រតែមួយ ជាទីត្រេកអរពេញព្រះ ទ័យហើយទ្រង់ត្រាស់ថា នៃបុត្រ ស្រុកទាំង ៦០.០០០ បរិបូណ ដោយវត្ថុទាំងពួង ចូរបាថែទាំស្រុកទាំងនោះចុះ អញនឹងប្រគល់ រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹង ថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃ កាមទាំងឡាយ ដូចជាក្អែកនោតឡើយ ។

## សដ្ឋិនិបាតេ បឋមំ សោណកជាតកំ

សដ្ឋី នាគសហស្សានិ សព្វាលង្ការភូសិតា
សុវណ្ណកច្ឆា មាតង្គា ហេមកប្បនវាសសា ។
អារូឡ្ហា គាមណីយេភិ តោមរង្កុសបាណិភិ
តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។
អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។
សដ្ឋី អស្សសហស្សានិ សព្វាលង្ការភូសិតា
អាជានីយា ច ជាតិយា សិន្ធវា សីឃវាហនា
អារូឡ្ហា គាមណីយេភិ ឥន្ទិយាចាបធារិភិ
តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។
អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។
សដ្ឋី រថសហស្សានិ សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា ។
អារូឡ្ហា គាមណីយេភិ ចាបហត្ថេហិ វម្មិភិ(១)
តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

១ ឱ. វម្មិហិ ។ ម. វម្មិកិ ។

ដំរី ៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានខ្សែជង្គង់ធ្វើអំពីមាស បិទបាំងដោយកម្រាលដែលធ្វើអំពីមាស ជាដំរីកើតក្នុងព្រៃមាតង្គៈ ៗ ដំរីណាដែលពួកហ្មដំរីមានដៃកាន់អាវុធនឹងកង្វេរឡើងជិះ នែបុត្រ អ្នកចូរថែទាំពួកដំរីទាំងនោះចុះ អញប្រគល់រាជ្យដល់អ្នក ៗ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកឆោតឡើយ ៗ សេះ ៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ជាសេះអាជានីយដោយកំណើតជាសេះសិន្ធវៈជាពាហនៈយ៉ាងលឿន ដែលពួកសារថីកាន់ស៊ែនឹងធ្នូជិះ នែបុត្រ បាចូរថែទាំសេះទាំងនោះចុះ អញប្រគល់រាជ្យដល់បា ៗ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ៗ រថ ៦០.០០០ ដែលគេទឹមហើយ ដោតទង់ជ័យ គ្រោបដោយស្បែកខ្លាដំបង គ្រោបដោយស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ៗ អ្នកបររថ មានដៃកាន់ធ្នូ ស្លៀកខែលហើយឡើងជិះ នែបុត្រ បាចូរថែទាំរថទាំងនោះចុះ អញប្រគល់រាជ្យដល់បា ៗ

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាបុរិសោ ទុម្មេធោ កាមានំ វសមន្វគំ ។
សដ្ឋី ធេនុសហស្សានិ ទោហញ្ញា បុង្គវូសភា
តា បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។
អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាបុរិសោ ទុម្មេធោ កាមានំ វសមន្វគំ ។
សោឡសិត្ថីសហស្សានិ សព្វាលង្ការភូសិតា
វិចិត្រវត្ថាភរណា អាមុត្តមណិកុណ្ឌលា
តា បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។
អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាបុរិសោ ទុម្មេធោ កាមានំ វសមន្វគំ ។

(៨២) ទហរស្សេវ មេ តាត មាតា មតាតិ មេ សុតំ
តយា វិនា អហំ តាត ជីវិតុំបិ ន ឧស្សហេ ។
យថា អារញ្ញកំ នាគំ បោតោ អន្វេតិ បច្ឆតោ
ជេស្សន្តំ (១) គិរិទុគ្គេសុ សមេសុ វិសមេសុ ច ។

---

១ ម. ទេស្សន្តំ ។

អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកនោតឡើយ ៗ មេគោ ៦០ ០០០ ជាមេគោក្រហមប្រកបដោយគោខ្វាន (គោបា) នែបុត្រ ចូរថែទាំមេគោទាំងនោះចុះ អញប្រគល់រាជ្យដល់ចា ៗ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកនោតឡើយៗ ស្ត្រី ១៦.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាងមានសំពត់នឹងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលកែវមណី នែបុត្រ ចូរថែទាំស្ត្រីទាំងនោះចុះ អញប្រគល់រាជ្យដល់ចា ៗ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណា គប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកនោតឡើយ ៗ

[៨២] (ព្រះរាជកុមារ...) បពិត្រព្រះវរបិតា កាលដែលទូលព្រះបង្គំជាខ្ញុំនៅក្មេងនៅឡើយ ទូលព្រះបង្គំជាខ្ញុំបានឮថាព្រះវរមាតាទ្រង់សោយពិរាល័យទៅហើយ បពិត្រព្រះវរបិតាទូលព្រះបង្គំជាខ្ញុំព្រាត់ប្រាសចាកព្រះអង្គហើយ មិនអាចនឹងរស់នៅបានទេៗ កូនដំរីមែងទៅតាមក្រោយដំរីដែលទៅក្នុងព្រៃ ដើរទៅក្នុងជង្ហុកនៃភ្នំទាំងឡាយដែលរាបស្មើ នឹងមិនរាបស្មើ យ៉ាងណាមិញ ៗ

## សដ្ឋិនិបាតេ បឋមំ សោណកជាតកំ

ឯវន្តំ អនុគច្ឆាមិ បុត្តមាទាយ បច្ឆតោ
សុភរោ តេ ភវិស្សាមិ ន តេ ហេស្សាមិ ទុព្ភរោ ។
(៨៣) យថា សាមុទ្ទិកំ នាវំ វាណិជានំ ធនេសិនំ
វោហារោ តត្ថ គណ្ហេយ្យ វាណិជា ព្យសនី សិយា
ឯវមេវាយំ បុត្តកលិ អន្តរាយករោ មម ។
(៨៤) ឥមំ កុមារំ បាវេថ បាសាទំ រតិវឌ្ឍនំ
តត្ថ កម្ពុសហត្ថាយោ យថា សក្កំវ អច្ឆរា
តា នំ តត្ថ រមិស្សន្តិ តាហិ ចេសោ រមិស្សតិ ។
(៨៥) តតោ កុមារំ បាវេសុំ បាសាទំ រតិវឌ្ឍនំ
តំ ទិស្វា អវចុំ កញ្ញា ទីឃាវុំ រដ្ឋវឌ្ឍនំ ។
ទេវតា នុសិ គន្ធព្វោ អាទុ សក្កោ បុរិន្ទទោ
កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ ។

ទូលព្រះបង្គំជាខ្ញុំ នាំយកកូនទៅតាមព្រះអង្គ ក៏យ៉ាងនោះដែរ ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលព្រះអង្គចិញ្ចឹមងាយ ពុំមែនព្រះអង្គពិបាកចិញ្ចឹមឡើយ ។

(៨៣) (ព្រះរាជា...) សត្វជាអ្នកបំផ្លាញ គប្បីចាប់សំពៅដែលដើរក្នុងសមុទ្រ របស់ពួកពាណិជដែលស្វែងរកទ្រព្យក្នុងសមុទ្រនោះ ពួកពាណិជត្រូវវិនាស យ៉ាងណាមិញ នៃកូនលាមកឯងនេះ ធ្វើសេចក្តីអន្តរាយ ដល់អញ ក៏យ៉ាងនោះដែរ ។

(៨៤) អ្នកទាំងឡាយ ចូរញុំាងកុមារនេះឲ្យដល់ប្រាសាទ ដែលញុំាងតម្រេកឲ្យចំរើន ក្នុងប្រាសាទនោះមានពួកស្រីមានដៃស្អិតស្អាងដោយគ្រឿងអាភរណៈ ធ្វើអំពីមាស ស្ត្រីទាំងនោះនឹងត្រេកអរចំពោះកុមារនោះ ក្នុងប្រាសាទនោះ ដូចជាពួកស្រីអប្សរត្រេកអរនឹងសក្កទេវរាជ កុមារនុះនឹងត្រេកអរដោយស្ត្រីទាំងនោះ ។

(៨៥) (អភិសម្ពុទ្ធគាថា) លំដាប់អំពីនោះមក ពួកអាមាត្យបានញុំាងកុមារឲ្យដល់ប្រាសាទ ដែលញុំាងតម្រេកឲ្យចំរើន ឯពួកនាងកញ្ញា ឃើញទីឃាវុកុមារនោះ ជាអ្នកញុំាងដែនឲ្យចំរើនហើយ ក៏បានពោលថា លោកជាទេវតាឬជាគន្ធព្វ ឬក៏ជាព្រះឥន្ទ្រឈ្មោះបុរិន្ទទៈ លោកជាអ្វី ជាបុត្រនៃអ្នកណា ធ្វើដូចម្តេច យើងនឹងអាចស្គាល់លោកបាន ។

(៨៦) នត្ថិ លោកេ ន តន្ទេព្វា នបិ សក្កោ បុរិន្ទទោ

កាសិរញ្ញោ អហំ បុត្តោ ទីឃាវុ រដ្ឋវឌ្ឍនោ

មមំ ភរថ ភទ្ទំ វោ(១) អហំ ភត្តា ភវាមិ វោ ។

(៨៧) តំ តត្ថ អវចុំ កញ្ញា ទីឃាវុំ រដ្ឋវឌ្ឍនំ

កុហឹ រាជា អនុប្បត្តោ ឥតោ រាជា កុហឹ គតោ ។

(៨៨) បង្កំ រាជា អតិក្កន្តោ ថលេ រាជា បតិដ្ឋិតោ

អកណ្ដកំ អគហនំ បដិបន្នោ មហាបថំ ។

អហញ្ច បដិបន្នាស្មិ មគ្គំ ទុគ្គតិគាមិនំ

សកណ្ដកំ សគហនំ យេន គច្ឆន្តិ ទុគ្គតឹ ។

(៨៩) តស្ស តេ ស្វាគតំ រាជ សីហស្សេវ គិរិព្វជំ

អនុសាស មហារាជ ត្វំ នោ សព្វាសមិស្សរោតិ ។

សោណកជាតកំ បឋមំ ។

---

១ ម. ភទ្ទន្តេ ។

(៨៦) (ព្រះរាជកុមារ...) យើងមិនមែនជាទេវតា មិនមែនជាគន្ធព្វ ទាំងមិនមែន ជាព្រះឥន្ទ្រឈ្មោះបុរិន្ទទៈទេ យើងជាកូននៃព្រះរាជាក្នុងដែនកាសី ឈ្មោះទីឃាវុ ជាអ្នកញុំាងដែន ឲ្យចំរើន នាងទាំងឡាយ ចូរប្រាថ្នាយើងចុះ សេចក្ដីចំរើននឹងមានដល់ពួកនាងទាំងឡាយ យើងជាកស្ដារបស់ពួកនាង ។

(៨៧) (អភិសម្ពុទ្ធគាថា) ពួកនាងកញ្ញា បានទូលសួរទីឃាវុកុមារនោះដែលញុំាងដែនឲ្យចំរើនក្នុងប្រាសាទនោះថា ព្រះរាជាស្ដេចយាងទៅក្នុងទីណា ព្រះរាជាស្ដេចចេញអំពីទីនេះទៅក្នុងទីណា ។

(៨៨) (ព្រះរាជកុមារ...) ព្រះរាជាទ្រង់បានឈានកន្ទក់ (រាគាទិកិលេស) ព្រះរាជាទ្រង់បានឋិតនៅស៊ប់លើគោក (ផ្នួស) ទ្រង់យាងទៅកាន់ផ្លូវធំ (ជាទីទៅកាន់សួគ៌និងព្រះនិព្វាន) ដែលមិនមានបន្លា មិនមានព្រៃញាតស្បាត (រាគៈ) ។ ចំណែកយើងជាអ្នកដើរទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិ ប្រកបដោយបន្លា ប្រកបដោយព្រៃញាតស្បាត សម្រាប់ទៅកាន់ទុគ្គតិ របស់ពួកសត្វ ។

(៨៩) (ពួកនាងកញ្ញា...) បពិត្រព្រះរាជា ព្រះអង្គនោះយាងមកល្អហើយ ហាក់ដូចជាសីហៈដែលមកកាន់គិរិព្វជៈ (គុហាមាស) បពិត្រមហារាជ សូមព្រះអង្គគ្រប់គ្រងចុះ ព្រះអង្គជាម្ចាស់របស់ពួកខ្ញុំម្ចាស់ទាំងអស់គ្នា ។

ចប់ សោណកជាតក ទី ១ ។

# សង្កិច្ចជាតកំ

(៩០) ទិស្វា និសិន្នំ រាជានំ   ព្រហ្មទត្តំ រថេសភំ
អថស្ស បដិវេទេសិ   យស្សាសិ អនុកម្បកោ ។
សង្កិច្ចាយំ អនុប្បត្តោ   ឥសីនំ សាធុសម្មតោ
តរមានរូបោ និយ្យាហិ   ខិប្បំ បស្ស មហេសិនំ ។
តតោ ច រាជា តរមានោ   យុត្តមារុយ្ហ សន្ទនំ
មិត្តាមច្ចបរិព្យូឡ្ហោ   អគមាសិ រថេសភោ ។
និក្ខិប្ប បញ្ចកកុធានិ   កាសីនំ រដ្ឋវឌ្ឍនោ
វាឡពីជនិមុណ្ហីសំ   ខគ្គំ ឆត្តញ្ចុបាហនំ ។
ឱរុយ្ហ រាជា យានម្ហា   ឋបយិត្វា បដិច្ឆទំ
អាសីនំ ទាយបស្សស្មឹ   សង្កិច្ចមុបសង្កមិ ។
ឧបសង្កមិត្វា សោ រាជា   សម្មោទិ ឥសិនា សហ
តំ កថំ វីតិសារេត្វា   ឯកមន្តំ ឧបាវិសិ ។
ឯកមន្តំ និសិន្នោវ   អថ កាលំ អមញ្ញថ
តតោ បាបានិ កម្មានិ   បុច្ឆិតុំ បដិបជ្ជថ ។

# សង្កិច្ចជាតក

(៩០) (អភិសម្ពុទ្ធគាថា) (ឧយ្យានបាលនោះ) ឃើញព្រះរាជាទ្រង់ព្រះនាមព្រហ្មទត្ត ប្រសើរក្នុងរថ ហើយក្រាបទូលព្រះរាជានោះក្នុងគ្រានោះថា ព្រះអង្គជាបុគ្គលឈឺឆ្អាល ដល់ឥសីណា ៗ ឥសីឈ្មោះសង្កិច្ចៈនេះដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសីមកដល់ហើយ សូមព្រះអង្គប្រញាប់ប្រញាល់ យាងចេញទៅជួបនឹងមហាឥសីឲ្យឆាប់ ៗ លំដាប់នោះ ព្រះរាជាប្រសើរក្នុងរថ មានមិត្រនឹងអាមាត្យហែហម ទ្រង់ប្រញាប់ឡើងកាន់រថដែលគេទឹមហើយ ទ្រង់យាងទៅ ៗ ព្រះរាជាញុំាងដែននៃពួកកាសីឲ្យចំរើន ទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង គឺ ផ្លិតរោមសត្វ១ មកុដ១ ព្រះខាន់១ ឆ័ត្រ១ សុពណ៌បាទុកា១ ៗ លុះព្រះរាជាទ្រង់យាងចុះអំពីយាន ទុកគ្រឿងកកុធៈ ហើយទើបយាងចូលទៅរកសង្កិច្ចឥសី ដែលអង្គុយក្នុងឧទ្យានឈ្មោះទាយបស្សៈ ៗ ព្រះរាជានោះចូលទៅសំណេះសំណាលជាមួយនឹងឥសី លុះបញ្ចប់ពាក្យនោះហើយ ក៏គង់ក្នុងទីដ៏សមគួរ ៗ ព្រះរាជាគង់ស៊ប់ក្នុងទីសមគួរហើយ ទើបទ្រង់ជ្រាបនូវកាលគួរប្រតិបត្តិដើម្បីសួរនូវបាបកម្មទាំងឡាយ ក្នុងពេលនោះ ៗ

ឥសឹ បុច្ឆាម សង្កិច្ចំ ឥសីនំ សាធុសម្មតំ

អាសីនំ ទាយបស្សស្មឹ ឥសិសង្ឃបុរក្ខតំ ។

កំ គតឹ បេច្ច គច្ឆន្តិ នរា ធម្មាតិចារិនោ

អតិចិណ្ណោ មយា ធម្មោ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៩១) ឥសិ អវច សង្កិច្ចោ កាសីនំ រដ្ឋវឌ្ឍនំ

អាសីនំ ទាយបស្សស្មឹ មហារាជ សុណោហិ មេ ។

ឧប្បថេន វជន្តស្ស យោ មគ្គមនុសាសតិ

តស្ស ចេ វចនំ កយិរា នាស្ស មគ្គេយ្យ កណ្ដកោ ។

អធម្មំ បដិបន្នស្ស យោ ធម្មមនុសាសតិ

តស្ស ចេ វចនំ កយិរា ន សោ គច្ឆេយ្យ ទុគ្គតឹ ។

(៩២) ធម្មោ បថោ មហារាជ អធម្មោ បន ឧប្បថោ

អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគ្គតឹ ។

អធម្មចារិនោ រាជ នរា វិសមជីវិនោ

យំ គតឹ បេច្ច គច្ឆន្តិ និរយេ តេ សុណោហិ មេ ។

យើងសូមសួរសង្កិច្ចឥសី ដែលគេសន្មតថាជាសប្បុរសរបស់ពួក ឥសី ដែលពួកឥសីហោមរោមហើយ គង់ក្នុងទាយបស្សឧទ្យាន ។ ពួកជនអ្នកប្រព្រឹត្តរំលងធម៌ លុះស្លាប់ទៅវិញ ទៅកាន់គតិណា ធម៌ គឺបិតុឃាតកម្ម ខ្ញុំបានប្រព្រឹត្តកន្លងហើយ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្តីនោះដល់ខ្ញុំ ។

(៩១) សង្កិច្ចឥសី បានពោលនឹងព្រះរាជាអ្នកញុំាងដែនកាសីឲ្យចំរើន គង់ក្នុងទាយបស្សឧទ្យានថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាព ។ អ្នកណាប្រាប់ផ្លូវដល់បុគ្គលអ្នកដើរផ្លូវខុស បើបុគ្គលនោះធ្វើតាមពាក្យរបស់អ្នកប្រាប់នោះ បន្ទា(ទោស) មិនគប្បីប៉ះពាល់បុគ្គលអ្នកធ្វើតាមនោះទេ ។ អ្នកណាប្រៀនប្រដៅធម៌ដល់បុគ្គលប្រតិបត្តិអធម៌ បើបុគ្គលនោះធ្វើតាមពាក្យរបស់អ្នកប្រដៅនោះ បុគ្គលនោះមិនគប្បីទៅកាន់ទុគ្គតិទេ ។

(៩២) បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌នាំសត្វទៅកាន់នរក ធម៌ញុំាងសត្វឲ្យដល់សុគតិ ។ បពិត្រព្រះរាជា ពួកជនអ្នកមិនប្រព្រឹត្តធម៌ ចិញ្ចឹមជីវិតខុសគន្លងធម៌ លុះស្លាប់ទៅវិញហើយ រមែងទៅកាន់គតិ (នរក)ណា សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យអាត្មាភាព (ដែល សំដែងអំពីនរក) ទាំងនោះ ។

## សដ្ឋិនិបាតេ ទុតិយំ សង្កិច្ចជាតកំ

សញ្ជីវោ កាឡសុត្តោ ច សង្ឃាតោ ទ្វេ ច រោរុវា
អថាបរោ មហាវីចិ តាបនោ ច បតាបនោ ។
ឥច្ចេតេ អដ្ឋ និរយា អក្ខាតា ទុរតិក្កមា
អាកិណ្ណា លុទ្ទកម្មេហិ បច្ចេកា សោឡសុស្សទា ។
(១)
កទរិយា តាបនា ឃោរា អច្ចិមន្តោ មហាព្ភយា
លោមហំសនរូបា ច ភេស្មា បដិភយា ទុខា ។
ចតុក្កណ្ណា ចតុទ្វារា វិភត្តា ភាគសោ មិតា
អយោបាការបរិយន្តា អយសា បដិកុជ្ជិតា ។
តេសំ អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផុដា តិដ្ឋន្តិ សព្វទា ។
ឯតេ បតន្តិ និរយេ ឧទ្ធំបាទា អវំសិរា
ឥសីនំ អតិវត្តារោ សញ្ញតានំ តបស្សិនំ ។
តេ ភូនហុនោ បច្ចន្តិ មច្ឆា ពីលកតា យថា
សំវច្ឆរេ អសង្ខេយ្យេ នរា កិព្វិសការិនោ ។

---

១ កទរិយតាបនាតិ អដ្ឋកថាយំ ។

សញ្ជីវនរក ១ កាឡសុត្តៈ ១ សង្ឃាដៈ ១ រោរុវៈ ២ នរកដទៃទៀត គឺមហាអវិចិ ១ តាបនៈ ១ បតាបនៈ ១ ៗ នរកទាំង ៨ នុ៎ះដែលអ្នកប្រាជ្ញទាំងឡាយបានសំដែងហើយដោយប្រការដូច្នេះ កម្រមានបុគ្គលណាកន្លងរំលងបាន តាន់តាប់ដោយពួកសត្វដែលមានកម្មអាក្រក់បំពោះមហានរកមួយ ៗ មានឧស្សទនរក ១៦ ៗ ( នរកទាំងនោះ) ជាទីក្ដៅអ្នកកំណាញ់ស្វិតស្វាញ ជានរកដ៏ពន្ទឹក មានអណ្ដាតភ្លើង មានភ័យធំ មានសភាពជាទីព្រឺរោម គួរឲ្យស្ញៀមបណ្ដាលឲ្យខ្លបខ្លាច ជាទុក្ខ ៗ ( នរកទាំងនោះ ) មានមុំ ៤ មានទ្វារ ៤ ដែលបាបកម្មចែកវាស់ដោយបំណែក មានកំពែងដែកព័ទ្ធជុំវិញ ប្រក់ដោយគ្រឿងដែក ៗ ភូមិរបស់នរកទាំងនោះជាវិការៈនៃដែកឆេះឡើង ប្រកបដោយកំដៅ ( នរកទាំងអស់នោះ )ផ្សាយទៅអស់ទី ១០០ យោជន៍ជុំវិញ ឋិតនៅសព្វ ៗ កាល ៗ ពួកជនអ្នកតិះដៀលពួកឥសី ជាអ្នកសង្រួមមានតបៈនុ៎ះរមែងធ្លាក់ទៅក្នុងនរកមានជើងឡើងលើ មានក្បាលចុះក្រោម ៗ ពួកជនអ្នកធ្វើអំ-ពើអាក្រក់ ជាអ្នកបំផ្លិចបំផ្លាញសេចក្ដីចំរើននោះត្រូវពួកនិរយបាលដុត ដូចជាពួកត្រីដែលគេធ្វើឲ្យជាបំណែក ( ដោតអាំង )អស់ឆ្នាំរាប់មិនអស់ ។

ឧយ្ហមានេន គត្តេន ឆិទ្ទំ សន្តរពាហិរំ
នេរយា ពាដិគច្ឆន្តិ ទ្វារំ និក្ខមនេសិនោ ។
បុរត្ថិមេន ធាវន្តិ តតោ ធាវន្តិ បច្ឆតោ
ឧត្តរេនបិ ធាវន្តិ តតោ ធាវន្តិ ទក្ខិណំ
យំ យញ្ហិ ទ្វារំ គច្ឆន្តិ តន្តទេវ បិធិយ្យរេ ។
ពហូនិ សតសហស្សានិ ជនា និរយគាមិនោ
ពាហា បគ្គយ្ហ កន្ទន្តិ បត្វា ទុក្ខំ អនប្បកំ ។
អាសីវិសំវ កុប្បិតំ តេជស្សី ទុរតិក្កមំ
ន សាធុរូបេ អាសីទេ សញ្ញតានំ តបស្សិនំ ។
អតិកាយោ មហិស្សាសោ អជ្ជុនោ កេកកាធិបោ
សហស្សពាហុ ឧច្ឆិន្នោ(១) ឥសិមាសជ្ជ គោតមំ ។
អរជំ រជសា វច្ឆំ កិសំ អវកិរិយ ទណ្ឌកី
តាលោវ មូលតោ ឆិន្នោ ស រាជា វិភវង្គតោ ។

---
១ ម. អច្ឆិន្នោ ។

ពួកសត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុងខាងក្រៅជានិច្ច ស្វែងរកនូវទីចេញអំពីនរកតែមិនបាននូវទ្វារ ។ ពួកសត្វនរកនោះស្ទុះទៅទិសខាងកើត ស្ទុះអំពីទិសខាងកើតនោះ ទៅទិសខាងលិច ស្ទុះទៅទិសខាងជើង ស្ទុះអំពីទិសខាងជើង ទៅទិសខាងត្បូង សត្វនរកទាំងនោះទៅដល់ទ្វារណា ៗ ទ្វារនោះ ៗ ឯង ក៏បិទជិត ។ ពួកជនដែលទៅកាន់នរក រងទុក្ខច្រើន ផ្គងដើមដៃកន្ទក់កន្ទេញ អស់សែននៃឆ្នាំជាច្រើន ។ បុគ្គលមិនគប្បីចូលទៅបៀតបៀន នូវពួកឥសី ដែលមានសភាពជាសប្បុរស ដូចជាបុគ្គលមិនគួរចូលទៅជិតអាសិរពិស ដែលខឹងមានតេជះ គេកន្លងរំលងបានដោយក្រ ( ជនទាំងនោះ រមែងធ្លាក់ទៅក្នុងនរក ព្រោះតែបៀតបៀន ) នូវពួកឥសីអ្នកសង្រួមមានតបៈ ។ ព្រះរាជាព្រះនាមអជ្ជុនៈមានខ្នាន់ធ្នូដ៏ប្រសើរមានពួកពលដ៏ច្រើន ជាអធិបតីក្នុងដែនឈ្មោះកេតកៈ អាចលើកធ្នូដែលពួកខ្នាន់ធ្នូ ៥០០ លើកឡើងបានដោយដើមដៃ ១.០០០ បៀតបៀនឥសីឈ្មោះគោតមៈ ហើយវិនាស ។ ព្រះរាជាទណ្ឌកីបានបាចពោយធូលី ( ស្តោះ ) លើតាបស ឈ្មោះ កិសវច្ឆៈមិនមានធូលី ( កិលេស ) ព្រះរាជានោះ ក៏ដល់នូវសេចក្តីវិនាស ដូចជាដើមត្នោត ដែលគេកាត់ត្រង់គល់ ។

## សន្ធិនិបាតេ ទុតិយំ សង្កិច្ចជាតកំ

ឧបហច្ច មនំ មេជ្ឈោ មាតង្គស្មឹ យសស្សិនេ
សបារិសជ្ជោ ឧច្ឆិន្នោ មេជ្ឈារញ្ញំ តទា អហុ ។
កណ្ហទីបាយនាសជ្ជ ឥសឹ អន្ធកវេណ្ឌយោ
អញ្ញមញ្ញំ មុសលេ ហន្ត្វា សម្បត្តា យមសាធនំ ។
អថាយំ ឥសិនា សត្តោ អន្តលិក្ខចរោ បុរេ
បាវេក្ខិ បថវឹ ចេច្ចោ ហីនត្តោ កាលបរិយាយំ ។
តស្មា ហិ ឆន្ទាគមនំ នប្បសំសន្តិ បណ្ឌិតា
អទុដ្ឋចិត្តោ ភាសេយ្យ គិរំ សច្ចូបសំហិតំ ។
មនសា ចេ បទុដ្ឋេន យោ នរោ បេក្ខតេ មុនឹ
វិជ្ជាចរណសម្បន្នំ គន្ត្វា សោ និរយំ អធោ ។
យេ វុឌ្ឍេ បរិភាសន្តិ ផរុសូបក្កមា ជនា
អនបច្ចា អទាយាទា តាលវត្ថូ ភវន្តិ តេ ។
យោ ច បព្វជិតំ ហន្តិ កតកិច្ចំ មហេសិនំ
ស កាឡសុត្តេ និរយេ ចិររត្តាយ បច្ចតិ ។

ព្រះរាជាព្រះនាម មេជ្ឈៈ ព្រមទាំងបរិស័ទ ញុំាងចិត្តឲ្យប្រទូស្ត ក្នុងតាបសឈ្មោះមាតង្គបណ្ឌិត មានយស ហើយក៏ដល់នូវសេចក្តីវិនាស ក្នុងកាលនោះដែនឈ្មោះមេជ្ឈៈក៏ទៅជាព្រៃ ៗ ពួកព្រះរាជា ជាផៅពង្សអន្ធកវេណ្ឌុ បៀតបៀននូវឥសីឈ្មោះកណ្ហទីបា-យនៈកានយកអង្រែសំឡាប់គ្នានឹងគ្នា ហើយក៏ធ្លាក់ទៅក្នុងនរក ៗ ព្រះរាជាព្រះនាមចេតិយៈនេះ កាលពីដើមហោះលើអាកាសបាន ដល់មកខាងក្រោយ ត្រូវកបិលឥសីផ្តាសាហើយ មានអត្តភាពសាបសូន្យប៉ុលទៅកាន់ផែនដី ដល់នូវសេចក្តីស្លាប់ ព្រោះហេតុនោះ បានជាពួកបណ្ឌិតមិនសរសើរអគតិ ៤ មានឆន្ទាគតិជាដើមឡើយ បុគ្គលមានចិត្តមិនប្រទូស្ត គប្បីពោលពាក្យប្រកបដោយសច្ចៈ បើនរណាមានចិត្តប្រទូស្តហើយ សំឡក់ទៅរកអ្នកប្រាជ្ញដែលបរិបូណ៌ដោយវិជ្ជានឹងចរណៈ នរៈនោះនឹងធ្លាក់ទៅក្នុងនរកខាងក្រោម ៗ ពួកជនណាមានសេចក្តីព្យាយាមអាក្រក់ ជេរប្រទេចពួកចាស់ព្រឹទ្ធាចារ្យ ពួកជននោះ (លុះទៅកើតក្នុងភពខាងមុខ) គេកូនគ្មាន គេញាតិគ្មានដូចគោតកំបុតគល់ ៗ ជនណាសម្លាប់បព្វជិតដែលមានកិច្ចធ្វើហើយ អ្នកស្វែងរក នូវគុណដ៏ធំ ជននោះរមែងឆេះនៅក្នុងកាឡសុត្តនរកអស់កាលជាយូរអង្វែង ៗ

យោ ច រាជា អធម្មដ្ឋោ រដ្ឋវិទ្ធំសនោ មគោ
តាបយិត្វា ជនបទំ តាបនេ បេច្ច បច្ចតិ ។
សោ ច វស្សសហស្សានិ សតំ ទិព្យានិ បច្ចតិ
អច្ចិសង្ឃបរេតោ សោ ទុក្ខំ វេទេតិ វេទនំ ។
តស្ស អគ្គិសិខា កាយា និច្ឆរន្តិ បភស្សរា
តេជោភក្ខស្ស គត្តានិ លោមេហិ ច នខេហិ ច ។
ឧយ្ហមានេន គត្តេន និច្ចំ សន្តរពាហិរំ
ទុក្ខាភិតុន្នោ នទតិ នាគោ តុណ្ណដ្ដិតោ យថា (១) ។
យោ លោភា បិតរំ ហន្តិ ទោសា វា បុរិសាធមោ
ស កាឡសុត្តេ និរយេ ចិរំ រត្តាយ បច្ចតិ ។
ស តាទិសោ បច្ចតិ លោហកុម្ភិយំ
បក្កញ្ច សត្តីហិ ហនន្តិ និត្តចំ
អន្ធំ ករិត្វា មុត្តករីសភក្ខំ
ខារេ និមុជ្ជន្តិ តថាវិធំ នរំ ។
តត្តំ បក្កុដ្ឋិតមយោគុឡញ្ច
ទីឃេ ច ផាលេ ចិររត្តតាបិតេ

---

១ ឱ. តុត្តទ្ទិ តោ យថា ។ ម. តុត្តដ្ដិតោយថា ។

ព្រះរាជាណា មិនតាំងនៅក្នុងធម៌ កំចាត់កំចាយអ្នកដែន ដុតកំ-
ដៅអ្នកជនបទ ព្រះរាជានោះលុះទ្រង់ទិវង្គតទៅ រមែងឆេះនៅក្នុង
តាបននរក ។ ព្រះរាជានោះក៏ឆេះអស់សែនឆ្នាំទិព្វ ព្រះរាជា
នោះត្រូវគំនរអណ្ដាតភ្លើងហ៊ុំជុំវិញហើយ ក៏សោយទុក្ខវេទនាខ្លាំង ៗ
អណ្ដាតភ្លើងទាំងឡាយដ៏រន្ទាលព្រាលផ្លោ ផ្សាយចេញអំពីកាយ
របស់សត្វនរកនោះ ខ្លួនរបស់សត្វនរកដែលមានភ្លើងជាអាហារ
( មានអណ្ដាតៈភ្លើងតែមួយជាមួយគ្នា ) ទឹងចុងរោមទាំងឡាយផង
ទឹងក្រចកទាំងឡាយផង ៗ សត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ
ទាំងខាងក្នុង ខាងក្រៅជានិច្ច ត្រូវសេចក្ដីទុក្ខចាក់ដោតហើយ
ក៏ពេទ៍ដូចជាដំរី ដែលគេចាក់ដោយងៀងកង្វេរ ៗ បុរសណាមក
ណា សម្លាប់បិតា ព្រោះតែលោភៈឬព្រោះទោសៈ បុរសណាមក
នោះ រមែងឆេះនៅក្នុងកាឡសុត្តនរក អស់កាលជាយូរអង្វែង ៗ
បុរសបែបនោះ រមែងឆេះនៅក្នុងលោហកុម្ភីនរក ពួកនិរយបាល
( នាំចេញ ) នូវសាច់ដ៏ឆ្អិន ធ្វើមិនឲ្យមានស្បែក ហើយចាក់
ដោយលំពែងទាំងឡាយ ធ្វើឲ្យខ្វាក់ ឲ្យស៊ីនូវមូត្រនិងលាមក
ហើយជ្រមុជជនបែបនោះទៅ ក្នុងទឹកខារ ( ទឹកទង់ដែង ) ៗ
ពួកនិរយបាល ( ញុំាងសត្វនរកឲ្យស៊ីនូវលាមក ) កំពុងពុះ ទឹង
ដុំដែកដ៏ក្ដៅ ហើយយកបណ្ដាញដ៏វែង ដែលកំដៅអស់កាលយូរ

## សដ្ឋិនិបាតេ ទុតិយំ សង្កិច្ចជាតកំ

វិក្ខម្ភមាទាយ វិភជ្ជ(១) រជ្ជុភិ
វិហនេ មុខេ សំសរយន្តិ រក្ខសា ។
សាមា ច សោណា សពលា ច គិជ្ឈា
កាកោលសង្ឃា ច ទិជា អយោមុខា
សង្គម្ម ខាទន្តិ វិផន្ទមានំ
ជិវ្ហំ វិភជ្ជ វិឃាសំ សលោហិតំ ។
តំ ទឌ្ឍតាលំ បរិភិន្នគត្តំ
និប្បោថយន្តា អនុវិចរន្តិ រក្ខសា
រតី ហិ តេសំ ទុក្ខិនោ បនីតរេ
ឯតាទិសស្មឹ និរយេ វសន្តិ
យេ កេចិ លោកេ ឥធ បេត្តិឃាតិនោ ។

បុត្តោ ច មាតរំ ហន្ត្វា ឥតោ គន្ត្វា យមក្ខយំ
ភុសមាបជ្ជតេ ទុក្ខំ អត្តកម្មផលូបគោ ។
អមនុស្សា អតិពលា ហន្តារំ ជនយន្តិយា
អយោមយេហិ វាលេហិ បីឡយន្តិ បុនប្បុនំ ។
តំ បស្សវំ សកា គត្តា រុហិរំ អត្តសម្ភវំ
តម្ពលោហវិលីនំវ តត្តំ បាយេន្តិ មត្តិឃំ ។

---

១ ម. វិពន្ធ ។

មកបើកមាត់ (ហើយបោះសន្ទួចដែក) ដែលចង ដោយខ្សែ (ទាញអណ្តាតចេញហើយបោះដុំដែក) ទៅក្នុងមាត់ ដែលប្រហោនោះ ៗ ពួកឆ្កែក្រហម ឆ្កែពពាល ពួកត្មាត ពួកក្អែកនិងពួកសត្វស្លាប (ឯទៀតច្រើនពួក) មានចំពុះដែក នាំគ្នាមកចោមរោមចឹកដណ្តើមស៊ីនូវអណ្តាត (នៃពួកសត្វនរក) ដែលញាប់ញ័រ (ដូចជាស៊ី) នូវរំពាព្រមទាំងឈាម មានឈាមកំពុងហូរចេញ ៗ ពួកនិរយបាលវាយសំពងសត្វនរកនោះ ដែលភ្លើងកំពុងឆេះ មានខ្លួនរយះរយាយ ដោយតម្រេករបស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរកទាំងឡាយក្រៅនេះក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណាទីមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់បិតា ពួកជននោះតែងទៅនៅក្នុងនរកបែបនុ៎ះ ៗ កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្មរបស់ខ្លួន ក៏ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំង ៗ ពួកអមនុស្ស (និរយ-បាល) ព្រហើនក្រៃលែង យកសរសៃដែក (មករុំ) នូវបុគ្គលអ្នកសម្លាប់មាតា ហើយគាប (ដោយឃ្នាបដែក) រឿយ ៗ ៗ ពួកនិរយបាល ញុំាងបុគ្គលអ្នកសម្លាប់មាតានោះ ឲ្យផឹកនូវឈាមដ៏ក្តៅ ដែលហូរចេញអំពីកាយរបស់ខ្លួន ដូចជាទឹកទង់ដែងរលាយ ៗ

ជិគុច្ឆំ កុណបំ បូតឹ ទុគ្គន្ធំ គូថកទ្ទមំ

បុព្វលោហិតសង្កាសំ រហទោគ្គយ្ហ(១) តិដ្ឋតិ ។

តមេនំ កិមិយោ តត្ថ អតិកាយា អយោមុខា

ឆវឹ ភេត្វាន ខាទន្តិ បតិទ្ធា មំសលោហិតេ ។

សោ ច តំ និរយំ បត្តោ និមុគ្គោ សតបោរិសំ

បូតិកំ កុណបំ វាតិ សមន្តា សតយោជនំ ។

ចក្ខុមាបិ ហិ ចក្ខូនិ តេន គន្ធេន ជិយ្យតិ

ឯតាទិសំ ព្រហ្មទត្ត មាតុយោ លភតេ ទុខំ ។

ខុរធារមនុក្កម្ម តិក្ខំ ទុរភិសម្ភវំ

បតន្តិ គព្ភបាតិនិយោ ទុគ្គំ វេតរណឹ នទឹ ។

អយោមយា សិម្ពលិយោ សោឡសង្គុលិកណ្ដកា

ឧភតោ អភិលម្ពន្តិ ទុគ្គំ វេតរណឹ នទឹ ។

តេ អច្ចិមន្តោ តិដ្ឋន្តិ អគ្គិក្ខន្ធាវ អារកា

អាទិត្តា ជាតវេទេន ឧទ្ធំ យោជនមុគ្គតា ។

ឯតេ បជ្ជន្តិ និរយេ តត្តេ តិខិណកណ្ដកេ

នារិយោ ច អតិចារិនិយោ នរា ច បរទារគូ ។

បុគ្គលអ្នកសម្លាប់មាតានោះ ចុះទៅឋិតនៅ ក្នុងរណ្តៅគួរខ្ពើម ដូចជាអសុភមានក្លិនស្អុយ មានលាមក ជាភក់ មានក្លិនអាក្រក់ ប្រហែលគ្នា ដោយខ្ទុះនឹងឈាម ។ ក្នុងនរកនោះមានពួកដង្កូវ មានខ្លួនធំ មានមាត់ដូចម្ជុលដែក រុកត្បាល ចូលទៅក្នុងសាច់នឹងឈាមទំលាយស្បែកសម្បុរថ្ងៃ ហើយស៊ីសត្វនរកនោះ (ទាំងខួរក្នុងឆ្អឹង) ។ បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះជ្រមុជ(ក្បាល)ចុះទៅ ចំនួនមួយរយដួរបុរស សាកសពដ៏ស្អុយ ក៏ផ្សាយទៅកាន់ទីចម្ងាយមួយរយយោជន៍ជុំវិញ ។ ព្រោះថាសម្បីជនមានចក្ខុ ធុញទ្រាន់ដោយក្លិននោះ ព្រោះអាស្រ័យចក្ខុ បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្តីទុក្ខបែបនេះ ។ ពួកស្ត្រីរំលូតគភ៌ កន្លងនូវខុរធារនរកដ៏មុត ដែលគេគ្របសង្កត់បានដោយក្រ ធ្លាក់ទៅក្នុងស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ ។ ដើមរកាទាំងឡាយជាវិការៈនៃដែក មានបន្លាប្រវែង១៦ធ្នាប់សំយុងចុះមកត្រង់ត្រើយទាំងពីរខាងនៃស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ ។ ដើមរកាទាំងនោះ ត្រូវភ្លើងឆេះមានអណ្តាតខ្ពស់ឡើងទៅលើ ១ យោជន៍ដូចជាគំនរភ្លើង អំពីឆ្ងាយ ។ ពួកស្រីប្រព្រឹត្តក្បត់ចិត្តប្តី នឹងពួកប្រុសដែលគប់រកប្រពន្ធគេ ជនទាំងនុ៎ះ រមែងធ្លាក់ទៅក្នុងសិម្ពលីនរក ដែលក្តៅ មានបន្លាស្រួចៗ

## សដ្ឋិនិបាតេ ទុតិយំ សង្កិច្ចជាតកំ

តេ បតន្តិ អធោក្ខន្ធា  វិត្តា វិហតា បុថុ
សយន្តិ វិនិវទ្ធង្គា  ទីឃំ ជគ្គន្តិ សព្វទា (១) ។
តតោ រត្យា វិវសានេ  មហតឹ បព្វតូបមំ
លោហកុម្ភឹ បវជ្ជន្តិ  តត្តំ អគ្គិសមូទកំ ។
ឯវំ ទិវា ច រត្តោ ច  ទុស្សីលា មោហបារុតា
អនុភោន្តិ សកំ កម្មំ  បុព្វេ ទុក្កដមត្តនោ ។
យា ច ភរិយា ធនក្កីតា  សាមិកំ អតិមញ្ញតិ
សស្សុំ វា សស្សុរំ វាបិ  ជេដ្ឋំ វាបិ ននន្ទរំ
តស្សា វង្កេន ជិវ្ហគ្គំ  និព្ពហន្តិ សពន្ធនំ ។
ស ព្យាមមត្តំ កិមីនំ  ជិវ្ហំ បស្សតិ អត្តនោ (២)
វិញ្ញាបេតុំ ន សក្កោតិ  តាបនេ បេច្ច បច្ចតិ ។
ឱរព្ភិកា សូករិកា  មច្ឆិកា មិគពន្ធកា
ចោរា គោឃាតកា លុទ្ទា  អវណ្ណេ វណ្ណការកា ។
សត្តីហិ លោហកូដេហិ  នេត្តឹសេហិ ឧសូហិ ច

---

១ ឱ សិរី ។ ២ ឱ.ម. អត្តនិ ។

ពួកសត្វនរកទាំងនោះ មានក្បាលចុះក្រោម ត្រូវពួកនិរយបាលចាក់ (ដោយអាវុធ) ច្រើនដង ក៏វិលធ្លាក់មកវិញ មានខ្លួនធ្លុះធ្លាយ រមែងដេក រមែងភ្ញាក់ អស់កាលដ៏យូរអង្វែងសព្វ ៗ កាល ៗ (ពួកសត្វនរក ត្រូវពួកនិរយបាលចាប់បោះទៅ) ក្នុងនរកឈ្មោះលោហកុម្ភី មានឧបមាដោយភ្នំធំ មានទឹកស្ពាន់ភ្លើងដ៏ក្តៅ រមែងឆេះអស់កាលកន្លងទៅនៃរាត្រីដ៏យូរអង្វែង ៗ ពួកមនុស្សទ្រុស្តសីល (គប់រកប្រពន្ធគេ) ដែលមោហៈគ្របសង្កត់ហើយ រមែងរើកម្មរបស់ខ្លួន ដែលខ្លួនធ្វើអាក្រក់ក្នុងកាលមុន ទាំងថ្ងៃទាំងយប់យ៉ាងនេះ ៗ ប្រពន្ធណាដែលគេទិញមកដោយទ្រព្យ មើលងាយប្តី ម្តាយក្មេក ឪពុកក្មេក បងថ្លៃប្រុស បងថ្លៃស្រី ពួកនិរយបាល តែងទាញយកអណ្តាតព្រមទាំងគល់ របស់នាងនោះព្រមទាំងបំណងដោយសន្ទូច ៗ សត្វនរកនោះ ឃើញអណ្តាតរបស់ខ្លួនប្រមាណមួយព្យាមពេញដោយដង្កូវមិនអាចអង្វរ (ពួកនិរយបាល) បាន លុះស្លាប់ទៅរមែងឆេះនៅក្នុងតាបននរកទៀត ៗ ពួកអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ត្រី ទាក់ម្រឹគ ពួកចោរ ពួកអ្នកសម្លាប់គោ ពួកព្រាន ពួកអ្នកធ្វើគុណក្នុងទោស (អ្នកញុះញង់) ៗ ពួកសត្វនរកនោះ ត្រូវពួកនិរយបាលបៀតបៀន ដោយលំពែង ដោយញញួរលោហៈ ដោយសំសែ ដោយព្រួញទាំងឡាយ

ហញ្ញមានា ខារនទឹ បបតន្តិ អវំសិរា ។

សាយំ ឆាតោ កូដការី អយោកូដេហិ ហញ្ញតិ

តតោ វន្តំ ទុរត្តានំ បរេសំ ភុញ្ជតេ សទា ។

ធង្កា[1] ភេរណ្ឌកា គិជ្ឈា កាកោលា ច អយោមុខា

វិប្ផន្ទមានំ ខាទន្តិ នរំ កិព្ពិសការកំ ។

យេ មិគេន មិគំ ហន្តិ បក្ខឹ វា បន បក្ខិនា

អសន្តោ រជសា ឆន្នា គន្ត្វា តេ និរយុស្សទំ ។

(៩៣) សន្តោវ ឧទ្ធំ គច្ឆន្តិ សុចិណ្ណេនិធ កម្មុនា

សុចិណ្ណស្ស ផលំ បស្ស សិន្ទា ទេវា សព្រហ្មកា

តន្តំ ព្រូមិ មហារាជ ធម្មំ រដ្ឋបតី ចរ

តថា តថា រាជ ចរាហិ ធម្មំ

យថា តំ សុចិណ្ណំ នានុតប្បេយ្យ បច្ឆាតិ ។

សង្កិច្ចជាតកំ ទុតិយំ ។

---

១ ម. វង្កា ។

មានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងស្ទឹងខារ ។ អ្នកធ្វើអំពើវៀច គ្រប់ពួកនិរយបាល ដំដោយញញួរដែកទាំងឡាយទាំងល្ងាចទាំងព្រឹក ហើយ ស៊ីនូវកំអួតរបស់ពួកសត្វនរកដទៃ ដែលមានអត្តភាពអាក្រក់នោះសព្វៗកាល ។ ពួកក្អែក ចចក ត្មាត ក្អែកព្រៃ មានចំពុះដែក នាំគ្នាចឹកប្រដែង នូវជនអ្នកធ្វើអំពើអាក្រក់កំពុងញាប់ញ័រ ។ ពួកជនណាសម្លាប់ម្រឹគ(១) ដោយម្រឹគ សម្លាប់បក្សី(២) ដោយបក្សី ពួកជននោះជាអសប្បុរស បិទបាំងដោយធូលី គឺរាគាទិក្កិលេស រមែងទៅកាន់ឧស្សទនរក ។

(៩៣) ពួកសប្បុរសក្នុងលោកនេះ មានកម្មសន្សំល្អហើយ តែងទៅកាន់លោកខាងលើ សូមព្រះអង្គទតមើលផលនៃអំពើដែលគេបានសន្សំល្អ ដូចពួកទេវតាព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម បពិត្រមហារាជ អាត្មាភាពពោលហេតុនោះនឹងព្រះអង្គ បពិត្រព្រះអង្គជាម្ចាស់នៃដែន សូមព្រះអង្គប្រព្រឹត្តធម៌ បពិត្រព្រះរាជា អំពើដែលព្រះអង្គប្រព្រឹត្តល្អនោះ មិនគប្បីដុតកំដៅឡើយ ។ ក្នុងកាលជាខាងក្រោយ យ៉ាងណាៗ សូមព្រះអង្គប្រព្រឹត្តធម៌យ៉ាងនោះៗចុះ ។

ចប់ សង្កិច្ចជាតក ទី ២ ។

---

១–២– យកម្រឹគ ឬ បក្សីផងគ្នាធ្វើឆ្នាក់ ។

សដ្ឋិនិបាតេ ទុតិយំ សង្កិច្ចជាតកំ

## តស្សុទ្ទានំ

អថ សដ្ឋិនិបាតម្ហិ សុណាថ មម ភាសិតំ

ជាតកសវ្ហយនោ បវរោ

សោណកអរិន្ទមសវ្ហយនោ

តថាវុត្តរថេសភសង្កិច្ចវរោ ។

សដ្ឋិនិបាតំ និដ្ឋិតំ ។

---

# ឧទ្ទាននៃសត្តនិបាត

អ្នកទាំងឡាយ ប៉ូរស្តាប់គាថារបស់ខ្ញុំ ក្នុងសត្តនិបាត បន្ទាប់

អំពីបញ្ញាសនិបាតនោះគឺ

និយាយអំពីឈ្មោះជាតកដ៏ប្រសើរ ដែលហៅថាសោណកតាបស

នឹងព្រះរាជាទ្រង់ព្រះនាមអរិន្ទមៈ ១ ព្រះរាជាដ៏ប្រសើរ ក្នុងរថ

ដែលយើងពោលហើយដូច្នោះ នឹងសង្កិច្ចតាបស ១ ។

ចប់ សត្តនិបាត ។

# សត្តតិនិបាតជាតកំ

## កុសជាតកំ

(៩៤) ឥទន្តេ រដ្ឋំ សធនំ សយោគ្គំ
សកាយុរំ សព្វកាមូបបន្នំ
ឥទន្តេ រដ្ឋំ អនុសាស អម្ម
គច្ឆាមហំ យត្ថ បិយា បភាវតី ។

(៩៥) អនុជ្ជុភូតេន ហរំ មហន្តំ
ទិវា ច រត្តោ ច និសីថកាលេ
បដិគច្ឆ ត្វំ ខិប្បំ កុសាវតឹ
និច្ឆាមិ ទុព្វណ្ណមហំ វសន្តំ ។

(៩៦) នាហំ គមិស្សាមិ ឥតោ កុសាវតឹ
បភាវតី វណ្ណបលោភិតោ តវ
រមាមិ មទ្ទស្ស និកេតរម្មេ
ហិត្វាន រដ្ឋំ តវ ទស្សនេ រតោ ។
បភាវតី វណ្ណបលោភិតោ តវ
សម្មត្តរូបោ វិចរាមិ មេទនឹ
ទិសំ ន ជានាមិ កុតោម្ហិ អាគតោ
តយម្ហិ មត្តោ មិគមន្ទលោចនេ

# សត្តតិនិបាតជាតក

## កុសជាតក

[៩៤] ( ព្រះបាទកុសរាជពោធិសត្វ ត្រាស់ថា ) បពិត្រព្រះមាតា ដែនរបស់ព្រះមាតានេះ ប្រកបដោយទ្រព្យ ប្រកបដោយយាន ប្រកបដោយគ្រឿងសំរាប់រាជ្យ បរិបូណ៌ដោយកាម គ្រប់យ៉ាង សូមព្រះមាតាត្រួតត្រាដែន របស់ព្រះមាតានេះចុះ ខ្ញុំនឹងទៅកាន់នគរ ជាទីនៅរបស់នាងបភាវតី ជាទីស្រឡាញ់ ។

[៩៥] ( នាងបភាវតី ពោលថា ) ព្រះអង្គមានព្រះទ័យមិនត្រង់ នាំយកអម្រែកធំ (វង់ទុក្ខ) ទាំងថ្ងៃទាំងយប់ទាំងពេលអធ្រាត្រ សូមព្រះអង្គត្រឡប់ទៅក្រុងកុសាវតីវិញឲ្យឆាប់ ខ្ញុំម្ចាស់មិនចង់បានព្រះអង្គ ដែលមានរាងពៅអាក្រក់ មកនៅ ( ក្នុងទីនេះ ) ទេ ។

[៩៦] ( ព្រះពោធិសត្វ... ) ហៃនាងបភាវតី អញនឹងមិនទៅអំពីទីនេះ កាន់ក្រុងកុសាវតីទេ ព្រោះអញជាប់ចិត្តនឹងវណ្ណៈរបស់នាង ទើបត្រេកអរក្នុងដំណាក់ជាទីត្រេកអររបស់ព្រះបាទមទ្ទៈ ស៊ូលះបង់ដែន មកត្រេកអរ ក្នុងការឃើញនាង ។ ហៃនាងបភាវតី អញជាប់ចិត្តនឹងវណ្ណៈរបស់នាង មានសភាពវង្វេង ត្រាច់រង្គាត់ទៅកាន់ផែនដី មិនស្គាល់ទិសថា អញមកអំពីទីណា ហៃនាងមានភ្នែកថ្លា ដូចភ្នែកម្រឹគ អញជាមនុស្សវក់ចិត្តក្នុងនាង ។

សោវណ្ណចីរវសនេ ជាតរូបសុមេខលេ
សុស្សោណិ តវ កាមា ហិ នាហំ រជ្ជេន អត្ថិកោ ។

[៩៧] អព្ភុតិ តស្ស ភោ ហោតិ យោ អនិច្ឆន្តមិច្ឆតិ
អកាមំ រាជ កាមេហិ អកន្តោ កន្តមិច្ឆសិ[១] ។

[៩៨] អកាមំ វា សកាមំ វា យោ នរោ លភតេ បិយំ
លាភមេត្ថ បសំសាម អលាភោ តត្ថ បាបកោ ។

[៩៩] បាសាណសារំ ខណសិ កណិការស្ស ទារុនា
វាតំ ជាលេន ពាធេសិ យោ អនិច្ឆន្តមិច្ឆសិ ។

[១០០] បាសាណោ នូន តេ ហទយេ ឱហិតោ មុទុលក្ខណេ
យោ តេ សាតំ ន វិន្ទាមិ តិរោជនបទាគតោ ។

---

១ ម. អកន្តំ កន្តុមិច្ឆសិ ។

ហៃនាងមានគ្រឿងសម្លៀករំលេចដោយមាស មានខ្សែក្រវាត់ល្អ
ជាវិការៈនៃមាស មានបង្កើះល្អ អញមិនត្រូវការដោយរាជសម្បត្តិ
ព្រោះតែសេចក្ដីប្រាថ្នាបំពោះនូវនាង ។

(៩៧) ( នាងបភាវតី... ) បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីមិនចំរើន
តែងមានដល់បុគ្គលដែលប្រាថ្នា បុគ្គលកាលមិនប្រាថ្នា ( ខ្លួន )
បពិត្រព្រះរាជា ព្រះអង្គមិនជាទីស្រឡាញ់ ចង់បានស្ត្រីជាទី
ស្រឡាញ់ ដែលមិនមានសេចក្ដីប្រាថ្នា ដោយកាមទាំងឡាយ ។

(៩៨) (ព្រះពោធិសត្វ...) ជនណាបាននាងជាទីស្រឡាញ់ ទោះ
មិនមានសេចក្ដីប្រាថ្នាក្ដី មានសេចក្ដីប្រាថ្នាក្ដី យើងសរសើរ
នូវការបានរបស់ជននុ៎ះ បណ្ដាការបានទាំងមិនបាននោះ ឯការ
មិនបាន ពាក់ថាជារបស់លាមក ។

(៩៩) ( នាងបភាវតី... ) ព្រះអង្គចង់បានស្ត្រីដែលគេមិនចង់បាន
ព្រះអង្គ ដូចជាគេជីកខ្ទឹមឬដោយដើមកណិការ ឬដូចជាគេទាក់
ខ្យល់ដោយសំណាញ់ ។

(១០០) ( ព្រះពោធិសត្វ... ) ហៃនាងមានលក្ខណៈទន់ភ្លន់ អញមក
អំពីជនបទខាងក្រៅ មិនបានសេចក្ដីស្រួល ( ក្នុងសំណាក់ )របស់
នាង ឈ្មោះថានាងយកថ្មសង្កត់លើហឫទ័យ(នៃអញ)ដោយពិត ។

យថា មំ ភកុដិំ កត្វា រាជបុត្តី ឧទិក្ខតិ
អាឡារិកកតោ ហោមិ រញ្ញោ មទ្ទស្សន្តេបុរេ ។
យថា ឧម្ហយមានា មំ រាជបុត្តី ឧទិក្ខតិ
អនាឡារិកកតោ ហោមិ រាជា ហោមិ តទា កុសោ ។

(១០១) សចេ ហិ វចនំ សច្ចំ នេមិត្តានំ ភវិស្សតិ
នេវ មេ ត្វំ បតី អស្ស កាមំ ឆិន្ទន្តុ សត្តធា ។

(១០២) សចេ ហិ វចនំ សច្ចំ អញ្ញេសំ យទិ វា មមំ
នេវ តុយ្ហំ បតី អត្ថិ អញ្ញោ សីហស្សរា កុសា ។

(១០៣) នេក្ខំ គីវំ តេ ការេស្សំ បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ នាគនាសូរូ ឱលោកេយ្យ បភាវតី ។
នេក្ខំ គីវំ តេ ការេស្សំ បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ នាគនាសូរូ អាលបេយ្យ បភាវតី ។
នេក្ខំ គីវំ តេ ការេស្សំ បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ នាគនាសូរូ ឧម្ហាយេយ្យ បភាវតី ។

ព្រះរាជបុត្រីធ្វើមុខក្រញូវ ហើយសំឡឹងមើលមកអញ ក្នុងវេលាណា អញក៏ទៅជានាយពិសេសក្នុងរាំង របស់ព្រះបាទមទ្ទៈក្នុងវេលានោះ ។ ព្រះរាជបុត្រី ញញឹមញញែម ក្រឡេកមើលអញក្នុងវេលាណា អញមិនទៅជានាយពិសេស ក្នុងវេលានោះទេ អញនឹងជាព្រះបាទកុសៈក្នុងវេលានោះវិញ ។

[១០១] (នាងបភាវតី...) ប្រសិនបើពាក្យរបស់ហោរពិតមែន ព្រះអគ្គមិនត្រូវបានជាកស្ត្រារបស់ខ្ញុំម្ចាស់ទេ សូមឲ្យគេកាត់ (ខ្ញុំម្ចាស់) ជាប្រាំពីរកំណាត់ចុះ ។

[១០២] (ព្រះពោធិសត្វ...) ប្រសិនបើពាក្យ របស់ហោរដទៃ ឬរបស់អញពិតមែន កស្ត្រារបស់នាងក្រៅអំពីព្រះបាទកុសៈ ដែលមានព្រះសូរស័ព្ទស្មើនឹងសំឡេងសីហៈ ក៏មិនមានទេ ។

[១០៣] នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីក្រឡេកមើលអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ដោរដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីហៅរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ដោរដល់នាង ។

## សត្តតិនិបាតេ បឋមំ កុសជាតកំ

នេក្ខំ គីវំ តេ ការេស្សំ  បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ នាគនាសូរូ  បម្ហាយេយ្យ បភាវតី ។
នេក្ខំ គីវំ តេ ការេស្សំ  បត្វា ខុជ្ជេ កុសាវតឹ
សចេ មំ នាគនាសូរូ  បាណីភិ ឧបសំផុសេ ។

(១០៤) នហិ នូនាយំ រាជបុត្តី  កុសេ សាតំបិ វិន្ទតិ
អាឡារិកេ ភតេ ពោសេ  វេត្តនេន អនត្ថិកេ ។

(១០៥) នហិ នូន អយំ ខុជ្ជា  លភតិ ជិវ្ហាយ ឆេទនំ
សុនិសិតេន សត្ថេន  ឯវំ ទុព្ភាសិតំ ភណំ ។

(១០៦) មា នំ រូបេន បាមេសិ  អារោហេន បភាវតី
មហាយសោតិ កត្វាន  ករស្សុ រុចិរេ បិយំ ។

នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីញ-ញឹមញាញែមរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្រោរដល់នាង ៗ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីសើចក្អាកក្អាយរកអញ លុះអញទៅដល់ក្រុងកុសាវតីនឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្រោរដល់នាង ៗ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីមកប៉ះពាល់អញដោយដៃទាំងឡាយ លុះអញទៅដល់ក្រុងកុសាវតីនឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្រោរដល់នាង ៗ

(១០៤) (ស្ដ្រីគម...) ព្រះរាជបុត្រីនេះ មិនបាននូវសេចក្ដីស្រួលចិត្តទៅរកព្រះបាទកុសៈ ជាបុរសនាយពិសេសអ្នកស៊ីឈ្នួល មិនត្រូវការដោយថ្លៃឈ្នួលទេ ៗ

(១០៥) (នាងបភាវតី...) ស្ដ្រីគមនេះមិនហ៊ានកាត់អណ្ដាតដោយកាំបិតដ៏មុតដោយពិត តែហ៊ាននិយាយពាក្យជាទុព្ភាសិតយ៉ាងនេះ ៗ

(១០៦) (ស្ដ្រីគម...) បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ (នឹងទំហំរបស់ខ្លួននាង)ឡើយ បពិត្រព្រះនាងស្រស់បំប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានយសធំហើយធ្វើនូវសេចក្ដីស្រឡាញ់ (ចំពោះព្រះបាទកុសៈនោះ) ចុះ ៗ

មា នំ រូបេន ជានេសិ អារោហេន បភាវតី

មហទ្ធនោតិ កត្វាន ការស្សុ រុចិរេ បិយំ ។

មា នំ រូបេន ជានេសិ អារោហេន បភាវតី

មហព្ពលោតិ កត្វាន ការស្សុ រុចិរេ បិយំ ។

មា នំ រូបេន ជានេសិ អារោហេន បភាវតី

មហារដ្ឋោតិ កត្វាន ការស្សុ រុចិរេ បិយំ ។

មា នំ រូបេន ជានេសិ អារោហេន បភាវតី

មហារាជោតិ កត្វាន ការស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈ
នោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉-
ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ )
មានទ្រព្យច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។
បពិត្រព្រះនាងបភាវតី ព្រះនាង កុំប្រៀបផ្ទឹមនូវព្រះបាទកុសៈ
នោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់
ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថាព្រះបាទកុសៈនោះ )
មានកម្លាំងច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។
បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ
ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះ
នាងសូមធ្វើទុក ( ក្នុងហឫទ័យថាព្រះបាទកុសៈនោះ ) មានដែនធំ
ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។
បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ
ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះ
នាងសូមធ្វើទុក ( ក្នុងហឫទ័យថាព្រះបាទកុសៈនោះ ) ជាព្រះរាជា
ធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

## សត្តតិនិបាតេ បឋមំ កុសជាតកំ

មា នំ រូបេន បាមេសិ អារោហេន បភាវតី

សីហស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

វគ្គុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

ពិន្ទុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

មញ្ជុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រែ ព្រះនាង សូមធ្វើទុក(ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសំឡេងស្មើនឹងសំឡេងនៃសីហៈ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសំឡេងដ៏ពីរោះ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសំឡេងមូល ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងល្អ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

មហុស្សាហោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

សតសិប្បោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

ខត្តិយោតិបិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

កុសរាជាតិ កត្វាន ករស្សុ រុចិរេ បិយំ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ)មានសំឡេងដ៏ផ្អែមល្ហែម ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសិល្បៈច្រើនហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈៈនោះ) ជាក្សត្រិយ៍ (សុទ្ធ) ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំប្រៃ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) ជាព្រះរាជាមាននាមស្មើនឹងស្បូវក្រាំង (ដែលព្រះឥន្ទ្រប្រទាន) ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

(១០៧) ឃរេ ទាសា ឧបត្ថទ្ធា សព្វេ តដ្ឋិង្តិ វម្មិកា
បុក មត្តិ ទាការំ អានេថេតំ បការតី ។

(១០៨) សត្តិលេ ការត្វាន(១) អហមេតំ បការតី
ខត្តិយានំ បនស្សាមិ យេមំ ហន្តុំ វិជានតា ។

(១០៩) អបុជ្ជហិ រាជបុត្តី សាមា កោសេយ្យវាសិនី
អស្សុបុណ្ណេហិ នេត្តេហិ ទាសីគណបុរក្ខតា ។

(១១០) តំ ត្វំ ការញ្ញបនិសេវិតំ មុខំ
អាទាសទណ្ឌដុបច្ចវេក្ខិតំ
សុភំ សុនេត្តំ វិរជំ អនង្គណំ
ឆុទ្ធំ វនេ បស្សតិ ខត្តិយេហិ ។
តេ ត្វំ មេ អសិនេ វេល្លិតគ្គេ
កេសេ មុទ្ធ ចន្ទនសារលិត្តេ
សមាកុលេ សីវថិកាយ មជ្ឈេ
កោនេហិ គិជ្ឈា បរិកឌ្ឍយន្តិ ។

---

១ សត្ត ខណ្ឌតិ អន្ទុកហាយ ទិស្សតិ ។

[១០៧] (អាមាត្យទាំងឡាយ...) ព្រះរាជាដ៏ប្រសើរ ទាំងអស់នុ៎ះ ជាព្រះរាជា គឺយើងមកហើយ ប្រដាប់ដោយគ្រឿងក្រោះ (សូមព្រះអង្គផ្ញើព្រះរាជសារទៅថា) អ្នកទាំងឡាយ ចូរនាំព្រះនាងបភាវតីនុ៎ះមក (បញ្ជូនទៅថ្វាយព្រះរាជាទាំងនោះ) កុំឲ្យទំលាយកំពែងមុនទាន់ ។

[១០៨] (ព្រះរាជា...) អញនឹងធ្វើនាងបភាវតីនុ៎ះ ឲ្យជា ៧ កំណាត់ ហើយឲ្យដល់ពួកក្សត្រិយ៍ដែលមកក្នុងទីនេះ ដើម្បីសម្លាប់អញ ។

[១០៩] (អភិសម្ពុទ្ធគាថា) ព្រះរាជបុត្រីមានសម្បុរលឿង ទ្រង់ព្រះពស្ត្រជាវិការៈនៃសូត្រ(រំលេចដោយមាស) ដែលពួកទាសីហែហមមាននេត្រាដ៏ពេញដោយព្រះអស្សុជល បានក្រោក(ចាកអាសនៈ) ។

[១១០] (នាងបភាវតី...) បពិត្រព្រះមាតា មុខ (របស់ខ្ញុំ) នោះ ធ្លាប់លាបស្រឡាបគ្រឿងលំអិត ដុះកញ្ចក់មានក្រប ជាវិការៈនៃភ្លុក ជាមុខល្អ មានភ្នែកល្អ រលីងរលោង ត្រូវពួកក្សត្រិយ៍លះបោលហើយ នឹងតាំងនៅក្នុងព្រៃ ។ ពួកក្អែកនឹងលើកជើងទាំងឡាយកកាយនូវសក់ទាំងនោះ របស់ខ្ញុំ ជាសក់ខ្មៅមានចុងង ទន់លាបដោយខ្លឹមចន្ទន៍ ឲ្យប្រឡូកប្រឡល់ ក្នុងកណ្ដាលព្រៃស្មសាន

តា នូន មេ តម្ពនខា សុលោមា
ពាហា មុទូ ចន្ទនសារលិត្តា
ឆិន្នា វនេ ឧជ្ឈិតា ខត្តិយេហិ
គយ្ហ ធង្កោ(១) គច្ឆតិ យេន កាមំ ។
តេ នូន តាលូបនិភេ អលម្ពេ
និសេវិតេ កាសិកចន្ទនេន
ថនេសុ មេ លម្ពិស្សន្តិ សិគាលោ
មាតូវ បុត្តេ តរុណេ តនុជេ ។
តំ នូន សោណឹ បុថុលំ សុកោដ្ដិតំ
និសេវិតំ កញ្ចនមេខលាហិ
ឆិន្នំ វនេ ខត្តិយេហិ អវត្ថំ
សិគាលសង្ឃា បរិកឌ្ឍយន្តិ ។
សោណា ធង្កា សិគាលា ច យេ ចញ្ញេ សន្តិ ទាឋិនោ
អជរា នូន ហេស្សន្តិ ភក្ខយិត្វា បការតឹ ។
សចេ មំសានិ ហរឹសុ ខត្តិយា ធូរតាមិនោ
អដ្ឋីនិ អម្ម យាចិត្វា អនុបថេ ទហាថ នំ ។
ខេត្តានិ អម្ម ការេត្វា កណិការេត្ថ រោបយេ

១ ឱ. វកោ ។

ក្អែកបឹកដៃ របស់ខ្ញុំនោះ ដែលមានក្រចកក្រហម មានរោមល្អ ទន់ លាបដោយខ្លឹមចន្ទន៍ ជាប់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រិយ៍បោលក្នុងព្រៃ ហើយហើរទៅតាមប្រាថ្នា ៗ បបក(ញីស្ងួនរបស់ខ្ញុំ)នោះ ស្រដៀងគ្នានឹងផ្លែត្នោត មិនយារ លាបដោយខ្លឹមចន្ទន៍ ដំល្អិត ហើយបៀម នូវស្ដន របស់ខ្ញុំនោះ ដូចជាកូនខ្ចីបង្កើត ដែលបៀមនូវស្ដន របស់មាតា ៗ ហ្វូងបបក ជញ្ជូនត្រគាក ( របស់ខ្ញុំ ) នោះ ជាអវយវៈទូលាយ ដែលគេដំល្អហើយ ពាក់ដោយ ខ្សែក្រវាត់មាសទាំងឡាយ ជាប់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រិយ៍បោលក្នុងព្រៃ ៗ ពួកផ្កែ ក្អែក បបក នឹងសត្វឯទៀត ដែលមានបក្ខម ស៊ីនានាបការតី មុខជានឹងមិនចាស់គ្រាំគ្រាដោយពិត ៗ ប្រសិនបើពួកក្សត្រិយ៍ដែលទៅឆ្ងាយ នាំយកសាច់ទាំងឡាយ (របស់ខ្ញុំ)ទៅ បពិត្រព្រះមាតាបូរ ព្រះអង្គសូមយកឆ្អឹងទាំងឡាយ ហើយដុតឆ្អឹងនោះក្នុងទីបន្ទាប់ផ្លូវ ( ក្នុងចន្លោះនៃផ្លូវដើរនឹងផ្លូវធំ ) ៗ បពិត្រព្រះមាតា សូមព្រះ-មាតាប្រើគេធ្វើសួនច្បារ ហើយដាំដើមកណិការក្នុងសួនច្បារនុ៎ះ

## សត្តតិនិបាតេ បឋមំ កុសជាតកំ

យថា ទេ បុដ្ឋិតា អស្សុ ហោមត្តានំ ហិមត្ថយេ
សរេយ្យាថ មមំ អម្ម ឯវំវណ្ណា បភាវតី ។

(១១១) តស្សា មាតា ឧបដ្ឋាសិ ខត្តិយា ទេវវណ្ណិនី
ទិស្វា អសិញ្ចុ សុវញ្ចុ រញ្ញោ មនុស្សេន្តបុរេ ។

(១១២) វិមោ ទូន អសិតា សុសញ្ញំ តនុមជ្ឈិមំ
ជីតរំ មនុ ហាទ្ធន ខត្តិយានំ បនស្សសិ(១)

(១១៣) ន មេ អកាសិ វចនំ អត្ថកាមាយ បុត្តិកេ
ស្វាជ្ជ លោហិតសញ្ឆន្នា គច្ឆសិ យមសាទនំ ។
ឯវមាបជ្ជតី បោសោ បាបិយញ្ច និគច្ឆតិ
យោ វេ ហិតានំ វចនំ ន ករោតិ អត្ថទស្សិនំ
សចេ វ អជ្ជ ធារេសិ កុមារំ ចារុទស្សនំ
កុសេន ជាតំ ខត្តិយំ សុវណ្ណមណិមេខលំ ។
បូជិតំ ញាតិសង្ឃេហិ ន គច្ឆសិ យមក្ខយំ

---

១ ឱ.ម. បទស្សតិ ។

ក្នុងវេលាណាដែលដើមកណិការទាំងនោះមានផ្កា ក្នុងអំណើះទៅ
នៃកាលជាទីធ្លាក់នៃទឹកសន្សើមក្នុងហេមន្តរដូវ បពិត្រព្រះមាតា
សូមព្រះមាតា ព្រកខ្ញុំថា នាងបភាវតី មានវណ្ណៈ យ៉ាងនេះ ។

(១១១) (អភិសម្ពុទ្ធគាថា) ក្សត្រិយ៍មានវណ្ណៈដូចវណ្ណៈទេវតាជា មាតា
របស់នាងបភាវតីនោះ ក្រោកចាកអាសនៈទៅកាន់សំណាក់ព្រះ
រាជាហើយ បានឃើញដាវនឹងជ្រញ់ក្នុងព្រះរាជវាំងព្រះបាទមទ្ទៈ ។

(១១២) (ព្រះមាតា...) បពិត្រព្រះបាទមទ្ទៈ ព្រះអង្គនឹងសម្លាប់
ធីតាដែលគេចំណាំបានដោយងាយ មានចង្កេះរៀវ ដោយប៉ូវថៅ
នេះ ហើយប្រទាន ដល់ពួកក្សត្រិយ៍ដោយពិត ។

(១១៣) ហៃបុត្រី នាងមិនបានធ្វើតាមពាក្យរបស់អញដែលប្រាថ្នាប្រ-
យោជន៍ នាងមុខជានឹងពេញពាសដោយឈាម ហើយទៅកាន់
ភពរបស់មច្ចុរាជ ក្នុងថ្ងៃនេះ ៗ បើសត្វដែលមិនធ្វើតាមពាក្យរបស់
ពួកជនដែលបង្ហាញសេចក្តីចំរើន បង្ហាញប្រយោជន៍ហើយ តែងប៉ះ
ទង្គិចយ៉ាងនេះផង តែងចួបប្រទះនូវសេចក្តីអាក្រក់ជាង(នេះ)ផង ៗ
បើក្នុងថ្ងៃនេះនាងនឹងបានទ្រទ្រង់កុមារស្រស់ប៉ប្រៃ ជាក្សត្រិយ៍ដែល
កើតព្រោះព្រះបាទកុសៈមានខ្សែក្រវាត់ជាវិការៈនៃមាសនឹងកែវម-
ណីដែលពួកញាតិបូជាហើយ នាងនឹងមិនទៅកាន់លំនៅយមរាជទេ

យត្ថស្សុ ភេរី នទតិ កុញ្ជរោ ច និកូជតិ
ខត្តិយានំ កុលេ ភទ្ទេ កឹ នុ សុខតរំ តតោ ។
អស្សោ ហសីយតិ(១) ទ្វារេ កុមារោ ឧបរោទតិ
ខត្តិយានំ កុលេ ភទ្ទេ កឹ នុ សុខតរំ តតោ ។
មយូរកោញ្ចាភិរុទេ កោកិលាភិនិកូជិតេ
ខត្តិយានំ កុលេ ភទ្ទេ កឹ នុ សុខតរំ តតោ ។

(១១៤) កហំ នុ សោ សត្តុមទ្ទនោ បររដ្ឋប្បមទ្ទនោ
កុសោ សោឡារបញ្ញាណោ យោ នោ ទុក្ខា បមោចយេ ។

(១១៥) ឥធេវ សោ សត្តុមទ្ទនោ បររដ្ឋប្បមទ្ទនោ
កុសោ សោឡារបញ្ញាណោ យោ តេ សព្វេ វធិស្សតិ ។

(១១៦) ឧម្មត្តិកា នុ ភណសិ អន្ធពាលា បភាសសិ
កុសោ ចេ អាគតោ អស្ស កឹ នុ ជានេមុ តំ មយំ ។

---

១ ម. អស្សោ ច សីសតិ ។

នៃនាងជំបំរើន ស្គរលាន់ឮក្តី ជរីស្រែកក្តី ក្នុងខត្តិយត្រកូល
ណា ( នាងឃើញ ) អ្វីដែលជាសុខក្រៃលែងជាងខត្តិយត្រកូល
នោះ ( បានជានាងមកក្នុងទីនេះ ) ។ សេះក្តាប្រដាប់ប្របទ្វារ
កុមារអ្នកបំប្រើ ក្នុងខត្តិយត្រកូលណា នៃនាងជំបំរើន ( នាង
ឃើញ ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ ។
កាលបើក្ងោកនិងក្រៀលយំនឹងតាមើយពុទ្រហឹងអឹងកងក្នុងខត្តិយ-
ត្រកូលណា នៃនាងជំបំរើន ( នាងឃើញ ) អ្វី ដែលជាសុខ
ក្រៃលែងជាងខត្តិយត្រកូលនោះ ។

[១១៤] ព្រះបាទកុសៈជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះ
រាជាដទៃមានប្រាជ្ញាឆើត គប្បីដោះយើងឲ្យរួចចាកទុក្ខបាន តើ
នៅក្នុងទីណា ។

[១១៥] ( នាងបភាវតី... ) ព្រះបាទកុសៈជាអ្នកញាំញីខ្មាំងសត្រូវ
ញាំញីដែនរបស់ព្រះរាជាដទៃ មានប្រាជ្ញាឆើត សម្លាប់ក្សត្រិយ៍
ទាំងអស់នោះ នៅក្នុងទីនេះឯង ។

[១១៦] ( ព្រះមាតា... ) នាងជាស្រីឆ្កួត ជាស្រីអន្ធពាល ចេះតែ
និយាយ ( ឲ្យរួចតែពីមាត់ ) បើព្រះបាទកុសៈគប្បីមក ពួក
យើងធ្វើដូចម្តេចនឹងស្គាល់ព្រះបាទកុសៈនោះបាន ។

(១១៧) ឯសោ អាឡារិកោ បោសោ  កុមារីបុរមន្តរេ

ទឡ្ហំ កត្វាន សំវេល្លិំ  កុម្ភឹ ធោវតិ ឱណតោ ។

(១១៨) វេណី ត្វមសិ ចណ្ឌាលី  អទូសិ កុលគន្ធិនី

កថំ មទ្ទកុលេ ជាតា  ទាសំ កយិរាសិ កាមុកំ ។

(១១៩) នម្ហិ វេណី ន ចណ្ឌាលី  ន ចម្ហិ កុលគន្ធិនី

ឱក្កាកបុត្តោ ភទ្ទន្តេ  ត្វំ នុ ទាសោតិ មញ្ញសិ ។

(១២០) យោ ព្រាហ្មណសហស្សានិ  សទា ភោជេតិ វីសតិ

ឱក្កាកបុត្តោ ភទ្ទន្តេ  ត្វំ នុ ទាសោតិ មញ្ញសិ ។

យស្ស នាគសហស្សានិ  សទា យោជេន្តិ វីសតិ

ឱក្កាកបុត្តោ ភទ្ទន្តេ  ត្វំ នុ ទាសោតិ មញ្ញសិ ។

(១១៧) ( នាងបភាវតី... ) (ព្រះបាទកុសៈ) គឺបុរសនាយពិសេស នុះ បង់ក្បិនយ៉ាងមាំ ខ្ទនលាងឆ្នាំង ( សូមព្រះមាតាទត ) ត្រង់បន្ទោះដំណាក់កុមារី ។

(១១៨) ( ព្រះមាតា... ) នាងជាស្រីនៃត្រកូលជាងចាំង ជាស្រីចណ្ឌាល ឬជាស្រីទ្រុស្តត្រកូលទេឬ នាងកើតក្នុងត្រកូលព្រះបាទមទ្ទៈ គួរធ្វើស្វាមី (របស់ខ្លួន) ឲ្យជាទាសៈ ដូចម្តេចកើត ។

(១១៩) ( នាងបភាវតី... ) ខ្ញុំមិនមែនជាស្រីត្រកូលជាងចាំង មិនមែនស្រីចណ្ឌាល មិនមែនជាស្រីទ្រុស្តត្រកូលទេ បពិត្រព្រះមាតា (ព្រះបាទកុសៈនោះ) ជាបុត្ររបស់ព្រះបាទឧក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។

(១២០) ព្រះបាទកុសៈណា ញ៉ាំងពួកព្រាហ្មណ៍ទាំងម្ភៃពាន់ ឲ្យបរិភោគសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្ររបស់ព្រះបាទឧក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមដំរីទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឧក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។ ពួកជន តែងទឹមសេះ ទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល

យស្ស អស្សសហស្សានិ សតា យោជេន្តិ វីសតិ
ឥក្ខាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។
យស្ស រថសហស្សានិ សតា យោជេន្តិ វីសតិ
ឥក្ខាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។
យស្ស ធេនុសហស្សានិ សតា ទុហន្តិ វីសតិ
ឥក្ខាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។

(១២១) តស្ស តេ ទុក្កដំ ពាលេ យំ ខត្តិយំ មហព្វលំ
ញាតំ មណ្ឌូកវណ្ណេន ន នំ អក្ខាសិ មាតតំ ។

(១២២) អបរាធំ មហារាជ ត្វំ នោ ខម រថេសភ
យំ ត្វំ អញ្ញាតវេសេន នាញ្ញាសិម្ហា ឥធាគតំ ។

(១១៣) មាទិសស្ស ន តំ ឆន្នំ យោហំ អាទុរិកោ ភវេ
ត្វញ្ញេវ មេ បសីទស្សុ នត្ថិ តេ ទេវ ទុក្កដំ ។

បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឧក្កាកៈ (បំរើណកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។ ពួកជន តែងទឹមរថទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្ររបស់ព្រះបាទឧក្កាកៈ (បំរើណកខាង) ព្រះមាតាទេតើសំគាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងតែទឹកដោះមេគោទាំងម្ភៃពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្ររបស់ព្រះបាទឧក្កាកៈ (បំរើណកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។

[១៦១] (ព្រះរាជា...) ម្នាលស្រីពាល ហេតុឯងធ្វើខ្ញុំខ្ញាដល់ក្សត្រិយ៍ដែលមានកម្លាំងច្រើន ដូចជាដំរី ដោយភេទនៃកន្ទើប នាងមិនបានប្រាប់ក្សត្រិយ៍នោះដែលយាងមកហើយ ។

[១៦២] បពិត្រមហារាជ ជាបុគ្គលប្រសើរលើរថ សូមព្រះអង្គទ្រង់អត់កំហុសដល់យើង ព្រោះយើងមិនបានដឹងថា ទ្រង់យាងមកក្នុងទីនេះ ដោយភេទក្រសោះ ។

[១៦៣] (ព្រះមហាសត្វ...) បពិត្រព្រះសម្មតិទេព ដំណើរដែលទូលព្រះបង្គំជាខ្ញុំធ្វើជានាយពិសេសនោះ មិនកំបាំងដល់ជនដូចទូលព្រះបង្គំជាខ្ញុំទេ សូមព្រះអង្គជ្រះថ្លានឹងទូលបង្គំជាខ្ញុំចុះ អំពើខ្ញុំខ្ញា របស់ព្រះអង្គមិនមានទេ ។

### សត្តតិនិបាតេ បឋមំ កុសជាតកំ

(១២៤) គច្ឆ បាទេ ខមាបេហិ កុសរាជំ មហព្ពលំ
ខមាបិតោ កុសរាជា សោ តេ ទស្សតិ ជីវិតំ ។

(១២៥) បិតុស្ស វចនំ សុត្វា ទេវវណ្ណី បភាវតី
សិរសា អគ្គហី បាទេ កុសរាជំ មហព្ពលំ ។

(១២៦) យាវ រត្យោ[1] អតិក្កន្តា តា មា ទេវ តយា វិនា
វន្ទេ តេ សិរសា បាទេ មា មេ កុជ្ឈ រថេសភ ។

សច្ចន្តេ[2] បដិជានាមិ មហារាជ សុណោហិ មេ
ន ចាបិ អប្បិយំ តុយ្ហំ ករេយ្យាមិ អហំ បុន ។

ឯវញ្ចេ យាចមានាយ វចនំ មេ ន កាហសិ
ឥទានិ មំ តាតោ ហន្ត្វា ខត្តិយានំ បទស្សតិ ។

---

១ ម. យាមា ។ ២ ម. សព្វន្តេ ។

[១២៤] (ព្រះរាជា...) ម្នាលស្រីពាល នាងឯង ចូរទៅសូមខមា-
ទោសនឹងព្រះបាទកុសៈ ដែលមានកម្លាំងច្រើន ព្រះបាទកុសៈ
នោះ កាលបើនាងសូមខមាទោសហើយនឹងប្រទានជីវិតដល់នាងៗ

[១២៥] (អភិសម្ពុទ្ធគាថា) នាងបភាវតី មានវណ្ណៈដូចជាវណ្ណៈនៃ
ទេវតា ឮព្រះឱង្ការ របស់ព្រះបិតា (ក៏ក្រាប) ដោយសីសៈ
អាចចាប់ព្រះបាទកុសៈដ៏មានកម្លាំងច្រើន ត្រង់ព្រះបាទាបាន ៗ

[១២៦] (នាងបភាវតី...) បពិត្រព្រះសម្មតិទេព រាត្រីទាំងនោះ
វៀរចាកព្រះអង្គកន្លងទៅ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ
ខ្ញុំម្ចាស់សូម (ក្រាប) ដោយក្បាល ថ្វាយបង្គំព្រះបាទទាំងគូ
របស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងខ្ញុំម្ចាស់ ៗ បពិត្រមហា-
រាជ ខ្ញុំម្ចាស់សូមប្តេជ្ញាពាក្យពិតចំពោះព្រះអង្គ សូមព្រះអង្គទ្រង់
ព្រះសណ្តាប់ពាក្យរបស់ខ្ញុំម្ចាស់ ៗ លែងធ្វើនូវការមិនស្រឡាញ់
ព្រះអង្គទៀតហើយ ៗ កាលបើខ្ញុំម្ចាស់អង្វរករយ៉ាងនេះហើយ
បើព្រះអង្គនឹងមិនធ្វើតាមពាក្យខ្ញុំម្ចាស់ទេ ព្រះរាជបិតាមុខជានឹង
សម្លាប់ខ្ញុំម្ចាស់ឥឡូវនេះ ហើយប្រទានដល់ពួកក្សត្រិយ៍មិនខាន ៗ

(១២៧) ឯវន្តេ យាចមានាយ    កឹ ន កាហាមិ តេ វចោ

វិក្កុទ្ធោ ត្យស្មិ កល្យាណី    មា ត្វំ ភាយិ បភាវតី ។

សព្វន្តេ បដិជានាមិ    រាជបុត្តី សុណោហិ មេ

ន ចាបិ អប្បិយំ តុយ្ហំ    ករេយ្យាមិ អហំ បុន ។

តវ កាមា ហិ សុស្សោណិ    ពហុទុក្ខំ តិតិក្ខិសំ

ពហុមទ្ទកុលំ ហន្ត្វា    នយិតុំ តំ បភាវតី ។

(១២៨) យោជយន្តុ រថេ អស្សេ    នានាចិត្តេ សមាហិតេ

អថ ទក្ខថ មេ វេគំ    វិធមេន្តស្ស សត្តវេ ។

តញ្ច តត្ថ ឧទិក្ខឹសុ    រញ្ញោ មទ្ទស្សន្តេបុរេ

វិជម្ភមានំ សីហំវ    ផោដេន្តំ ទិគុណំ ភុជំ ។

(១២៩) ហត្ថិក្ខន្ធញ្ច អារុយ្ហ    អារោបេត្វា បភាវតឹ

សង្គាមំ ឱតរិត្វាន    សីហនាទំ នទិ កុសោ ។

(១២៧) ( ព្រះមហាសត្វ... ) កាលបើនាងអង្វរករយ៉ាងនេះហើយ យើងនឹងមិនធ្វើតាមពាក្យរបស់នាងឯណាបាន នែនាងបភាវតី ស្រីកល្យាណី បងលែងខឹងនឹងនាងហើយ នាងកុំភ័យឡើយ ៗ នែរាជបុត្រី យើងសូមប្តេជ្ញាពាក្យពិតចំពោះនាង ៗ ចូរស្តាប់ពាក្យរបស់យើង ៗ លែងធ្វើនូវសេចក្តីមិនជាទីស្រឡាញ់នាងទៀត ៗ នែនាងបភាវតី ជាស្រីមានចង្កេះរៀវ យើងអត់ទ្រាំសេចក្តីទុក្ខ ច្រើនដង ព្រោះតែចង់បាននាង យើងហ៊ានសម្លាប់ត្រកូលរបស់ព្រះបាទមទ្ទៈជាច្រើន ហើយនាំយកនាងទៅបាន ៗ

(១២៨) ពួកជនទាំងឡាយ ចូរទឹមសេះដំរលេច ដោយគ្រឿងប្រដាប់ផ្សេងៗ ជាសត្វរៀបរយក្នុងរថ កាលបើទឹមហើយ អ្នកទាំងឡាយមុខជានឹងឃើញកម្លាំង របស់ខ្ញុំដែលកំចាត់ពួកខ្មាំងបាន ៗ ( អភិសម្ពុទ្ធគាថា ) ពួកស្រីក្នុងព្រះរាជវាំង របស់ព្រះបាទមទ្ទៈ ( នាំគ្នាបើកបង្អួច ) អែតមើលព្រះបាទកុសៈនោះដែលកំពុងមិតពត់កំពុងទង្គិចដើមដៃទាំងពីរខាង ដូចជាសីហៈក្នុងទីនោះ ៗ

(១២៩) ព្រះបាទកុសៈ លើកព្រះនាងបភាវតី ឡើងកាន់កដំរ លុកលុយចូល ទៅក្នុងសង្គ្រាម ហើយក៏បន្លឺនូវសីហនាទ ៗ

## សត្តតិនិបាតេ បឋមំ កុសជាតកំ

តស្ស តំ នទតោ សុត្វា សីហស្សរវរេ មិគា
ខត្តិយា វិបលាយឹសុ កុសសទ្ទភយដ្ដិតា ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
អញ្ញមញ្ញស្ស ឆិន្ទិត្ដិ កុសសទ្ទភយដ្ដិតា ។
តស្មឹ សង្គាមសីសស្មឹ បស្សិត្វា ហដ្ឋមានសោ
កុសស្ស រញ្ញោ ទេវិន្ទោ អទា វេរោចនំ មណឹ ។
សោ តំ វិជិត្វា សង្គាមំ លទ្ធា វេរោចនំ មណឹ
ហត្ថិក្ខន្ធគតោ រាជា បាវេក្ខិ នគរំ បុរំ ។
ជីវគ្គាហំ គហេត្វាន ពន្ធិត្វា សត្ត ខត្តិយេ
សសុរស្សុបនាមេសិ ឥមេ តេ ទេវ សត្តវោ ។
សព្វេវ តេ វសំ គតា អមិត្តា វិហតា តវ
កាមំ ករោហិ តេ តយា មុញ្ចវា តេ ហនស្សុ វា ។

ពួកក្សត្រិយ៍ឮព្រះបាទកុសៈនោះបន្លឺសីហនាទនោះ ត្រូវភ័យអំពីសំឡេងគម្រាម នៃព្រះបាទកុសៈបៀតបៀនហើយ ក៏នាំគ្នារត់បែកខ្ញែកដូចជាពួកម្រឹគដទៃ(ដែលភ័យនឹងសម្រែក) នៃសីហៈៗ ពួកទាហានដំរី ទាហានសេះ ទាហានរថ ទាហានថ្មើរជើង ត្រូវភ័យអំពីសំឡេងនៃព្រះបាទកុសៈបៀតបៀនហើយ ក៏រត់ជាន់គ្នាទៅវិញទៅមក ៗ ទេវរាជជាធំជាងទេវតាបានឃើញហើយក៏មានព្រះហឫទ័យរីករាយ បានប្រទានកែវមណីឈ្មោះវេរោចនៈ ដល់ព្រះបាទកុសៈក្នុងប្រធាននៃសង្គ្រាមនោះ ៗ ព្រះរាជានោះលុះឈ្នះសង្គ្រាមនោះ បានកែវមណីឈ្មោះវេរោចនៈ ហើយគង់លើកដំរីក៏យាងចូលទៅកាន់បុរី ៗ ព្រះបាទកុសៈ បានចាប់យកក្សត្រិយ៍ទាំង ៧ អង្គទាំងរស់ ចងនាំមកថ្វាយ ដល់ព្រះបិតាក្រោកថា បពិត្រព្រះសម្មតិទេព ក្សត្រិយ៍ទាំង ៧ នេះហើយជាសត្រូវរបស់ព្រះអង្គ ៗ ពួកក្សត្រិយ៍ជាសត្រូវទាំងអស់ ជាអ្នកបៀតបៀនព្រះអង្គ លុះក្នុងអំណាច របស់ព្រះអង្គហើយ សូមព្រះអង្គធ្វើតាមបំណង របស់ព្រះអង្គចុះ ទោះព្រះអង្គលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ ៗ

(១៣០) តុយ្ហេវ សត្តវេ ឃតេ ទហិ តេ មយ្ហ សត្តវេ

ត្វញ្ញេវ នោ មហារាជ មុញ្ចវេតេ ហនស្សុ វា ។

(១៣១) ឥមា តេ ធីតរោ សត្ត ទេវកញ្ញូបមា សុភា

ទទាហិ តេសំ ឯកេកំ ហោន្តុ ជាមាតរោ តវ ។

(១៣២) អម្ហាកញ្ចេវ តាសញ្ច ត្វំ នោ សព្វេសមិស្សរោ

ត្វញ្ញេវ នោ មហារាជ ទេហិ តេសំ យទិច្ឆសិ ។

(១៣៣) ឯកមេកស្ស ឯកេកំ អទា សីហស្សរោ កុសោ

ខត្តិយានំ តទា តេសំ រញ្ញោ មទ្ទស្ស ធីតរោ ។

បីណិតា តេន លាភេន តុដ្ឋា សីហស្សរេ កុសេ

សករដ្ឋានិ បាយឹសុ ខត្តិយា សត្ត តាវទេ ។

[១៣០] (ព្រះរាជា...) បពិត្រមហារាជ ព្រះរាជាទាំងនុ៎ះ ជាសត្រូវ របស់ព្រះអង្គ ព្រះរាជាទាំងនោះ មិនមែនជាសត្រូវ របស់ខ្ញុំទេ ព្រះអង្គ(ជាឥស្សរៈ) របស់ពួកយើងស្រាប់ហើយ ទោះលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ ។

[១៣១] (ព្រះមហាសត្ត...) ធីតាទាំងឡាយរបស់ព្រះអង្គទាំង ៧ នេះ ល្អមានឧបមាដោយទេវកញ្ញា សូមព្រះអង្គប្រទានធីតាមួយអង្គ ៗ ដល់ព្រះរាជាទាំងនោះ ៗ ចូរជាកូនប្រសា របស់ព្រះអង្គចុះ ។

[១៣២] (ព្រះបាទមទ្ទៈ...) បពិត្រមហារាជ ព្រះអង្គជាឥស្សរៈ របស់ពួកយើងទាំងអស់គ្នា គឺ (ព្រះរាជាទាំង ៧ នេះផង) ខ្ញុំផង ធីតាទាំងនោះផង ព្រះអង្គប្រាថ្នានឹង (ប្រទាន) ធីតាណា (ដល់ព្រះរាជាណា) សូមប្រទាន (ធីតានោះ) ដល់ព្រះរាជានោះចុះ ។

[១៣៣] (អភិសម្ពុទ្ធគាថា) ព្រះបាទកុសៈមានព្រះរាជស័ព្ទស្មើនឹងសំឡេងសីហៈ បានប្រទានពួកធីតារបស់ព្រះបាទមទ្ទៈមួយអង្គ ៗ ដល់ក្សត្រិយ៍ទាំងនោះមួយអង្គ ៗ ។ ពួកក្សត្រិយ៍ទាំង ៧ អង្គ មានព្រះហឫទ័យស្កប់ស្កល់ ដោយលាភនោះហើយ ក៏ត្រេកអរចំពោះព្រះបាទកុសៈ ដែលមានព្រះសូរជាស្មើនឹងសំឡេងសីហៈ បានទៅកាន់ដែនទាំងឡាយរៀងខ្លួនក្នុងលំដាប់នោះឯង ។

បភាវតិញ្ច អានាយ មណី វេរោចនំ សុភំ
កុសាវតី កុសោ រាជា អគមាសិ មហព្វលោ ។
ឥស្សស្សុ ឯការេថ យត្ថ បរិសត្ថ កុសាវតី
សមានា វណ្ណរូបេន អញ្ញមញ្ញាតិរោចិសុំ ។
មាតា បុត្តេន សង្គញ្ឆិ ឧក្កយោ ច ជយម្បតី
សមគ្គា តេ តទា អាសុំ ផីតំ ធរណិមាវសុន្តិ ។

កុសជាតកំ បឋមំ ។

# សោណនន្ទជាតកំ

(១៣៤) ទេវតា នុសិ គន្ធព្វោ អាទុ សក្កោ បុរិន្ទទោ
មនុស្សភូតោ ឥទ្ធិមា កថំ ជានេមុ តំ មយំ ។
(១៣៥) នម្ហិ ទេវោ ន គន្ធព្វោ នម្ហិ សក្កោ បុរិន្ទទោ
មនុស្សភូតោ ឥទ្ធិមា ឯវំ ជានាហិ ភារថ ។

ចំណែកឯព្រះបាទកុសៈមានកម្លាំងច្រើន បាននាំយកនាងបភាវតីនឹងកែវមណី ឈ្មោះវេរោចនៈដ៏ល្អ ហើយទ្រង់ស្តេចវិលត្រឡប់ទៅកាន់ក្រុងកុសាវតីវិញ ។ ក្សត្រិយ៍ទាំងនោះគង់លើរថជាមួយគ្នា បរសំដៅចូលទៅកាន់ក្រុងកុសាវតី ស្មើគ្នាដោយវណ្ណៈនិងរូប មិនរុងរឿងជាងគ្នាប៉ុន្មានទេ ។ ព្រះមាតាបានចួបជុំដោយបុត្រ ចំណែកអគ្គមហេសីនឹងព្រះរាជស្វាមីទាំងពីរព្រះអង្គនោះ បានព្រមព្រៀងគ្នា នៅគ្រប់គ្រងរាជធរណីដ៏សម្បូណ៌សប្បាយក្នុងកាលនោះ ។

ចប់ កុសជាតក ទី ១ ។

## សោណនន្ទជាតក

[១៣៨] (ព្រះរាជាព្រះនាម មនោជៈ ត្រាស់សួរថា) លោកជាទេវតាឬជាគន្ធព្វ ជាសក្កបុរិន្ទទៈ ឬជាមនុស្សមានឫទ្ធិ ធ្វើដូចម្ដេច យើងនឹងស្គាល់លោកបាន ។

[១៣៩] (តាបសឈ្មោះនន្ទបណ្ឌិតពោលថា) អាត្មាភាពមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជាទ្រង់នូវការៈ(ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

[១៣៦] ភត្តរូបមិទំ ភោតោ វណ្ណវន្តំ អនប្បកំ

ទេវម្ហិ វស្សមានម្ហិ អនោវស្សំ កិំ អកា ៗ

ឥតោ វាតា តបេ ឃោរេ សីតច្ឆាយំ កិំ អកា

ឥតោ អមិត្តមជ្ឈេសុ សរតាណំ កិំ អកា ៗ

ឥតោ ជីតានិ រដ្ឋានិ វសិតោ តេ កិំ អកា

ឥតោ ឯកសតំ ខត្យេ អនុយន្តេ កិំ អកា ៗ

បតិតាស្សុ មយំ ភោតោ វរតំ កុញ្ជមិច្ឆសិ

ហត្ថិយានំ អស្សរថំ នារិយោ ច អលង្កតា

និវេសនានិ រម្មានិ មយំ ភោតោ ទទាមសេ ៗ

អថវង្គេ វា មគធេ មយំ ភោតោ ទទាមសេ

អថវា អស្សកាវន្តី សុមនា ទម្ម តេ មយំ ៗ

ឧបឌ្ឍំ វាបិ រជ្ជស្ស មយំ ភោតោ ទទាមសេ

សចេ តេ អត្ថោ រជ្ជេន អនុសាស យទិច្ឆសិ ៗ

[១៣៦] (ព្រះបាទមនោជៈ...) ការខ្វល់ខ្វាយបំរើ មានភាពដែល លោកដ៏ចំរើនធ្វើហើយ នេះជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចំរើនអាចធ្វើមិនឲ្យមានភ្លៀងបាន ។ តអំពីនោះមក លោកដ៏ចំរើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បាន ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ខ្លាំង តពីនោះមក លោកដ៏ចំរើន អាចធ្វើគ្រឿងការពារព្រួញ ក្នុងកណ្តាលនៃសត្រូវទាំងឡាយបាន ។ តពីនោះមក លោកដ៏ចំរើនអាចធ្វើដែនទាំងឡាយដ៏សម្បូណ៌(នឹង) អ្នកដែនទាំងនោះឲ្យលុះក្នុងអំណាច (របស់យើងខ្ញុំ) តពីនោះមក លោកដ៏ចំរើនអាចធ្វើក្សត្រិយ៍ ១០១ ឲ្យជាបំណុះ(នៃយើងខ្ញុំបាន) ។ យើងខ្ញុំត្រេកអរនឹងលោកដ៏ចំរើន លោកចង់បានរតនៈ ( ណា ) ចូរទទួលយករតនៈនោះចុះ យើងខ្ញុំប្រគេនយានដំរី រថសេះ ពួកនាងនារីដែលប្រដាប់ស្រេច ទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយ ដល់លោកដ៏ចំរើន ។ មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈ ឬមគធៈ ដល់លោកដ៏ចំរើន មួយទៀត យើងខ្ញុំសប្បាយចិត្ត ប្រគេនដែនអស្សកៈ ឬដែនអវន្តិដល់លោក ។ យើងខ្ញុំប្រគេនរាជ្យពាក់កណ្តាល ដល់លោកដ៏ចំរើន បើលោកត្រូវការដោយរាជ្យ លោកចង់បានរបស់ណា សូមត្រួតត្រារបស់នោះចុះ ។

(១៣៧) ន មេ អត្ថោបិ រជ្ជេន នគរេន ធនេន វា

អថោបិ ជនបទេន អត្ថោ មយ្ហំ ន វិជ្ជតិ ។

(១៣៨) ភោតោវ រដ្ឋេ វិជិតេ អរញ្ញេ អត្ថិ អស្សមោ

បិតា មយ្ហំ ជនេត្តិ ច ឧភោ សម្មន្តិ អស្សមេ ។

តេសាហំ បុព្វាចរិយេសុ បុញ្ញំ ន លភាមិ កាតវេ

ភវន្តំ អជ្ឈាវរំ កត្វា សោណំ យាចេមុ សំវរំ ។

(១៣៩) ករោមិ តេ តំ វចនំ យំ មំ ភណសិ ព្រាហ្មណ

ឯតញ្ច ខោ នោ អក្ខាហិ កីវន្តោ ហោន្តុ យាចកា ។

(១៤០) បរោសតំ ជានបទា មហាសាលា ច ព្រាហ្មណា

ឥមេ ច ខត្តិយា សព្វេ អភិជាតា យសស្សិនោ

ភវញ្ច រាជា មនោជោ អលំ ហេស្សន្តិ យាចកា ។

(១៤១) ហត្ថី អស្សេ ច យោជេន្តុ រថំ សន្នយ្ហ សារថិ

(១៣៧) (នន្ទបណ្ឌិតតាបស...) អាត្មាភាព មិនត្រូវការដោយពង្ស ដោយនគរ ឬដោយទ្រព្យ ទាំងមិនត្រូវការដោយជនបទទេ ។

(១៣៨) កន្លែងក្នុងដែនជាអាណាខេត្តរបស់ព្រះអង្គដ៏ចំរើន មានអាស្រមមួយ បិតាមាតារបស់អាត្មាភាពទាំងពីរនាក់ នៅក្នុងអាស្រមនោះ ។ អាត្មាភាពមិនបានធ្វើបុណ្យចំពោះបុព្វាចារ្យទាំងនោះ យើងធ្វើព្រះអង្គដ៏ចំរើនឲ្យប្រសើរលើសលុប ឲ្យសូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស ។

(១៣៩) (ព្រះរាជា...) បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោកដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះ ដល់យើងខ្ញុំ តើឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរគេ ។

(១៤០) (នន្ទបណ្ឌិតតាបស...) ពួកគហបតីមហាសាលជាងមួយរយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ នឹងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចំរើន ទើបល្មមជាអ្នកជួយអង្វរគេ ។

(១៤១) (ព្រះរាជា...) ពួកអ្នកគេក្រដំរី ពួកអ្នកគេក្រសេះ ចូរនាំគ្នា ចាត់ចែងនូវពួកដំរីពួកសេះ ម្នាលសារថី អ្នកចូរផ្ទឹមរថ

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

អាពន្ធតិ តម្ហា ច      ធាតាសុ ស្សុរយេន្ទជេ
អស្សមន្តំ គមិស្សាមិ      យត្ថ សម្មតិ កោសិយោ ។

(១៤២) តតោ ច រាជា បាយាសិ      សេនាយ ចតុរង្គិនី
អគមាសិ អស្សមំ រម្មំ      យត្ថ សម្មតិ កោសិយោ ។

(១៤៣) កស្ស កាទម្ពយោ កាជេ      វេហាសំ ចតុរង្គុលំ
អំសំ អសំផុសំ ឯតិ      ឧទហារស្ស គច្ឆតោ ។

(១៤៤) អហំ សោណោ មហារាជ      តាបសោ សហិតព្វតោ
ភរាមិ មាតាបិតរោ      រត្តិន្ទិវមតន្ទិតោ ។
វនេ ផលញ្ច មូលញ្ច      អាហរិត្វា ទិសម្បតិ
បោសេមិ មាតាបិតរោ      បុព្វេ កតមនុស្សរំ ។

(១៤៥) ឥច្ឆាម អស្សមំ គន្តុំ      យត្ថ សម្មតិ កោសិយោ
មគ្គំ នោ សោណ អក្ខាហិ      យេន គច្ឆេមុ អស្សមំ ។

អ្នកទាំងឡាយ ចូរយកគ្រឿងប្រដាប់សម្រាប់ចង (ឯដំរីសេះរថ) ជនទាំងឡាយ ចូរលើកទង់ជ័យ ត្រង់ដើមទង់ជ័យដែលដំកល់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត ។

(១៤២) (អភិសម្ពុទ្ធគាថា) លំដាប់ពីនោះមក ព្រះរាជាបានយាងទៅដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្តេចទៅកាន់អាស្រមជាទីរីករាយ ជាទីនៅនៃកោសិយគោត្ត ។

(១៤៣) (ព្រះបាទមនោជៈ...) ដងរែក ជាភារៈនៃឈើក្តម្ពរបស់អ្នកណា ដែលទៅដងទឹក ហើយមិនប៉ះពាល់ស្មា ទៅលើអាកាសចំនួន ៤ ហាប់ ។

(១៤៤) (ព្រះមហាសត្វ...) បពិត្រមហារាជ អាត្មាភាពជាតាបសឈ្មោះសោណៈ ប្រកបដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតា ទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាព រលឹកឃើញឧបការៈដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើនឹងមើមឈើក្នុងព្រៃ មកចិញ្ចឹមមាតាបិតា ។

(១៤៥) (ព្រះរាជា...) យើងខ្ញុំចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត បពិត្រព្រះសោណៈ សូមលោកម្ចាស់ប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម ។

(១៦៦) អយំ ឯកបទី រាជ យេនេតំ មេឃសន្និភំ
កោវិឡារេហិ សញ្ឆន្នំ ឯត្ថ សម្មតិ កោសិយោ ។

(១៦៧) ឥទំ វត្វាន បក្កាមិ ព្រាហ្មណោ មហាឥសិ
វេហាសេ អន្តលិក្ខស្មឹ អនុសាសេត្វាន ខត្តិយេ ។
អស្សមំ បរិមជ្ជិត្វា បញ្ញាបេត្វាន អាសនំ
បណ្ណសាលំ បវិសិត្វា បិតរំ បដិពោធយិ ។
ឥមេ អាយន្តិ រាជានោ អភិជាតា យសស្សិនោ
អស្សមា និក្ខមិត្វាន និសីទ ត្វំ មហាឥសេ ។
តស្ស តំ វចនំ សុត្វា ព្រាហ្មណោ មហាឥសិ
អស្សមា និក្ខមិត្វាន សទ្វារម្ហិ (១) ឧបាវិសិ ។

(១៦៨) តញ្ច ទិស្វាន អាយន្តំ ជលន្តំរិវ តេជសា
ខត្តសង្ឃបរិព្យូឡ្ហំ កោសិយោ ឯតទព្រវិ ។
កស្ស ភេរី មុទិង្គា ច សង្ខា បណវទិន្ទិមា
បុរតោ បដិបន្នានិ ហាសយន្តា រថេសភំ ។

---

១ ឱ. បន្នទ្វារម្ហិ ។

(១៤៦) (ព្រះមហាសត្ត...) បពិត្រព្រះរាជា ផ្លូវដើរប៉ុនតែជើង ១ នេះ មានព្រៃមានពណ៌ដូចជាផ្ទៃមេឃ ដុះដេរដាសដោយដើមរល្ហុសផ្អុន្ទុះ ជាទីនៅរបស់កោសិយគោត្ត ។

(១៤៧) (អភិសម្ពុទ្ធគាថា) លុះមហាឥសីពោលពាក្យនេះទូលប្រាប់ពួកក្សត្រិយ៍ហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ(កាន់ស្រះអនោតត្ត) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសំអាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលាហើយដំរាបបិតាឲ្យជ្រាបថា បពិត្រមហាឥសី ព្រះរាជាទាំងនេះ មានជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពីអាស្រមមកគង់ចាំទទួល ។ មហាឥសីឮពាក្យនោះរបស់កូននោះហើយក៏ប្រញាប់ប្រញាល់ ចេញអំពីអាស្រម មកអង្គុយជិតទ្វារ ។

(១៤៨) កោសិយគោត្តតាបស បានឃើញស្តេចនោះ ដូចជារុងរឿងដោយតេជះ មានពួកក្សត្រិយ៍ហែហម កំពុងយាងមក ហើយបានពោលពាក្យនេះថា ស្គរ សម្ភោរ សង្ខ ស្គរតូចនិងមហោរធឹករបស់អ្នកណា ញុំាងស្តេចជាបុគ្គលប្រសើរលើរថ ឲ្យរីករាយទៅខាងមុខ ។

កស្ស កញ្ចនបដ្ដេន បុថុនា វិជ្ជុវណ្ណិនា
យុវា កលាបសន្នទ្ធោ កោ បតិ សិរិយា សហ ។
ឧក្កាមុខបហដ្ឋំវ ខទិរង្គារសន្និភំ
មុខញ្ច រុចិរា ភាតិ កោ បតិ សិរិយា សហ ។
កស្ស បគ្គហិតំ ឆត្តំ សសលាកំ មនោរមំ
អាទិច្ចរំសាវរណំ កោ បតិ សិរិយា សហ ។
កស្ស អង្គំ បរិគ្គយ្ហ វាលវីជនិមុត្តមំ
ចរន្តិ វរបុញ្ញស្ស ហត្ថិក្ខន្ធេន អាយតោ ។
កស្ស សេតានិ ឆត្តានិ អាជានីយា ច វម្មិកា
សមន្តា បរិកិរន្តិ កោ បតិ សិរិយា សហ ។
កស្ស ឯកសតំ ខត្យា អនុយន្តា យសស្សិនោ
សមន្តា អនុបរិយន្តិ កោ បតិ សិរិយា សហ ។
ហត្ថិអស្សរថបត្តិ សេនា ច ចតុរង្គិនី
សមន្តា អនុបរិយន្តិ កោ បតិ សិរិយា សហ ។

(ទីបំផុតថ្ងាស) នៃអ្នកណា (បិទបាំង) ដោយដំបារមាសដ៏ធំ មានពណ៌ដូចជាផ្កាបន្ទោរ ប្រុសកំឡោះណា សៀតបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក ៗ អ្នកណាមានមុខរុងរឿងភ្លឺថ្លាំង ដូចជាមាសភ្លឺចិញ្ចាចត្រង់មាត់ចារ ស្រដៀងនឹងរងើកភ្លើងនៃខសគគីរ រុងរឿងដោយសិរី ហើយដើរមក ៗ អ្នកណា បាំងឆ័ត្រព្រមទាំងធ្អឹន ជាទីរីករាយនៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក ៗ ពួកជនបិទបាំងជុំវិញខ្លួន នៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ កំពុងជិះលើកនៃដំរី ដោយផ្ទិតរោមសត្វដ៏ឧត្តម ហើយដើរទៅ ៗ ពួកឆ័ត្រសទនឹងពួកអាជានេយ្យប្រដាប់ដោយគ្រោះខ្នាន់ខ្នាប់ជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរីហើយដើរមកៗពួកក្សត្រិយ៍មួយរយមួយ សុទ្ធតែមានយសជាស្តេចចំណុះ ដើរហែហមជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ដើរមក ៗ ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី១ សេះ១ រថ១ ពលថ្មើរជើង១ ដើរហែហមជុំវិញ (នៃអ្នកណា) អ្នកណារុងរឿងដោយសិរី ដើរមក ៗ

តស្សេសា មហតី សេនា បិដ្ឋិតោ អនុវត្តតិ

អក្ខោភិណី អបរិយន្តា សាគរស្សេវ ឩមិយោ ។

(១៤៩)រាជាភិរាជា មនោជោ ឥន្ទោវ ជយតំ បតិ

នន្ទស្សជ្ឈាវរំ ឯតិ អស្សមំ ព្រហ្មចារិនំ ។

តស្សេសា មហតី សេនា បិដ្ឋិតោ អនុវត្តតិ

អក្ខោភិណី អបរិយន្តា សាគរស្សេវ ឩមិយោ ។

(១៥០)អនុលិត្តា ចន្ទនេន កាសិកុត្តមធារិនោ

សព្វេ បញ្ជលិកា ហុត្វា ឥសីនំ អជ្ឈុបាគមុំ ។

(១៥១)កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ

កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។

កច្ចិ ឌំសា មកសា ច អប្បមេវ សរីសបា

សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំកើបបាន មិនមានទីបំផុត ដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា ។

(១៨៩) (ព្រះមហាសត្ត...) ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរ ជាងពួកព្រះរាជា ដូចជាព្រះឥន្ទ្រជាធំជាងពួកទេវតា ក្នុងឋាន ត្រៃត្រិង្ស ដែលមានជ័យជំនះ បានដល់នូវភាពជាបរិស័ទនៃនន្ទ-តាបស មកកាន់អាស្រមនៃពួកព្រហ្មចារីបុគ្គល(ដើម្បីខមាទោស នឹងយើង) ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយ ឲ្យរំកើប បាន មិនមានទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាង ក្រោយនៃព្រះបាទមនោជៈនោះ ។

(១៩០) (អកិសមុទ្ទគាថា) ពួកព្រះរាជាទាំងអស់ លាបស្រឡាប ដោយខ្លឹមចន្ទន៍ ទ្រង់កាសិកព័ស្ត្រដ៏ឧត្តម បានផ្គងអញ្ជលីចូល ទៅរកពួកឥសី ។

(១៩១) (ព្រះបាទមនោជៈ...) លោកដ៏ចំរើន មានសេចក្តីសុខ ស្រួលទេឬ លោកដ៏ចំរើន មានអនាម័យទេឬ លោកទាំងឡាយ ចិញ្ចឹមជីវិត ដោយការស្វែងរកឬ មើមឈើនឹងផ្លែឈើ មានច្រើនដែរឬ ។ ពួករបោម មូស ពស់ មានតិចតួចដែរឬ

វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតិ ។

(១៥២) កុសលញ្ចេវ នោ ភន្តេ អថោ ភន្តេ អនាមយំ

អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។

អថោ ឌំសា មកសា ច អប្បមេវ សរីសបា

វនេ វាឡមិគាកិណ្ណេ ហឹសា មយ្ហំ ន វិជ្ជតិ ។

ពហូនិ វស្សបូគានិ អស្សមេ សម្មតំ ឥធ

នាភិជានាមិ ឧប្បន្នំ អាពាធំ អមនោរមំ ។

ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ

ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។

តិន្ទុកានិ បិយាលានិ មធុកេ កាសុមារិយោ

ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។

ឥទំបិ បានីយំ សីតំ អាភតំ គិរិគព្ភរា

តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ ។

ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ ។

[១៨២] (កោសិយគោត្ត...) បពិត្រព្រះរាជា អាត្មាភាព មានសេចក្តីស្រួលទេ បពិត្រព្រះរាជា មួយទៀត អាត្មាភាព មិនមានសេចក្តីឈឺចាប់ទេ អាត្មាភាព ចិញ្ចឹមជីវិតដោយការស្វែងរក (ផលាផល) ស្រួលទេ ទាំងមើមឈើនិងផ្លែឈើក៏មានច្រើន ។ មួយទៀត ពួករបោម បូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ ក៏មិនបៀតបៀនអាត្មាភាពទេ ។ អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្ត កើតឡើងទេ ។ បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល ៗ បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែព្រីង ផ្លែស្រគំ ផ្លែមាក់ផោក មានសេចក្តីឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ ៗ ទឹកត្រជាក់នេះ អាត្មាភាព បានដងមក អំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ ៗ

## សត្តតិនិបាតេ ទុតិយំ សោណនន្ទជាតកំ

(១៨៣)បដិគ្គហិតំ យំ ទិន្នំ   សព្វស្ស អគ្ឃិយំ កតំ
នន្ទស្សាបិ និសាមេថ   វចនំ សោ បវក្ខតិ ។
អជ្ឈាវរម្ហា នន្ទស្ស   ភោតោ សន្តិកមាគតា
សុណាតុ មេ ភវំ វចនំ   នន្ទស្ស បរិសាយ ច ។

(១៨៤)បរោសតំ ជានបទា មហាសាលា ច ព្រាហ្មណា
ឥមេ ច ខត្តិយា សព្វេ   អភិជាតា យសស្សិនោ
ភវញ្ច រាជា មនោជោ   អនុមញ្ញន្តុ មេ វចោ ។
យេ ច សន្តិ សមិតារោ   យក្ខានិ ឥធមស្សមេ
អរញ្ញេ ភូតភព្យានិ   សុណន្តុ វចនំ មម ។
នមោ កត្វាន ភូតានំ   ឥសឹ វក្ខាមិ សុព្វតំ
សោត្យាហំ ទក្ខិណាពាហុ តវ កោសិយ សម្មតោ ។

[១៨៣] (ព្រះរាជា...) របស់ណាដែលលោកឲ្យហើយ (របស់នោះ) ឈ្មោះថា យើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនូនដល់ជនទាំងពួង លោកទាំងឡាយ ចូរស្តាប់ពាក្យនន្ទបណ្ឌិតតាបស លោកនឹងនិយាយឥឡូវនេះ ពួកយើងជាបរិស័ទនៃនន្ទបណ្ឌិតតាបស បានមកកាន់សំណាក់នៃលោកដ៏ចំរើន សោណបណ្ឌិតដ៏ចំរើន ចូរស្តាប់ពាក្យ នៃខ្ញុំផង នៃបរិស័ទរបស់នន្ទបណ្ឌិតតាបសផង ៗ

[១៨៤] (នន្ទបណ្ឌិតតាបស...) ពួកគហបតិមហាសាលជាងមួយរយ ពួកព្រាហ្មណមហាសាលជាងមួយរយ នឹងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចំរើន សូមជ្រាបតាមសំដីរបស់អាត្មាភាពចុះ ៗ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូតនឹងទេវតា ក្នុងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្តាប់នូវពាក្យរបស់អាត្មា ៗ អាត្មាធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី (ឈ្មោះសោណបណ្ឌិត) ដែលមានវត្តល្អថា ខ្ញុំនោះហើយដែលកោសិយគោត្តសន្មតថាជាដើមដៃស្តាំ របស់លោក ៗ

បិតរំ មេ ជនេត្តី ច ភត្តុកាមស្ស មេ សតោ
វីរ បុញ្ញមិទំ ឋានំ មា មំ កោសិយ វារយ ។
សព្ភិ ហេតំ ឧបញ្ញាតំ មមេតំ ឧបនិស្សជ
ឧដ្ឋានបារិចរិយាយ ទីឃរត្តំ តយា កតំ
មាតាបិតូសុ បុញ្ញានិ មម លោកទទោ ភវ ។
តថេវ សន្តិ មនុជា ធម្មេ ធម្មបទំ វិទូ
មគ្គោ សគ្គស្ស លោកស្ស យថា ជានាសិ ត្វំ ឥសេ ។
ឧដ្ឋានបារិចរិយាយ មាតាបិតុសុខាវហំ
តំ មំ បុញ្ញា និវារេតិ អរិយមគ្គាវរោ នរោ ។
(១៨៨) សុណន្តុ ភោន្តោ វចនំ ភាតុរជ្ឈាវរា មម
កុលវំសំ មហារាជ បោរាណំ បរិហាបយំ ។
អធម្មចារី ជេដ្ឋេសុ និរយំ សោ ឧបបជ្ជតិ ។

បពិត្រអ្នកមានព្យាយាម ការទំនុកបំរុងមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំដែលជាអ្នកប្រាថ្នាចិញ្ចឹមបិតានិងមាតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ ៗ ការទំនុកបំរុងមាតាបិតា +នុះ ពួកសប្បុរសបានដឹងហើយ សូមលោកលះនូវការទំនុកបំរុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ ( កុសល ) ដោយការខ្នះខ្នែងនឹងការបម្រើយូរយារណាស់មកហើយ (ឥឡូវនេះ ខ្ញុំចង់ធ្វើ) បុណ្យទាំងឡាយដល់មាតានិងបិតា សូមលោកប្រគល់សួគ៌ទេវ-លោកដល់ខ្ញុំ ៗ បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ទេវលោកយ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ ក្នុងធម៌ក៏យ៉ាងនោះដែរៗ កិរិយានាំមកនូវសេចក្ដីសុខដល់មាតាបិតា ដោយការខ្នះខ្នែងនឹងការបំរើ ឥឡូវនេះ ជន ( សោណបណ្ឌិត ) ហាមឃាត់ខ្ញុំនោះចាកបុណ្យ ឈ្មោះថាជាអ្នកពាំងផ្លូវដ៏ប្រសើរ ( ឋានសួគ៌ ) ៗ

[១៥៥] ( ព្រះមហាសត្ត... ) លោកដ៏ចំរើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្ដាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណា មិនប្រព្រឹត្តធម៌ ចំពោះបុគ្គលជាច្បងទាំងឡាយ ញ៉ាំងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក ៗ

សត្តតិនិបាតេ ទុតិយំ សោណនន្ទជាតកំ

យេ ច ធម្មស្ស កុសលា បោរាណស្ស ទិសម្បតិ
ចារិត្តេន ច សម្បន្នា ន តេ គច្ឆន្តិ ទុគ្គតឹ ។
មាតា បិតា ច ភាតា ច ភគិនី ញាតិពន្ធវា
សព្វេ ជេដ្ឋស្ស តេ ភារា ឯវំ ជានាហិ ភារថ ។
អាទិយិត្វា គរុំ ភារំ នាវិកោ វិយ ឧស្សហោ
ធម្មញ្ច នប្បមជ្ជាមិ ជេដ្ឋោ ចស្មិ រថេសភ ។
(១៥៦) អធិគម្ហា(១) តមេ ញាណំ ជាលំវ ជាតវេទតោ
ឯវមេវ នោ ភវំ ធម្មំ កោសិយោ បវិទំសយិ ។
យថា ឧទយមាទិច្ចោ វាសុទេវោ បភង្ករោ
បាណីនំ បវិទំសេតិ រូបំ កល្យាណបាបកំ
ឯវមេវ នោ ភវំ ធម្មំ កោសិយោ បវិទំសយិ ។
(១៥៧) ឯវំ មេ យាចមានស្ស អញ្ជលឹ នាវពុជ្ឈថ
តវ បទ្ធចរោ ហេស្សំ វុដ្ឋិតោ បរិចារកោ ។

---

១ ឱ. អធិគតម្ហា ។ ម. អធិគមា ។

បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណា ឈ្លាសវៃក្នុងធម៌ (ជេដ្ឋាបចាយនធម៌) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្ដាប់ធ្នាប់ ពួកជននោះរមែងមិនទៅកាន់ទុគ្គតិទេ ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក (ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតា បងប្អូនប្រុសស្រី ញាតិនឹងផៅពង្សទាំងអស់នោះជាភារៈរបស់កូនច្បង ។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពដូចជានាយសំពៅអាចនាំយកនូវភារៈដ៏ធ្ងន់ អាត្មាភាពពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះអាត្មាភាពជាច្បង ។

(១៩៦) (ព្រះរាជាទាំងឡាយ...) ពួកយើងបានញាណដូចបុគ្គលបានអណ្ដាតភ្លើងអំពីភ្លើង ក្នុងទីងងឹត កោសិយតាបសដ៏ចំរើនបានឆ្លុះបញ្ចាំងធម៌ដល់ពួកយើង យ៉ាងនេះឯង ។ ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើង តែងឆ្លុះបញ្ចាំងនូវរូបល្អអាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈដ៏ចំរើន បានឆ្លុះបញ្ចាំងនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ ។

(១៩៧) (នន្ទបណ្ឌិតតាបស...) កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិនទទួលអញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រឹងបំរើលោក ។

(១៥៨)អទ្ធា នូន វិជានាសិ  សទ្ធម្មំ សព្ភិ ទេសិតំ
អរិយោ អរិយសមាចារោ  ពាឡ្ហំ ត្វំ មម រុច្ចសិ ។
ភវន្តំ វន្ទាមិ កោណ្ឌញ្ញ  សុណោថ វចនំ មម
នាយំ ភារោ ភារមត្តោ  អហុ មយ្ហំ កុទាចនំ ។
តំ មំ ឧបដ្ឋិតំ សន្តំ  មាតាបិតុសុខាវហំ
នន្ទោ អជ្ឈាវរំ កត្វា  ឧបដ្ឋានាយ យាចតិ ។
យោ វេ ឥច្ឆតិ កាមេន  សន្តានំ ព្រហ្មចារិនំ
នន្ទំ វោ វរថ ឯកោ  កំ នន្ទោ ឧបតិដ្ឋតុ ។
(១៥៩)តយា តាត អនុញ្ញាតា  សោណ តំ និស្សិតា មយំ
ឧបឃាតុំ លភេ នន្ទំ  មុទ្ធនិ ព្រហ្មចារិនំ ។
(១៦០)អស្សត្ថស្សេវ តរុណំ  បវាលំ មាលុតេរិតំ
ចិរស្សំ នន្ទំ ទិស្វាន  ហទយំ មេ បវេធតិ ។
យទា សុត្តាបិ សុបិនេ  នន្ទំ បស្សាមិ អាគតំ
ឧទគ្គា សុមនា ហោមិ  នន្ទោ នោ អាគតោ អយំ ។

(១៥៨) ( ព្រះមហាសត្វ... ) ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរស សំដែងហើយមែន អ្នកជាមនុស្សល្អ មានឫកពាល្អ ត្រូវចិត្តយើងហើយ ៗ ខ្ញុំសូមនិយាយនឹងបិតាដ៏ចំរើន នឹងមាតាដ៏ចំរើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈនេះមិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំក្នុងកាលម្តង ៗ ទេ ៗ នន្ទៈផ្ញើនូវខ្ញុំដែលជាអ្នកបំរើ នាំមកនូវសេចក្តីសុខដល់មាតានឹងបិតានោះ ឲ្យជាធំ ហើយសូមដើម្បីការបំរើដែរ ៗ បណ្តា (មាតានឹងបិតា ) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយកនន្ទៈ តាមប្រាថ្នាចុះ តើឲ្យនន្ទៈបំរើលោកណា ៗ

(១៥៩)(មាតា...)នែសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈ ជាព្រហ្មចារី ៗ

(១៦០) ដួងហឫទ័យរបស់ម្តាយរំដួល ព្រោះខានឃើញនន្ទៈអស់កាលយូរហើយ ដូចជាស្លឹកខ្ចីរបស់អស្សត្ថព្រឹក្ស ដែលត្រូវខ្យល់បក់ ៗ វេលាណា ម្តាយដេកលក់ យល់សប្តិឃើញនន្ទៈមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ ( ដោយគិតថា ) នន្ទៈរបស់យើងនេះមកហើយ ៗ

សត្តកនិបាតេ ទុតិយំ សោណនន្ទជាតកំ

យថា ច បដិពុជ្ឈិត្វា ឥទ្ធំ បស្សាមិ ជាគតំ
កិយ្យោ អាវិសតិ សោកោ ទោមនស្សញ្ចនប្បកំ ។
សាហំ អជ្ជ ចិរស្សំបិ ឥទ្ធំ បស្សាមិ អាគតំ
ភត្តុ ច មយ្ហញ្ច បិយោ នន្ទោ នោ បាវិសី ឃរំ ។
បិតុ ច នន្ទោ សុប្បិយោ យំ នន្ទោ នប្បវិសេ ឃរំ
លភតុ តាត នន្ទោ តំ មំ នន្ទោ ឧបតិដ្ឋតុ ។
(១៦១) អនុកម្បកា បតិដ្ឋា ច បុព្វេ រសទទី ច នោ
មគ្គោ សគ្គស្ស លោកស្ស មាតា តំ វរតេ ឥសេ ។
បុព្វេ រសទទី គោត្តី មាតា បុញ្ញូបសញ្ហិតា
មគ្គោ សគ្គស្ស លោកស្ស មាតា តំ វរតេ ឥសេ ។
(១៦២) អាកង្ខមានា បុត្តផលំ ទេវតាយ នមស្សតិ
នក្ខត្តានិ ច បុច្ឆតិ ឧតុសំវច្ឆរានិ ច ។
តស្សា ឧតុសិ ន្ហាតាយ ហោតិ គព្ភស្សវក្កមោ
តេន ទោហឡិនី ហោតិ សុហទា តេន វុច្ចតិ ។
សំវច្ឆរំ វា ឩនំ វា បរិហរិត្វា វិជាយតិ

វេលាណាម្ដាយភ្ញាក់ឡើង មិនឃើញនន្ទៈមកទេ សេចក្ដីសោក នឹងទោមនស្សជាច្រើន រឹងរឹតតែបណ្ដាលឡើង ។ យូរណាស់ ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្ដាយនោះឃើញនន្ទៈមកដល់ នន្ទៈ ជាទីស្រឡាញ់នៃស្វាមីរបស់ម្ដាយផង នៃម្ដាយផង បានចូល មកកាន់ផ្ទះរបស់ពួកយើង ។ នន្ទៈជាទីស្រឡាញ់ក្រៃលែងរបស់ បិតា កុំឲ្យនន្ទៈទៅប្រាសចេញអំពីផ្ទះ នៃកូន ឯនន្ទៈ ( ចង់បាន អ្នកណា ) ចូរបានអ្នកនោះចុះ នន្ទៈចូរបំរើនូវអញចុះ ។

(១៦១) ( ព្រះមហាសត្វ... ) ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ ទេវលោក ចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នក គ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវ-លោក ម្នាលឥសី មាតាចង់បានអ្នក ។

(១៦២) មាតាកាលប្រាថ្នាចង់បានផ្លែគឺកូន រមែងនមស្ការទេវតាសួរ នក្ខត្តឫក្សទាំងឡាយផង សួររដូវនឹងឆ្នាំទាំងឡាយផង ។ កាល មាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌សិប មាតាជាស្ត្រីមានសេចក្ដីចាញ់ផ្ទៃដោយហេតុនេះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា(មានដួងហឫទ័យល្អ) ។ មាតា រក្សា(ផ្ទៃ)អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយប្រសូតបុត្រមក

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ជាតកំ

តេន សា ជនយន្តីតិ ជនេត្តី តេន វុច្ចតិ ។
ថនខីរេន គីតេន អង្គបាវុរណេន ច
រោទន្តំ បុត្តំ តោសេតិ តោសេន្តី តេន វុច្ចតិ ។
តតោ វាតាតបេ ឃោរេ មមំ កត្វា ឧទិក្ខតិ
ទារកំ អប្បជានន្តំ បោសេន្តី តេន វុច្ចតិ ។
យញ្ច មាតុ ធនំ ហោតិ យញ្ច ហោតិ បិតុទ្ធនំ
ឧភយម្បេតស្ស គោបេតិ អបិ បុត្តស្ស នោ សិយា ។
ឯវំ បុត្ត អទុំ បុត្ត ឥតិ មាតា វិហញ្ញតិ
បមត្តំ បរទារេសុ និសីថេ បត្តយោព្វនេ
សាយំ បុត្តំ អនាយន្តំ ឥតិ មាតា វិហញ្ញតិ ។
ឯវំ កិច្ឆាភតោ បោសោ មាតុ អបរិចារកោ

ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា ជនយន្តី ផង ជនេត្តីផង(អ្នកបង្កើតកូន) ៗ មាតាញុំាងកូន ដែលកំពុងយំឲ្យត្រេកអរ ដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី (អ្នកញុំាងកូនឲ្យត្រេកអរ) ៗ តពីនោះមក មាតាផ្ញើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារក ដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា បោសេន្តី (អ្នកបិញ្ចឹមកូន) ៗ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាក៏គ្រប់គ្រងទ្រព្យទាំងពីរចំណែកដើម្បីកូននោះ ( ដោយបំណងថា ទ្រព្យនេះ ) ត្រូវមានដល់កូនរបស់យើង ៗ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូនដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាថក្នុងរាជត្រកូលជាដើម ) យ៉ាងនេះ ម្នាលកូន ( ឯងចូរធ្វើការ ) ឯណោះៗ កាលបើកូនមានវ័យចំរើនឡើងហើយ មាតា(បានដឹង) កូននោះប្រមាថក្នុងប្រពន្ធរបស់អ្នកដទៃក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏រមែងលំបាកចិត្តដូច្នេះ ៗ សត្វដែលមាតាបិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបំរើមាតា

## សត្តតិនិបាតេ ទុតិយំ សោណនន្ទជាតកំ

មាតរំ មិច្ឆាចរិត្វាន　　និរយំ សោ ឧបបជ្ជតិ ៗ
ឯវំ កិច្ឆាភតោ បោសោ　　បិតុ អបរិហារកោ
បិតរំ មិច្ឆាចរិត្វាន　　និរយំ សោ ឧបបជ្ជតិ ៗ
ធនម្បិ ធនកាមានំ　　នស្សតិ ឥតិ មេ សុតំ
មាតរំ អបរិចរិត្វាន　　កិច្ឆំ វា សោ និគច្ឆតិ ៗ
ធនម្បិ ធនកាមានំ　　នស្សតិ ឥតិ មេ សុតំ
បិតរំ អបរិចរិត្វាន　　កិច្ឆំ វា សោ និគច្ឆតិ ៗ
អានន្ទោ ច បមោទោ ច　　សទា ហសិតកីឡិតំ
មាតរំ បរិចរិត្វាន　　លព្ភមេតំ វិជានតោ ៗ
អានន្ទោ ច បមោទោ ច　　សទា ហសិតកីឡិតំ
បិតរំ បរិចរិត្វាន　　លព្ភមេតំ វិជានតោ ៗ
ទានញ្ច បិយវាចញ្ច　　អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ　　តត្ថ តត្ថ យថារហំ ៗ
ឯតេ ខោ សង្គហា លោកេ　　រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ　　ន មាតា បុត្តការណា
លភេថ មានំ បូជំ វា　　បិតា វា បុត្តការណា ៗ

ប្រព្រឹត្តខុសក្នុងមាតា នោះតែងទៅកើតក្នុងនរក ៗ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបំរើបិតាប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ៗ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាកព្រោះមិនបំរើមាតា ៗ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យតែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាកព្រោះមិនបំរើបិតា ៗ បណ្ឌិតបំរើមាតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វ ៗ កាល ៗ បណ្ឌិតបំរើបិតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វ ៗ កាល ៗ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើក្នុងជេដ្ឋាបចាយនធម៌នោះ ៗ តាមសមគួរ ១ ៗ សង្គហធម៌ទាំង ៤ នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្លៅនៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះមិនមានទេ មាតាមិនត្រូវបាននូវសេចក្តីរាប់អាននឹងការបូជា ព្រោះហេតុនៃកូន ទាំងបិតា ក៏មិនត្រូវបាននូវសេចក្តីរាប់អាននឹងការបូជា ព្រោះហេតុនៃកូន ៗ

យស្មា ច សង្គហា ឯតេ  សមវេក្ខន្តិ បណ្ឌិតា
តស្មា មហត្តំ បប្បោន្តិ  បាសំសា ច ភវន្តិ តេ ។
ព្រហ្មាតិ មាតាបិតរោ  បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ  បជាយ អនុកម្បកា ។
តស្មា ហិ នេ នមស្សេយ្យ  សក្ការេយ្យ ច បណ្ឌិតោ
អន្នេន អថោ បានេន  វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន  បាទានំ ធោវនេន ច ។
តាយ នំ បារិចរិយាយ  មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ  បេច្ច សគ្គេ បមោទតិ ។

សោណនន្ទជាតកំ ទុតិយំ ។

## តស្សុទ្ទានំ

អថ សត្តតិមម្ហិ និបាតវរេ
សភាវន្តុ កុសាវតិរាជវរោ
អថ សោណសុនន្ទវរោ ច បុន
អភិវាសិតសត្តតិមម្ហិ សុតេ ។

សត្តតិនិបាតំ និដ្ឋិតំ ។

ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំងនុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វគឺបុត្រ បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតទឹកការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបំរើ ចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

ចប់ សោណនន្ទជាតក ទី ២ ។

## ឧទ្ទាននៃសត្តតិនិបាតនោះ គឺ

រឿងព្រះរាជាប្រសើរក្នុងក្រុងកុសាវតី ក្នុងនិបាតដ៏ប្រសើរគំរប់ចិតសិប នឹងរឿងសោណតាបសនឹងនន្ទតាបសដ៏ប្រសើរក្នុងសូត្រគំរប់ចិតសិប ។

ចប់ សត្តតិនិបាត ។

# អសីតិនិបាតជាតកំ

## ចុល្លហំសជាតកំ

(១៦៣) សុមុខ អនុបចិនន្តា បក្កមន្តិ វិហង្គមា

គច្ឆ តុវម្បិ មា កង្ខិ នត្ថិ ពទ្ធេ សហាយតា ។

(១៦៤) គច្ឆេ វាហំ ន វា គច្ឆេ ន តេន អមរោ សិយំ

សុខិតន្តំ ឧបាសិត្វា ទុក្ខិតន្តំ កថំ ជហេ ។

មរណំ វា តយា សទ្ធឹ ជីវិតំ វា តយា វិនា

តទេវ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។

នេស ធម្មោ មហារាជ យន្តំ ឯវំ គតំ ជហេ

យា គតិ តុយ្ហំ សា មយ្ហំ រុច្ចតេ វិហគាធិប ។

# អសីតិនិបាតជាតក

## បុល្លហំសជាតក

(១៦៣) (រាជហង្សឈ្មោះធតរដ្ឋៈពោលថា) ម្នាលហង្សឈ្មោះសុមុខៈ ពួកបក្សីកាលមិនគយគន់មើល ហើរចេញទៅ អ្នកចូរទៅចុះ កុំប្រាថ្នា (នៅក្នុងទីនេះឡើយ ព្រោះថា) ភាពនៃអ្នកជាសំឡាញ់នឹងយើងដែលជាប់ចំណង មិនមានទេ ។

(១៦៤) (ហង្សសេនាបតីឈ្មោះសុមុខៈ ក្រាបបង្គំទូលថា) ទូលព្រះបង្គំជាខ្ញុំ ទៅក្តី មិនទៅក្តី ទូលព្រះបង្គំជាខ្ញុំមិនមែនមិនស្លាប់ដោយការទៅ ឬការមិនទៅនោះទេ ទូលព្រះបង្គំជាខ្ញុំបួលទៅរកព្រះអង្គដែលដល់នូវសេចក្តីសុខហើយ នឹងលះព្រះអង្គដែលដល់នូវសេចក្តីទុក្ខដូចម្តេចកើត ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី ការរស់នៅវៀរចាកព្រះអង្គក្តី សេចក្តីស្លាប់នោះប្រសើរជាងទូលព្រះបង្គំជាខ្ញុំ តែវៀរចាកព្រះអង្គហើយ រស់នៅមិនប្រសើរសោះឡើយ ។ បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំលះបោលព្រះអង្គដែលដល់ (នូវសេចក្តីទុក្ខ) យ៉ាងនេះ ដោយសភាវៈណា សភាវៈនោះមិនមែនជាធម៌ទេ បពិត្រព្រះអង្គជាធំលើបក្សី ដំណើរណា របស់ព្រះអង្គ ដំណើរនោះទូលព្រះបង្គំជាខ្ញុំ ក៏គាប់ចិត្តដែរ ។

(១៦៥) កាកុតា សេនពន្ធស្ស គតិ អញ្ញា មហានសា

សា កាជំ ចេតយានស្ស មុត្តស្ស តវ វុច្ចតិ ។

គាំ វត្តុំ បស្សសេ អត្តំ មម តុយ្ហញ្ច បក្ខិម

ញាតីនំ ការសិដ្ឋានំ ឧកិន្ន ជីវិតក្ខយេ ។

យន្ទ កាញ្ចនទ្វេបិច្ឆ អទ្ទេន តមសា កាតំ

តាទិសេ សញ្ចជំ ធាណាំ កិមត្តមកិ ជោតយេ ។

(១៦៦) កាជំ ទុ បគតំ សេដ្ឋ ធម្មេ អត្តំ ន ពុជ្ឈសិ

ធម្មោ អបចិតោ សន្តោ អត្តំ ទស្សេតិ ធាណិនំ ។

សោភាំ ធម្មំ អបេក្ខាតោ ធម្មា ធត្តំ សមុជ្ជិតំ

កតិញ្ច តយិ សម្បស្សំ នាវកាដ្ខាមិ ជីវិតំ ។

(១៦៥) (រាជហំស្រ...) ដំណើរដូចម្ដេចរបស់ខ្ញុំ ដែលជាប់អន្ទាក់ ហើយ ដាទៃអំពីភេទគ្រួ ដំណើរនោះ ទៅជាពេញចិត្តដល់អ្នកដែលមានប្រាជ្ញា ជាអ្នកផុតអំពីអន្ទាក់ដូចម្ដេច ៗ ម្នាលអ្នកជាបក្សី កាលបើយើងទាំងពីរនាក់អស់ជីវិតហើយ អ្នកឃើញនូវប្រយោជន៍ដូចម្ដេច របស់ខ្ញុំផង របស់អ្នកផង របស់ពួកញាតិដ៏សេសផង ៗ ម្នាលអ្នកមានស្លាបទាំងពីរដូចជាមាស ការលះបង់នូវជីវិតរបស់អ្នកណា ការលះបង់នូវជីវិតរបស់អ្នកនោះហាក់ដូចជាធ្វើក្នុងទីងងឹតដោយសេចក្ដីល្ងិតល្ងង់ អ្នកកាលលះបង់នូវជីវិត ព្រោះគុណដែលមិនជាក់ច្បាស់ដូច្នោះ តើព្រោះធ្លុះឃើញនូវប្រយោជន៍អ្វី ៗ

(១៦៦) (ហំស្រសេនាបតី...) បពិត្រព្រះអង្គដ៏ប្រសើរផុត ព្រះអង្គមិនជ្រាបនូវប្រយោជន៍ដែលធ្លាក់ចុះ ក្នុងធម៌ដូចម្ដេច ដ្បិតធម៌ដែលពួកសត្វគោរពហើយ រមែងបង្ហាញនូវសេចក្ដីចំរើន ដល់សត្វទាំងឡាយ ៗ ទូលព្រះបង្គំជាខ្ញុំនោះ កាលឃើញនូវធម៌ផង នូវប្រយោជន៍ដែលកើតអំពីធម៌ផង ពិចារណាឃើញនូវសេចក្ដីស្រឡាញ់ចំពោះព្រះអង្គផង បានជាមិនប្រាថ្នាជីវិតទេ ។

អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

អន្វាយ សោ សតំ ធម្មោ យោ មិត្តោ មិត្តមាបទេ
ន ចជេ ជីវិតស្សាបិ ហេតុ ធម្មមនុស្សរំ ។

(១៦៧) ស្វាយំ ធម្មោ ច តេ ចិណ្ណោ ភត្តិ ច វិទិតា មយិ
កាមំ ករស្សុ មយ្ហេតំ គច្ឆេវានុមតោ មយា ។

អបិត្វេវំ គតេ កាលេ យំ ខណ្ឌំ ញាតិនំ មយា
តយា តំ ពុទ្ធិសម្បន្ន អស្ស បរមសំវុតំ ។

(១៦៨) ឥច្ចេវំ មន្តយន្តានំ អរិយានំ អរិយវុត្តិនំ
បច្ចទិស្សថ នេសាទោ អាតុរានមិវន្តកោ ។

តេ សត្តុមភិសញ្ចិក្ខ ទីឃរត្តំ ហិតា ទិជា
តុណ្ហីមាសិត្ថ ឧភយោ ន សញ្ចលេសុមាសនា ។

មិត្តណា កាលពួកឃើញនូវធម៌ ហើយមិនលះបង់មិត្តក្នុងកាល ដែលមានសេចក្តីអន្តរាយ ព្រោះហេតុនៃជីវិត ធម៌របស់មិត្រនោះ ឈ្មោះថាជាធម៌របស់សប្បុរសទាំងឡាយដោយពិត ។

(១៦៧) (រាជហង្ស...) ធម៌នោះអ្នកបានសន្សំហើយ ទាំងសេចក្តីស្រឡាញ់ចំពោះយើង ៗ ក៏បានដឹងច្បាស់ហើយ អ្នកចូរធ្វើតាមសេចក្តីប្រាថ្នារបស់យើងនុ៎ះ អ្នកគឺយើងបានអនុញ្ញាតហើយ ចូរទៅចុះ ។ ម្នាលអ្នកបរិបូណ៌ដោយប្រាជ្ញា មួយទៀត ការបែកបាក់នៃពួកញាតិណា ដែលយើងបានបិទបាំងហើយ ក្នុងកាលដែលប្រព្រឹត្តទៅយ៉ាងនេះ ការបែកបាក់នៃពួកញាតិនោះ អ្នកគួរបិទបាំងទុកឲ្យល្អចុះ ។

(១៦៨) (អភិសម្ពុទ្ធគាថា) កាលដែលអរិយហង្សទាំងឡាយ ជាសត្វមានការប្រព្រឹត្តដ៏ប្រសើរ កំពុងតែប្រឹក្សាគ្នាយ៉ាងនេះ ស្រាប់តែនាយនេសាទ មកប្រាកដដូចជាសេចក្តីស្លាប់ ដែលប្រាកដដល់បុគ្គលឈឺ ។ ហង្សទាំងពីរនោះ មានប្រយោជន៍ (ដល់គ្នានឹងគ្នា) យូរអង្វែងហើយ បានឃើញច្បាស់នូវសត្រូវ ក៏ទំនៅស្ងៀមទាំងពីរនាក់ មិនគក្រើក ចាកទ្រនំឡើយ ។

ឧតុវេជ្ជ ច និស្សាយ   សម្បត្តេ កាលេ កាលេ
អតិក្កមថ វេគេន   និជសត្តុ និជាធិបេ ។
សោ ច វេគេនតិក្កម្ម   អាសជ្ជ បរមេ និជេ
បច្ចាមិត្តេ នេសានោ   ពន្ធា ឥតិ វិចិន្តយំ ។
ឯកកញ្ចុ ពន្ធមាសីនំ   អពន្ធញ្ចុ វុដ្ឋាបរំ
អាសជ្ជ ពន្ធមាសីនំ   បេក្ខមានមទីនវំ ។
តតោ សោ វិមតោយេវ   បណ្ឌារេ អជ្ឈកាសថ
បវុទ្ធកាយេ អាសីនេ   និជសង្ឃគណាធិបេ
យន្តុ ឆាទេន មហតា   ពន្ធោ ន កុព្វេត និសំ
អថ កស្មា អពន្ធោ ត្វំ   ពលី បក្ខី ន គច្ឆសិ ។
កឹន្នុ ត្យាយំ និជោ ហោតិ   មុត្តោ ពន្ធំ ឧបាសសិ
ឱហាយ សកុណា យន្តិ   កឹ ឯកោ អវហីយសិ ។
(១៦៩) កថាមេ សោ និជាមិត្ត   សខា ញាណសមោ ច មេ

ព្រានព្រៃជាសត្រូវនៃសត្វស្លាប បានឃើញហង្សឈ្មោះសុមុខៈ នឹងរាជហង្សឈ្មោះធតរដ្ឋៈជាស្តេចនៃបក្សីកាលខិតចូលមករកគ្នា អំពីទីនោះ ៗ ក៏ស្ទុះទៅដោយប្រញាប់ៗ លុះនាយនេសាទនោះ ស្ទុះដោយប្រញាប់ទៅជិតពួកបក្សីប្រសើរហើយ ក៏គិតថា សត្វហង្សទាំងពីរនេះជាប់ហើយ ញាប់ញ័រៗក៏នាយនេសាទបានឃើញ សត្វហង្សមួយ ជាប់អន្ទាក់ហើយទំនៅ នឹងសត្វហង្សមួយទៀត ដែលមិនជាប់អន្ទាក់ ចូលមករកសត្វហង្សដែលជាប់អន្ទាក់ហើយ ទំនៅ សំឡឹងមើលនូវហង្សដែលមានទោស ៗ លំជាប់អំពី នោះទៅ នាយនេសាទនោះមានសេចក្តីសង្ស័យ ក៏បានសួរនូវ សត្វហង្សមានពណ៌ស មានកាយដ៏ធំ ជាអធិបតីលើហ្វូងនៃបក្សី ថា សត្វហង្សដែលជាប់អន្ទាក់ដ៏ធំដល់ម៉្លោះ មិនធ្វើនូវទិស (ដើម្បីហើរទៅ ) ដោយហេតុណា (ហេតុនោះគួរហើយ ) ម្នាល សត្វស្លាប ចុះអ្នកមិនជាប់អន្ទាក់ទេ ជាសត្វមានកំឡាំង ហេតុអ្វីក៏មិនហើរទៅ ៗ សត្វបក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នករួច (អំពីអន្ទាក់ហើយ) ចូលមករកបក្សីដែលជាប់អន្ទាក់វិញ បក្សីទាំងឡាយ នាំគ្នាហើរចោលទៅអស់ហើយ ថ្វីក៏អ្នកក្រាញនៅតែម្នាក់ឯង ៗ

[១៦៩](ហង្សសេនាបតី...) បពិត្រនាយនេសាទជាសត្រូវនៃសត្វបក្សី ឯហង្សនោះជាព្រះរាជានៃខ្ញុំផង ជាសំឡាញ់ស្មើដោយជីវិតនៃខ្ញុំផង

## អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

នេវ នំ វិជហិស្សាមិ  យាវ កាលបរិយាយំ (១) ។

[១៧០] កាជំ បណយំ វិហង្គោ  ពទ្ធស្ស បាសមោឌ្ឌិតំ

បទំ ហោតិ មហន្តានំ  ពោទ្ធុមរហតិ អាបទំ ។

[១៧១] យទា បរាភវោ ហោតិ  បោសោ ជីវិតសង្ខយេ

អថ ជាលញ្ច បាសញ្ច  អាសជ្ជាបិ ន បុជ្ឈតិ ។

[១៧២] អបិ ត្វេវ មហាបញ្ញ  បាសា ពហុវិធា តតា

គុយ្ហមាសជ្ជ ពជ្ឈន្តិ  អថេវំ ជីវិតក្ខយេ ។

[១៧៣] អបិ នាយំ តយា សទ្ធិំ  សំវាសស្ស សុខុទ្រយោ

អបិ នោ អនុមញ្ញាសិ  អបិ នោ ជីវិតំ ទទេ ។

[១៧៤] ន ចេវ មេ ត្វំ ពទ្ធាសិ  នបិ ឥច្ឆាមិ តេ វធំ

កាមំ ខិប្បមិតោ គន្ត្វា  ជីវ ត្វំ អនិឃោ ចិរំ ។

---

១ ឱ. យាវ កាលស្ស បរិយាយំ ។

ខ្ញុំនឹងមិនលះបង់នូវហង្សនោះ ដរាបដល់សេចក្ដីស្លាប់មកដល់ ។

(១៧០) (នាយនេសាទ...) ចុះហេតុអ្វី ហង្សនេះ ក៏មិនឃើញនូវអន្ទាក់ដែលគេដាក់ហើយ ដំណើរនេះហើយ ដែលជាដំណើរសម្រាប់ពួកសត្វធំ ៗ ពួកសត្វធំ ៗ គួរដឹងនូវសេចក្ដីអន្តរាយ ។

(១៧១) (ហង្សសេនាបតី...) កាលណា ដែលសត្វជាអ្នកមានសេចក្ដីវិនាស ក្នុងកាលជាទីអស់ទៅនៃជីវិត កាលនោះ សត្វនោះ សូម្បីបូលមកជិតដល់សំណាញ់នឹងអន្ទាក់ ក៏នៅតែមិនដឹងឡើយ ។

(១៧២) (នាយនេសាទ...) ម្នាលសត្វមានប្រាជ្ញាច្រើន មែនហើយ អន្ទាក់ទាំងឡាយ យើងបានដាក់ហើយជាច្រើន កាលបើសត្វមានជីវិតអស់ទៅយ៉ាងនេះ សត្វស្លាបទាំងឡាយ តែងបូលមកជាប់នឹងអន្ទាក់ដ៏កំបាំង ។

(១៧៣) (ហង្សសេនាបតី...) សូមឲ្យការនៅរួមជាមួយនឹងអ្នកនេះមានសុខជាកម្រៃ សូមអ្នកអនុញ្ញាតយើងខ្ញុំ សូមអ្នកឲ្យជីវិតដល់យើងខ្ញុំ ។

(១៧៤) (នាយនេសាទ...) ឯងមិនជាប់ (អន្ទាក់)អញទេ ទាំងអញទៀតសោត ក៏មិនប្រាថ្នាសម្លាប់ឯងដែរ ចូរឯងទៅអំពីទីនេះតាមប្រាថ្នាយ៉ាងឆាប់ ហើយរស់នៅមិនមានទុក្ខ អស់កាលជាអង្វែងចុះ ។

(១៧៨) នេហាហមេតមិច្ឆាមិ អញ្ញត្រ តស្ស ជីវិតា

សចេ ឃាតេន តុណ្ហាសិ មុញ្ចេតំ មញ្ចុ កត្វាយ ។

អាពេហាបរិណាហេន តុល្យស្សាវយសា ឧភោ

ន តេ លោកេន ជិនត្ថិ ឃាតេន និមិនា តុវំ ។

តធិស្ស សមបេក្ខស្សុ ហោតុ តិទ្ធិ តវស្សុសុ (១)

មំ បុត្តំ ពន្ធ ទាសេន បញ្ញា មុញ្ច និជានិបំ ។

តាវ ទេវ ច តេ លោកោ កាតស្ស យាចនាយ ច

មិត្តិ ច នតរដ្ឋេហិ យាវជីវាយ តេសិយា ។

(១៧៩) បស្សន្តុ នោ មហាសង្ឃា តយា មុត្តំ វតោ តតំ

មិត្តាមច្ចា ច ភច្ចា ច បុត្តទារា ច ពន្ធវា ។

ន ច តេ តាទិសា មិត្តា ពហុំ វន វិជ្ជរេ (២)

យថា ត្វំ នតរដ្ឋស្ស ទាណសាធារណោសខា ។

---

១ ម. តវម្ហេសុ ។ ២ ឱ.ម. វិជ្ជតិ ។

[១៧៥] (ហង្សសេនាបតី...) ខ្ញុំប្រាសចាកជីវិតនៃបក្សីនោះហើយ មិនប្រាថ្នាជីវិតទេ ។ បើអ្នកត្រេកអរដោយហង្សមួយ ចូរអ្នកលែងនូវហង្សនេះទៅ ចូរបរិភោគនូវខ្ញុំវិញចុះ ។ យើងទាំងពីរអ្នកនោះ មានកំពស់ ទំហំនិងវ័យស្មើ ៗ គ្នា អ្នកមិនមែនសាបសូន្យចាកលាភទេ សូមអ្នកប្តូរយកខ្ញុំដោយហង្សនេះ ។ ចូរអ្នកសង្កេតមើលដំណើរនេះចុះ សេចក្តីជាប់ចិត្តរបស់អ្នកចំពោះយើងទាំងឡាយ សូមលើកទុកសិន ចូរអ្នកយកអន្ទាក់ចងខ្ញុំមុនសិនចុះ រួចសឹមលែងស្តេចបក្សីជាខាងក្រោយ ។ លាភរបស់អ្នកក៏នៅដដែលផង សេចក្តីអង្វរនេះក៏ឈ្មោះថា អ្នកបានធ្វើតាមផង សេចក្តីរាប់អានដោយរាជហង្សឈ្មោះធតរដ្ឋៈ គប្បីមានដល់អ្នក ដរាបដល់អស់ជីវិតផង ។

[១៧៦] (នាយនេសាទ...) ពួកសត្វបក្សីជាច្រើន ដែលជាមិត្រ អាមាត្យក្តី មាតាបិតាក្តី កូនប្រពន្ធក្តី ជាផៅពង្សក្តី ចូរបួបនូវរាជហង្សនេះ ដែលរួចហើយ ព្រោះអ្នកហើរទៅអំពីទីនេះ ។ ពួកមិត្ររបស់ពួកសត្វដទៃជាច្រើន ដែលប្រហែលគ្នានឹងមិត្ររបស់អ្នក ដូចអ្នកជាសំឡាញ់ស្មើជីវិត នឹងរាជហង្សឈ្មោះធតរដ្ឋៈនេះ មិនមានក្នុងទីនេះទេ ។

## អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

សោ តេ សហាយំ មុញ្ចាមិ ហោតុ រាជា តវានុគោ
កាមំ ខិប្បមិតោ គន្ត្វា ញាតិមជ្ឈេ វិរោចថ ។

(១៧៧) សោ បតីតោ បមុត្តេន ភត្តុនា ភត្តុគារវោ
អជ្ឈភាសថ វក្កង្គោ វាចំ កណ្ណសុខំ ភណំ
ឯវំ លុទ្ទក នន្ទស្សុ សហ សព្វេហិ ញាតិភិ
យថាហមជ្ជ នន្ទាមិ មុត្តំ ទិស្វា ទិជាធិបំ ។

(១៧៨) ឯហិ តំ អនុសិក្ខាមិ យថា ត្វមបិ លច្ឆសេ
លាភំ តវាយំ[១] ធតរដ្ឋោ បាបំ កិញ្ចិ ន ទក្ខតិ ។
ខិប្បមន្តេបុរំ គន្ត្វា រញ្ញោ ទស្សេហិ នោ ឧភោ
អពទ្ធេ បកតីភូតេ កាជេ ឧភយតោ ឋិតេ ។
ធតរដ្ឋា មហារាជ ហំសាធិបតិនោ ឥមេ
អយំ ហិ រាជា ហំសានំ អយំ សេនាបតីតរោ ។

---

១ ឱ. យថាយំ ។

ខ្ញុំនោះបានលែងនូវរាជហង្សជាសំឡាញ់របស់អ្នក ព្រះរាជារបស់អ្នកចូរទៅតាមអ្នកចុះ អ្នកទាំងឡាយ ចូរហើរទៅអំពីទីនេះតាមប្រាថ្នាជាឆាប់ ហើយរុងរឿងក្នុងកណ្ដាលពួកញាតិចុះ ។

(១៧៧) (អភិសម្ពុទ្ធគាថា) ហង្សឈ្មោះសុមុខៈនោះ មានចិត្តត្រេកអរ ព្រោះម្ចាស់ផុតចាកបំណង ជាសត្វគោរពម្ចាស់ កាលពោលនូវវាចាដ៏ស្រួលដល់ត្រចៀក ទើបពោលថា បពិត្រនាយនេសាទ យើងត្រេកអរព្រោះបានឃើញនូវស្ដេចបក្សី ដែលរួចចាកអន្ទាក់ក្នុងថ្ងៃនេះ យ៉ាងណា លោកចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះចុះ ។

(១៧៨) លោកចូរមកនេះ ខ្ញុំប្រៀនប្រដៅលោកឲ្យបានលាភ រាជហង្សឈ្មោះធតរដ្ឋៈនេះ ឥតឃើញសេចក្ដីអាក្រក់ របស់លោកតិចតួចទេ ។ លោកចូរ(នាំយើងខ្ញុំ)ទៅក្នុងរាជបុរីជាឆាប់ ហើយបង្ហាញចំពោះព្រះរាជា នូវយើងខ្ញុំទាំងពីរនាក់ដែលមិនជាប់ចំណង មានសភាពជាប្រក្រតីឋិតនៅលើអង្រែកទាំងពីរខាង ។ (លោកក្រាបទូលថា) បពិត្រមហារាជ ហង្សទាំងពីរនេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។

អសំសយំ ឥមំ ទិស្វា ហំសរាជំ ធរាជិតោ

បតិតោ សុមុខោ វិត្តោ ពហុំ ឥស្សរិតេ ធនំ ។

(១៧៩) តស្ស តំ វចនំ សុត្វា កម្មុនា ឧបបាទយិ

ខិប្បមេទ្ធុរំ តត្ថ រញ្ញោ ហំសេ អទស្សយិ

អពទ្ធេ បកតីភូតេ កាជេ ឧភយតោ ឋិតេ ។

ធតរដ្ឋ មហារាជ ហំសាធិបតិនោ ឥមេ

អយំ ហិ រាជា ហំសានំ អយំ សេនាបតីតរោ ។

(១៨០) កថំ បនិមេ វិហង្គា តវ ហត្ថត្តមាគតា

កថំ លុទ្ទោ មហន្តានំ ឥស្សរេ ឥធ អជ្ឈគា ។

(១៨១) វិហិតា សន្តិមេ បាសា បល្លលេសុ ជនាធិប

យំ យទាយតនំ មញ្ញេ ទិជានំ បាណរោធនំ ។

ព្រះរាជាជាអធិបតីលើពួកជន ទ្រង់បានទតឃើញរាជហង្សនេះហើយ មុខជាទ្រង់មានព្រះរាជហឫទ័យត្រេកអរកាយ នឹងប្រទានទ្រព្យជាច្រើនដល់អ្នក ឥតសង្ស័យ ។

(១៧៩) នាយនេសាទ លុះបានស្តាប់ពាក្យហង្សឈ្មោះសុមុខៈនោះហើយ ក៏បង្ហើយកិច្ចការ រួច ( នាំហង្សទាំងពីរ ) ទៅខាងក្នុងបុរីយ៉ាងឆាប់ ហើយបង្ហាញចំពោះព្រះរាជានូវហង្សទាំងពីរ ដែលមិនជាប់អន្ទាក់ មានសភាពតាមប្រក្រតី ឋិតនៅលើអម្រែកទាំងពីរខាងថា បពិត្រមហារាជ ហង្សទាំងពីរនេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះ ជាសេនាបតី ។

(១៨០)(ព្រះរាជា...)ហង្សទាំងនេះ មកឋិតនៅក្នុងកណ្តាប់ដៃរបស់អ្នក តើដោយហេតុដូចម្តេច អ្នកជានាយព្រាន បានដល់នូវភាពជាធំជាងសត្វហង្សដ៏ធំ ៗ ទាំងឡាយក្នុងទីនេះ ដោយហេតុដូចម្តេច ។

(១៨១) ( ព្រានព្រៃ... ) បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំស្គាល់នូវកន្លែងជាទីប្រជុំនៃពួកសត្វស្លាបណា ៗ ជាទីធ្វើឲ្យអស់ទៅនៃជីវិត នៃពួកសត្វស្លាប ទូលព្រះបង្គំជាខ្ញុំបានដាក់អន្ទាក់ទាំងនេះលើកក់ទាំងឡាយ ( ក្នុងកន្លែងនោះ ៗ ) ។

អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

តាទិសំ ភាសមានស្ស ហំសរាជា អតជ្ឈប
ធំ អតេន្ត្រោ ឧបាសីនោ មមាយំ អជ្ឈភាសថ ។
សុទុត្តរំ អនរិយេហិ ទហតេ ភាវមុត្តមំ
ភត្តុរត្ថេ បរក្កន្តោ ធម្មយុត្តោ វិហង្គមោ ។
អត្តនោយំ ចជិត្វាន ជីវិតំ ជីវិតារហោ
អនុត្ថុនន្តោ អាសីនោ ភត្តុ យាចិត្ថ ជីវិតំ ។
តស្ស តំ វចនំ សុត្វា បសាទមហអជ្ឈគា
តតោ នំ បាមុចី បាសា អនុញ្ញាសិ សុខេន ច ។
សោ បតីតោ បមុត្តេន ភត្តុនា ភត្តុគារវោ
អជ្ឈភាសថ វក្កង្គោ វាចំ កណ្ណសុខំ ភណំ ។
ឯវំ លុទ្ទក នន្ទស្សុ សហ សព្វេហិ ញាតិភិ
យថាហមជ្ជ នន្ទាមិ មុត្តំ ទិស្វា ទិជាធិបំ ។
ឯហិ តំ អនុសិក្ខាមិ យថា ត្វមបិ លច្ឆសេ
លាភំ ត្យាយំ ធតរដ្ឋោ បាបំ កិញ្ចិ ន ទក្ខិតិ ។

រាជហង្សបានមកជាប់អន្ទាក់ប្រាកដដូច្នោះ ចំណែកហង្សជាសេនា-បតីនេះ មិនជាប់អន្ទាក់ទេ តែចូលទៅទំជិតនឹងរាជហង្សនោះ ហើយបាននិយាយនឹងទូលព្រះបង្គំជាខ្ញុំ ៗ ហង្សជាសេនាបតីនេះ ( បានធ្វើ) នូវអំពើដែលពួកជនមិនមែនជាអរិយៈធ្វើបានដោយក្រ ជាសត្វប្រកបដោយធម៌ សង្ហាតក្កុនប្រយោជន៍ របស់ម្ចាស់ បានប្រកាសនូវភាពនៃខ្លួនជាសត្វដ៏ឧត្តម ៗ ហង្សជាសេនាបតីនេះ ជាសត្វគួរនឹងរស់នៅ តែស៊ូលះបង់នូវជីវិតនៃខ្លួន កាលសរសើរ(នូវគុណនៃម្ចាស់)ហើយទំនៅ បានសុំនូវជីវិតម្ចាស់ ៗ ទូលព្រះបង្គំជាខ្ញុំបានស្ដាប់ពាក្យនោះ របស់ហង្សសេនាបតីនោះ ហើយ ទើបដល់នូវសេចក្ដីជ្រះថ្លា លំដាប់នោះ ទូលព្រះបង្គំ បានដោះរាជហង្សនោះចាកអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយស្រួល ៗ ហង្សជាសេនាបតីនោះ ក៏មានចិត្តរីករាយ ព្រោះម្ចាស់បានរួចហើយ ជាសត្វគោរពម្ចាស់ កាលនឹងពោលវាចាដ៏ស្រួលដល់ត្រចៀក បានពោលយ៉ាងនេះថា បពិត្រព្រានព្រៃ ថ្ងៃនេះខ្ញុំរីករាយ ព្រោះបានឃើញស្ដេចបក្សីដែលរួចហើយយ៉ាងណា សូមឲ្យលោករីករាយ ជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះ ៗ លោកចូរមកនេះ ខ្ញុំនឹងប្រៀនប្រដៅឲ្យបាននូវលាភ រាជហង្សឈ្មោះធតរដ្ឋៈនេះ ឥតឃើញសេចក្ដីអាក្រក់តិចតួចរបស់លោកទេ ៗ

ទិប្បមន្តេបុរំ គន្ត្វា     រញ្ញោ ឧស្សាហិតោ ឧភោ

អតន្ទេ បគតីភូតេ     កាលេ ឧភយតោ ឋិតេ ។

ធតរដ្ឋា មហារាជ     ហំសាធិបតិនោ សហ

អយញ្ហិ រាជា ហំសានំ អយំ សេនាបតីតរោ ។

អសំសយំ ឥមំ ទិស្វា     ហំសរាជំ នរាធិបោ

បតីតោ សុមនោ វិត្តោ     ពហុំ ទស្សតិ តេ ធនំ ។

ឃរមេតស្ស វចនា     អាជីតាមេ ឧភោ មយោ

ឃត្វា ហិ ឥមេ អស្សុ     ឧភោ អនុមតា មយោ ។

សោយំ ឃរត្តោ បត្តិ     ទិជោ បរមធម្មិកោ

មាទិសស្ស ហិ លុទ្ទស្ស     ជនយេយ្យាថ មន្ទុំ ។

ឧបយានញ្ច តេ ទេវ     នាញ្ញំ បស្សាមិ ឯទិសំ

សព្វសាកុណិកគាមេ     តំ បស្ស មនុជាធិប ។

លោកបូរនាំយើងខ្ញុំទៅក្នុងបុរីជាដាប់ ហើយបង្ហាញព្រះរាជានូវយើងខ្ញុំទាំងពីរនាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតីឋិតនៅលើអម្រែកទាំងពីរខាង ។ (លោកក្រាបទូលថា) បពិត្រមហារាជ ហង្សទាំងនេះ កើតនៅក្នុងត្រកូលធតរដ្ឋៈជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។ ព្រះរាជាជាធំលើពួកជនបានទតឃើញរាជហង្សនេះហើយ មុខជានឹងមានព្រះទ័យត្រេកអរសោមនស្សរីករាយ នឹងព្រះរាជទាននូវទ្រព្យដ៏ច្រើន ដល់លោកដោយពិត ។ ទូលព្រះបង្គំជាខ្ញុំ បាននាំហង្សទាំងពីរនេះមក តាមពាក្យហង្សជាសេនាបតីនេះយ៉ាងនេះ ព្រោះថា ទូលព្រះបង្គំជាខ្ញុំបានបើកលែងហង្សទាំងពីរនេះ ក្នុងទីនោះរួចទៅហើយ ។ សត្វបក្សីនោះជាទិជាត មានដំណើរយ៉ាងនេះ ប្រកបដោយធម៌ដ៏ក្រៃលែង ព្រោះថា សត្វបក្សីនោះបានញុំាងចិត្តដ៏ទន់ឲ្យកើតដល់ព្រានព្រៃប្រាកដដូចជាទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ មិនឃើញដង្វាយដទៃ ក្នុងស្រុកនៃព្រានបក្សីដ៏សមគួរដល់ព្រះអង្គឡើយ បពិត្រព្រះអង្គជាធំជាងពួកមនុស្ស សូមព្រះអង្គទតមើលនូវដង្វាយនោះ ។

## អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

(១៨២) ទិស្វា និសិន្នំ រាជានំ ពីឋេ សោវណ្ណមយេ សុភេ
អជ្ឈភាសថ វក្កង្គោ វាចំ កណ្ណសុខំ ភណំ ។
កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ រដ្ឋមិទំ ផីតំ ធម្មេន មនុសាសសិ ។ (១)

(១៨៣) កុសលញ្ចេវ មេ ហំស អថោ ហំស អនាមយំ
អថោ រដ្ឋមិទំ ផីតំ ធម្មេន មនុសាសហំ ។

(១៨៤) កច្ចិ ភោតោ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ
កច្ចិ ច តេ តវត្ថេសុ នាវកង្ខន្តិ ជីវិតំ ។

(១៨៥) អថោបិ មេ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ
អថោបិ តេ មមត្ថេសុ នាវកង្ខន្តិ ជីវិតំ ។

(១៨៦) កច្ចិ តេ សាទិសី ភរិយា អស្សវា បិយភាណិនី
បុត្តរូបយសូបេតា តវ ឆន្ទវសានុគា

---

១ ឱ. មនុសេស្សតិ ។

(១៨២) រាជហង្សបានឃើញព្រះរាជា ទ្រង់គង់នៅលើតាំងជាវិការៈនៃមាសដ៏ស្អាត កាលនឹងពោលនូវវាចាឲ្យស្រួលដល់ត្រចៀក បានពោលថា ព្រះអង្គបានសេចក្ដីសុខស្រួលទេឬ ព្រះអង្គមិនមានជម្ងឺអ្វីទេឬ មួយទៀត ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ដែរឬ ។

(១៨៣) (ព្រះរាជា...) ម្នាលហង្ស យើងមានសេចក្ដីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជម្ងឺអ្វីទេ ម្យ៉ាងទៀត យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ហើយ ។

(១៨៤) (រាជហង្ស...) កំហុសបន្តិចបន្តួចរបស់ព្រះអង្គមិនមានក្នុងពួកអាមាត្យទេឬ ពួកអាមាត្យទាំងនោះ មិនអាល័យជីវិតព្រោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ ។

(១៨៥) (ព្រះរាជា...) កំហុសបន្តិចបន្តួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យជីវិតព្រោះប្រយោជន៍ទាំងឡាយរបស់យើងទេ ។

(១៨៦) (រាជហង្ស...) អគ្គមហេសីរបស់ព្រះអង្គដែលមានជាតិស្មើគ្នា ជាស្រីស្ដាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្រ រូបនិងយស លុះអំណាចសេចក្ដីប្រាថ្នារបស់ព្រះអង្គដែរឬ ។

(១៨៧) អថោ មេ សាទិសី ភរិយា អស្សវា បិយភាណិនី
បុត្តរូបយសូបេតា មម ឆន្ទវសានុគា ។

(១៨៨) ភវន្តុ(១) កច្ចិ នុ មហា- សត្តុហត្ថត្តំ គតោ
ទុក្ខមាបជ្ជ វិបុលំ តស្មិំ បឋមមាបទេ ។
កច្ចិ យន្តាបតិត្វាន ឧញ្ឆោន សមភោជយិ
ឋវមេតេសំ ជម្មានំ ឆាតិកំ ភវតិ តាវទេ ។

(១៨៩) ខេមមាសិ មហារាជ ឋវមាបរិយាសតិ
ន ហយំ កិញ្ចិវស្មាសុ សត្តូវ សមបជ្ជថ ។
បច្ចាមិត្ត នេសានោ បុព្វេ អជ្ឈកាសថ
តទាយំ សុមុខោ យេវ បណ្ឌិតោ បច្ចភាសថ ។
តស្ស តំ វចនំ សុត្វា បសាទមយមជ្ឈគា
តតោ មំ ឆាមុចិ ឆាសា អនុញ្ញាសិ សុខេន ច ។
ឥទញ្ច សុមុខេនេវ ឯតទត្ថាយ ចិន្តិតំ
ភោតោ សកាសេ អាគមនំ ឯតស្ស ធនមិច្ឆតា ។

---

១ ឱ. ភវន្តុ ។ ម. ភវន្តំ ។

(១៨៧) ( ព្រះរាជា... ) អគ្គមហេសីរបស់យើងដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្រ រូប និងយស លុះអំណាចសេចក្តីប្រាថ្នារបស់យើងៗ

(១៨៨) អ្នកដ៏ចំរើន លុះក្នុងកណ្តាប់ដៃសត្រូវដ៏ធំ ដល់នូវសេចក្តីទុក្ខដ៏ធំ ក្នុងអន្តរាយទីមួយនោះដែរឬ ។ ព្រានព្រៃបានស្ទុះចូលទៅសំពងអ្នកដោយដំបងដែរឬ ដ្បិតអំពើយ៉ាងនេះ តែងមានជាធម្មតា ដល់ពួកអ្នកធ្វើអំពើអាក្រក់ ក្នុងខណៈនោះ ។

(១៨៩) (រាជហង្ស...) បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំបានសេចក្តីក្សេមក្សាន្តទេ កាលបើមានហេតុយ៉ាងនេះ ព្រានព្រៃនេះ មិនដល់ ( នូវភាពនៃខ្លួន ) ដូចជាសត្រូវចំពោះទូលព្រះបង្គំជាខ្ញុំតិចតួចឡើយ ។ ព្រានព្រៃនេះ ថយបន្តិច ៗ ក៏បានសាកសួរទូលព្រះបង្គំជាមុន គ្រានោះ ហង្សឈ្មោះសុមុខៈ ជាបណ្ឌិតបាននិយាយតបវិញ ។ ព្រានព្រៃបានស្តាប់ពាក្យហង្សឈ្មោះសុមុខៈនោះហើយ ក៏បានដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះព្រានព្រៃបានដោះទូលព្រះបង្គំជាខ្ញុំអំពីអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយស្រួលផង ។ ដំណើរមកក្នុងសំណាក់នៃព្រះអង្គនេះគឺហង្សឈ្មោះសុមុខៈចង់បានទ្រព្យដល់ព្រានព្រៃនុ៎ះ បានគិតហើយដើម្បីប្រយោជន៍ដល់ព្រានព្រៃនុ៎ះ ។

## អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

(១៩០) ស្វាគតញ្ញេវិទំ ភវតំ បតីតោ ចស្មិ ទស្សនា

ឯសោ ចាបិ ពហុវិត្តោ លភតំ យាវទិច្ឆតិ ។

(១៩១) សន្តប្បយិត្វា នេសាទំ ភោគេហិ មនុជាធិបោ

អជ្ឈភាសថ វក្កង្គំ វាចំ កណ្ណសុខំ ភណំ

(១៩២) យំ ខលុ ធម្មមាធីនំ វសោ វត្តតិ កិញ្ចនំ

សព្វត្ថិស្សរិយំ ភវតំ បសាសថ យទិច្ឆថ ។

ទានត្ថំ ឧបភោត្តុំ វា យញ្ចញ្ញំ ឧបកប្បតិ

ឯតំ ទទាមិ វោ វិត្តំ ឥស្សរិយំ វិស្សជាមិ វោ ។

(១៩៣) យថា ច ម្យាយំ សុមុខោ អជ្ឈភាសេយ្យ បណ្ឌិតោ

កាមសា ពុទ្ធិសម្បន្នោ តមស្ស បរមប្បិយំ ។

(១៩៤) អហំ ខលុ មហារាជ នាគរាជារិវន្តរំ

បដិវត្តុំ ន សក្កោមិ ន មេ សោ វិនយោ សិយា ។

[១៩០] (ព្រះរាជា...) ដំណើរមករបស់អ្នកដ៏ចំរើនទាំងឡាយ ជាការស្រួលណាស់ហើយ យើងមានចិត្តត្រេកអរព្រោះការបានឃើញអ្នកឯព្រានព្រៃនេះ ចូរបានទ្រព្យជាច្រើនដរាបទល់អស់បំណងចុះ ។

[១៩១] (អភិសម្ពុទ្ធគាថា) ព្រះរាជាជាធំជាងមនុស្ស បានញុំាងនាយនេសាទឱ្យឆ្អែតស្កប់ស្កល់ដោយភោគៈតាមដំណើរដែលសត្វបក្សីហង្សនិយាយនូវពាក្យដ៏សុខស្រួលដល់គ្នាទៀត បានពោលហើយ ។

[១៩២](ព្រះរាជា...)អំណាច (របស់យើង) ប្រព្រឹត្តទៅអស់ទីជាទីទ្រង់ទុកនូវធម៌ (ច្បាប់) ណា អ្នកដ៏ចំរើនចូរជាធំក្នុងទីទាំងអស់នោះ សូម្បីតិចតួច ចូរគ្រប់គ្រងនូវទីជាទីប្រាថ្នាចុះ ។ ម្យ៉ាងទៀត ទ្រព្យណាដទៃអាចសម្រេចដើម្បីនឹងឱ្យទាន ឬជាគ្រឿងប្រើប្រាស់ យើងឱ្យនូវទ្រព្យនោះដល់អ្នក យើងនឹងលះនូវភាវៈជាធំដល់អ្នក ។

[១៩៣] ប្រសិនបើហង្សឈ្មោះសុមុខៈ ជាបណ្ឌិតបរិបូណ៌ដោយប្រាជ្ញានេះ ពោលនូវពាក្យដល់យើងតាមសេចក្តីប្រាថ្នា ពាក្យនោះជាទីស្រឡាញ់របស់យើងក្រៃពេក ។

[១៩៤] (ហង្សសេនាបតី...) បពិត្រព្រះមហារាជ ទូលព្រះបង្គំជាខ្ញុំ ដូចជានាគរាជ (ចូលទៅ) កាន់ចន្លោះ (នៃភ្នំ) មិនអាចនឹងក្រាបទូលតបបានទេ ដ្បិតការក្រាបទូលតបនោះមិនមែនជាច្បាប់ សម្រាប់ទូលព្រះបង្គំ ជាខ្ញុំឡើយ ។

អញ្ញាតះ ចេវ សោ សេដ្ឋោ ភុត្វា ឧត្តមសត្តវោ

កុម្មិឆាលោ មនុស្សិន្ទោ ហុត្វា ពហូហិ ហេតុភិ ។

តេសំ ឧភិន្នំ ភណាតំ វត្តមានេ វិនិច្ឆយេ

នន្ទិំ បដិវត្តត្វា បោសេស្សន មនុជាធិប ។

(១៩៥)ធម្មេន កិរះ នេសាទោ បណ្ឌិតោ អណ្ឌជោ ឥតិ

ន ហេវ អកតត្តស្ស នយោ ឯតាទិសោ សិយា ។

ឯវំ អក្តបកតិមា ឯវំ ឧត្តមសត្តវោ

យាវតត្ថមយា ទិដ្ឋា នាញ្ញំ បស្សាមិ ឯទិសំ ។

តុដ្ឋាស្មិ វោ បកតិយា វាក្យេន មទុវេន ច

ឯសោ ចាបិ មមច្ឆន្ទោ(១) ចិរំ បស្សេយ្យ វោ ឧភោ ។

(១៩៦)យំ កិញ្ចិ បរមេ មិត្តេ កតមស្មាសុ តំ តយា

បត្តា និស្សំសយំ ត្យម្ហា ភត្តិរស្មាសុ យា តវ ។

---

១ ឱ. យំ កិញ្ចិ ។

រាជហង្សប្រសើរបំផុតជាងពួកទូលព្រះបង្គំជាខ្ញុំនោះផង ព្រះអង្គ ជាសត្វដ៏ឧត្តមក្រៃលែងជាងជនមនុស្សផង គួរទូលព្រះបង្គំជាខ្ញុំ បូជាដោយហេតុដ៏ច្រើនៗ បពិត្រព្រះអង្គជាធំជាងមនុស្ស កាល ដែលការវិនិច្ឆ័យ កំពុងប្រព្រឹត្តទៅ អាមាត្យជាអ្នកបំរើមិនគប្បីក្រាប ទូលក្នុងចន្លោះនៃព្រះអង្គទាំងពីរកំពុងមានព្រះបន្ទូលនោះឡើយៗ

[១៩៥] (ព្រះរាជា...) បានឮថា នាយព្រាន បានសរសើរអ្នក ដោយធម៌ថា អ្នកជាបក្សីបណ្ឌិត ព្រោះថាបែបនេះមិនគប្បីមាន ដល់សត្វដែលមានអត្តភាពមិនទាន់សម្រេច ៗ អ្នកមានប្រក្រតី ដ៏ប្រសើរយ៉ាងនេះ ជាសត្វខ្ពង់ខ្ពស់យ៉ាងនេះ សត្វទាំងឡាយ ទាំងប៉ុន្មានដែលយើងបានឃើញហើយ យើងមិនដែលឃើញនូវ សត្វដទៃបែបនេះ ៗ យើងត្រេកអរដោយបានឃើញអ្នកទាំងពីរ ជាដំបូងផង ដោយពាក្យដ៏ពីរោះផង នុះជាសេចក្តីពេញចិត្តរបស់ យើង យើងគប្បីបូជានូវអ្នកទាំងពីរ អស់កាលជាអង្វែង ៗ

[១៩៦] (រាជហង្ស...)អំពើណាដែលគួរធ្វើចំពោះមិត្តដ៏ប្រសើរ អំពើ នោះព្រះអង្គបានធ្វើហើយចំពោះទូលព្រះបង្គំទាំងពីរ សេចក្តី រាប់អានណា របស់ព្រះអង្គ ចំពោះទូលព្រះបង្គំទាំងពីរ ទូល ព្រះបង្គំទាំងពីរឃ្លាតហើយចាកព្រះអង្គ ដោយឥតសង្ស័យ ៗ

## អសីតិនិបាតេ បឋមំ ចុល្លហំសជាតកំ

អនុញ្ញ ជូន សុមហា- ញាតិសង្ឃស្ស មន្តរំ

អទស្សនេន អស្មាកំ ទុក្ខំ ពហូសុ បក្ខិសុ ។

តេសំ សោកវិឃាតាយ តយា អនុមតា មយំ

តំ បទក្ខិណតោ កត្វា ញាតី បស្សេមុរិន្ទម ។

អទ្ធាហំ វិបុលំ បីតី ភវតំ វិន្ទាមិ ទស្សនា

ឯសោ ចាបិ មហាអត្ថោ ញាតិវិស្សាសនា សិយា ។

(១៩៧) ឥទំ វត្វា ធតរដ្ឋោ ហំសរាជា នរាធិបំ

ឧត្តមំ ជវមន្វាយ ញាតិសង្ឃមុបាគមុំ ។

តេ អរោគេ អនុប្បត្តេ ទិស្វាន បរមេ ទិជេ

កេកាតិមករុំ ហំសា បុថុសទ្ទោ អជាយថ ។

តេ បតីតា បមុត្តេន ភត្តុនា ភត្តុគារវា

សមន្តា បរិកិរិំសុ អណ្ឌជា លទ្ធបច្ចយា ។

សេចក្តីទុក្ខឯណោះ បានកើតឡើងហើយក្នុងបក្សីជាច្រើន ព្រោះមិនឃើញនូវទូលព្រះបង្គំជាខ្ញុំទាំងពីរ ក្នុងចន្លោះនៃពួកញាតិជាច្រើន ដោយពិត ៗ ឃើញទាំងពីរដែលព្រះអង្គអនុញ្ញាតហើយ ដើម្បីកំចាត់បង់នូវសេចក្តីសោក របស់បក្សីទាំងនោះ បពិត្រព្រះអង្គជាអ្នកទូន្មាននូវសត្រូវ ទូលព្រះបង្គំជាខ្ញុំទាំងពីរ សូមធ្វើប្រទក្សិណព្រះអង្គ ហើយទៅជួបនឹងពួកញាតិ ៗ ទូលព្រះបង្គំជាខ្ញុំ បានសេចក្តីត្រេកអរដ៏ធំទូលាយ ព្រោះបានជួបព្រះអង្គដោយពិត ម្យ៉ាងទៀត ប្រយោជន៍ធំនេះ កើតមានព្រោះតែសេចក្តីស្និទ្ធស្នាលចំពោះញាតិ ៗ

(១៩៧) (អភិសម្ពុទ្ធគាថា) លុះរាជហង្សឈ្មោះធតរដ្ឋៈ (នឹងហង្សឈ្មោះសុមុខៈ) បានពោលពាក្យនេះ ចំពោះព្រះរាជាជាធំលើជនរួចហើយ ក៏ហើរសំដៅទៅរកពួកញាតិ អាស្រ័យនូវសន្ទុះដ៏ឧត្តម ៗ សត្វហង្សទាំងឡាយ បានឃើញនូវហង្សដ៏ឧត្តមទាំងពីរនោះមិនមានរោគមកដល់ហើយ ក៏បានធ្វើនូវសម្លេងថា កេកា ៗ សូរសំឡេងយ៉ាងខ្លាំង ក៏កើតមានឡើង ៗ បក្សីទាំងនោះ មានសេចក្តីត្រេកអរ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពចំពោះម្ចាស់ ជាសត្វបាននូវទីពឹង ហើយហើរក្រឡឹងជុំវិញ ៗ

(១៩៨) ឯវំ មិត្តវតំ អត្ថា សព្វេ ហោន្តិ បទក្ខិណា
ហំសា យថា ធតរដ្ឋា ញាតិសង្ឃមុបាគមុន្តិ ។

ចុល្លហំសជាតកំ បឋមំ ។

# មហាហំសជាតកំ

(១៩៩) ឯតេ ហំសា បក្កមន្តិ វង្កង្គា ភយមេរិតា
ហរិត្តច ហេមវណ្ណ កាមំ សុមុខ បក្កម ។
ឱហាយ មំ ញាតិគណា ឯកំ បាសវសំ គតំ
អនបេក្ខមានា គច្ឆន្តិ កឹ ឯកោ អវហីយសិ ។
បតេវ បតតំ សេដ្ឋ នត្ថិ ពទ្ធេ សហាយតា
មា អនីឃាយ ហាបេសិ កាមំ សុមុខ បក្កម ។
(២០០) នាហំ ទុក្ខបរេតោបិ ធតរដ្ឋ តុវំ ជហេ
ជីវិតំ មរណំ វា មេ តយា សទ្ធឹ ភវិស្សតិ ។
នាហំ ទុក្ខបរេតោបិ ធតរដ្ឋ តុវំ ជហេ
ន មំ អនរិយសំយុត្តេ កម្មេ យោជេតុមរហសិ ។

(១៩៨) ប្រយោជន៍ទាំងអស់ របស់ពួកជនអ្នកមានមិត្ត រមែងសម្រេចសេចក្តីសុខយ៉ាងនេះ ដូចជាហង្សឈ្មោះធតរដ្ឋៈ នឹងហង្សឈ្មោះសុមុខៈ បានហើរបុលទៅរកពួកញាតិដូច្នោះ ។

ចប់ ចុល្លហង្សជាតក ទី ១ ។

# មហាហំសជាតក

(១៩៩) (រាជហង្សពោលថា) ហង្សទាំងឡាយនេះ ត្រូវភ័យគំរាមហើយ នាំគ្នាហើរទៅ ម្នាលសុមុខៈ អ្នកមានស្បែកដូចមាស មានសម្បុរដូចមាស អ្នកចូរហើរទៅតាមប្រាថ្នាចុះ ។ ពួកបក្សីជាញាតិ បានលះបោលនូវយើង ដែលលុះអំណាចនៃអន្ទាក់តែម្នាក់ឯង មិនអាល័យហើរទៅ អ្នកក្រាញនៅតែម្នាក់ឯងដូចម្តេច ។ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សី អ្នកចូរហើរទៅចុះ ព្រោះថាភាពជាសំឡាញ់ នឹងយើងដែលជាប់បំណង់ មិនមានទេ អ្នកកុំធ្វើខ្លួនឲ្យសាបសូន្យចាកសេចក្តីសុខឡើយ ម្នាលសុមុខៈ អ្នកចូរហើរទៅតាមប្រាថ្នាចុះ ។

(២០០) (ហង្សសេនាបតីឈ្មោះសុមុខៈពោលថា) បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះបោលព្រះអង្គ ជីវិតឬសេចក្តីស្លាប់របស់ទូលព្រះបង្គំជាខ្ញុំនឹងមានជាមួយព្រះអង្គ ។ បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះបោលព្រះអង្គ ទាំងព្រះអង្គក៏មិនគួរប្រកបទូលព្រះបង្គំជាខ្ញុំ ក្នុងអំពើមិនប្រសើរទេ ។

## អសីតិនិបាតេ ទុតិយំ មហាហំសជាតកំ

សកុមារេ សទារ ត្យម្ហិ សចិត្តេ សមិតោ ឋិតោ ។
ញាតោ សេនាបតិ ត្យាហំ ហំសានំ បវរុត្តម
កថមហំ វិកត្ថិស្សំ ញាតិមជ្ឈេ ឥតោ គតោ
តំ ហិត្វា បតតំ សេដ្ឋ កិន្តេ វក្ខាមិតោ គតោ
ឥធ បាណំ ចជិស្សាមិ នានរិយំ កត្តុមុស្សហេ ។
(២០១) ឯសោ ហិធម្មោ សុមុខ យំ ត្វំ អរិយបទេ ឋិតោ
យោ ភត្តារំ សខារំ មំ ន បរិច្ចត្តុមុស្សហេ ។
តញ្ហិ មេ បេក្ខមានស្ស ភយំ នត្វេ ជាយតិ
អធិគច្ឆសិ ត្វំ មយ្ហំ ឯវំ ភូតស្ស ជីវិតំ ។
(២០២) ឥច្ចេវំ មន្តយន្តានំ អរិយានំ អរិយវុត្តិនំ
ទណ្ឌមាទាយ នេសាទោ អាបតី តុរិតោ ភុសំ ។

ទូលព្រះបង្គំជាខ្ញុំ ជាកុមារមានវ័យស្មើគ្នា ជាសំឡាញ់នឹងព្រះអង្គ ឋិតនៅក្នុងអំណាចចិត្ត របស់ព្រះអង្គ ដែលជាចិត្តប្រព្រឹត្តទៅដោយប្រពៃ បពិត្រព្រះអង្គដ៏ប្រសើរខ្ពង់ខ្ពស់ ជាធំពួកនៃហង្ស ទូលព្រះបង្គំជាខ្ញុំ ប្រាកដជាសេនាបតីរបស់ព្រះអង្គ លុះទូលព្រះបង្គំជាខ្ញុំហើរទៅអំពីទីនេះ នឹងថ្លែងសេចក្តីក្នុងកណ្តាលញាតិដោយប្រការដូចម្តេច បពិត្រព្រះអង្គដ៏ប្រសើរ ជាធំពួកបក្សី ទូលព្រះបង្គំលះបោលព្រះអង្គ ហើយទៅអំពីទីនេះ នឹងប្រាប់ (ដំណឹង) របស់ព្រះអង្គដូចម្តេច ទូលព្រះបង្គំនឹងលះបង់ជីវិតក្នុងទីនេះ មិនអាចនឹងធ្វើអំពើ មិនប្រសើរទេ ។

(២០១) (រាជហង្ស..) ម្នាលសុមុខៈ នុ៎ះជាធម៌ (របស់បោរាណកបណ្ឌិតទាំងឡាយ) ព្រោះថា អ្នកឋិតនៅក្នុងគន្លងរបស់ជនដ៏ប្រសើរ មិនអាចលះបង់នូវយើងដែលជាម្ចាស់ផង ជាសំឡាញ់ផង ។ ដ្បិតថា កាលយើងសំឡឹងមើលអ្នក សេចក្តីភ័យក៏មិនកើតសោះទេ អ្នកបាននាំយើងដែលមានសភាពយ៉ាងនេះ ឲ្យបាននូវជីវិត ។

(២០២) (អភិសម្ពុទ្ធគាថា) កាលដែលហង្ស ដ៏ប្រសើរ (ពីរ) មានការប្រព្រឹត្តិ ដ៏ប្រសើរ កំពុងប្រឹក្សាគ្នា យ៉ាងនេះ ដូច្នេះ នាយនេសាទកាន់ដម្បង ប្រញាប់មក ដល់ភ្លាម ។

តមាបតន្តំ ទិស្វាន សុមុខោ អភិព្រូហយិ(១)

អដ្ឋាសិ បុរតោ រញ្ញោ ហំសោ វិស្សាសយំ ព្យថំ ។

មា ភាយិ បតតំ សេដ្ឋ ន ហិ ភាយន្តិ តាទិសា

អហំ យោគំ បយុញ្ជិស្សំ យុត្តំ ធម្មូបសញ្ហិតំ

តេន បរិយាបទានេន ខិប្បំ បាសា បមោក្ខសិ ។

(២០៣) តស្ស តំ វចនំ សុត្វា សុមុខស្ស សុភាសិតំ

បហដ្ឋលោមោ នេសាទោ អញ្ជលិស្ស បណាមយិ ។

ន មេ សុតំ វា ទិដ្ឋំ វា ភាសន្តោ មានុសឹ ទិជោ

អរិយំ ព្រុវន្តោ វក្កង្គោ ចជន្តោ មានុសឹ គិរំ ។

កិន្នុ តាយំ ទិជោ ហោតិ មុត្តោ ពន្ធំ ឧបាសសិ

វិហាយ សកុណា យន្តិ កឹ ឯកោ អវហីយសិ ។

(២០៤) រាជា មេ សោ ទិជាមិត្ត សេនាបច្ចស្ស ការយិ

តមាបទេ បរិច្ចត្តុំ នុស្សហេ វិហាតជិំ ។

---

១ ឱ. អបរិព្រូហហិ ។

ហង្សឈ្មោះសុមុខៈ លុះបានឃើញនាយនេសាទនោះ មកដល់ ក៏ឋិតនៅខាងមុខរាជហង្ស ហើយលួងលោមរាជហង្សដែលកំពុងភ័យ រួចបានស្រែកថា បពិត្រព្រះអង្គដ៏ប្រសើរ ជាងសត្វស្លាប ព្រះអង្គកុំភ័យឡើយ ព្រោះថាបក្សីទាំងឡាយប្រហែលព្រះអង្គ រមែងមិនភ័យទេ ទូលព្រះបង្គំជាខ្ញុំ នឹងប្រកបសេចក្តីព្យាយាម ដ៏សមគួរ ដែលអាស្រ័យនូវធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់ ជាឆាប់ ដោយសេចក្តីព្យាយាមនោះមិនខាន ។

(៤០៣) នាយនេសាទ បានឮសុភាសិត របស់ហង្សឈ្មោះសុមុខៈនោះហើយ ក៏ព្រឺរោម បង្អោននូវអញ្ជលី ចំពោះហង្សឈ្មោះសុមុខៈនោះថា អ្នកជាបក្សីពោលនូវភាសា របស់មនុស្ស ពោលពាក្យដ៏ប្រសើរ បញ្ចេញនូវវាចាជារបស់មនុស្សដែលអញមិនធ្លាប់ឮ មិនធ្លាប់ឃើញ ។ បក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នកជាសត្វរួចហើយ ចូលមករកសត្វជាប់ ពួកបក្សីហើរចោលអស់ទៅហើយ ម្តេចក៏អ្នកក្រាញនៅតែម្នាក់ឯង ។

(៤០៤)(ហង្សសេនាបតី ..) ឱព្រានព្រៃជាសត្រូវនឹងបក្សី ឯរាជហង្សនោះជាព្រះរាជារបស់ខ្ញុំ ខ្ញុំជាសេនាបតីរបស់រាជហង្សនោះ ខ្ញុំមិនអាចលះបោលស្តេចបក្សីនោះ ក្នុងកាលមានសេចក្តីអន្តរាយទេ ។

មហាគណាយំ ភត្តា មេ   មា ឯកោ ព្យសនំ អគា
យថា តំ សម្មនេសាន   ភត្តាយំ អភិតោ រមេ ។

(២០៥) អរិយវត្តសិ វក្កង្គ   យោ បិណ្ឌមបចាយសិ
ចជាមិ តេ តំ ភត្តារំ   គច្ឆថូភោ យថាសុខំ ។

(២០៦) សចេ អត្តប្បយោគេន   ឱហិតោ ហំសបក្ខិនំ
បដិគ្គណ្ហាម តេ សម្ម   ឯតំ អភយទក្ខិណំ ។

នោ ចេ អត្តប្បយោគេន   ឱហិតោ ហំសបក្ខិនំ
អនិស្សរោ មុញ្ចំ អម្ហេ   ថេយ្យំ កយិរាសិ លុទ្ទក ។

(២០៧) យស្ស ត្វំ ភតកោ រញ្ញោ   កាមំ តស្សេវ បាបយ
តត្ថ សំយមនោ រាជា   យថាភិញ្ញំ ករិស្សតិ ។

ព្រះរាជារបស់ខ្ញុំនេះ ជាម្ចាស់នៃពួកហង្សដ៏ច្រើន កុំដល់នូវសេចក្តីវិនាសតែម្នាក់ឯងឡើយ បពិត្រនាយនេសាទជាសំឡាញ់ ព្រោះថា រាជហង្សនេះជាម្ចាស់ ខ្ញុំតែងត្រេកអរកាយ (ក្នុងសំណាក់រាជហង្សនោះ) ។

(២០៥) (ព្រានព្រៃ...) ម្នាលសត្វហង្ស អ្នកណា បានគោរពដុំអាហារ (ដែលបានអំពីម្ចាស់) អ្នកនោះឈ្មោះថា ប្រព្រឹត្តធម៌ដ៏ប្រសើរ យើងនឹងលែងនូវម្ចាស់របស់អ្នកនោះ អ្នកទាំងពីរចូរទៅតាមស្រួលចុះ ។

(២០៦) (ហង្សសេនាបតី...) នែសំឡាញ់ បើលោកដាក់អន្ទាក់ពួកហង្សនឹងបក្សីដ៏សេស ដោយសេចក្តីព្យាយាមរបស់ខ្លួន យើងខ្ញុំនឹងទទួលនូវអភយទាននេះ របស់លោក បើលោកមិនដាក់អន្ទាក់ពួកហង្ស នឹងបក្សីដ៏សេស ដោយសេចក្តីព្យាយាមរបស់ខ្លួនទេ បពិត្រនាយនេសាទ លោកមិនមែនជាធំ កាលលែងនូវយើងខ្ញុំ ឈ្មោះថា ធ្វើនូវការលួច ។

(២០៧) លោកជាបុគ្គលស៊ីឈ្នួល របស់ព្រះរាជាណា លោកចូរនាំយើងខ្ញុំឡើងដល់ទៅព្រះរាជានោះតាមប្រាថ្នាចុះ ព្រះរាជាព្រះនាមសំយមៈ នឹងធ្វើតាមគាប់ព្រះទ័យ ក្នុងព្រះរាជនិវេសន៍នោះ ។

(២០៨) ឥច្ចេវំ វុត្តោ នេសាទោ ហេមវណ្ណេ ហរិត្តចេ

ឧភោ ហត្ថេហិ បគ្គយ្ហ[១] បញ្ជរេ អជ្ឈវោទហិ ។

តេ បញ្ជរគតេ បក្ខី ឧភោ ភស្សរវណ្ណិនេ

សុមុខំ ធតរដ្ឋញ្ច លុទ្ទោ អាទាយ បក្កមិ ។

(២០៩) ហរិយមានោ ធតរដ្ឋោ សុមុខំ ឯតទព្រវិ

ពាឡ្ហំ ភាយាមិ សុមុខ សាមាយ លក្ខណូរុយា

អស្មាកំ វធមញ្ញាយ អថត្តានំ វធិស្សតិ ។

បាកហំសា ច សុមុខ សុហេមា ហេមសុត្តចា

កោញ្ចី សមុទ្ទតីរេវ កបណា នូន រុច្ចតិ ។

(២១០) ឯវំ មហត្តោ លោកស្ស អប្បមេយ្យោ មហាគណី

ឯកិត្ថិមនុសោចេយ្យ នយិទំ បញ្ញវតាមិវ ។

---

១ ឱ. សំគយ្ហ ។

[៦០៨] (អភិសម្ពុទ្ធគាថា) លុះហង្សឈ្មោះសុមុខៈ និយាយយ៉ាងនេះហើយ នាយនេសាទ ក៏យកដៃស្ទួយនូវហង្សទាំងពីរ ដែលមានសម្បុរនឹងស្បែកដូចមាស ហើយដាក់ទៅក្នុងទ្រុង ៗ ព្រានព្រៃបាននាំយកបក្សីឈ្មោះសុមុខៈ ១ ឈ្មោះធតរដ្ឋៈ ១ ទាំងពីរមានសម្បុរដ៏ភ្លឺផ្លេក ទំនៅក្នុងទ្រុងនោះហើយចៀសចេញទៅ ។

[៦០៩] រាជហង្សឈ្មោះធតរដ្ឋៈ ដែលព្រានព្រៃ កំពុងនាំទៅ បានពោលពាក្យនេះនឹងហង្សឈ្មោះសុមុខៈថា ម្នាលសុមុខៈ ខ្ញុំខ្លាច (សេចក្តីស្លាប់) នៃនាងបក្សីឈ្មោះសុហេមា ដែលមានសម្បុរដូចមាស មានភ្លៅប្រកបដោយលក្ខណៈខ្ពង់ណាស់ តែនាងសុហេមាបានដឹងថាគេសម្លាប់នូវយើងទាំងពីរហើយ មុខជានឹងសម្លាប់នូវខ្លួនដែរ ៗ ម្នាលសុមុខៈ នាងបក្សីឈ្មោះសុហេមាជាធីតានៃបាកហង្ស ដែលមានស្បែកល្អដូចមាស ជាសត្វកំព្រាខ្ញុំយំដោយពិត ដូចជាក្រៀលញី ខ្ញុំយំប្របឆ្នេរសមុទ្រដូច្នោះ ។

[៦១០] (ហង្សសេនាបតី...) ព្រះអង្គជាធំជាងហង្ស មានគុណប្រមាណមិនបាន ជាម្ចាស់នៃហ្វូងហង្ស ជាច្រើនយ៉ាងនេះហើយសោកស្តាយ នូវមេហង្សមួយ ការយំនេះ ហាក់ដូចជាមិនសមគួរ ដល់ព្រះអង្គ ដែលមានប្រាជ្ញាឡើយ ។

## អសីតិនិបាតេ ទុតិយំ មហាហំសជាតកំ

ភតោវ គន្ធមាទេតិ ឧភយំ ជេកពាបកំ

ពាលោ អាមកបក្កំវ លោលោ អម្ពំវ អាមិសំ ។

អវិចិន្តយញ្ញ អត្ថេសុ អប្បញ្ញោ បជិកាសិ មំ

កិច្ចាកិច្ចំ ន ជានាសិ សម្បត្តោ កាលបរិយាយំ ។

អទ្ធុម្មត្តោ ឧទីរេសិ យោ សេយ្យោ មញ្ញសិត្ថិយោ

ពហុសាធារណា ហេតា សោណ្ឌានំវ សុរាឃរំ ។

មាយា ចេតា មរីចីវ សោកា រោគា ចុបទ្ទវា

ខរា ច ពន្ធនា ចេតា មច្ចុបាសា គុហាសយា ។

តាសុ យោ វិស្សសេ បោសោ សោ នរេសុ នរាធមោ ។

ព្រះអង្គសោកស្តាយ ព្រោះតែស្ត្រីទាំងឡាយ ឧបមាស្ត្រីទាំងឡាយដូចជាខ្យល់កួចយក នូវក្លិនទាំងល្អទាំងអាក្រក់ទាំងពីរ ឬដូចជាក្មេងល្ងង់ ចាប់យកផ្លែឈើទាំងខ្ចីទាំងទុំ ពុំនោះសោតដូចមនុស្សខ្លាក់ ជាអ្នកស្រេកឃ្លាន កាន់យកអាមិសៈ (ទាំងល្អទាំងអាក្រក់) ។ ព្រះអង្គមិនដឹងនូវការវិនិច្ឆ័យក្នុងប្រយោជន៍ទាំងឡាយ ដូចជាមនុស្សល្ងង់ប្រាកដ ដល់ទូលព្រះបង្គំ លុះដល់កាលជាទីស្លាប់ទៅតែមិនដឹងអំពើដែលគួរធ្វើនិងមិនគួរធ្វើឡើយ ។ ព្រះអង្គជាបុគ្គលឆ្កួតពាក់កណ្តាល និយាយផ្តេសផ្តាស ព្រោះថាព្រះអង្គសំគាល់នូវស្ត្រីទាំងឡាយថាប្រសើរបំផុត ព្រោះថាស្ត្រីទាំងនេះជាសាធារណៈដល់ជនច្រើន ដូចជារោងសុរាជាសាធារណៈដល់ពួកអ្នកលេង ។ មួយទៀត ស្ត្រីទាំងនេះ មានមាយាដូចជាថ្ងៃបណ្តើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះមានអធ្យាស្រ័យដ៏វេរូស ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ (របស់មច្ចុរាជ) បុរសណា ទុកចិត្តក្នុងស្ត្រីទាំងនោះ បណ្តាបុរសទាំងឡាយ បុរសនោះឈ្មោះថា បុរសថោកទាប ។

(២១១) យំ វុឌ្ឍេហិ ឧបញ្ញាតំ កោ តំ និន្ទិតុមរហតិ
មហាក្ខត្តិយោ នាម លោកស្មឹ ឧបបជ្ជសុំ ។
វិញ្ញូ បណ្ឌិតា តាសុ(១) រតិ តាសុ(២) បតិដ្ឋិតា
វីជានិ តាសុ(៣) វុឌ្ឍិ យទិទំ សត្តា បជាយរេ
តាសុ កោ និព្វិជេ បោសោ ភាណមាសជ្ជ ភាណិកិ ។
ត្វមេវ នាញ្ញោ សុមុខ ជិនំ អត្ថេសុ យុញ្ជសិ
តស្ស ត្យជ្ជ ភយេ ជាតេ ភីតេន ជាយតេ មតិ ។
សព្វេ ហិ សំសយំ បត្តា ភយំ ភីរុ តិតិក្ខតិ
បណ្ឌិតា ហិ មហន្តានោ អត្ថេ យុញ្ជន្តិ ទុយ្យុជេ ។
ឯតទត្ថាយ រាជានោ សូរមិច្ឆន្តិ មន្តិនំ
បដិពាហតិ យំ សូរោ អាបទំ អត្តបរិយាយំ ។

១–២ ឱ. ម. ត្យាសុ ។ ៣ ម. ពីជានិ ត្យាសុ ។

[៦១១] (រាជហង្ស...) (វត្ថុគឺស្ត្រី) ណា ដែលពួកជនអ្នកចំរើន ដោយប្រាជ្ញាបញ្ញត្តហើយ បុគ្គលណា គួរតិះដៀលនូវស្ត្រីនោះបាន ធម្មតាស្ត្រីទាំងឡាយ មានគុណច្រើន ហើយកើតឡើងក្នុងលោក (មុនគេ) ។ ល្បែងគេតាំងទុក ក្នុងស្ត្រីទាំងនោះ សេចក្តីត្រេកអរក៏តាំងនៅក្នុងស្ត្រីទាំងនោះដែរ ពូជទាំងឡាយ រមែងលូតលាស់ឡើងក្នុងស្ត្រីទាំងនោះ គឺពួកសត្វទាំងអស់ តែងកើត (ត្រូវអាស្រ័យស្ត្រីទាំងនោះ) បុរសដូចម្តេច ប្តូរជីវិតដោយជីវិតហើយ គប្បីនឿយណាយក្នុងស្ត្រីទាំងនោះ ។ ម្នាលសុមុខៈ អ្នកឯងហ្នឹងហើយ មិនមែនជាអ្នកដទៃ រមែងប្រកបក្នុងប្រយោជន៍ចំពោះពួកស្ត្រី ភ័យកើតឡើងដល់អ្នកក្នុងថ្ងៃនេះ គំនិតរបស់អ្នកក៏កើតឡើងដោយសេចក្តីភ័យ ។ ជនទាំងអស់ដល់នូវសេចក្តីសង្ស័យ ក្នុងជីវិតហើយជាអ្នករន្ធត់ ប្រឹងអត់ទ្រាំនូវសេចក្តីខ្លាច បំណែកពួកបណ្ឌិត ជាអ្នកឋិតនៅក្នុងទីដ៏ប្រសើរ តែងប្រកបក្នុងប្រយោជន៍ដែលគេប្រកបបានដោយក្រ ។ ព្រះរាជាទាំងឡាយ តែងប្រាថ្នានូវមន្ត្រី ដែលមានសេចក្តីក្លៀវក្លា ដើម្បីប្រយោជន៍ការពារ នូវអន្តរាយនេះ ព្រោះមន្ត្រីដែលក្លៀវក្លា រមែងឃាត់ នូវសេចក្តីអន្តរាយ នឹងការពារ នូវខ្លួនបាន ។

មា នោ អជ្ជ វិកន្តិំសុ រញ្ញោ សូទា មហានសេ
តតោហិ វេឡ្ហោ បត្តានំ ផលំ វេឡុំវ តំ វធិ ។
មុត្តោបិ នេច្ឆិ ឧឌ្ឌេតុំ សយំ ពន្ធំ ឧបាគមិ
សោបជ្ជ សំសយំ បត្តោ អត្ថំ គណ្ហាហិ មា មុខំ ។

[២១២] សោ ត្វំ យោគំ បយុញ្ជស្សុ យុត្តំ ធម្មូបសំហិតំ
តវ បរិយាបទានេន មម បាណេសនំ ចរ ។

[២១៣] មា ភាយិ បតតំ សេដ្ឋ នហិ ភាយន្តិ តាទិសា
អហំ យោគំ បយុញ្ជិស្សំ យុត្តំ ធម្មូបសំហិតំ
មម បរិយាបទានេន ខិប្បំ បាសា បមោក្ខសិ ។

[២១៤] សោ លុទ្ទោ ហំសកាជេន រាជទ្វារំ ឧបាគមិ
បដិវេទេថ មំ រញ្ញោ ធតរដ្ឋាយមាគតោ ។

ពួកពិសេសរបស់ព្រះរាជាកុំវះនូវយើងក្នុងពេលគ្រួកងថ្ងៃនេះ យ៉ាងណា (អ្នកប្រាជ្ញ) យ៉ាងនោះចុះ ដ្បិតសម្បុរស្លាបសម្រាប់អ្នក (នឹង) យើង ដូចផ្លែឫស្សីសម្រាប់នូវដើមឫស្សី ។ អ្នករួច (ជាមួយនឹងយើង) ហើយមិនចង់ហើរទៅ ចូលមករកបំណងដោយខ្លួនឯងវិញថ្ងៃនេះ អ្នកនោះដល់នូវសេចក្តីសង្ស័យ (ក្នុងជីវិត) អ្នកចូរកាន់យកនូវប្រយោជន៍ចុះ កុំបានតែមាត់ឡើយ ។

(២១២) អ្នកនោះ ចូរប្រកបព្យាយាមដ៏សមគួរ ប្រកបដោយធម៌ ប្រព្រឹត្តនូវការស្វែងរកនូវជីវិត ឲ្យដល់យើង ដោយព្យាយាមរបស់អ្នកចុះ ។

(២១៣) (ហង្សសេនាបតី...) បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំខ្លាចឡើយ ដ្បិតសត្វទាំងឡាយ ប្រហែលព្រះអង្គ រមែងមិនខ្លាច ទូលព្រះបង្គំជាខ្ញុំនឹងប្រកបនូវព្យាយាមដ៏សមគួរប្រកបដោយធម៌ ព្រះអង្គនឹងរួចពាក់អន្ទាក់ យ៉ាងឆាប់ ដោយព្យាយាម របស់ទូលព្រះបង្គំជាខ្ញុំ ។

(២១៤) (អភិសម្ពុទ្ធគាថា) ព្រានព្រៃនោះ បានចូលទៅកាន់ទ្វារព្រះ-រាជវាំងទាំងអង្រែក ហង្ស (ពោលថា) អ្នកទាំងឡាយ ចូរក្រាបទូលព្រះរាជាថា ខ្ញុំជារាជហង្សឈ្មោះធតរដ្ឋៈ នេះមកហើយ ។

(២១៤) តេ និស្សា បុញ្ញសង្ខាតេ ឧរោ បេក្ខណាសម្មតេ

ឲលុ សញ្ញមតោ រជា អមច្ចេ អជ្ឈភាសថ ។

នេថ លុទ្ទស្ស វត្ថានិ អន្នំ ទានញ្ច ភោជនំ

កាមង្ករេ ហិរញ្ញស្ស យាវន្តំ ឃរេ វដ្ឋតិ ។

(២១៦) និស្សា លុទ្ទំ បសន្នត្តំ កាសិរាជេនឧទ្រិ

យនាយំ សម្ម ខេមក បុណ្ណាហំ សេហិ តិដ្ឋតិ ។

កាចំ រុចិមជ្ឈគតំ ទាសហាត្វា ឧទាគមិ

ឱកិណ្ណំ ញាតិសង្ឃេហិ និម្មជ្ឈិមំ កាចំ គហិ ។

(២១៧) អជ្ជមេ សត្តមា រត្តិ អាទាជានិ ឧទាសតោ

បទមេតស្ស អន្វេសំ អប្បមត្តោ ឃដស្សិតោ ។

អថស្ស បទមទ្ទក្ខឹ ចរតោ អាទនេសនំ

តត្ថាហំ ឱនហឹ ទាសំ ឃវន្តំ និជមគ្គហឹ ។

[២១៥] ព្រះរាជា ព្រះនាមសំយមៈ ទតឃើញហង្សទាំងពីរនោះ ប្រាកដស្មើដោយបុណ្យ ដែលសន្មតថា មានលក្ខណៈល្អ ទ្រង់ត្រាស់ទៅ នឹងពួកអាមាត្យថា អ្នកទាំងឡាយ ចូរឲ្យសំពត់ បាយ ទឹក នឹងភោជន ដល់នាយព្រាន ចូរបំពេញសេចក្តីប្រាថ្នា ដោយប្រាក់ដែលព្រាននេះប្រាថ្នាចុះ ។

[២១៦] ព្រះរាជាក្នុងដែនកាសី ទ្រង់បានទតឃើញព្រានព្រៃមានចិត្តរីករាយ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលខេមកៈជាសំឡាញ់ បើស្រះបោក្ខរណីពេញពាសដោយពួកហង្ស ។ អ្នកមានដៃកាន់អន្ទាក់ចូលទៅរកហង្ស ដែលឋិតនៅក្នុងកណ្តាលនៃពួកហង្សដ៏រុងរឿង ដោយប្រការដូចម្តេច អ្នកចាប់ហង្សដ៏ឧត្តមដែលនៅលាយឡំដោយពួកហង្សជាញាតិ ដោយប្រការដូចម្តេច ។

[២១៧] (ព្រានព្រៃ...) កាលទូលព្រះបង្គំជាខ្ញុំ ចូលទៅកាន់ទីជាទីកាន់យកនូវចំណី (របស់ហង្ស) ថ្ងៃនេះ ជារាត្រីគំរប់ ៧ ទូលព្រះបង្គំជាខ្ញុំ ស្វែងរកនូវស្នាមជើងនៃហង្សនោះ ឥតមានធ្វេសប្រហែស អាស្រ័យនៅតែក្នុងពាង ។ លុះទូលព្រះបង្គំជាខ្ញុំ បានឃើញស្នាមជើងនៃរាជហង្សនោះ ត្រាច់ស្វែងរកទីជាទីកាន់យកចំណីហើយ ទើបទូលព្រះបង្គំជាខ្ញុំបានដាក់អន្ទាក់ក្នុងទីនោះ រួចចាប់យករាជហង្សនោះ ដោយឧបាយយ៉ាងនេះ ។

(២១៨) លុទ្ទន្តេន មេ សកុណា អជ ឃោរាតិ ភាសសិ

ចិត្តំ នុ តេ វិបរិយត្តំ អាទុ តានិន្តុ ជិគីសសិ ។

(២១៩) យស្ស លោហិតកា តាលា តបនេយ្យានិភា សុភា

ឧរំ សំហច្ច តិដ្ឋន្តិ សោ មេ ពន្ធំ ឧបាគមិ ។

អថាយំ គស្សកោ បក្ខី អពទ្ធោ ពទ្ធមាតុរំ

អរិយំ ព្រូហន្តោ(១) អដ្ឋាសិ វទន្តោ មានុសឹ គិរំ ។

(២២០) កថន្នុ នាធិ សុមុខ ហនុំ សំហច្ច តិដ្ឋសិ

អាទុ មេ បរិសំ បត្តោ ភយា ភីតោ ន ភាសសិ ។

(២២១) នាហំ កាសិបតិ ភីតោ ឱគ្គយ្ហ បរិសំ តវ

នាហំ ភយា ន ភាសិស្សំ វាក្យំ អត្ថស្មិំ តាទិសេ ។

---

១ ឱ. ព្រូហនោ ។

[២១៨] (ព្រះរាជា...) ម្នាលនាយព្រាន បក្សីនេះ ចុះហេតុអ្វីក៏បានជាអ្នកពោលថា បក្សីមួយ ចិត្តរបស់អ្នកប្រែប្រួលឬ ឬមួយអ្នកប្រាថ្នា ដូចម្តេចវិញ ។

[២១៩] (ព្រានព្រៃ...) ឆ្នូតក្រហមល្អក្លី រុងរឿង ឋិតនៅផ្ទាល់នឹងទ្រូងនៃហង្សណា ហង្សនោះ បានចូលមកជាប់អន្ទាក់ របស់ទូលព្រះបង្គំជាខ្ញុំ ចំណែកបក្សីដែលក្លឹផ្លុកនេះ មិនបានជាប់អន្ទាក់ទេ ចំរើននូវអរិយធម៌ បានឈរនិយាយវាចាជារបស់មនុស្ស នឹងបក្សីដែលជាប់ចំណងកំពុងតែក្តៅក្រហាយ (ដោយទុក្ខ) ។

[២២០] (ព្រះរាជា...) ម្នាលសុមុខៈ ឥឡូវនេះ អ្នកឈរទល់ចង្កា (បិទមាត់) តើព្រោះហេតុអ្វី ឬក៏អ្នកមកកណ្តាលបរិស័ទរបស់យើងហើយ មានសេចក្តីភ័យខ្លាច ទើបមិនពោល ។

[២២១] (ហង្សសេនាបតី...) បពិត្រព្រះអង្គ ជាធំក្នុងដែនកាសី ទូលព្រះបង្គំជាខ្ញុំ មិនមែនខ្លាច ព្រោះតែចូលមកកាន់បរិស័ទរបស់ព្រះអង្គទេ ទូលព្រះបង្គំជាខ្ញុំ មិនមែនជានឹងមិននិយាយព្រោះខ្លាចទេ កាលបើមានហេតុប្រាកដដូច្នោះហើយ ទូលព្រះបង្គំជាខ្ញុំមុខជានឹង (បញ្ចេញ) នូវវាចា ។

[២២២] ន តេ អភិស្សំ បស្សេ ន វជេ នបិ បត្ថិកេ

ណាស្ស ចម្មំ វា កីជំ វា វម្មិនេ ច ជនុត្តមោ ។

ន ហិរញ្ញំ សុវណ្ណំ វា នគរំ វា សុមាបិតំ

ឧកិណ្ណាបរិក្ខំ ទុគ្គំ ទឡ្ហមដ្ដាលកោដ្ឋកំ

យត្ថ បវិដ្ឋា សុមុខ ការយិតុំ ន ការយេសិ ។

[២២៣] ន មេ អភិស្សរេនត្ថោ នគរេន ជនេន វា

អបថេន បទំ យាម អន្តលិក្ខេចរា មយំ ។

សុតា ច បណ្ឌិតា ត្យម្ហា និបុណា ចត្ថចិន្តកា

ភាសេមត្ថវតឹ វាចំ សច្ចេ ចស្សុ បតិដ្ឋិតោ ។

កិញ្ច តុយ្ហំ អសច្ចស្ស អនរិយស្ស ករិស្សតិ

មុសាវាទិស្ស លុទ្ទស្ស ភណិតំបិ សុភាសិតំ ។

(២២២) (ព្រះរាជា...) យើងមិនឃើញទាហាន មិនឃើញពលរថ មិនឃើញពលជើងដើរ មិនឃើញខែល មិនឃើញជនអ្នកកាន់អម្បែង មិនឃើញជនអ្នកពាក់អាវក្រោះ មិនឃើញអ្នកកាន់ធ្នូរបស់អ្នកឡើយ ។ ម្នាលសុមុខៈ យើងមិនឃើញប្រាក់ ឬមាស ឬនគរ ដែលគេសាងល្អហើយ ជានគរមានគូដ៏ជ្រៅជាស មិនងាយទៅមកបាន ជានគរមានប៉មនិងក្លោងទ្វារដ៏មាំទេ ជាកន្លែងដែលអ្នកចូលទៅហើយ មិនខ្លាចនូវហេតុដែលគេគួរខ្លាច ។

(២២៣) (ហង្សសេនាបតី...) ទូលព្រះបង្គំជាខ្ញុំ មិនត្រូវការដោយទាហាន ដោយនគរ ឬដោយទ្រព្យទេ ពួកទូលព្រះបង្គំជាខ្ញុំតែងទៅកាន់ផ្លូវតាមផ្លូវ មិនមែនជាផ្លូវដែលព្រះអង្គទៅបានទេ ទូលព្រះបង្គំជាខ្ញុំត្រាច់ទៅក្នុងអាកាស ។ ព្រះអង្គបានទ្រង់ឮហើយថា ពួកទូលព្រះបង្គំជាខ្ញុំ ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង បើព្រះអង្គប្រតិស្ឋានក្នុងសច្ចៈ ពួកទូលព្រះបង្គំជាខ្ញុំនឹងពោលនូវវាចាដែលមានប្រយោជន៍ ។ ឯវាចាជាសុភាសិត ដែលព្រះអង្គមិនមានសច្ចៈជាបុគ្គលមិនប្រសើរបានពោលដល់ព្រានព្រៃ ជាអ្នកឃ្លោកនិយាយកុហកដែរ នឹងធ្វើដូចម្តេច ។

អសីតិនិបាតេ ទុតិយំ មហាហំសជាតកំ

(២២៨) តំ ព្រាហ្មណា ធំវចជា ឥមំ ខេមមការយិ
អភយញ្ច តយា ឃុដ្ឋំ ឥមាយោ ទសធា ទិសា ។
ឱគ្គយ្ហ តេ បោក្ខរណី វិប្បសន្នោទកា សុចី
បហូតំ ខាទនំ តត្ថ អហឹសា ចេត្ថ បក្ខិនំ ។
ឥទំ សុត្វាន និគ្ឃោសំ អាគតម្ហា តវន្តិកេ
តេ តេ ពទ្ធស្មា បាសេន ឯតន្តេ ភាសិតំ មុសា ។
មុសាវាទំ បុរក្ខត្វា ឥច្ឆាលោភញ្ច បាបកំ
ឧភោ សន្ធឹ អតិក្កម្ម អសាតំ ឧបបជ្ជតិ ។
(២២៩) នាបរជ្ឈាម សុមុខ នបិ លោភាវ មគ្គហី
សុតា ច បណ្ឌិតាត្យត្ថ និបុណា អត្ថចិន្តកា ។
អប្បេវត្ថវតី វាចំ ព្យាហរេយ្យុំ ឥធាគតា
តថាយំ សម្មនេសា នោ វុត្តា សុមុខ មគ្គហិ ។

[៦៦៨] ព្រះអង្គបានឱ្យគេធ្វើស្រះបោក្ខរណីឈ្មោះខេមានោះ តាមសំដីនៃពួកព្រាហ្មណ៍ ម្យ៉ាងទៀតព្រះអង្គឱ្យគេឃោសនានូវអភ័យគ្រប់ទិសទាំង ១០ នេះ ។ ជាបើកឱ្យសត្វបក្សីចុះកាន់ស្រះបោក្ខ-រណីដែលមានទឹកដ៏ថ្លាស្អាតចុះ ដ្បិតមានវត្ថុសម្រាប់ទំពាស៊ីក្នុងស្រះនោះជាច្រើន ទាំងមិនមានការបៀតបៀននូវពួកសត្វបក្សីក្នុងស្រះនោះទេ ។ ពួកទូលព្រះបង្គំជាខ្ញុំបានឮនូវអភ័យនេះ ដែលព្រះអង្គឱ្យឃោសនាហើយ បានជាមកក្នុងសំណាក់នៃព្រះអង្គ ទូលព្រះបង្គំជាខ្ញុំទាំងនោះ ជាប់ដោយអន្ទាក់របស់ព្រះអង្គ នេះហើយជាសំដីកុហករបស់ព្រះអង្គ ។ បុគ្គលធ្វើនូវមុសាវាទផង នូវសេចក្តីលោភគឺសេចក្តីប្រាថ្នាដ៏លាមកផង ឱ្យជាប្រធាន រមែងកន្លងនូវបដិសន្ធិក្នុងលោកទាំងពីរ ហើយចូលទៅកាន់ទីមិនមានសេចក្តីត្រេកអរ (នរក) ។

[៦៦៩] (ព្រះរាជា...) ម្នាលសុមុខៈ យើងមិនមែនប្រទូស្តអ្នកទេ យើងមិនមែនចាប់អ្នក ព្រោះសេចក្តីលោភទេ យើងបានឮថាអ្នកទាំងឡាយ ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង ។ ធ្វើម្តេចហ្ន៎ ហង្សទាំងឡាយបានមកក្នុងទីនេះ ពោលនូវវាចាមានប្រយោជន៍ ម្នាលសុមុខៈជាសំឡាញ់ ព្រោះហេតុនោះ បានជាយើងប្រាប់នាយនេសាទនេះ ឱ្យចាប់ (អ្នក) ។

(១)

(២២៦) នេវ ភូតា កាសិបតិ  ឧបនីតស្មិ ជីវិតេ

ភាសេមត្ថតី ភចំ  សម្បត្តា កាលបរិយាយំ ។

យោ មិគេន មិគំ ហន្តិ  បក្ខិំ បន បក្ខិនា

សុតេន វា សុតំ កិណ្យា  កឹ អនរិយតរំ តតោ ។

យោ អរិយរុទំ ភាសេ  អនរិយធម្មវស្សិតោ

ឧភោ សោ ធំសតេ លោកា  ឥធ ចេវ បរត្ថ ច ។

ន មជ្ជេថ យសំ បត្តោ  ន ព្យាធេ បត្តសំសយំ

វាយមេថេវ កិច្ចេសុ  សំវរេ វិវរានិ ច ។

យេ វុឌ្ឍា អព្ភតិក្កន្តា  សម្បត្តា កាលបរិយាយំ

ឥធ ធម្មំ ចរិត្វាន  យន្តិ តេ តិទិវង្គតា ។

---

១ ឱ. ភីតា ។

(២២៦) (ហង្សសេនាបតី...) បពិត្រព្រះអង្គដ៏ធំ ក្នុងដែនកាសី យើងទាំងឡាយ ជាសត្វ កាលបើជីវិតចូលទៅរក (សេចក្តីស្លាប់) ហើយដល់នូវកាលកំណត់ដែលត្រូវស្លាប់ហើយ ពោលនូវពាក្យដែលមានប្រយោជន៍មិនបានទេ ៗ បុគ្គលណា សម្លាប់ម្រឹគដោយម្រឹគ ឬបក្សីដោយបក្សី ម្យ៉ាងទៀត បៀតបៀននូវបុគ្គលដែលមានឈ្មោះល្បី ដោយរបស់ ដែលមានឈ្មោះល្បី អំពើអ្វីដែលអាក្រក់ជាងអំពើ របស់បុគ្គលនោះទៅទៀត ៗ បុគ្គលណា និយាយសំដីដ៏ប្រសើរ ប៉ុន្តែជាបុគ្គលមិនប្រព្រឹត្តធម៌ដ៏ប្រសើរ បុគ្គលនោះ រមែងឃ្លាតចាកលោកទាំងពីរ គឺលោកនេះនឹងលោកខាងមុខ ៗ បុគ្គលដែលបាន នូវយស មិនគួរស្រវឹង ដល់នូវការសង្ស័យ ក្នុងជីវិត មិនគួរទុក្ខលំបាកឡើយ គួរព្យាយាមក្នុងកិច្ចទាំងឡាយផង គួរបិទនូវប្រហោងគឺ (ទោស) ទាំងឡាយផង ៗ ពួកបុគ្គលណា ចំរើនដោយគុណ ដល់កាលកំណត់ដែលត្រូវស្លាប់ មិនល្មើសធម៌ ទាំងបានប្រព្រឹត្តធម៌ក្នុងលោកនេះ ពួកបុគ្គលនោះ រមែងទៅកើតក្នុងត្រៃត្រិង្សយ៉ាងនេះ ៗ

ឥទំ សុត្វា កាសិបតិ ធម្មត្ថិ បាលយ
ជនិន្ទញ្ច មុញ្ចាហិ ហំសានំ បវរុត្តមំ ។

(២២៧) អាហារត្ថុទកំ បជ្ជំ អាសនញ្ច មហារហំ
បញ្ជរតោ បមោក្ខាមិ ជនិន្ទំ យសស្សិនំ ។

តញ្ច សេនាបតី ធីរំ និបុណំ អត្ថចិន្តកំ
យោ សុខេ សុខិតោ រញ្ញោ ទុក្ខិតេ ហោតិ ទុក្ខិតោ ។

ឯទិសោ វោ អរហតិ បិណ្ឌមស្នាតុ ភត្តុនោ
យថាយំ សុមុខោ រញ្ញោ បាណសាធារណោ សខា ។

(២២៨) បីឋញ្ច សព្វសោវណ្ណំ អដ្ឋបាទំ មនោរមំ
មដ្ឋំ កាសិកវត្ថិនំ[1] ជនិន្ទោ ឧបាវិសិ ។

---
១ ម. កាសិកមត្ថុនំ ។

បពិត្រព្រះអង្គជាធំក្នុងដែនកាសី ព្រះអង្គទ្រង់ព្រះសណ្ដាប់នូវពាក្យនេះហើយ សូមរក្សានូវធម៌ក្នុងព្រះអង្គចុះ ម្យ៉ាងទៀត សូមព្រះអង្គទ្រង់ដោះលែងនូវរាជហង្សឈ្មោះធតរដ្ឋៈ ដ៏ប្រសើរលើសជាងពួកហង្ស ។

(២២៧) (ព្រះរាជា...) ពួកអ្នកបំរើ ចូរនាំមកនូវទឹក (សម្រាប់លាងជើង) ផង នូវប្រេងសម្រាប់លាបជើងផង នូវអាសនៈដែលមានថ្លៃច្រើនផង យើងនឹងដោះនូវរាជហង្សឈ្មោះធតរដ្ឋៈដ៏មានយសចេញអំពីទ្រុង ។ ម្យ៉ាងទៀត ហង្សណា កាលបើព្រះរាជា បានសេចក្ដីសុខ ខ្លួនក៏បានសេចក្ដីសុខដែរ ព្រះរាជាបានសេចក្ដីទុក្ខ ខ្លួនក៏បានសេចក្ដីទុក្ខដែរ យើងនឹងលែងនូវហង្សនោះ ជាសេនាបតី ជាអ្នកប្រាជ្ញ មានប្រាជ្ញាល្អិត អ្នកគិតនូវអាថ៌កំបាំង ។ បុគ្គលបែបនេះ ទើបគួរបរិភោគដុំបាយរបស់ម្ចាស់បាន ដូចជាហង្សសេនាបតីឈ្មោះសុមុខៈនេះជាសំឡាញ់មានជីវិតស្មើនឹងស្ដេច ។

(២២៨) (អភិសម្ពុទ្ធគាថា) រាជហង្សឈ្មោះធតរដ្ឋៈ បានចូលទៅទំលើតាំង ជាវិការៈនៃមាសសុទ្ធ មានជើងប្រាំ ជាទីរីករាយនៃចិត្ត ជាតាំងដ៏រលើង ក្រាលដោយសំពត់អ្នកដែនកាសី ។

គោចរញ្ច សព្វសោវណ្ណំ   វេឡុរិយបរិសិព្វិតំ
សុមុខោ អជ្ឈភាសិត្ថ   ធតរដ្ឋស្សនន្តរា ។
តេសំ កញ្ចនបត្តេហិ   បុថូ អាទាយ កាសិយោ
ហំសានំ អភិហារេសុំ   អគ្គំ រញ្ញោ បវាសិតំ ។
(២២៩) ទិស្វា អភិហដំ អគ្គំ   កាសិរាជេន បេសិតំ
កុសលោ ខត្តធម្មានំ   តតោ បុច្ឆិ អនន្តរា
កច្ចិ នុ ភោតោ កុសលំ   កច្ចិ ភោតោ អនាមយំ
កច្ចិ រដ្ឋមិទំ ផីតំ   ធម្មេន អនុសាសសិ ។
(២៣០) កុសលញ្ចេវ មេ ហំស   អថោ ហំស អនាមយំ
អថោ រដ្ឋមិទំ ផីតំ   ធម្មេន អនុសាសហំ ។
(២៣១) កច្ចិ ភោតោ អមច្ចេសុ   ទោសោ កោចិ ន វិជ្ជតិ
កច្ចិ ច តេ តវត្ថេសុ   នាវកង្ខន្តិ ជីវិតំ ។

ចំណែកហង្សសេនាបតី ឈ្មោះសុមុខៈ បានចូលទៅទំលើកៅអី ជាវិការៈនៃមាសសុទ្ធ ដែលពាសដោយស្បែកខ្លាក្នុងទីជាលំដាប់ នៃរាជហង្សឈ្មោះធតរដ្ឋៈ ។ ពួកអ្នកដែនកាសីជាច្រើន បាននាំយកនូវភោជនមានរសដ៏ប្រសើរ ដែលគេបញ្ជូនទៅថ្វាយព្រះរាជា ដោយភាជន៍ជាវិការៈនៃមាសទាំងឡាយ ហើយក៏បង្អោនទៅដល់ហង្សទាំងនោះ ។

[២២៩] រាជហង្សឈ្លាសវៃ ក្នុងបដិសណ្ឋារធម៌ លុះបានឃើញទឹកនឹងភោជនដ៏ប្រសើរ ដែលគេនាំមក ដែលព្រះរាជាក្នុងដែនកាសីទ្រង់បញ្ជូនមកហើយ សួរក្នុងកាលជាលំដាប់នោះថា ព្រះអង្គទ្រង់បានសេចក្តីសុខស្រួលដែរឬ ព្រះអង្គមិនមានជម្ងឺជម្ងាត់អ្វីទេឬ ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ ដោយធម៌ដែរឬ ។

[២៣០] (ព្រះរាជា...) ម្នាលហង្ស យើងមានសេចក្តីសុខស្រួលដែរ ម្នាលហង្ស យើងមិនមានជម្ងឺជម្ងាត់អ្វីទេ យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះត្រឹមត្រូវ ដោយធម៌ហើយ ។

[២៣១] (រាជហង្ស...) ទោសតិចតួច របស់ព្រះអង្គមិនមានក្នុងពួកអាមាត្យទេឬ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតបំពោះប្រយោជន៍ទាំងឡាយ របស់ព្រះអង្គទេឬ ។

(២៣២) អថោបិ មេ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ
អថោបិ តេ មមត្ថេសុ អវកង្ខន្តិ ជីវិតំ ។

(២៣៣) កច្ចិ តេ សាទិសី ភរិយា អស្សវា បិយភាណិនី
បុត្តរូបយសូបេតា តវ ឆន្ទវសានុគា ។

(២៣៤) អថោ មេ សាទិសី ភរិយា អស្សវា បិយភាណិនី
បុត្តរូបយសូបេតា មម ឆន្ទវសានុគា ។

(២៣៥) កច្ចិ រដ្ឋំ អនុប្បីឡំ អកុតោចិឧបទ្ទវំ
អសាហសេន ធម្មេន សមេន អនុសាសសិ ។

(២៣៦) អថោ រដ្ឋំ អនុប្បីឡំ អកុតោចិ ឧបទ្ទវំ
អសាហសេន ធម្មេន សមេន អនុសាសហំ ។

(២៣៧) កច្ចិ សន្តោ អបចិតា អសន្តោ បរិវជ្ជិតា
នោ ច ធម្មំ និរង្កត្វា អធម្មមនុវត្តសិ ។

[២៣២] ( ព្រះរាជា... ) ទោសតិចតួច របស់យើងមិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតចំពោះប្រយោជន៍ទាំងឡាយ របស់យើងទេ ។

[២៣៣] (រាជហង្ស...) អគ្គមហេសីដែលមានជាតិស្មើនឹងព្រះអង្គ ជាស្ត្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយស ជាស្ត្រីលុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គទេឬ ។

[២៣៤] (ព្រះរាជា...) អគ្គមហេសីដែលមានជាតិស្មើនឹងយើង ជាស្ត្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ បានប្រកបដោយបុត្ត រូបនិងយស ជាស្ត្រីលុះអំណាចសេចក្តីប្រាថ្នារបស់យើង ។

[២៣៥] (រាជហង្ស...) ព្រះអង្គមិនបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយអាការ មិនរួសរាន់តាមធម៌ដ៏ស្មើទេឬ ។

[២៣៦] (ព្រះរាជា..) យើងមិនបានបៀតបៀនអ្នកដែនដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយការមិនរួសរាន់តាមធម៌ដ៏ស្មើ ។

[២៣៧] (រាជហង្ស...) ព្រះអង្គទ្រង់បានគោរពពួកសប្បុរសវៀរបង់ពួកអសប្បុរស មិនលះបង់នូវធម៌ ហើយប្រព្រឹត្តនូវអធម៌ទេឬ ។

(២៣៨) សន្តោ ច មេ អបចិតា  អសន្តោ បរិវជ្ជិតា
ធម្មេ មេ កនុវត្តាមិ  អធម្មោ មេ និរន្តោ ។
(១)
(២៣៩) កច្ចិ នុ ជាតតំ ទីឃំ  សមវេក្ខសិ ខត្តិយ
កច្ចិ មត្តោ មទនីយេ  បរលោកំ ន សន្តសិ ។
(២៤០) អហំ អជាតតំ ទីឃំ  សមវេក្ខាមិ បក្ខិម
(២)
ឋិតោ ទសសុ ធម្មេសុ  បរលោកំ ន សន្តសឹ ។
ទានំ សីលំ បរិច្ចាគំ  អាជ្ជវំ មទ្ទវំ តបំ
អក្កោធំ អវិហឹសញ្ច  ខន្តិញ្ច អវិរោធនំ ។
ឥច្ចេតេ កុសលេ ធម្មេ  ឋិតេ បស្សាមិ អត្តនិ
តតោ មេ ជាយតេ បីតិ  សោមនស្សញ្ចនប្បកំ ។
សុមុខោ ច អចិន្តេត្វា  វិសជ្ជិ ផរុសំ គិរំ
ភាវទោសមនញ្ញាយ  អស្មាកាយំ វិហង្គមោ ។

១ ឱ. កច្ចិ នាជាតតំ ។ ២ ឱ.ម. សន្តសេ ។

[២៣៨] (ព្រះរាជា...) យើងបានគោរពនូវពួកសប្បុរស វៀរបង់នូវពួកអសប្បុរស យើងបានលះបង់នូវអធម៌ ហើយប្រព្រឹត្តតាមធម៌តែម្យ៉ាង ។

[២៣៩] (រាជហង្ស...) បពិត្រក្សត្រ ព្រះអង្គទ្រង់រំពឹង នូវកាលជាអនាគតដ៏វែងដែរឬ ព្រះអង្គស្រវឹង ក្នុងអារម្មណ៍ ជាទីតាំងនៃសេចក្តីស្រវឹងហើយ មិនតក់ស្លុតនឹងបរលោកទេឬ ។

[២៤០] (ព្រះរាជា...) ម្នាលបក្សី យើងតែងប្រមើលមើលនូវកាលអនាគតដ៏វែង យើងឋិតនៅ ក្នុងធម៌ ១០ ប្រការ មិនតក់ស្លុតនឹងបរលោកឡើយ ។ (ធម៌១០ប្រការគឺ) ទាន ១ សីល ១ បរិច្ចាគ ១ ភាពនៃចិត្តត្រង់ ១ ភាពនៃចិត្តទន់ ១ តបៈគឺឧបោសថ-សីល ១ ការមិនក្រោធ ១ ការមិនបៀតបៀន ១ ខន្តិ ១ កិរិយាមិនក្ញាត់១ ។ យើងឃើញ នូវកុសលធម៌ទាំងនេះ ឋិតនៅក្នុងខ្លួន លំដាប់នោះ បីតិនិងសោមនស្សជាច្រើន កើតឡើងដល់យើង ដោយប្រការដូច្នេះ ។ ឯបក្សី ឈ្មោះសុមុខៈ មិនបានគិត ហើយបញ្ចេញ នូវវាចាដ៏ទ្រគោះ ព្រោះតែមិនបានដឹងច្បាស់ នូវការប្រទូស្ត ក្នុងចិត្ត របស់យើង ។ បក្សីនោះ

សោ កុទ្ធោ ផរុសំ វាចំ និច្ឆារេសិ អយោនិសោ
យានស្មាសុ ន វិជ្ជន្តិ នយិទំ បញ្ញវតាមិវ ៕

[២៤១] អត្ថិ មេ តំ អតិសារំ វេគេន មនុជាធិប
ធតរដ្ឋេ ច ពទ្ធស្មឹ ទុក្ខំ មេ វិបុលំ អហុ ៕
ត្វំ នោ បិតាវ បុត្តានំ ភូតានំ ធរណីរិវ
អស្មាកំ អធិបន្នានំ ត្វមស្សុ រាជកុញ្ជរ ៕

[២៤២] ឯវំ តេ អនុមោទាម យំ ភាវំ ន និគូហសិ
សីលំ បតិដ្ឋសិ បក្ខិ ឧជុកោសិ វិហង្គម ៕

[២៤៣] យង្កិញ្ចិ រតនំ អត្ថិ កាសិរាជនិវេសនេ
រជតំ ជាតរូបញ្ច មុត្តា វេឡុរិយា ពហូ ៕

លុះខឹងហើយ ក៏បញ្ចេញនូវវាចាដ៏ទ្រគោះ ដោយឥតគំនិត (ពោល) នូវទោសទាំងឡាយដែលមិនមានក្នុងពួកយើង ពាក្យនេះមិនមែនដូចពាក្យនៃបុគ្គលមានប្រាជ្ញា (ពោលហើយ)ទេ ។

[២៨១] (ហង្សសេនាបតី...) បពិត្រព្រះអង្គជាធំជាងពួកមនុស្ស ទូលព្រះបង្គំជាខ្ញុំ មានសេចក្ដីក្ដាំងក្ដាត់នោះ ព្រោះពោលពាក្យដោយរួសរាន់ពេក ដ្បិតកាលដែលរាជហង្សឈ្មោះធតរដ្ឋៈ ជាប់បំណាន់ ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីទុក្ខដ៏ធំ ។ បពិត្រព្រះអង្គ ជារាជកុញ្ជរ ព្រះអង្គ (ជាទីពឹង) នៃពួកទូលព្រះបង្គំជាខ្ញុំ ដូចជាបិតា (ជាទីពឹង) នៃកូន ឬដូចធរណី (ជាទីពឹង) នៃពួកកូន សូមព្រះអង្គអត់ទោស ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលត្រូវសេចក្ដីខុសគ្របសង្កត់ ។

[២៨២] (ព្រះរាជា...) យើងរីករាយចំពោះអ្នកយ៉ាងនេះ ព្រោះថាអ្នកមិនលាក់នូវភាវៈនៃចិត្តដ៏កំបាំងរបស់ខ្លួន ម្នាលបក្សី អ្នកបានទំលាយចោលនូវចិត្តរឹងត្អឹង ម្នាលបក្សី អ្នកជាសត្វមានចិត្តត្រង់ ។

[២៨៣] រតនៈណាមួយ គឺប្រាក់ មាស កែវមុក្ដា កែវពៃទូរ្យ ជាច្រើន មាននៅ ក្នុងព្រះរាជនិវេសន៍ ក្នុងដែនកាសី ។

មណយោ សង្ខមុត្តញ្ច វត្ថកំ ហរិចន្ទនំ
អជិនំ ទន្តភណ្ឌញ្ច លោហំ កាឡាយសំ ពហុំ
ឯតំ ទទាមិ តេ វិត្តំ ឥស្សរំ វិស្សជាមិ តេ ។

(២៤៤) អទ្ធា អបចិតា ត្យម្ហា សក្កតា ច រថេសភ
ធម្មេសុ វត្តមានានំ ត្វំ នោ អាចរិយោ ភវ ។
អាចរិយ សមនុញ្ញាតា តយា អនុមតា មយំ
តំ បទក្ខិណតោ កត្វា ញាតិំ បស្សេមុរិន្ទម ។

(២៤៥) សព្វរត្តិំ ចិន្តយិត្វា មន្តយិត្វា យថាតថំ
កាសិរាជា អនុញ្ញាសិ ហំសានំ បវរុត្តមំ ។

(២៤៦) តតោ រត្យា វិវសានេ សុរិយុគ្គមនំ បតិ
បេក្ខតោ កាសិរាជស្ស ភវនា តេ វិគាហិសុំ ។

មួយទៀត កែវមណី សង្ខ(ជាទក្ខិណាវដ្ដ)កែវមុក្ដា( មានសណ្ឋាន មូលដូចផ្លែកន្ទួតព្រៃ) សំពត់ខ្មៅចន្ទន៍ក្រហម ស្បែកខ្លាឃ្មុំ កណ្ឌៈ ជាវិការៈនៃក្តុក លោហៈក្រហម និងលោហៈឡើងច្រើន យើងឲ្យនូវទ្រព្យទាំងនេះដល់អ្នក យើងនឹងលះបង់នូវការៈជាធំដល់អ្នក ។

(២៨៤) ( ពងហង្ស... ) បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ព្រះអង្គបានគោរព ធ្វើសក្ការៈ (ដល់យើងទាំងឡាយ) ដោយពិត សូមព្រះអង្គជាអាចារ្យរបស់យើង ដែលជាអ្នកប្រព្រឹត្ត ក្នុងធម៌ទាំងឡាយ ។ បពិត្រព្រះអង្គជាអាចារ្យ ព្រះអង្គបានអនុញ្ញាត បើកយើងទាំងឡាយឲ្យទៅដោយស្រួលហើយ បពិត្រព្រះអង្គជាអ្នកទូន្មាននូវសត្រូវ យើងទាំងឡាយ សូមធ្វើប្រទក្សិណនូវព្រះអង្គហើយទៅចួបនឹងពួកញាតិ ។

(២៨៥) ( អភិសម្ពុទ្ធគាថា ) ព្រះរាជាក្នុងដែនកាសី ទ្រង់បានគិតបានប្រឹក្សា នូវហេតុដ៏គួរតាមពិត ពេញមួយរាត្រី ហើយទ្រង់អនុញ្ញាតឲ្យពងហង្សដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកហង្ស ហើរទៅ ។

(២៨៦) លំដាប់នោះ កាលដែលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង កាលព្រះរាជា ក្នុងដែនកាសី ទ្រង់កំពុងទតមើលសត្វហង្សទាំងពីរ ក៏ហើរចេញទៅ អំពីទីនៅរបស់ព្រះរាជា ។

(២៨៧) តេ អហេ តេ អនុប្បត្តេ និស្សាន បរមេ និធេ
ភោគាតិមគុំ ហំសា បុថុសទ្ធោ អជាយេថ ។
តេ បតីតា បមុត្តេន ភត្តុនា ភត្តុគារវា
សមន្តា បរិកិរិំសុ អណ្ឌជា លទ្ធបច្ចយា ។
(២៨៨) ឯវំ មិត្តវតំ អត្ថា សព្វេ ហោន្តិ បទក្ខិណា
ហំសា យថា ធតរដ្ឋា ញាតិសង្ឃមុបាគមុន្តិ ។

មហាហំសជាតកំ ទុតិយំ ។

# សុធាភោជនជាតកំ

(២៨៩) នេវ កិណាមិ ន វិក្កិណាមិ
ន ចាបិ មេ សន្និចយោ ឥធត្ថិ[១]
សុកិច្ឆរូបំ វតិទំ បរិត្តំ
បត្ថោទនោ នាលមយំ ទុវិន្នំ ។
(២៩០) អប្បម្ហា អប្បកំ ទជ្ជា អនុមជ្ឈតោ មជ្ឈកំ
ពហុម្ហា ពហុកំ ទជ្ជា អទានំ នុបបជ្ជតិ ។

---

១ ឱ.ម. ប អត្ថិ ។

(២៤៧) ហង្សទាំងឡាយ លុះបានឃើញបក្សីហង្សដ៏ប្រសើរ ទាំងពីរនោះ មិនមានភេទ មកដល់ហើយ ក៏ធ្វើនូវសាមុងថាកេកា ។ ដូច្នេះ សូរសព្ទាំពង់ក៏កើតឡើង ។ បក្សីហង្សជាអណ្ឌជាតិ ទាំងនោះ មានចិត្តរីករាយ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពម្ចាស់ ជាសត្វបាននូវទីពឹង ក៏ហោមរោមម្ចាស់ដោយជុំវិញ ។

(២៤៨) ប្រយោជន៍គ្រប់យ៉ាង របស់ពួកជនអ្នកមានមិត្រល្អ រមែងជាប្រយោជន៍គួរចំរើន ដូចហង្សឈ្មោះធតរដ្ឋៈនឹងហង្សឈ្មោះសុមុខៈ បានចូលទៅចួបនឹងពួកញាតិ ។

ចប់ មហាហង្សជាតក ទី ២ ។

## សុធាភោជនជាតក

(២៤៩) (កោសិយសេដ្ឋី ពោលថា) ខ្ញុំមិនមែនទិញ មិនមែនលក់ទេ មួយទៀត ការសន្សំទុករបស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ របស់នេះ មានប្រមាណតិច មានសភាពដ៏ក្រណាស់ បាយបំនួនអឌ្ឍមួយនាឡិនេះ មិនល្មមដល់ជនពីរនាក់ទេ ។

(២៥០) (សក្កទេវរាជ ពោលថា) បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គួរឲ្យវត្ថុ ពាក់កណ្ដាល អំពីវត្ថុ ពាក់កណ្ដាល គួរឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិនកើតទេ ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារូហ នេកាសី លភតេ សុខំ ។

[២៨១] មោឃញ្ចស្ស ហុតំ ហោតិ មោឃញ្ចាបិ សមីហិតំ

អតិថិស្មិំ យោ និសិន្នស្មិំ ឯកោ ភុញ្ជតិ ភោជនំ ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារូហ នេកាសី លភតេ សុខំ ។

[២៨២] សច្ចញ្ចស្ស ហុតំ ហោតិ សច្ចញ្ចាបិ សមីហិតំ

អតិថិស្មិំ យោ និសិន្នស្មិំ នេកោ ភុញ្ជតិ ភោជនំ ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារូហ នេកាសី លភតេ សុខំ ។

ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យនូវទានផង ចូរបរិភោគផង អ្នកចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

[២៤១] (ចន្ទទេវបុត្ត...) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ បរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការឥតអំពើ ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ (របស់បុគ្គលនោះ) ក៏ឥតអំពើដែរ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

[២៤២] (សុរិយទេវបុត្ត...) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ មិនបរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការបូជាពិតមែន ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ(របស់បុគ្គលនោះ)ក៏ជាការព្យាយាមពិតមែន ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(២៨៣) សរញ្ចេ ជុហតិ បោសោ ពហុកាយ គយាយ ច
ទោណេ តិម្ពរុតិត្ថស្មិំ សីឃសោតេ មហាវហេ ។
អគ្គញ្ចស្ស ហុតំ ហោតិ អគ្គញ្ចស្ស សមីហិតំ
អតិថិស្មិំ យោ និសិន្នស្មិំ នេកោ ភុញ្ជតិ ភោជនំ ។
តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ នេកាសី លភតេ សុខំ ។

(២៨៤) ពលិសំ ហិ សោ និគិលតិ ទីឃសុត្តំ សពន្ធនំ
អតិថិស្មិំ យោ និសិន្នស្មិំ ឯកោ ភុញ្ជតិ ភោជនំ ។
តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ នេកាសី លភតេ សុខំ ។

(៤៩៣) (មាតលិទេវបុត្ត...) បុរសបូជាស្រះក្តី ទន្លេឈ្មោះពហុកា ឬស្រះបោក្ខរណីឈ្មោះគយាក្តី ក៏ពង់ឈ្មោះទោណៈ ឬក៏ពង់ឈ្មោះតិម្ពរុក្តី ទន្លេដ៏មានខ្សែទឹកដ៏រហ័សក្តី ។ ការបូជារបស់បុរសនោះក្នុងទីនោះ រមែងមាន (ផល) ទាំងការព្យាយាមជាហេតុឱ្យកើតទ្រព្យរបស់បុរសនោះ ក្នុងទីទាំងនោះ ក៏មានផលដែរ ព្រោះថា បុរសនោះ កាលបើភ្ញៀវអង្គុយនៅហើយ មិនគួរបរិភោគភោជនម្នាក់ឯងទេ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឱ្យទានផង បរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគភោជនម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(៤៩៤)(បញ្ចសិខទេវបុត្ត...)បុគ្គលណា កាលបើភ្ញៀវអង្គុយនៅហើយ បរិភោគភោជនម្នាក់ឯង បុគ្គលនោះឈ្មោះថាលេបសន្ទូចដែលមានខ្សែដ៏វែងព្រមទាំងចំណី ។ ម្នាលកោសិយៈព្រោះហេតុនោះ យើងនិយាយនឹងអ្នកចូរអ្នកឱ្យទានផងចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសុខទេ ។

[២៥៥] ឧឡារវណ្ណា វត ព្រាហ្មណា ឥមេ
អយញ្ច វោ សុនខោ កិស្ស ហេតុ
ឧច្ចាវចំ វណ្ណនិភំ វិកុព្វតិ
អក្ខាថ នោ ព្រាហ្មណា កេ នុ តុម្ហេ ។
[២៥៦] ចន្ទោ ច សុរិយោ ច ឧភោ ឥធាគតា
អយំ បន មាតលិ ទេវសារថិ
សក្កោហមស្មិ តិទសានមិន្ទោ
ឯសោ ច ខោ បញ្ចសិខោតិ វុច្ចតិ ។
[២៥៧] ឆាណិស្សរា មុទិង្គា ច មុរជាលម្ពរានិ ច
សុត្តមេនំ បពោធេន្តិ បដិពុទ្ធោ ច នន្ទតិ ។
[២៥៨] យេ កេចិមេ មច្ឆរិនោ កទរិយា
បរិភាសកា សមណព្រាហ្មណានំ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា និរយំ វជន្តិ ។
យេ កេចិមេ សុគតិមាសីសមានា
ធម្មេ ឋិតា សំយមេ សំវិភាគេ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា សុគតឹ វជន្តិ ។

[២៤៥] ( កោសិយសេដ្ឋី... ) អើហ្ន៎ ព្រាហ្មណ៍ទាំងនេះ ពេញជាមានសម្បុរល្អលើសលុប ប៉ុន្តែនេះ របស់ពួកអ្នក ក្លែងខ្លួនឲ្យមានពណ៌រុងរឿងប្លែកៗ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយប្រាប់យើង អ្នកទាំងឡាយជាអ្វី ។

[២៤៦] ( ព្រះឥន្ទ្រ... ) ព្រាហ្មណ៍ទាំងពីរនាក់ដែលមកក្នុងទីនេះ គឺចន្ទទេវបុត្ត និងសុរិយទេវបុត្ត ចំណែកព្រាហ្មណ៍នេះ គឺមាតលិទេវបុត្ត ដែលជាទេវសារថី ឯយើងជាសក្កៈ ជាធំជាងពួកទេវតាក្នុងជាន់តាវត្តិង្ស ឯព្រាហ្មណ៍នេះគេហៅថាបញ្ចសិខៈ ។

[២៤៧] ល្បែងទះដៃក្តី ស្គរសំភោរក្តី ស្គរតូចនិងស្គរធំក្តី តែងញុំាងបញ្ចសិខទេវបុត្តនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើងបាន លុះបញ្ចសិខទេវបុត្តនោះ ភ្ញាក់ឡើងហើយ រមែងរីករាយ ។

[២៤៨] ពួកជនណានីមួយ មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកប្រទេចផ្តាសានូវសមណព្រាហ្មណ៍ ពួកជននោះ ដាក់ចុះនូវរាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយរាងកាយហើយ រមែងទៅកើតក្នុងនរក ។ ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌គឺការសង្រួមនិងការចែករំលែកនូវទាន ពួកជននោះ ដាក់ចុះនូវរាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយរាងកាយ រមែងទៅកាន់សុគតិ ។

អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

(២៥៩) ត្វំ នោ ញាតិ បុរិមាសុ ជាតិសុ
សោ មច្ឆរី កោសិយោ បាបធម្មោ
តវេវ អត្ថាយ ឥធាគតម្ហា
មា បាបធម្មោ និរយំ អបត្ថ ។

(២៦០) អទ្ធា ហិ មេ តេ ហិតកាមា យំ មំ សមនុសាសថ
សោហំ តថា ករិស្សាមិ សព្វំ វុត្តំ ហិតេសិភិ ។
ឯសោហមជ្ជេវ ឧបារមាមិ
ន ចាបិហំ កិញ្ចិ ករេយ្យ បាបំ
ន ចាបិ មេ កិញ្ចិ អទេយ្យមត្ថិ
ន ចាបិទត្វា ឧទកំ បិវាមិ ។
ឯវញ្ច មេ ទទតោ សព្វកាលំ
ភោគាបិ មេ វាសវ ខីយិស្សន្តិ
តតោ អហំ បព្វជិស្សាមិ សក្ក
ហិត្វា កាមានិ យថោធិកានិ ។

(២៦១) នគុត្តមេ គិរិវរេ គន្ធមាទនេ
មោទន្តិ តា ទេវវរាភិបាលិតា

[២៥៩] អ្នកជាញាតិរបស់យើងក្នុងជាតិមុន អ្នកនោះឈ្មោះកោសិយៈ ជាបុគ្គលកំណាញ់ មានធម៌ដ៏លាមក យើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នកតែម្យ៉ាងថា ញាតិរបស់យើងដែលមានធម៌ដ៏លាមក កុំទៅកាន់នរកឡើយ ។

[២៦០] ( កោសិយសេដ្ឋី... ) អ្នកទាំងឡាយនោះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះថា អ្នកទាំងឡាយបានប្រៀនប្រដៅខ្ញុំដោយល្អ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលអ្នកទាំងឡាយជាអ្នកស្វែងរកប្រយោជន៍ បានពោលហើយដូច្នោះ ។ ខ្ញុំនោះវៀរចាកសេចក្តីកំណាញ់ ក្នុងថ្ងៃនេះឯង ខ្ញុំមិនធ្វើអំពើអាក្រក់តិចតួច ខ្ញុំមិនមែនជាមិនឲ្យវត្ថុតិចតួចទេ បើខ្ញុំមិនទាន់បានឲ្យទានទឹក មិនផឹកនូវទឹកទេ ។ បពិត្រព្រះវាសវៈ កាលខ្ញុំឲ្យទានសព្វកាលយ៉ាងនេះ ភោគៈទាំងឡាយរបស់ខ្ញុំ មុខជានឹងអស់ទៅ បពិត្រសក្កៈ តអំពីនេះទៅ ខ្ញុំនឹងលះនូវកាមទាំងឡាយតាមចំណែកហើយបួស ។

[២៦១] ( អភិសម្ពុទ្ធគាថា ) ពួកទេវតានោះ ដែលទេវរាជ ត្រេក ហើយករកាយ លើកគន្ធមានទន់ប្រសើរ ដែលជាក្ដំខ្ពង់ខ្ពស់

អជាគមា ឥសិវរោ សព្វលោកគូ
សុបុប្ផិតំ ទុមវរសាខមាទិយ ។
សុចឹ សុគន្ធំ តិទសេហិ សក្កតំ
បុប្ផុត្តមំ អមរវរេភិ សេវិតំ
អលទ្ធមញ្ញេហិ វ ទានវេហិ
អញ្ញត្រ ទេវេហិ តទរហំ ហិតំ ។
តតោ ចតស្សោ កនកត្តចូបមា
ឧដ្ឋាយ នារិយោ បមុទាជិតា មុនឹ
អាសា ច សទ្ធា ច សិរី តតោ ហិរី
ឥច្ចុត្រាំ នាមំ ទេវព្រាហ្មណំ ។
សចេ អនុទ្ទិដ្ឋំ តយា មហាមុនិ
បុប្ផំ ឥទំ បារិឆត្តស្ស ព្រហ្មេ
ទទាហិ នោ សព្វា គតិ តេ ឥជ្ឈតុ
តុម្បិ នោ ហោហិ យថេវ វាសវោ ។
តំ យាចមានាភិសមេក្ខ នារទោ
ឥច្ចព្រវី សង្កលហំ ឧទីរយិ
ន មយ្ហមត្ថិ ឥមេហិ កោចិ នំ
យាយេវ វោ សេយ្យសិ សា បិឡន្ធតុ[១] ។

១ ឱ. បិលយ្ហហថ ។ ម. បិឡន្ធថ ។

គ្រានោះ ឥសីដ៏ប្រសើរ ជាអ្នកអាចទៅកាន់លោកទាំងអស់ បានកាន់យក នូវផ្កាទិព្វសាខា ដែលកើស្គុះស្គុយ និមន្តមក ៗ ផ្កានោះ ជាផ្កាស្អាត មានក្លិនក្រអូប ដែលពួកទេវតាក្នុងជាន់ត្រៃត្រិង្ស ធ្វើសក្ការៈហើយ ជាផ្កាដ៏ឧត្តម ដែលពួកទេវតាដ៏ប្រសើរសេពហើយ ពួកមនុស្សដទៃក្តី ពួកអសុរក្តី វៀរលែងតែពួកទេវតាមិនដែលបានឡើយ ព្រោះថា ផ្កានោះ ជាប្រយោជន៍ដ៏សមគួរដល់ ( ពួកទេវតាទាំងនោះ ) ៗ លំដាប់នោះ នារីទាំងបួន ដែលជាធំលើសអស់ពួកស្រី មានស្បែកក្លិនដូចមាស ឈ្មោះអាសា ១ សទ្ធា១ សិរី ១ ហិរី ១ បានក្រោកឡើង ហើយទូលសួរនារទតាបស ជាអ្នកប្រាជ្ញ ទាំងជាព្រាហ្មណ៍ដ៏ប្រសើរដូច្នេះថា បពិត្រមហាមុនីដ៏ប្រសើរ បើផ្កាបរិច្ឆត្តព្រឹក្សនេះ លោកមិនឧទ្ទិស (អ្នកណាទេ) សូមលោកឲ្យដល់ពួកយើង គតិ ( នៃចិត្ត ) ទាំងពួង សូមសម្រេចដល់លោក ទោះបីលោកក៏សូម (ឲ្យមានមេត្តា) ចំពោះពួកយើង ដូចជាព្រះវាសវៈដែរ ៗ នារទតាបស បានឃើញពួកនារីមកសុំនូវផ្កានោះ ក៏ពោលថា នាងនិយាយនូវពាក្យនាំឲ្យបង្កជំលោះ ប្រយោជន៍តិចតួចដោយផ្កាឈើទាំងនេះ មិនមានដល់យើងទេ នាងណា ដែលបម្យុងជាងនាងទាំងឡាយ នាងនោះ ចូរប្រដាប់ផ្កានេះចុះ ៗ

អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

(២៦២) ត្វំ នោត្តមោភាភិសមេក្ខ (១) នារទ
យស្សិច្ឆសិ តស្សានុប្បវេច្ឆសុ
យស្សា ហិ នោ នារទ ត្វំ បទស្សសិ
សាយេវ នោ ហោហិតិ សេដ្ឋសម្មតា ។

(២៦៣) អកល្យមេតំ វចនំ សុគត្តេ
កោ ព្រាហ្មណោ កោ កលហំ ឧទីរយេ
គន្ត្វាន ភូតាធិបមេវ បុច្ឆ
សចេ ន ជានាថ ឥធុត្តមធម្មំ ។

(២៦៤) តា នារទេន បរមប្បកោបិតា
ឧទីរិតា វណ្ណមទេន មត្តា
សកាសំ គន្ត្វាន សហស្សចក្ខុនោ
បុច្ឆឹសុ ភូតាធិបំ កា នុ សេយ្យសិ ។

(២៦៥) តា ទិស្វា អាយត្តមនា បុរិន្ទទោ
ឥច្ចាព្រវី ទេវវរោ កតញ្ជលី

១ ឱ. នោត្តមោវាភិសមេក្ខ ។

[២៦២] ( ពួកទេវធីតា... ) បពិត្រនារទតាបសដ៏ឧត្តម សូមលោករមិលមើលនូវពួកយើងចុះ បើលោកប្រាថ្នានឹងឲ្យដល់នាងណា សូមលោកបោះផ្កានោះសំដៅទៅនាងនោះ បពិត្រនារទតាបស ព្រោះថាបណ្តាពួកយើង បើលោកឲ្យដល់នាងណា នាងនោះឯងយើងសន្មតថា ប្រសើរបំផុតជាងគេ ៗ

[២៦៣] ( នារទតាបស... ) នែនាងមានខ្លួនដ៏ល្អ សំដីនេះមិនគួរទេ បុគ្គលដូចម្តេច ដែលហៅថាព្រាហ្មណ៍ បុគ្គលដូចម្តេច គួរពោលពាក្យដែលនាំបង្កជំលោះ បើនាងទាំងឡាយមិនដឹងធម៌ដ៏ខ្ពង់ខ្ពស់ ក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ ៗ

[២៦៤] ពួកទេវធីតាទាំងនោះ ដែលនារទតាបស បានពោលយ៉ាងនេះហើយ ក៏មានចិត្តក្រេវក្រោធយ៉ាងក្រៃលែង ជាស្ត្រីស្រវឹងដោយសេចក្តីស្រវឹងនឹងសម្បុរ ហើយបានទៅកាន់សំណាក់ព្រះឥន្ទ្រ ជាសហស្សចក្ខុ រួចសួរនូវព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាថា ( បណ្តាពួកយើង ) នាងណាប្រសើរជាងគេ ៗ

[២៦៥] ព្រះឥន្ទ្រ ដ៏ប្រសើរជាងពួកទេវតា ដែលពួកទេវតាតែងប្រណម្យអញ្ជលី លុះបានឃើញ នូវពួកទេវធីតា ទាំងនោះ មានចិត្តខ្វល់ខ្វាយ ក៏បានពោលតប ដូច្នេះថា

សព្វាវ តេ ហោន្តុ សុកត្តេ(១) សាធិសី
កោសេវ កត្តុ កលហំ ឧទីរយិ ។

(២៦៦) យោ សព្វលោកត្តរកោ មហាមុនិ
ធម្មេ ឋិតោ នារទ(២) សព្វធិក្ខមោ
សោ នោ ព្រូហិ គិរិវរេ គន្ធមាទនេ
គន្ត្វាន កុតាធិបមេវ បុច្ឆ
សបេ ន ជានាថ អនុត្តមជ្ឈំ ។

(២៦៧) អស្ស ព្រហ្មារញ្ញចរកេ មហាមុនិ
ជាតត្វា កត្តុំ វរគត្តេ កុញ្ជតិ
វិចេយ្យ នានានិ ធនានិ កោសិយោ
យស្ស ហិ សោ ទស្សតិ សាវ សេយ្យសិ ។

(២៦៨) អស្ស ហិ សោ សម្មតិ ទក្ខិណំ ទិសំ
គន្តាយ តីរេ ហិមវន្តបស្សនិ(៣)
ស កោសិយោ ទុល្លភបានភោជនោ
តស្ស សុធំ បាបយ ទេវសារថិ ។

(២៦៩) សោ មាតលិ ទេវវរេន បេសិតោ

---

១ ឱ. ម. សុគត្តេ ។ ២ ឱ. ម. ទារកេ ។ ៣ ឱ. ម. ហិមវន្តបស្សនិ ។

ដែននាងមានជោគល្អ នាងទាំងអស់ប្រហែល ៗ គ្នាទេ ម្នាលនាងដ៏ចំរើន ចុះបុគ្គលណាហ្ន៎ បានពោលពាក្យ ដែលនាំបង្កដំណោះ ៗ

[២៦៦] (ពួកទេវធីតា...) នារទតាបសណា ជាមហាមុនីអាចត្រាច់ទៅក្នុងលោកទាំងអស់បាន ឋិតនៅក្នុងធម៌ មានព្យាយាមដ៏ទៀងទាត់ នារទតាបសនោះ បានពោលនឹងពួកយើងលើក្តីដ៏ប្រសើរឈ្មោះគន្ធមាទន៍ថា បើនាងទាំងឡាយ មិនដឹងនូវធម៌ដ៏ឧត្តមក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ ៗ

[២៦៧] (ព្រះឥន្ទ្រ...) ម្នាលនាងមានខ្លួនដ៏ប្រសើរ តាបសឯណោះជាមហាមុនី ជាអ្នកត្រាច់ទៅក្នុងព្រៃធំ បើមិនទាន់ឲ្យទាន មិនបរិភោគនូវភត្តទេ កោសិយតាបសនោះ ពិចារណាហើយ ទើបឲ្យនូវទានទាំងឡាយ ព្រោះថា តាបសនោះ នឹងឲ្យផ្កាដល់នាងណា នាងនោះឯង ពេញជាប្រសើរជាងគេ ៗ

[២៦៨] តាបសឯណោះនោះ គង់នៅក្នុងទិសខាងត្បូងនៃភ្នំហិមវន្តប្របឆ្នេរទន្លេគង្គា កោសិយតាបសនោះ បានទឹកនឹងភោជនដោយកម្រ ម្នាលមាតលិទេវបុត្ត ជាទេវសារថិ អ្នកចូរនាំសុធាភោជន ឲ្យសម្រេចដល់កោសិយតាបសចុះ ៗ

[២៦៩] មាតលិទេវបុត្តនោះ លុះព្រះឥន្ទ្រប្រសើរជាងទេវតាប្រើហើយ

អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

សហស្សយុត្តំ អភិរុយ្ហ សន្ទនំ
សុខិប្បមេវ ឧបគម្ម អស្សមំ
អទិស្សមានោ មុនិនោ សុធំ អទា(១) ។

[២៧០] ឧទ្ទគ្គិហុត្តំ ឧបតិដ្ឋតោ ហិ មេ
បភង្ករំ លោកតមោនុទុត្តមំ
សព្វានិ ភូតានិ អធិច្ច វាសវោ
កោ នេវ មេ បាណិសុ កឹ សុធោទហិ ។
សង្ខូបមំ សេតមតុល្យទស្សនំ
សុចឹ សុគន្ធំ បិយរូបមព្ភុតំ
អទិដ្ឋបុព្វំ មម ជាតិចក្ខុភិ
កា ទេវតា បាណិសុ កឹ សុធោទហិ ។

[២៧១] អហំ មហិន្ទេន មហេសិ បេសិតោ
សុធាភិហាសឹ តុរិតោ មហាមុនិ
ជានាសិ មំ មាតលិ ទេវសារថិ
ភុញ្ជស្សុ ភត្តុត្តមំ មាភិវារយិ(២) ។
ភុត្តា ច សា ទ្វាទស ហន្តិ បាបកេ
ខុទ្ទំ បិបាសំ អរតឹ ទរថំ កិលំ(៣)

---

១ ឱ. អទាតិ ។ ម. អទាសិ ។ ២ ឱ. មាភិវារយិ ។ ៣ ឱ. ទុក្ខំ ។ ម. ទរថក្លមំ ។

ក៏ឡើងជិះទេវរថ ដែលទឹមដោយសេះមួយពាន់ ហើយចូលទៅកាន់អាស្រមយ៉ាងរហ័ស មិនបង្ហាញកាយឲ្យឃើញ ស្រាប់តែប្រគេននូវសុធាភោជន ដល់តាបសជាអ្នកប្រាជ្ញ ។

(២៧០) (កោសិយតាបស...) កាលដែលអាត្មាអញបំរើនូវការបូជាភ្លើងនិងព្រះអាទិត្យដ៏ឧត្តម ដែលបន្ទោបង់នូវងងឹតក្នុងលោក អ្នកណាហ្ន៎ ដូចព្រះវាសវៈ កន្លងនូវពួកទេវតាទាំងអស់ ដាក់សុធាភោជន លើដៃទាំងពីររបស់អញហ្ន៎ ។ សុធាភោជននោះដ៏សដូចជាស័ង្ខ គួរមិលមើល រកអ្វីប្រៀបគ្មាន ជាភោជនស្អាត មានក្លិនក្រអូប មានសភាពគួរពេញចិត្តយ៉ាងចំឡែក ក្នុងរបស់អញតាំងអំពីកើតមក មិនដែលឃើញសោះឡើយ ទេវតាណាហ្ន៎ ដាក់នូវសុធាភោជន លើដៃទាំងពីររបស់អញហ្ន៎ ។

(២៧១) (មាតលិទេវបុត្ត...) បពិត្រលោក ជាមហាមុនី អ្នកស្វែងរកនូវគុណដ៏ធំ ខ្ញុំដែលព្រះឥន្ទ្រជាធំបានប្រើមក ខ្ញុំក៏បាននាំសុធាភោជនយ៉ាងរួសរាន់ លោកបានស្គាល់នូវខ្ញុំថាឈ្មោះមាតលិទេវបុត្ត ជាទេវសារថី សូមលោកឆាន់នូវភត្តដ៏ឧត្តមចុះ លោកកុំប្រកែករាំងឡើយ ។ ឯសុធាភោជននោះ លុះលោកបរិភោគហើយ រមែងកំចាត់បង់បាបធម៌ ១២ យ៉ាងបានគឺ សេចក្តីឃ្លាន១ ការស្រេក១ សេចក្តីអផ្សុក១ ក្រវល់ក្រវាយកាយ១ លំបាកកាយ១

កោធូបនាហញ្ច វិវាទបេសុណំ
សីតុណ្ហតណ្ហិញ្ច រសុត្តមំ ឥទំ ។
[២៧២] ន ទេវប្បតិ មាតលិ មយ្ហ កុញ្ចិតុំ
បុត្តេ អទត្វា ឥតិ មេ វតុត្តមំ
ន ចាបិ ឃាសេនមរិយបូជិតំ
អសំវិភាគី ច សុខំ ន វិន្ទតិ ។
[២៧៣] ជីយាតកា យេ កោចិមេ បរទារិកា
មិត្តទ្ទុនោ យេ ច សបន្តិ សុព្វតេ
សព្វេ តេ មច្ឆរិបញ្ចមាធមា
តស្មា អទត្វា ឧទកម្បិ អស្និយេ ។
សោ ហិត្ថិយា វា បុរិសស្ស វា បន
ទស្សាមិ ទានំ វិទុសម្បវណ្ណិតំ
សទ្ធា វទញ្ញូ ឥធ វីតមច្ឆរា
ភវន្តិ ហេតេ សុចិសច្ចសម្មតា ។
[២៧៤] អតោ មតា ទេវវរេន បេសិតា
កញ្ញា ចតស្សោ កនកត្តចូបមា
អាសា ច សទ្ធា ច សិរី តតោ ហិរី

ក្រោធ១ ចងសេចក្តីក្រោធក្នុងចិត្ត១ ឈ្មោះប្រកែក១ ញុះញង់១ ត្រដាក់១ ក្តៅ១ ខ្ញិល១ ដូចគោជននេះ មានសេដ៏ខុត្តម ។

[២៧២] (កោសិយ...) ម្នាលទេវបុត្តឈ្មោះមាតលិ ការដែលអាត្មាមិនបានឲ្យទានជាមុនសិនហើយបរិភោគ មិនគួរទេ ព្រោះវត្តនេះជាវត្តឧត្តមរបស់អាត្មា ឯការបរិភោគតែម្នាក់ឯង ជាអំពើដែលព្រះអរិយៈ មិនបូជាឡើយ មួយទៀត បុគ្គលអ្នកមិនបានចែករំលែក រមែងមិនបាននូវសេចក្តីសុខទេ ។

[២៧៣] ពួកជនណាមួយ ជាអ្នកសម្លាប់ស្ត្រី ជាអ្នកប្រព្រឹត្តបរទារិក-កម្ម ឬក៏ពួកជនណា ជាអ្នកប្រទូស្តមិត្ត ជេរប្រទេចពួកបុគ្គលអ្នកមានវត្តល្អ ជនទាំងអស់នោះ សុទ្ធតែមានសេចក្តីកំណាញ់ដ៏ថោកទាបជាគំរប់ប្រាំ ព្រោះហេតុនោះ អាត្មាបើមិនបានឲ្យសូម្បីនូវទឹក ក៏មិនបរិភោគទេ ។ មួយទៀត អាត្មានោះ ត្រូវតែឲ្យទានដែលអ្នកប្រាជ្ញសរសើរហើយ ដល់ស្ត្រីឬបុរស ដូចបុគ្គលអ្នកមានសទ្ធា អ្នកដឹងនូវពាក្យស្តួម ប្រាសចាកសេចក្តីកំណាញ់ទាំងនុ៎ះ លោកសន្មតថាជាអ្នកមានសុចិៈដ៏ស្អាត ក្នុងលោកនេះ ។

[២៧៤] (អភិសម្ពុទ្ធគាថា) លំដាប់នោះនាងកញ្ញាទាំង៤នាក់ ដែលមានស្បែកដូចជាមាសឈ្មោះ អាសា១ សទ្ធា១ សិរី១ ហិរី១ ដែលព្រះឥន្ទ្រប្រសើរជាងទេវតា បានយល់ព្រមប្រើទៅហើយ

អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

តំ អស្សមំ អាគមុ យត្ថ កោសិយោ ។
តា ទិស្វា សព្វា បរមប្បមោទិតា
សុភេន វណ្ណេន សិខារិវគ្គិយោ
កញ្ញា ចតស្សោ ចតុរោ ចតុទ្ទិសា
ឥច្ចាព្រវី មាតលិនោ សម្មុខា ។
បុរិំ ទិសំ កា ត្វំ បភាសិ ទេវតេ
អលង្កតា តារវរាវ ឱសធី
បុច្ឆាមិ តំ កញ្ចនវេល្លិវិគ្គហេ
អាចិក្ខ មេ ត្វំ កតមាសិ ទេវតា(១) ។
[២៧៤] សិរាហ ទេវី មនុជេសុ បូជិតា
អបាបសត្តូបនិសេវិនី សទា
សុធាវិវាទេន តវន្តិមាគតា
តំ មំ សុធាយ វរបញ្ញ ភាជយ ។
យស្សាហមិច្ឆាមិ សុធំ មហាមុនិ
សោ សព្វកាមេហិ នរោ បមោទតិ
សិរីតិ មំ ជានាហិ ជូហាតុត្តម
តំ មំ សុធាយ វរបញ្ញ ភាជយ ។

---

១ ម. ទេវតេ ។

នាងក៏មកកាន់អាស្រមជាទីនៅនៃកោសិយតាបសនោះ ។ កោសិយតាបស បានឃើញនាងកញ្ញាទាំង ៤ នោះ ដែលមានចិត្តត្រេកអរយ៉ាងលើសលុបទាំងអស់គ្នា មានវណ្ណៈដ៏ល្អដូចអណ្តាតភ្លើងឋិតនៅក្នុងទិសទាំងបួន ហើយបានពោលដូច្នេះក្នុងទីចំពោះមុខនៃមាតលិទេវបុត្តថា· ម្នាលទេវតា នាងជាអ្វី មានកាយប្រដាប់ហើយ បានញុំាងទិសខាងកើតឲ្យភ្លឺ ដូចជាផ្កាយព្រឹកដ៏ប្រសើរ ម្នាលនាងមានរាងកាយដូចជារូបប្រៀប ជាវិការៈនៃមាស អាត្មាសូមសួរនាង ចូរនាងប្រាប់អាត្មា នាងជាទេវតាឈ្មោះអ្វី ។

(២៧៥) (នាងសិរី...) ខ្ញុំជាទេវធីតាឈ្មោះសិរី ដែលគេបូជាក្នុងពួកមនុស្ស មិនចូលទៅគប់រកនូវសត្វលាមកគ្រប់កាល មកកាន់សំណាក់លោក ព្រោះទាស់ទែងគ្នាអំពីសុធាភោជន បពិត្រលោកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ ។ បពិត្រលោកជាមហាមុនី ខ្ញុំប្រាថ្នាសុធាភោជនរបស់ជនណា ជននោះឯងរមែងរីករាយ ដោយកាមគ្រប់យ៉ាង បពិត្រលោកដ៏ខ្ពង់ខ្ពស់ជាងពួកជនអ្នកបូជាភ្លើង សូមលោកដឹងនូវខ្ញុំថាជាទេវធីតាឈ្មោះសិរី បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជន ដល់ខ្ញុំ ។

[២៧៦] សិប្បេន វិជ្ជាចរណេន ពុទ្ធិយា
នរា ឧបេតា បគុណា សកម្មុនា
តយា វិហីនា ន លភន្តិ កិញ្ចិ នំ
តយិទំ ន សាធុ យទិទំ តយា កតំ ។
បស្សាមិ វោសំ អលសំ មហគ្ឃសំ
សុទុក្កុលីនំបិ អរូបិមំ នរំ
តយានុគុត្តោ សិរិ ជាតិមាមបិ
បេសេតិ ទាសំ វិយ ភោគវា សុខី ។
តំ ត្វំ អសច្ចំ អវិភជ្ជ សេវិនី
ជានាមិ មុឡ្ហំ វិទុរនុទាសិនី
ន តាទិសី អរហតិ អាសនូបកំ
កុតោ សុខា គច្ឆ ន មយ្ហ រុច្ចសិ ។

[២៧៧] កា សុក្កទាឋា បដិមុត្តកុណ្ឌលា
ចិត្តង្គទា កម្ពុវិមដ្ឋធារិនី
ឱសិត្តវណ្ណំ បរិទយ្ហ សោភសិ
កុសគ្គិរត្តំ អបិឡយ្ហ មញ្ជរី ។
មិគីវ ភន្តា សរចាបធារិនា
វិរាធិតា មន្ទមិវ ឧទិក្ខសិ

[២៧៦] (កោសិយៈ ..) ពួកជនដែលប្រកបដោយសិល្បៈវិជ្ជាចរណៈ និងប្រាជ្ញា ជាអ្នកឈ្លាតជំនាញ ដោយអំពើរបស់ខ្លួន ត្រឡប់ជាថោកទាបជាងនាងវិញ មិនបានយសឬសេចក្ដីសុខនោះតិចតួចសោះឡើយ អំពើណា ដែលនាងបានធ្វើហើយ អំពើនោះមិនប្រពៃទេ ។ អាត្មាបានឃើញនូវជនខ្ជិលប្រអូស បរិភោគច្រើន ទាំងមានត្រកូលថោកទាប មានរូបអាក្រក់ បុរសនោះ ដែលនាងបានរក្សាហើយ ក៏បែរទៅជាអ្នកមានសិរី អាចប្រើនូវជនដែលមានជាតិខ្ពស់ ដូចជនអ្នកមានភោគៈ មានសេចក្ដីសុខប្រើនូវខ្ញុំកំដរ ។ ព្រោះហេតុនោះ យើងដឹងនូវនាងជាស្រីមិនមានសច្ចៈ គប់រកឥតរើសមុខ ជាស្រីល្ងង់បៀតបៀនអ្នកប្រាជ្ញ ស្រីប្រហែលដូចនាង មិនគួរទទួលអាសនៈនិងទឹកទេ សុធាភោជននឹងមានពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ។

[២៧៧] នាងជាអ្វី មានចង្កូមស ពាក់កុណ្ឌល មានគ្រឿងប្រដាប់ដើមដៃដ៏វិចិត្រ ទ្រទ្រង់គ្រឿងប្រដាប់មាសដ៏រលើងស្អាត ស្លៀកដណ្ដប់សំពត់មានពណ៌ដូចទៃនទឹកដែលគេស្រោចចុះ សៀតត្រួយឈើមានពណ៌ក្រហមដូចភ្លើងឆេះស្បូវ ល្អរងើរៀង ៗ នាងដូចមេម្រឹគដែលព្រានព្រៃបាញ់ខុសហើយ ក៏ភ្ញាក់ផ្អើលក្រឡេកមើលភ្លៀក ៗ

អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

កោ តេ ទុតិយោ ឥធ មន្ទលោចនេ
ន ភាយសិ ឯកិកា កាននេ វនេ ៗ

(២៧៨) ន មេ ទុតិយោ ឥធមត្ថិ កោសិយ
មសក្កសារប្បភវម្ហិ ទេវតា
អាសា សុធាសាយ តវន្តិមាគតា
តំ មំ សុធាយ វរបញ្ញ ភាជយ ៗ

(២៧៩) អាសាយ យន្តិ វណិជា ធនេសិនោ
នាវំ សមារុយ្ហ បរេន្តិ អណ្ណវេ
តេ តត្ថ សីទន្តិ អថោបិ ឯកទា
ជិនាធនា ឯន្តិ វិនដ្ឋទាគតា ៗ

អាសាយ ខេត្តានិ កសន្តិ កស្សកា
វបន្តិ ពីជានិ ករោន្តុទាយសោ
ឦតីនិទាតេន អវុដ្ឋិតាយ វា
ន កិញ្ចិ វិន្ទន្តិ តតោ ផលាគមំ ៗ

អថត្ថកាមានិ ករោន្តិ ភត្តុសុ
អាសំ បុរក្ខត្វា នរា សុខេសិនោ
តេ ភត្តុរត្ថា អតិគាឡ្ហិតា (១) បុន
ទិសា បនស្សន្តិ (២) អលទ្ធ កិញ្ចិនំ ៗ

ម. អតិគាឡ្ហិតា ។ ២ ម. បនាយន្តិ ។

ដូច្នោះ ម្នាលនាងមានភ្នែកស្រទន់ បុគ្គលណាជាគំរប់ពីរនៃនាង ក្នុងទីនេះ នាងតែម្នាក់ឯង នៅក្នុងព្រៃធំ មិនខ្លាចទេឬ ។

(២៧៨) (នាងអាសា...) បពិត្រកោសិយតាបស ក្នុងទីនេះ មិនមានបុគ្គលជាគំរប់ពីរនៃខ្ញុំទេ ខ្ញុំជាទេវតាឈ្មោះអាសា កើតក្នុងកពតាវត្តិង្ស មកកាន់សំណាក់លោកដោយ (សេចក្តីប៉ុនប៉ង) នូវសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជន ដល់ខ្ញុំ ។

(២៧៩) (កោសិយៈ...) ពួកពាណិជអ្នកស្វែងរកទ្រព្យ ទើបនឹងសំពៅទៅក្នុងសមុទ្រ ព្រោះសេចក្តីប្រាថ្នា ពាណិជទាំងនោះ ជួនកាល លិចចុះក្នុងសមុទ្រនោះ ជួនកាល សាបសូន្យបាតទ្រព្យ បាត់ទាំងដើមទុន ។ ពួកកសិករបានភ្ជួររាស់ស្រែទាំងឡាយ ព្រោះនូវពូជទាំងឡាយ ធ្វើ (កិច្ចនោះៗ) ដោយឧបាយ ក៏មិនបាននូវផលិតផលបន្តិចបន្តួចអំពីស្រូវនោះ ដោយសេចក្តីអន្តរាយឬគ្មានភ្លៀង ព្រោះតែសេចក្តីប្រាថ្នា ។ ពួកជនអ្នកស្វែងរកសេចក្តីសុខ បានធ្វើនូវសេចក្តីប្រាថ្នាជាប្រធាន ទើបធ្វើនូវសេចក្តីព្យាយាមក្នុងទីយុទ្ធភូមិ ដើម្បីម្ចាស់ ជនទាំងនោះធ្វើនូវប្រយោជន៍ដល់ម្ចាស់ ត្រូវពួកបច្ចាមិត្ត បៀតបៀនយ៉ាងខ្លាំង មិនបាននូវឥស្សរិយយសនោះតិចតួច ក៏រត់ទៅកាន់ទិសទាំងឡាយ ។

ជហិត្វ ធញ្ញញ្ច ធនញ្ច ញាតកេ
អាសាយ សត្តាធិមនា សុមេធសោ
តបន្តិ លូខំបិ តបំ ចិរន្តរំ
កុម្មគ្គមារុយ្ហ បវេន្តិ ទុគ្គតឹ ។
អាសា វិសំវាទិកសម្មតា ឥមេ
អាសេ សុធាយ វិនយស្សុ អត្តនិ
ន តាទិសី អរហតិ អាសនូទកំ
កុតោ សុធា គច្ឆ ន មយ្ហ រុច្ចសិ ។
(២៨០) ឥទ្ធល្វមាណា យសសា យសស្សិនី
ជិឃញ្ញនាមវ្ហយនំ ទិសំបតិ
បុច្ឆាមិ តំ កញ្ចនវេល្លិវិគ្គហេ
អាចិក្ខ មេ ត្វំ កតមាសិ ទេវតា ។
(២៨១) សទ្ធាហ ទេវី មនុជេសុ បូជិតា
អបាបសត្តូបនិសេវិនី សទា
សុធាវិវាទេន តវន្តិមាគតា
តំ មំ សុធាយ វរបញ្ញ ភាជយ ។

ពួកជនអ្នកបង់ទៅកាន់ឋានសួគ៌ ស្វែងរកសេចក្ដីសុខ ក៏លះបង់នូវស្រូវទ្រព្យនឹងពួកញាតិ ហើយដុតកំដៅនូវតបៈដ៏សៅហ្មងអស់កាលយូរអង្វែង តែបែរជាឡើងកាន់ផ្លូវខុស ត្រឡប់ទៅកាន់ទុគ្គតិ ព្រោះតែសេចក្ដីប្រាថ្នា ។ នែនាងអាសា នាងឯងដែលឈ្មោះថាអាសា គេសន្មតថាជាស្រីបោកប្រាស់នូវជនទាំងនេះ(ហេតុនោះ) នាងចូរបន្ទោបង់នូវសុធាភោជនចំពោះខ្លួនឯងចុះ ស្រីប្រហែល នាងមិនគួរទទួលអាសនៈនឹងទឹកទេ សុធាភោជននឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ។

(២៨០) នាងជាស្រីមានយស រុងរឿងដោយយស ជាធំក្នុងទិស គេហៅដោយឈ្មោះថាកទាប ម្នាលនាងមានរាងកាយដូចរូបប្រៀបជាវិការនៃមាស អាត្មាសួរនាង នាងចូរប្រាប់ដល់អាត្មា នាងជាទេវតាឈ្មោះអ្វី ។

(២៨១) (នាងសទ្ធា...) ខ្ញុំជានាងទេវីឈ្មោះសទ្ធា ដែលគេបូជាក្នុងពួកមនុស្ស មិនសេពគប់នូវសត្វដ៏លាមកសព្វៗកាល មកកាន់សំណាក់លោកដោយការឈ្លោះប្រកែក ព្រោះសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែករំលែក នូវសុធាភោជន ដល់ខ្ញុំ ។

អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

(២៨២) នាហំ ទមំ ចាគមថោបិ សំយមំ
អាទាយ សទ្ធាយ ការោន្តិ ហេកទា
ថេយ្យំ មុសា កូដមថោបិ បេសុណំ
ការោន្តិ ហេកេ បុន វិជ្ជតា តយា ។
ភរិយាសុ ចោសោ សទិសីសុ បេក្ខវា
សីលូបបន្នាសុ បតិព្វតាសុបិ
វិនេត្វា ឆន្ទំ កុលិត្ថិយាសុបិ
ការោតិ សទ្ធំ បុន កុម្ភទាសិយា ។
ត្វមេវ សទ្ធេ បរទារសេវិនី
បាបំ ការោសិ កុសលំ និរញ្ជសិ
ន តាទិសី អរហតិ អាសនូទកំ
កុតោ សុធា តច្ឆ ន មយ្ហ រុច្ចសី ។

(២៨៣) ជិយញ្ញារត្តី អរុណស្មិមូហតេ
យា ទិស្សតិ ឧត្តមរូបវណ្ណិនី
តថូបមា មំ បដិភាសិ ទេវតេ
អាចិក្ខ មេ ត្វំ កតមាសិ អច្ឆរា ។

(២៨២) (កោសិយៈ...) ជួនកាល មនុស្សទាំងឡាយពឹងផ្អែកលើសទ្ធា ទើបធ្វើនូវទាន នូវការទូន្មានឥន្ទ្រិយ នូវការបរិច្ចាគនឹងការសង្រួមក៏មាន មនុស្សពួកខ្លះ ដែលឃ្លាតអំពីនាង (សទ្ធា) វិញ ក៏ធ្វើនូវការលួច កុហក បន្តុំ និងញុះញង់ក៏មាន ៗ បុរសអ្នកប្រាជ្ញក្នុងករិយាទាំងឡាយ ដែលមានគុណសម្បត្តិស្មើគ្នា ជាស្រីបរិបូណ៌ដោយសីល មានវត្តចំពោះប្តី តែលះបង់នូវសេចក្តីប្រាថ្នាក្នុងពួកស្រីដែលមានត្រកូលល្អ ហើយធ្វើនូវការដៀបចំពោះកុម្ភទាសីវិញក៏មាន ៗ ម្នាលនាងសទ្ធា នាងឯងគប់គេនូវប្រពន្ធរបស់ជនដទៃ ហើយធ្វើនូវអំពើដ៏លាមក លះបោលនូវកុសល ស្រីប្រហែលនាង មិនគួរទទួលនូវអាសនៈនិងទឹកទេ សុធាភោជននឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ៗ

(២៨៣) ទិសខាងកើត ឯណា មានសម្បុររូប ដ៏ឧត្តម ប្រាកដច្បាស់ ក្នុងវេលាអរុណរះឡើង ក្នុងទីបំផុតនៃរាត្រី ម្នាលនាងទេវធីតា នាងប្រាកដច្បាស់ ដល់អាត្មា ដូចជាទិសខាងកើតនោះដែរ នាងចូរប្រាប់អាត្មា នាងជាស្រីអប្សរអ្វី ៗ

កាឡា និទាឃេរិវ អគ្គិជារិវ
អនិលេរិតា លោហិតបត្តមាលិនី
កា តិដ្ឋសិ មន្ទមិគាវលោកយំ
ភាសេសមានាវ គិរំ ន មុញ្ចសិ ។

(២៨៤) ហិរាហា ទេវី មនុជេសុ បូជិតា
អបាបសត្តូបនិសេវិនី សទា
សុធាវិវាទេន តវន្តិមាគតា
សាហំ ន សក្កោមិ សុជំបិ យាចិតុំ
កោបីនរូបា វិយ យាចនិត្ថិយា ។

(២៨៥) ធម្មេន ញាយេន សុគត្តេ លព្ភសិ
ឯសោ ហិ ធម្មោ ន ហិ យាចនោ សុធំ
តំ តំ អយាចន្តិមហំ និមន្តយេ
សុធំ យំ យញ្ចិច្ឆសិ តំបិ ទម្មិ តេ ។
សា ត្វំ មយា អជ្ជ សកម្ហិ អស្សមេ
និមន្តិតា កញ្ចនវេល្លិវិគ្គហេ
តុវញ្ហិ មេ សព្វរសេហិ បូជិតា
តំ បូជយិត្វាន សុធំបិ អស្និយេ ។

នាងឈ្មោះអ្សី ដូចជាវល្លិ៍ប្រេង ដែលត្រូវខ្យល់មានរបៀបនៃស្លឹកដ៏ក្រហមក្នុងនិទាឃរដូវ ឬដូចជាអណ្តាតភ្លើង ពុំនោះសោត ដូចម្រឹគស្មារ កាលក្រះឡេកមើលនាងហាក់ដូចជាមានប្រាថ្នានឹងនិយាយ តែមិនបញ្ចេញនូវវាចាទៅវិញ ។

[២៨៤] (នាងហិរី...) ខ្ញុំជានាងទេវីឈ្មោះហិរី ដែលគេបូជាក្នុងពួកមនុស្ស ជាស្រីមិនសេពគប់នូវសត្វដ៏លាមកសព្វៗកាល មកកាន់សំណាក់លោកដោយការឈ្លោះប្រកែក ព្រោះសុធាភោជន តែខ្ញុំនោះមិនអាចនឹងសុំនូវសុធាភោជនទេ ធម្មតាការសុំគេនៃស្រី ដូចជាការបើកបង្ហាញកេរ្តិ៍ខ្មាស ។

[២៨៥] (កោសិយ:...) ម្នាលនាងមានរាងកាយល្អ នាងនឹងបាន (នូវសុធាភោជន) តាមសភាពតាមហេតុ នេះពិតជាធម៌ហើយ ដ្បិតថាសុធាភោជន គេមិនបានព្រោះការសុំទេ ព្រោះហេតុនោះ អាត្មានឹងអញ្ជើញនាងដែលមិនសុំ នាងប្រាថ្នានូវសុធាភោជនណា ៗ អាត្មានឹងឲ្យនូវសុធាភោជនៈនោះៗដល់នាង ។ ម្នាលនាងមានរាងកាយដូចរូបប្រៀបជាវិការៈនៃមាស នាងនោះអាត្មានឹងអញ្ជើញទៅក្នុងអាស្រមរបស់អាត្មាក្នុងថ្ងៃនេះ នាងជាស្រីគួរអាត្មាបូជាដោយវត្ថុមានរសគ្រប់យ៉ាង អាត្មាលុះបូជានាងហើយ ទើបនឹងបរិភោគនូវសុធាភោជនដែរ ។

(២៨៦) សា កោសិយេនានុមតា ជុតីមតា
អទ្ធា ហិរី រម្មំ បាវិសិយស្សមំ
ឧទកវន្តំ ផលមរិយបូជិតំ
អធាបសត្តុបនិសេវិតំ(១) សទា ។
រុក្ខគ្គហានា ពហុកេត្ថ បុប្ផិតា
អម្ពា បិយាលា បនសា ច កឹសុកា
សោភញ្ជនា លោទ្ទមថោបិ បទ្មកា
កេកា ច ភង្គា តិលកា ច បុប្ផិតា ។
សាលា ករេរី ពហុកេត្ថ ជម្ពុយោ
អស្សត្ថនិគ្រោធមធុកា ច វេទិសា
ឧទ្ទាលកា បាដលិ សិន្ទុវារិតា
មនុញ្ញគន្ធា មុចលិន្ទកេតកា ។
ហរេណុកា វេឡុកា វេណុតិន្ទុកា
សាមាកនីវារមថោបិ ចីនកា
មោចា កទលី ពហុកេត្ថសាលិយោ
បវីហយោ អាភុជិនោ ច តណ្ឌុលា ។

---

១ ម. អញាបសត្តុ បនិសេវិតំ ។

(៤៨៦) ( អភិសម្ពុទ្ធគាថា ) នាងហិរីនោះ ជាស្រីមិនសេពគប់នូវសត្តលាមកសព្វៗកាល ដែលកោសិយតាបសមានអានុភាពដ៏រុងរឿងអនុញ្ញាតហើយ ក៏ចូលទៅកាន់អាស្រមជាទីកកាយ ជាអាស្រមមានទឹក មានផ្លែឈើ ដែលពួកអរិយជនបូជាហើយ ។ ជិតអាស្រមនោះ មានព្រៃឈើស៊ុមទ្រុមដ៏ច្រើន មានផ្ការីកហើយ ដើមស្វាយ ដើមទ្រយឹង ដើមខ្នុរ ដើមបារ ដើមម្រុម ដើមលោទ ដើមក្តោកផ្តិប ដើមលំពែក ដើមចន្ទន៍ ដើមត្រមូច មានផ្ការីកហើយ ។ ជិតអាស្រមនោះ មានដើមឈើច្រើន គឺដើមពិង ដើមថ្កាន់ ដើមព្រីង ដើមពោធិ៍បាយ ដើមជ្រៃ ដើមស្រគំ មានផែកទោរទន់ចុះ និងដើមកជព្រឹក្ស ដើមប្រនៀង ដើមជ្រៃព្នួរ ដើមពិងអន្ទក់ និងដើមលំពែក មានក្លិនផ្សព្វផ្សាយគួរគាប់ចិត្ត ។ ជិតអាស្រមនោះ មានអបរណ្ណជាតិ អំពៅខ្មៅ សណ្តែកព្រៃ ដើមទន្លាប់ ស្រងែ និងគែលលក សណ្តែកកជមាស ពេកមានគ្រាប់ និងស្រូវស ស្រូវក្រហមជាច្រើន ផ្លែចេញជាអង្ករគួរបរិភោគបាន ។

តស្ស ច ឧត្តរបស្សេន ជាតា បោក្ខរណី សិវា

អកក្កសា អបព្ភារា សាទុ អប្បដិគន្ធិកា ។

តត្ថ មច្ឆា សន្និរតា ខេមិនោ ពហុភោជនា

សិង្គុសវង្កា សកុលា សតវង្កា ច រោហិតា

អាឡិគគ្គរកាកិណ្ណា បាឋីនា កាកមច្ឆកា ។

តត្ថ បក្ខី សន្និរតា ខេមិនោ ពហុភោជនា

ហំសា កោញ្ចា មយូរា ច ចក្កវាកា ច កុក្កុហា

កុណាលកា ពហូ ចិត្រា សិខណ្ឌី ជីវជីវកា ។

តត្ថ បាណា សមាយន្តិ នានាមិគគណា ពហូ

សីហា ព្យគ្ឃា វរាហា ច អច្ឆកោកតរច្ឆយោ

បលសទា ច គវជា មហិសា រោហិតា រុរូ

ឯណេយ្យា ច វរាហា ច គណិនោ និកសូករា ។

កទលិមិគា ពហុកេត្ថ ពិឡារា សសកណ្ណិកា

ឆមាគិរី បុប្ផវិចិត្រសន្ថតា

ទិជាភិឃុដ្ឋា ទិជសង្ឃសេវិតា ។

នៅខាងជើង នៃទីអាស្រមនោះ មានជាតស្រះបោក្ខរណីដ៏ក្សេម មិនមានវត្ថុអាក្រក់ មានកំពង់មិនចោត ជាស្រះដ៏ស្អាត ប្រកបដោយទឹកមានក្លិនមិនគួរខ្ពើម ។ ក្នុងស្រះនោះ មានពួកត្រីត្រេកត្រអាល ជាសត្វមានសេចក្ដីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺ ត្រីផ្ទក់ ត្រីខ្ញឹង ត្រីក្រាយ បង្កង ត្រីឆ្ពិន ត្រីស្លាត និងត្រីក្អក ក៏ហែបហែលៈទៅមកដេរដាស ។ ក្នុងស្រះនោះ មានពួកសត្វស្លាបត្រេកត្រអាល ជាសត្វមានសេចក្ដីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺហង្ស ក្រៀល ក្ងោក ចាកក្រពាក អកតាវ៉ៅ ក្ងោកមាស ទោម ព្រហ៊ិត ដ៏ច្រើន ។ មានពួកសត្វគឺហ្វូងនៃម្រឹគផ្សេងៗ ជាច្រើន គឺសីហៈ ខ្លាធំ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន រមាស គោព្រៃ ក្របី រមាំង ប្រើស ទ្រាយ ជ្រូកព្រៃ ក្ដាន់ និងជ្រូកស្រុក មកប្រជុំគ្នាក្បែរស្រះនោះ ។ មានល្បួស ធ្នា ទន្សាយនឹងខ្ទីងជាច្រើន ផែនដីនឹងភ្នំ ពេញពាសដោយផ្កាដ៏វិចិត្រ កង់រពង់ដោយសម្លេងនៃសត្វបក្សី មានហ្វូងបក្សីគប់រកជានិច្ច ក្បែរស្រះនោះ ។

(២៨៧) សា សុត្វា នីលទុមាភិលម្ពិតា
វិជ្ជុប្បភាមេឃរិវានុបជ្ជថ
តស្សា សុសម្មដ្ឋសិរំ កុសាមយំ
សុចី សុគន្ធំ អជិនូបសេវិតំ
អត្រិច្ឆកោច្ឆំ ហិរិមេតទព្រវិ
និសីទ កល្យាណិ សុខយិទមាសនំ ។
តស្សា តទា កោច្ឆគតាយ កោសិយោ
យទិច្ឆមានាយ ជដាជិនន្ធរោ
នវេហិ បត្តេហិ សយំ សហូទកំ
សុធាភិហាសី តុរិតោ មហាមុនិ ។
សា តំ បដិគ្គយ្ហ ឧភោហិ បាណិភិ
ឥច្ចព្រវី អត្តមនា ជដាធរំ
ហន្ទាហំ ឯតរហិ បូជិតា តយា
គច្ឆេយ្យំ ព្រហ្មេ តិទិវំ ជិតាវិនី ។

[២៨៧] នាងហិរីនោះ មានស្បែកដ៏ល្អ តោងដើមឈើមានពណ៌ដ៏ខៀវ បានចូលទៅ ( កាន់អាស្រម ) ហាក់ដូចជាផ្លេកបន្ទោររបស់មហាមេឃ កោសិយតាបសបានរៀបចំកៅអី ដែលមានបណ្ដាញប្រទាក់គ្នាដ៏ល្អ ជាវិការៈនៃស្បូវក្លាំងដ៏ស្អាត មានក្លិនដ៏ល្អ ពាសដោយស្បែកខ្លាឃ្មុំ បម្រុងនាងហិរីនោះ បានពោលពាក្យនេះនឹងនាងហិរីថា ម្នាលនាងមានលំអ នាងចូរអង្គុយឲ្យស្រួលចុះ នេះអាសនៈ ។ កាលដែលនាងហិរីនោះ ឋិតនៅលើកៅអី ប្រាថ្នានូវសុធាភោជនណា គ្រានោះ កោសិយ-តាបស អ្នកទ្រទ្រង់នូវផ្នួងសក់ដ៏រុងរឿង ជាមហាមុនី ប្រញាប់ប្រញាល់ បាននាំមកនូវសុធាភោជននោះ ព្រមទាំងទឹកដោយស្លឹកឈូកថ្មី ៗ ដោយខ្លួនឯង ។ នាងហិរីនោះ មានចិត្តត្រេកអរ បានទទួលនូវសុធាភោជននោះ ដោយដៃទាំងពីរ ហើយពោលនឹងកោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងសក់ដូច្នេះថា បពិត្រព្រហ្ម ឥឡូវនេះ ខ្ញុំដែលលោកបូជាហើយ ជាបុគ្គលមានជ័យជំនះ សូមទៅ កាន់ភពត្រៃត្រិង្សវិញ ។

សា កោសិយេនានុមតា ជុតីមតា
ឧទីរិតា(១) វណ្ណមទេន មត្តា
សកាសេ គន្ត្វាន សហស្សចក្ខុនោ
អយំ សុធា វាសវ ទេហិ មេ ជយំ ។
តមេនំ សក្កោបិ តទា អបូជយិ
សហិន្ទទេវា សុរកញ្ញមុត្តមំ
សា បញ្ជលី ទេវមនុស្សបូជិតា
នវម្ហិ កោច្ឆម្ហិ យទា ឧបាវិសិ ។
[២៨៨] តមេវ សំសី បុនទេវ មាតលី
សហស្សនេត្តោ តិទសានមិន្ទោ
គន្ត្វាន វាក្យំ មម ព្រូហិ កោសិយំ
អាសាយ សទ្ធាយ សិរិយា ច កោសិយ
ហិរី សុធំ កេនមលត្ថ ហេតុនា ។
[២៨៩] តំ សុប្បវត្តំ ឧទតារយី រថំ
ទទ្ទល្លមានំ ឧបការិយសាទិសំ
ជម្ពោនទីសំ តបនេយ្យសន្និភំ
អលង្កតំ កញ្ចនចិត្តសន្និភំ ។

---
១ ម. ឧទិរយិ ។

នាងហិរីនោះ ដែលកោសិយតាបសមានអនុភាពដ៏រុងរឿង បានអនុញ្ញាតហើយ ជាស្រីស្រស់ដោយការស្រស់នូវវណ្ណៈ ក៏ទៅក្នុងសំណាក់ព្រះឥន្ទ្រជាសហស្សនេត្ត រួចក្រាបទូលថា បពិត្រព្រះវាសវៈ នេះជាសុធាភោជន សូមព្រះអង្គទ្រង់ប្រទាននូវជ័យជំនះដល់ខ្ញុំ ។ នាងហិរីនោះ ដែលពួកទេវតានិងមនុស្សផ្គងអញ្ជលីបូជាហើយ ក៏ចូលទៅអង្គុយលើកៅអីដ៏ថ្កើងក្នុងកាលណា ព្រះឥន្ទ្រព្រមទាំងពួកទេវតា ក៏បូជានាងហិរីនោះ ជាទេវធីតាដ៏ឧត្តមក្នុងកាលនោះ ។

[២៨៨] សហស្សនេត្ត ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ទ្រង់បានត្រាស់នឹងមាតលិទេវបុត្តនោះម្តងទៀតថា អ្នកចូរទៅសួរកោសិយតាបសតាមពាក្យរបស់យើងថា បពិត្រកោសិយៈ នាងហិរី ដទៃអំពីនាងអាសា នាងសទ្ធា នាងសិរី បាននូវសុធាភោជនដោយហេតុអ្វី ។

[២៨៩] មាតលិទេវបុត្ត បានឡើងជិះរថនោះ អណ្តែតទៅដោយស្រួលដ៏រុងរឿងប្រហែលនឹងគ្រឿងឧបករណ៍ មានចន្ទោលជាវិការៈនៃមាសជម្ពូនទ ក្លៃដូចជាអណ្តាតភ្លើង ដែលបុញ្ញឫទ្ធិប្រដាប់ស្រស់ល្អ ប្រកបដោយកម្រាលជាវិការៈនៃមាស វិចិត្រដោយកែវ ៧ ប្រការ ។

## អសីតិនិបាតេ តតិយំ សុធាភោជនជាតកំ

សុវណ្ណចន្ទេត្ថ ពហូ និបាតិតា
ហត្ថី គវស្សា កឹបុរិសព្យគ្ឃទីបិយោ
ឯណេយ្យកា សល្លមយេត្ថ បក្ខិនោ
មិគេត្ថ វេឡុរិយមយា យុធាយុតា ។
តត្ថស្សរាជហរិយោ អយោជយុំ
ទសសតានិ សុសុនាគសាទិសេ
អលង្កតេ កញ្ចនជាលុរច្ឆទេ
អាវេឡិនេ សទ្ទគមេ អសង្គិតេ ។
តំ យានសេដ្ឋំ អភិរុយ្ហ មាតលិ
ទស ទិសា ឥមា អភិនាទយិត្ថ
នភញ្ច សេលញ្ច វនប្បតិញ្ច
សសាគរំ បព្យធយិត្ថ មេទនឹ ។
ស ខិប្បមេវ ឧបគម្ម អស្សមំ
បាវារមេកំសកតោ កតញ្ជលី
ពហុស្សុតំ វុឌ្ឍំ វិនីតវន្តំ
ឥច្ចព្រវី មាតលិ ទេវព្រាហ្មណំ ។

ក្នុងរថនុ៎ះ មានរូបព្រះចន្ទជាវិការៈនៃមាសរូបដំរីគោ សេះកិន្នរ ខ្លាធំ ខ្លា
ដម្បងទ្រាយជាច្រើនក្នុងរថនោះ មានរូបបក្សីជាវិការៈនៃកែវផ្សេង ៗ
ក្នុងរថនោះ មានទាំងរូបម្រឹគប្រកបដោយហ្វូងជាវិការៈនៃកែវពិទូរ្យ
ក្នុងរថនោះ ៗ ពួកទេវតាបានទឹមនូវស្តេចសេះ មានសម្បុរលឿង
មួយពាន់ក្នុងរថនោះ ជាសេះមានសម្បុរដូចមាស ប្រហែលនឹងដំរី
ស្ការ ប្រដាប់ដោយគ្រឿងអលង្ការ មានគ្រឿងប្រដាប់ទ្រូងជាវិការៈ
នៃបណ្តាញមាស មានគ្រឿងប្រដាប់ពាក់ត្រចៀក ស្ទុះទៅដោយ
គ្រាន់តែឮសម្លេង ជាសេះមានសន្ទុះដ៏លឿន ៗ មាតលិទេវបុត្ត
បានឡើងជិះរថនោះ ជាយានដ៏ប្រសើរ ហើយញុំាងទិសទាំង ១០
នេះ ឲ្យគឹកកងរំពងទាំងញុំាងអាកាសភ្នំ ឈើម្ចាស់ព្រៃ សាគរនឹង
ផែនដីឲ្យរំភើបញាប់ញ័រ ៗ មាតលិទេវបុត្តនោះ ចូលទៅកាន់
អាស្រមជាឆាប់ ពានាសំពត់ទិព្វជាស្រេច រួចផ្គងអញ្ជលីពោល
ទៅនឹងកោសិយតាបស ជាទេវព្រាហ្មណ៍ ដែលជាពហុស្សូត
ជាអ្នកចំរើនដោយគុណ មានអាចារ្យវត្តទន្ទានហើយ ដូច្នេះថា

ឥន្ទស្ស ភក្ខំ វិសភាមេហិ កោសិយ
ទូតោ អហំ បុច្ឆតិ តំ បុរិន្ទទោ
អាសាយ សទ្ធាយ សិរិយា ច កោសិយ
ហិរី សុធំ កេនមលត្ថ ហេតុនា ៗ

[២៩០] អន្ធា សិរី មំ បដិភាតិ មាតលិ
សទ្ធា អនិច្ចា បន ទេវសារថិ
អាសា វិសំវាទិកសម្មតា ហិ មេ
ហិរី ច អរិយម្ហិ គុណេ បតិដ្ឋិតា ៗ

[២៩១] កុមារិយោ យាចិមា គោត្តរក្ខិតា
ជិណ្ណា ច យា ច សភត្តុឥត្ថិយោ
តា ឆន្ទរាគំ បុរិសេសុ ឧគ្គតំ
ហិរិយា និវារេន្តិ សចិត្តមត្តនោ ៗ
សង្គាមសីសេ សរសត្តិសំយុតេ
បរាជិតានំ បតតំ បលាយិនំ
ហិរិយា និវត្តន្តិ ជហិត្វាន ជីវិតំ
តេ សម្បដិច្ឆន្តិ បុន ហិរីមនា ៗ
វេលា យថា សាគរវេគវារិណី
អយំ ហិរី បាបជនំ និវារិណី

បតិត្រកោសិយៈ សូមលោកស្តាប់ពាក្យព្រះឥន្ទ្រ ខ្ញុំឯងជាទូត ព្រះឥន្ទ្រ សូមសួរលោកថា បតិត្រកោសិយៈ ចុះនាងហិរិដទៃ អំពីនាងអាសា នាងសទ្ធា និងនាងសិរី តើបាននូវសុធាភោជន ដោយហេតុអ្វី ។

[២៩០] (កោសិយៈ...) ម្នាលមាតលិ ជាទេវសារថី នាងសិរីប្រាកដច្បាស់ដល់អាត្មា ថាជាស្ត្រីស្តុកស្តម្ភស្រាប់ហើយ បំណែកនាងសទ្ធា ប្រាកដដល់អាត្មា ថាជាស្ត្រីមិនទៀង នាងអាសា ក៏ប្រាកដដល់អាត្មា ថាជាស្ត្រីដែលគេសន្មត ថាជាស្រីចាកប្រាស ឯនាងហិរិ តាំងនៅស៊ប់ក្នុងគុណដ៏ប្រសើរ ។

[២៩១] ពួកនាងកុមារីណា ដែលត្រកូលរក្សា ហើយក្តី ពួកស្ត្រីចាស់ៗ (ស្ត្រីមេម៉ាយ) ណាក្តី ពួកស្ត្រីណា ដែលមានប្តីក្តី ស្ត្រីទាំងនោះ (ដឹងច្បាស់) នូវឆន្ទរាគដែលកើតឡើង ក្នុងពួកបុរស ហើយរារាំងនូវចិត្តរបស់ខ្លួនដោយហិរិ ។ កាលជនទាំងឡាយបរាជ័យក្នុងប្រធាននៃសង្គ្រាម ដែលប្រកបដោយព្រួញ និងលំពែង ស្លុះរត់ទៅ ជនទាំងនោះ បានលះបង់នូវជីវិត ក៏ត្រឡប់វិលវិញដោយហិរិ មានចិត្តប្រកបដោយហិរិ ទទួលយក(ម្ចាស់)វិញ ។ ច្រាំងជាគ្រឿងរារាំងនូវកំឡាំង នៃរលកទឹក ក្នុងសមុទ្រយ៉ាងណា ហិរិនេះ ក៏ឃាត់នូវជនចាកបាប យ៉ាងនោះដែរ

តំ សព្វលោកោ ហរិមរិយបូជិតំ
ឥន្ទស្ស តំ វេទយ ទេវសារថិ ។

(២៩២) កោ តេ ឥមំ កោសិយ ទិដ្ឋិមោទហិ
ព្រហ្មា មហិន្ទោ អថវា បជាបតិ
ហិរាយ ទេវេសុបិ សេដ្ឋសម្មតា
ធីតា មហិន្ទស្ស មហេសិ ជាយថ ។

(២៩៣) ហន្ទេហិ ទានិ តិទិវំ អបក្កម
រថំ សមារុយ្ហ មមាយិតំ ឥធ
ឥន្ទោ ច តំ ឥន្ទសគោត្ត កង្ខតិ
អជ្ជេវ ត្វំ ឥន្ទសហព្យតំ វជ ។

(២៩៤) ឯវំ វិសុជ្ឈន្តិ អបាបកម្មិនោ
អថោ សុចិណ្ណស្ស ផលំ ន នស្សតិ
យេ កេចិ អទ្ទក្ខុំ សុធាភោជនំ
សព្វេវ តេ ឥន្ទសហព្យតំ គតាតិ ។

(២៩៥) ហិរី ឧប្បលវណ្ណាសិ កោសិយោ ទានបតិ ភិក្ខុ
អនុរុទ្ធោ បញ្ចសិខោ អានន្ទោ អសិ មាតលិ
សុរិយោ កស្សបោ ភិក្ខុ មោគ្គល្លានោសិ ចន្ទិមា

ម្នាលទេវសារថី ព្រោះហេតុនោះ អ្នកចូរក្រាបទូលព្រះឥន្ទ្រថា ហារិនោះ ត្រូវអរិយជន បូជាហើយ ក្នុងលោកទាំងពួង ៗ

[២៩២] ( មាតលិទេវបុត្ត...) បពិត្រកោសិយៈ បុគ្គលណាជាព្រហ្ម ឬព្រះឥន្ទ្រ ឬបជាបតិ ប្រកាន់តាមសេចក្តីយល់របស់លោកនេះ ថា ធីតារបស់ព្រះឥន្ទ្រ ជាស្ត្រីស្វែងរកនូវគុណដ៏ប្រសើរ ដែល គេសន្មតថាជាស្ត្រីប្រសើរបំផុតក្នុងពួកទេវតា ព្រោះតែហារិ ៗ

[២៩៣] បើដូចនោះ ឥឡូវនេះ សូមលោកមក សូមលោកទៅកាន់ ឋានត្រៃត្រិង្ស សូមលោកឡើងជិះរថ ដែលជាទីគាប់ចិត្តនេះ បពិត្រលោកអ្នកមានគោត្រស្មើដោយព្រះឥន្ទ្រ ព្រះឥន្ទ្រទ្រង់នឹក លោក សូមលោកទៅនៅរួមជាមួយនឹងព្រះឥន្ទ្រក្នុងថ្ងៃនេះ ៗ

[២៩៤] ( អភិសម្ពុទ្ធគាថា ) ពួកសត្វអ្នកមិនធ្វើនូវអំពើបាប រមែង បរិសុទ្ធយ៉ាងនេះ មួយទៀត ផលនៃកុសល ដែលបុគ្គលបាន សន្សំល្អហើយ រមែងមិនសាបសូន្យទេ ពួកសត្វណាមួយ បាន ឃើញនូវសុធាភោជន ( ក្នុងកាលនោះ ) សត្វទាំងអស់នោះឯង រមែងដល់នូវការនៅរួមជាមួយនឹងព្រះឥន្ទ្រ ៗ

[២៩៥] នាងហារិទេវធីតា គឺនាងឧប្បលវណ្ណាភិក្ខុនី កោសិយតាបសគឺ ភិក្ខុជាម្ចាស់ទាន បញ្ចសិខទេវបុត្ត គឺអនុរុទ្ធភិក្ខុ មាតលិទេវបុត្ត គឺអានន្ទ សុរិយទេវបុត្ត គឺកស្សបភិក្ខុ ចន្ទទេវបុត្ត គឺមោគ្គល្លាន

នារទោ សារិបុត្តាសិ សម្ពុទ្ធោ អាសិ កោសិយោតិ។

សុធាភោជនជាតកំ តតិយំ ។

# កុណាលជាតកំ

(២៩៦) ឯវមក្ខាយតិ ឯវមនុសុយ្យតិ សព្វោស-
ធធរណីធរេ នេកបុប្ផមាល្យវិតតេ គជគវយមហិ-
សរុរុចាមរបសទខគ្គគោកណ្ណសីហព្យគ្ឃទីបិអច្ឆកោក-
តរច្ឆឧទ្ទារកទលិមិគពិឡារសសកណ្ណិកានុចរិតេ អា-
កិណ្ណនេឡមណ្ឌលមហាវរាហនាគកុលករេណុ-
សង្ឃាធិវុត្ថេ ឥស្សមិគសាខមិគសរភមិគឯណីមិគវា-
តមិគបសទមិគបុរិសាលុកឹបុរិសយក្ខរក្ខសនិសេវិតេ
អមជ្ជវមញ្ជរីធរបហដ្ឋបុប្ផផុសិតគ្គានេកបាទបគណវិ-
តតេ កុររចកោរវារណមយូរបរភុតជីវជីវកចេលាវ-
កពលាកភិង្ការករវិកមត្តវិហង្គសតសង្ឃុដ្ឋេអញ្ជន-

នារទតាបស គឺសារីបុត្ត ឯព្រះវាសវៈគឺតថាគត ជាព្រះសម្ពុទ្ធ ។

ចប់ សុធាភោជនជាតក ទី ៣ ។

# កុណាលជាតក

[២៩៦] ហេមវន្តប្រទេស ដែលគេតែងពោលយ៉ាងនេះ តែងឮយ៉ាងនេះ មានសេចក្តីដំណាលថា បក្សីកុណាល (តាវ៉) មានសម្បុរដ៏វិចិត្រក្រៃលែង មានស្លាបជាគ្រឿងបិទបាំងដ៏វិចិត្រក្រៃលែង តែងនៅអាស្រ័យក្នុងដងព្រៃជាទីរីករាយ មានសភាពយ៉ាងនេះ ជាប្រទេសទ្រទ្រង់នូវធរណី ប្រកបដោយឱសថ គ្រប់យ៉ាង រយោងរយានដោយបណ្តាមផ្កាជាច្រើន ជាប្រទេសជាទីបរទៅមករឿយ ៗ នៃដំរី គោ ក្របី ប្រើសមាស ចាមរី ក្តាន់ រមាស ខ្ទីង សីហៈ ខ្លាធំ ខ្លាដម្បង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន កេ ឈ្លូស ខ្លាត្រី ទន្សាយ រមាំង ជាទីអាស្រ័យនៅនៃហ្វូងដំរីតូច ៗ ខឹងដំរីធំ នឹងមេដំរីក្នុងនាគត្រកូល ដ៏ដេរដាស ជាទីអាស្រ័យនៅនៃខ្លាឃ្មុំ ស្វា សរភៈ ម្រឹគទ្រាយ ក្តាន់បុរិសាលុ (យក្ខិនីមានមុខដូចសេះ) កិន្នរ យក្ស អារក្សទឹក ជាព្រៃដ៏ដេរដាសដោយពួកឈើជាច្រើនយ៉ាង គឺឈើមានផ្កាក្រពុំ ឈើមានត្រួយលាស់រហង់ សឹងដ៏ខៀវខ្ចារដោយហ្វូងបក្សីជាច្រើន គឺសត្វអក លលកទ្រាំង ហង្សលិង្គ ក្ងោក ទីទុយ ប៉ោលគោក ចាប កុកក្រួក សម្បុកត្រពាំង ករវិក

នោសិលាហរិតាលហិង្គុលកហេមរជតកនកានេក-ធាតុសតវិនទ្ធបដិមណ្ឌិតប្បទេសេ ឯវរូបេ ខលុ ភោ រម្មេ វនសណ្ឌេ កុណាលោ នាម សកុណោ បដិវសតិ អតិរិវ ចិត្តោ អតិរិវ ចិត្តបត្តច្ឆទនោ ។ តស្សេវ ខលុ ភោ កុណាលស្ស សកុណស្ស អឌ្ឍុ-ឌ្ឍានិ ឥត្ថីសហស្សានិ បរិចារិកា ទិជកញ្ញាយោ ។ អថ ខលុ ភោ ទ្វេ ទិជកញ្ញាយោ កដ្ឋំ មុខេន ឌំសិត្វា តំ កុណាលំ សកុណំ មជ្ឈេ និសីទាបេត្វា ឧឌ្ឌេន្តិ មា នំ កុណាលំ សកុណំ អទ្ធានបរិយាយបថេ កិលមថោ ឧព្វាហេត្ថាតិ ។ បញ្ចសតា ទិជកញ្ញាយោ ហេដ្ឋតោ ហេដ្ឋតោ ឧឌ្ឌេន្តិ សចាយំ កុណាលោ សកុ-ណោ អាសនា បរិបតិស្សតិ មយំ តំ បក្ខេហិ បដិគ្គ-ហេស្សាមាតិ ។ បញ្ចសតា ទិជកញ្ញាយោ ឧបរូបរិ ឧឌ្ឌេន្តិ មា នំ កុណាលំ សកុណំ អាតបោ បរិតាបេសីតិ ។ បញ្ចសតា បញ្ចសតា ទិជកញ្ញាយោ ឧភតោ បស្សេន ឧឌ្ឌេន្តិ មា នំ កុណាលំ សកុណំ សីតំ វា ឧណ្ហំ វា តិណំ វា រជោ វា វាតោ វា ឧស្សាវោ វា ឧបប្ផុសីតិ ។

ជាប្រទេសដ៏ប្រដាប់ដោយវត្ថុ ជាទីត្រេកអរច្រើនយ៉ាង គឺថ្មនោសិលា មានពណ៌ខៀវ ដូចផ្កាអញ្ចន ជាតិហិង្គុល មាស ប្រាក់ មាសស្រួយ នឹងលោហធាតុជាច្រើនយ៉ាង ៗ បក្សីតាវ៉ៅនោះឯង មានបក្សីញីចំនួន ៣.៥០០ សុទ្ធតែបក្សីដ៏ទន់ចាំបំរើ ៗ មានសេចក្ដីដំណាលថា គ្រានោះ បក្សីញីដ៏ទន់ពីរ ពាំមែកឈើ ដោយចំពុះ ឲ្យបក្សីតាវ៉ៅឈ្មោលនោះទំត្រង់កណ្ដាលមែកឈើ ហើរទៀងទៅដោយគិតថា សូមកុំឲ្យមានសេចក្ដីលំបាកក្នុងផ្លូវឆ្ងាយ បៀតបៀនបក្សីតាវ៉ៅឈ្មោលនោះឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០០ ក៏ហើរពីខាងក្រោមៗដោយគិតថា បើបក្សីតាវ៉ៅនេះធ្លាក់ពីបង្គង យើងនឹងទទួលបក្សីតាវ៉ៅនោះដោយស្លាបទាំងឡាយ ៗ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអំពីខាងលើ ៗ ដោយគិតថា សូមកុំឲ្យកំដៅក្ដៅដល់បក្សីតាវ៉ៅឈ្មោលនោះឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០០ ម្នាង ៗ ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្ដៅ ស្មៅធូលី ខ្យល់ឬទឹកសន្សើមប៉ះពាល់ត្រូវបក្សីតាវ៉ៅឈ្មោលនោះឡើយ ៗ

បញ្ចសតា ទិជកញ្ញាយោ បុរតោ បុរតោ ឌេន្តិ ឥមំ
កុណាលំ សកុណំ គោបាលកា វា បសុបាលកា វា
តិណហារកា វា កដ្ឋហារកា វា វនកម្មិកា វា កដ្ឋេន
វា កឋលាយ វា បាណិនា វា (បាសាណេន) វា លេឌ្ឌុនា
វា ទណ្ឌេន វា សត្ថេន វា សក្ខរាហិ វា បហារំ អទំសុ
មាយំ កុណាលោ សកុណោ គច្ឆេហិ វា លតាហិ វា
រុក្ខេហិ វា សាខាហិ វា ថម្ភេហិ វា បាសាណេហិ
វា ពលវន្តេហិ វា បក្ខីហិ សង្គាមេសីតិ ។ បញ្ចសតា
ទិជកញ្ញាយោ បច្ឆតោ បច្ឆតោ ឌេន្តិ សណ្ហាហិ
សខិលាហិ មញ្ជូហិ មធុរាហិ វាចាហិ សមុទាចរន្តិយោ
មាយំ កុណាលោ សកុណោ អាសនេ បរិយុក្កណ្ឋីតិ ។
បញ្ចសតា ទិជកញ្ញាយោ ទិសោទិសំ ឌេន្តិ អនេ-
ករុក្ខវិវិធវិកតិផលមាហរន្តិយោ មាយំ កុណាលោ
សកុណោ ខុទ្ទាយ បរិកិលមិត្ថាតិ ។ អថ ខលុ ភោ
តា ទិជកញ្ញាយោ តំ កុណាលំ សកុណំ អារា-
មេនេវ អារាមំ ឧយ្យានេនេវ ឧយ្យានំ នទីតិត្ថេនេវ
នទីតិត្ថំ បព្វតសិខរេនេវ បព្វតសិខរំ អម្ពវនេនេវ
អម្ពវនំ ជម្ពុវនេនេវ ជម្ពុវនំ លពុជវនេនេវ លពុជវនំ

ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅអំពីខាងមុខ ៗ ដោយគិតថា សូមកុំឲ្យគង្វាលគោ គង្វាលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃ ប្រហារនូវបក្សីតាវ៉ៅឈ្មោលនោះ ដោយកំណាត់ឈើ ដោយអម្បែង ដោយដៃ (ដោយដុំថ្ម) ដោយដុំដី ដោយដម្បង ដោយសាស្ត្រាវុធ ឬដោយដុំក្រួសទាំងឡាយឡើយ សូមកុំឲ្យបក្សីតាវ៉ៅនោះប៉ះទង្គិចនឹងគុម្ពឈើ វល្លិ៍ ដើមឈើ មែកឈើ សសរ ថ្មក្និ ឬពួកបក្សីមានកម្លាំងឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអមអំពីខាងក្រោយ ៗ និយាយឆ្លើយឆ្លងគ្នា ដោយពាក្យស្រទន់ផូរផង់ពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យបក្សីតាវ៉ៅនេះ អផ្សុកនៅលើទ្រនំឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេង ៗ ចំឡែកជាច្រើនដោយគិតថា សូមកុំឲ្យបក្សីតាវ៉ៅនេះ លំបាកដោយការស្រេកឃ្លានឡើយ ។ គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំបក្សីតាវ៉ៅនោះអំពីសួនច្បារទៅកាន់សួនច្បារ អំពីឧទ្យាន ទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្លូទៅកាន់ព្រៃខ្នុរសម្លូ

នាឡិកេរសញ្ចារិយេនេវ នាឡិកេរសញ្ចារិយំ ខិប្បមេវ អភិសម្ភោន្តិ រតត្ថាយ ។ អថ ខលុ ភោ កុណាលោ សកុណោ តាហិ ទិជកញ្ញាហិ ទិវសំ បរិព្យូឡ្ហោ ឯវំ អបសាទេតិ នស្សថ តុម្ហេ វសលិយោ វិនស្សថ តុម្ហេ វសលិយោ ចោរិយោ ធុត្តិយោ អសតិយោ លហុចិត្តាយោ កតស្ស អប្បដិការិកាយោ អនិលោ វិយ យេនកាមង្គមាយោតិ ។

(២៩៧) តស្សេវ ខលុ ភោ ហិមវតោ បព្វតរាជស្ស បុរត្ថិមេ ទិសាភាគេ សុសុខុមសុនិបុណគិរិបភវា ហរិតុបយន្តិយោ ។ ឧប្បលបទុមកុមុទនឡិនសតបត្តសោគន្ធិកមន្ទាលកសម្បតិវិរូឡ្ហសុចិគន្ធមនុញ្ញមនាបកប្បទេសេ កុរវកមុចលិន្ទកេតកវេទិសវញ្ជុលបុន្នាគពកុលតិលកបិយកហសនសាលសលឡចម្បកអសោកនាគរុក្ខតិរីដិភុជបត្តលោទ្ទចន្ទនោឃវនេ កាឡាគរុបទុមបិយង្គុទេវទារុកចោចគហនេ

អំពីព្រៃដូនទៅកាន់ព្រៃដូន ដើម្បីសេចក្ដីសប្បាយរីករាយ ដោយឆាប់រហ័ស ។ គ្រានោះឯង បក្សីតាវៅនោះ ដែលពួកបក្សីកញ្ញាទាំងនោះ ចោមរោមហើយ ពេញមួយថ្ងៃ ក៏បណ្ដេញយ៉ាងនេះថា នៃមេចង្រៃ ហងឯងទាំងឡាយ ចូរចៀសចេញទៅ នៃមេចង្រៃ ជាចោរ ជាស្រីអ្នកលេង ហីនហោច មានចិត្តស្រាល មិនដឹងតបចំពោះឧបការគុណ ដែលគេធ្វើហើយ ជាអ្នករហើរហោច ក្នុងកាមដូចជាខ្យល់ ហងឯងទាំងឡាយ ចូរវិនាសទៅ ។

(២៩៧) មានសេចក្ដីដំណាលថា ក្នុងភាគទិសខាងកើត នៃស្ដេចភ្នំហិមវន្តនោះឯង មានស្ទឹងហូរនាំយកនូវស្មៅខៀវខ្ចី អំពីភ្នំដែលមានទឹកដ៏ល្អសុខុមថ្លាឈ្វេង ។ មានសេចក្ដីដំណាលថា តាវៅ-សឈ្មោះបុណ្ណមុខៈ មានសម្លេងដ៏ពីរោះក្រលួច មានភ្នែកក្រឡែត ដូចភ្នែកអ្នកស្រវឹង តែងអាស្រ័យនៅក្នុងដងព្រៃ ជាទីសប្បាយរីករាយ មានសភាពយ៉ាងនេះ គឺប្រទេសជាទីពេញចិត្តរីករាយ ដោយផ្កាឧប្បល ឈូកក្រហម កុមុទ ឈូកស ឈូកមានស្រទាប់ជាច្រើន ចង្កុលណី មានក្លិនក្រអូបឈ្ងុយឈ្ងប់ ទើបនឹងដុះឡើងថ្មីៗ ជាព្រៃដេរដាសដោយកុរវកព្រឹក្សពំងអន្ទក់កេតកព្រឹក្សវេទិស-ព្រឹក្ស ដើមជ្រៃ ដើមបុន្នាគ ពកុល ទ្រមូច ទ្រមូង កុម្ព ជន់ពំងភ្នំ ស្រឡៅ ចម្បក អសោកព្រឹក្ស ខ្លឹង ស្នាប់ លោទ្ធ នឹងចន្ទក្រហមជាព្រៃញាតស្បាត ដោយដើមឈើខ្មៅ បិយង្គុ មានពណ៌ក្រហម ទេពទារុ បេកមានគ្រាប់

កកុធកុដជអង្កោលកច្ចិការកណិការកណវេរកោ-
រណ្ឌកោវិឡារកិំសុកយោធិកវនមល្លិកមនង្គណមន-
វជ្ជភណ្ឌិសុរុចិភគិនិមាលមល្យធរេ ជាតិសុមនមធុគន្ធិ-
កជនុតក្ការិតាលិសតគរឧសីរកោដ្ឋកច្ឆវិតតេ អតិ-
មុត្តកសំកុសុមិតលតាវិតតបដិមណ្ឌិតប្បទេសេ ហំ-
សបិលវកាទម្ពការណ្ឌវាភិនាទិតេ វិជ្ជាធរសិទ្ធសម-
ណតាបសគណាធិវុត្ថេ វរទេវយក្ខរក្ខសទានវគន្ធព្វ-
កិន្នរមហោរគានុចិណ្ណប្បទេសេ ឯវរូបេ ខលុ ភោ រម្ម-
វនសណ្ឌេ បុណ្ណមុខោ នាម ផុស្សកោកិលោ បដិវសតិ
អតិវិយ មធុរគិរោ វិលាសិតនយនមត្តក្ខោ ។ តស្សេវ
ខលុ ភោ បុណ្ណមុខស្ស ផុស្សកោកិលស្ស អឌ្ឍុឌ្ឍានិ
ឥត្ថិសតានិ បរិចារិកា ទិជកញ្ញាយោ ។ អថ ខលុ ភោ
ទ្វេ ទិជកញ្ញាយោ កដ្ឋំ មុខេន ឌំសិត្វា តំ បុណ្ណមុខំ
ផុស្សកោកិលំ មជ្ឈេ និសីទាបេត្វា ឧឌ្ឌេន្តិ មា នំ បុណ្ណ-
មុខំ ផុស្សកោកិលំ អទ្ធានបរិយាយបថេ កិលមថោ
ឧព្ពាហេថាតិ ។ បញ្ញាស ទិជកញ្ញាយោ ហេដ្ឋតោ ហេដ្ឋ-
តោ ឧឌ្ឌេន្តិ សចាយំ បុណ្ណមុខោ ផុស្សកោកិលោ អាស-
នា បរិបតិស្សតិ មយំ តំ បក្ខេហិ បដិគ្គហេស្សាមាតិ ។

ជាព្រៃទ្រទ្រង់ នូវដើមថ្កាន់ ខ្ទិងគង់ ព្រូស ម៉ៃសាក់ កណិការ ដើមច្បារ ដើមប្រមោយដំរី ដើមល្ហុសផ្អុង ដើមចារ ដើមយុក្ថា និងបង្កោមផ្កាម្ទេះព្រៃ ក្ដាំងវា ចម្បា ចម្បី នួនស្រី ជាព្រៃដ៏ដេរដាស ដោយម្ទេះវល្ល បេកទេស ប្រទៀង ដើមទ្រាំង ក្រស្នា ស្បូវក្ដាំង និងគុម្ព ឈើជាពួក ៗ ជាប្រទេស ដ៏ប្រដាប់ដោយដើមឈើដ៏ដេរដាស គឺដើម រំដួលនិងល្វើមានផ្កាដ៏ល្អ ជាព្រៃឮសូរសម្រែកនៃសត្វ ហង្ស ទុង ប្រវឹក ក្អែកទឹក ជាទីដែលពួកវិទ្យាធរសមណៈ និងតាបសឥសី សក្ដិសិទ្ធនៅ អាស្រ័យ ជាប្រទេសដែលនរជន ទេវតា យក្ស អារក្សទឹក អសុរ គន្ធព្វ និងកិន្នរអាស្រ័យនៅជាច្រើន ៗ មានសេចក្ដីដំណាលថា សត្វតាវ៉ោ_ស ឈ្មោះបុណ្ណមុខៈនោះឯង មានបក្សីកញ្ញាចំនួន ៣៥០ ជាអ្នកបម្រើ ៗ មានសេចក្ដីដំណាលថា គ្រានោះឯង មានបក្សីកញ្ញាពីរ ពាំមែកឈើ ដោយមាត់ ហើយឱ្យសត្វតាវ៉ោ..ស ឈ្មោះបុណ្ណមុខៈនោះទំត្រង់កណ្ដាល ហើរទៅដោយគិតថា កុំឱ្យមានសេចក្ដីលំបាកក្នុងផ្លូវឆ្ងាយ ប៉ះពាល់តា_វ៉ោ_សឈ្មោះបុណ្ណមុខៈនោះឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរ ពីខាងក្រោម ៗ ដោយគិតថា បើតាវ៉ោ_សឈ្មោះបុណ្ណមុខៈនេះ និងធ្លាក់ អំពីបង្គង ពួកយើងនឹងទទួលតាវ៉ោ_សនោះ ដោយស្លាបទាំងឡាយ ៗ

បញ្ញាស និជកញ្ញាយោ ឧបរូបរិ ឱន្តិ មា នំ បុណ្ណមុខំ ផុស្ស-
កោកិលំ អាតាបោ បរិតាបេសីតិ ។ បញ្ញាស បញ្ញាស
និជកញ្ញាយោ ឧភតោ បស្សេន ឱន្តិ មា នំ បុណ្ណមុខំ
ផុស្សកោកិលំ សីតំ វា ឧណ្ហំ វា តិណំ វា រជោ វា វាតោ
វា ឧស្សាវោ វា ឧបប្ផុសីតិ ។ បញ្ញាស និជកញ្ញាយោ
បុរតោ បុរតោ ឱន្តិ មា នំ បុណ្ណមុខំ ផុស្សកោកិលំ
គោបាលកា វា បសុបាលកា វា តិណហារកា វា កដ្ឋ-
ហារកា វា វនកម្មិកា វា កដ្ឋេន វា កឋលាយ វា បាណិនា
វា (បាសាណេន វា) លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា
សក្ខរាហិ វា បហារំ អទំសុ មាយំ បុណ្ណមុខោ ផុស្សកោ-
កិលោ គច្ឆេហិ វា រុក្ខេហិ វា លតាហិ វា សាខាហិ វា
ថម្ភេហិ វា បាសាណេហិ វា ពលវន្តេហិ វា បក្ខីហិ សង្គា-
មេសីតិ ។ បញ្ញាស និជកញ្ញាយោ បច្ឆតោ បច្ឆតោ ឱន្តិ
សណ្ហាហិ សខិលាហិ មញ្ជូហិ មធុរាហិ វាចាហិ សមុ-
ទាចរន្តិយោ មាយំ បុណ្ណមុខោ ផុស្សកោកិលោ អាស-
នេ បរិយុក្កណ្ឋីតិ ។ បញ្ញាស និជកញ្ញាយោ ទិសោទិ-
សំ ឱន្តិ អនេករុក្ខវិវិធវិកតិផលមាហរន្តិយោ មាយំ
បុណ្ណមុខោ ផុស្សកោកិលោ ខុទ្ទាយ បរិកិលមិត្ថាតិ ។

ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរអំពីខាងលើ ៗ ដោយគិតថា សូមកុំឲ្យកំដៅក្តៅដល់តាបស ឈ្មោះបុណ្ណមុខៈនោះឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០ ( ម្ខាង ) ក៏ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ក្តៅស្មៅធូលី ខ្យល់ ឬទឹកសន្សើម ប៉ះពាល់ត្រូវតាបស ឈ្មោះបុណ្ណមុខៈនោះឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅអំពីខាងមុខ ៗ ដោយគិតថា សូមកុំឲ្យគង្វាលគោ គង្វាលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃ ប្រហារស្តបសត្វតាបសឈ្មោះបុណ្ណមុខៈនោះ ដោយកំណាត់ឈើ ដោយអម្បែង ដោយដៃ (ដោយដុំថ្ម) ដោយដុំដី ដោយដម្បង ដោយសាស្ត្រាវុធ ដោយដុំក្រួសទាំងឡាយ សូមកុំឲ្យតាបស ឈ្មោះបុណ្ណមុខៈនេះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ ដើមឈើ មែកឈើ សសរ ដុំថ្ម ឬក៏ពួកបក្សីមានកម្លាំងឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០ ហើរអំពីខាងក្រោយ ៗ និយាយឆ្លើយឆ្លងគ្នា ដោយពាក្យដ៏ស្រទន់ផ្ទួរផងពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យតាបសឈ្មោះបុណ្ណមុខៈអផ្សុកលើទ្រនំឡើយ ៗ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេង ៗ បំទៀកជាច្រើនយ៉ាង ដោយគិតថា សូមកុំឲ្យតាបសឈ្មោះបុណ្ណមុខៈនេះ លំបាកដោយការស្រេកឃ្លានឡើយ ៗ

អថ ខលុ ភោ តា និជ្ឈញ្ញាយោ តំ បុណ្ណមុខំ ផុស្ស-
កោកិលំ អាកាសេនេវ អាកាសំ ឧយ្យានេនេវ ឧយ្យានំ
នទីតិត្ថេនេវ នទីតិត្ថំ បព្វតសិខរេនេវ បព្វតសិខរំ
អម្ពវនេនេវ អម្ពវនំ ជម្ពុវនេនេវ ជម្ពុវនំ លពុជវនេនេវ
លពុជវនំ នាឡិកេរសញ្ចារិយេនេវ នាឡិកេរសញ្ចារិំ
ខិប្បមេវ អភិសម្ភោន្តិ រតិត្ថាយ ។ អថ ខលុ ភោ បុណ្ណ-
មុខោ ផុស្សកោកិលោ តាហិ និជ្ឈញ្ញាហិ និរស្សំ
បរិព្យូឡ្ហោ ឃរំ បសំសតិ សាធុ សាធុ ភគិនិយោ ឯតំ
ខោ ភគិនិយោ តុម្ហាកំ បដិរូបំ កុលធីតានំ យំ តុម្ហេ
ភត្តារំ បរិចរេយ្យាថាតិ ។

(២៩៨) អថ ខលុ ភោ បុណ្ណមុខោ ផុស្សកោកិលោ
យេន កុណាលោ សកុណោ តេនុបសង្កមិ ។ អទ្ទសំ-
សុ ខោ កុណាលស្ស សកុណស្ស បរិចារិកា និ-
ជ្ឈញ្ញាយោ តំ បុណ្ណមុខំ ផុស្សកោកិលំ ទូរតោវ
អាគច្ឆន្តំ ទិស្វាន យេន បុណ្ណមុខោ ផុស្សកោកិលោ
តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ បុណ្ណមុខំ ផុស្សកោ-
កិលំ ឯតទវោចុំ អយំ សម្ម បុណ្ណមុខ កុណាលោ
សកុណោ អតិវិយ ផរុសោ អតិវិយ ផរុសវាចោ
អប្បេវ នាម តុវំបិ អាគម្ម បិយវាចំ លភេយ្យាមាតិ ។

គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំតាវើសឈ្មោះបុណ្ណមុខៈ អំពីសួនបុប្ផា ទៅកាន់សួនបុប្ផា អំពីឧទ្យាន ទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹង ទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំ ទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយ ទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីង ទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្ល ទៅកាន់ព្រៃខ្នុរសម្ល អំពីព្រៃដូង ទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយដោយឆាប់រហ័ស ។ គ្រានោះឯង តាវើស ឈ្មោះបុណ្ណមុខៈ ដែលពួកបក្សីកញ្ញាទាំងនោះ បំរើល្បួងអស់ថ្ងៃមួយ សរសើរយ៉ាងនេះថា ម្នាលនាងទាំងឡាយ ប្រពៃណាស់ ៗ នាងទាំងឡាយ បំរើប្តីដោយហេតុណា ម្នាលនាងទាំងឡាយ ហេតុនោះឯង ជាកិច្ចដ៏សមគួរដល់នាងទាំងឡាយ ជាធីតាក្នុងត្រកូលហើយ ។

(២៩៨) គ្រានោះ តាវើសឈ្មោះបុណ្ណមុខៈ ចូលទៅរកកុណាលសកុណៈ (តាវើខ្មៅ) ។ បក្សីកញ្ញាជាអ្នកបំរើកុណាលសកុណៈ បានឃើញតាវើសឈ្មោះបុណ្ណមុខៈនោះមកពីចម្ងាយ លុះឃើញហើយ នាំចូលទៅរកតាវើស ឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយនិយាយពាក្យនេះនឹងតាវើស ឈ្មោះបុណ្ណមុខៈនោះថា បពិត្របុណ្ណមុខៈសម្លាញ់ កុណាលសកុណៈនេះ អាក្រក់ក្រៃលែង មានសំដីអាក្រក់ក្រៃលែង ពួកយើងសូមពឹងផ្អែកនូវលោក ក្រែងបានវាចាជាទីស្រឡាញ់(អំពីកុណាលៈ) ។

អបេ្សរ៍ នាម ភគិនិយោតិ វត្វា យេន កុណាលោ សកុណោ តេនុបសង្កមិ ឧបសង្កមិត្វា កុណាលេន សកុណេន សទ្ធឹ បដិសម្មោទិត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បុណ្ណមុខោ បុស្សកោកិលោ តំ កុណាលំ សកុណំ ឯតទវោច កិស្ស ត្វំ សម្ម កុណាល ឥត្ថីនំ សុជាតានំ កុលធីតានំ សម្មាបដិ-បន្នានំ មិច្ឆាបដិបន្នោសិ អមនាបភាណីនំបិ កិរ សម្ម កុណាល ឥត្ថីនំ មនាបភាណិនា ភវិតព្វំ កិមង្គំ បន មនាបភាណីនន្តិ ។ ឯវំ វុត្តេ កុណាលោ សកុណោ តំ បុណ្ណមុខំ បុស្សកោកិលំ ឯវំ អបសាទេសិ នស្ស ត្វំ សម្ម ជម្ម វសល វិនស្ស ត្វំ សម្ម ជម្ម វសល កោ នុ តយា វិយត្តោ ជាយាជិនេនាតិ ។ ឯវំ អបសាទិតោ ច បន បុណ្ណមុខោ បុស្សកោកិលោ តតោយេវ បដិនិវត្តិ ។

(២៩៩) អថ ខលុ ភោ បុណ្ណមុខស្ស បុស្សកោ-កិលស្ស អបរេន សមយេន អចិរស្សេវ អច្ច-យេន ខរោ អាពាធោ ឧប្បជ្ជិ ។ លោហិត-បក្ខន្ទិកា ពាឡ្ហា វេទនា វត្តន្តិ មារណន្តិកា ។

តាវ៉េស ឆ្លើយតបថា ឱប្អូនស្រីទាំងឡាយ យ៉ាងនោះឬ ហើយក៏ចូលទៅរកកុណាលសកុណៈ លុះចូលទៅដល់ហើយ ក៏និយាយសំណេះសំណាល ជាមួយនឹងកុណាលសកុណៈ ហើយទុំក្នុងទីដ៏សមគួរ ។ លុះតាវ៉េស ឈ្មោះបុណ្ណមុខៈ ទុំក្នុងទីដ៏សមគួរហើយ និយាយពាក្យនេះនឹងកុណាលសកុណៈនោះថា នែកុណាលៈសម្លាញ់ ហេតុអ្វី អ្នកប្រតិបត្តិខុសចំពោះតាវ៉េញី ដែលមានជាតិល្អ ជាធីតាក្នុងត្រកូល ជាអ្នកប្រតិបត្តិល្អ នែកុណាលៈសម្លាញ់ ឮថា អ្នកគួរនិយាយសំដី ជាទីពេញចិត្ត ទៅរកពួកតាវ៉េញី សូម្បីនិយាយសំដីមិនជាទីគាប់ចិត្ត នឹងចាប់និយាយប្ដីដល់ពួកតាវ៉េញី ជាសត្វនិយាយសំដីជាទីពេញចិត្ត ។ កាលបើតាវ៉េសនិយាយយ៉ាងនេះហើយ កុណាលសកុណៈ ក៏បណ្ដេញតាវ៉េសឈ្មោះបុណ្ណមុខៈនោះថា នែសំឡាញ់ ជាសត្វអាក្រក់ចង្រៃ អ្នកចូរចៀសចេញ នែសំឡាញ់ជាសត្វអាក្រក់ចង្រៃ អ្នកចូរវិនាសទៅ នរណាឡើយ ជាអ្នកឈ្លាសវៃជាងអ្នក ជាអ្នកចាញ់ស្រី ។ ចំណែកខាងតាវ៉េស ឈ្មោះបុណ្ណមុខៈ ត្រូវកុណាលសកុណៈ បណ្ដេញយ៉ាងនេះហើយ ក៏ត្រឡប់មកអំពីទីនោះវិញ ។

(២៩៩) គ្រានោះឯង លុះសម័យខាងក្រោយមក កន្លងទៅមិនយូរប៉ុន្មាន តាវ៉េស ឈ្មោះបុណ្ណមុខៈ មានជម្ងឺ ជាទម្ងន់ ។ មានវេទនាយ៉ាងខ្លាំង គឺរោគធ្លាក់ឈាម រៀបដល់ នូវមរណៈ ។

អថ ខលុ ភោ បុណ្ណមុខស្ស ផុស្សកោកិលស្ស បរិចារិកានំ ទិជកញ្ញានំ ឯតទហោសិ អាពាធិកោ ខោ អយំ បុណ្ណមុខោ ផុស្សកោកិលោ អប្បេវ-នាម ឥមម្ហា អាពាធា វុដ្ឋហេយ្យាតិ ។ តំ ឯកកំ អទុតិយំ ឱហាយ យេន កុណាលោ សកុណោ តេនុបសង្កមឹសុ ។ អទ្ទសា ខោ កុណាលោ សកុ-ណោ តា ទិជកញ្ញាយោ ទូរតោវ អាគច្ឆន្តិយោ ទិស្វាន តា ទិជកញ្ញាយោ ឯតទវោច កហំ បន តុម្ហំ វសលិយោ ភត្តាតិ ។ អាពាធិកោ ខោ សម្ម កុណាល បុណ្ណមុខោ ផុស្សកោកិលោ អប្បេវ នាម ឥមម្ហា អាពាធា វុដ្ឋហេយ្យាតិ ។ ឯវំ វុត្តេ កុណាលោ សកុណោ តា ទិជកញ្ញាយោ ឯវំ អបសាទេសិ នស្សថ តុម្ហេ វសលិយោ វិនស្សថ តុម្ហេ វសលិ-យោ ចោរិយោ ធុត្តិយោ អសតិយោ លហុចិត្តាយោ កតស្ស អប្បដិការិកាយោ អនិលោ វិយ យេន-កាមង្គមាយោតិ វត្វា យេន បុណ្ណមុខោ ផុស្ស-កោកិលោ តេនុបសង្កមិ ឧបសង្កមិត្វា តំ បុណ្ណមុខំ ផុស្សកោកិលំ ឯតទវោច ហំ សម្ម បុណ្ណមុខាតិ ។

គ្រានោះ ពួកបក្សីកញ្ញា ជាអ្នកបម្រើតាវើស ឈ្មោះបុណ្ណមុខៈ មានសេចក្តីត្រិះរិះយ៉ាងនេះថា តាវើស ឈ្មោះបុណ្ណមុខៈនេះ មានជម្ងឺជាខ្លាំង ធ្វើដូចម្តេច លោកនឹងបានសះស្បើយ ចាកជម្ងឺនេះ ។ ពួកបក្សីកញ្ញាបោះបង់តាវើសនោះ ឲ្យនៅតែម្នាក់ឯង មិនឲ្យមានគ្នា ជាគំរប់ពីរ ហើយនាំគ្នាចូលទៅរកកុណាលសកុណៈ ។ កុណាលសកុណៈនោះ បានឃើញពួកបក្សីកញ្ញាទាំងនោះ កំពុងមកពីចម្ងាយ លុះឃើញហើយ និយាយពាក្យនេះ នឹងពួកបក្សីកញ្ញានោះថា នែមេចង្រៃរាល់គ្នា ចុះប្តីរបស់ហងឯង ទៅក្នុងទីណា ។ ពួកបក្សីកញ្ញាទាំងនោះតបថា បពិត្រកុណាលៈជាម្ចាស់ តាវើសឈ្មោះបុណ្ណមុខៈ មានជម្ងឺជាខ្លាំង ធ្វើដូចម្តេច លោកនឹងបានសះស្បើយចាកជម្ងឺនោះ ។ កាលពួកបក្សីកញ្ញាឆ្លើយតបយ៉ាងនេះហើយ កុណាលសកុណៈ ក៏បណ្តេញពួកបក្សីកញ្ញាទាំងនោះយ៉ាងនេះថា នែពួកមេចង្រៃ ហងឯងចូរចៀសចេញទៅ នែមេចង្រៃជាចោរ ជាស្រីអ្នកលេង ហីនហោច មានចិត្តស្រាល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើរហោចក្នុងកាម ដូចជាខ្យល់ ហងឯងទាំងឡាយ ចូរវិនាសទៅ លុះពោលដូច្នេះហើយ ក៏ចូលទៅរកតាវើស ឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងតាវើស ឈ្មោះបុណ្ណមុខៈនោះថា នែបុណ្ណមុខៈសំឡាញ់ ម្តេចទៅហ៎ ។

ហំ សម្ម កុណាលាតិ ។ អថ ខលុ ភោ កុណាលោ សកុណោ តំ បុណ្ណមុខំ ផុស្សកោកិលំ បក្ខេហិ ច មុខតុណ្ឌកេន ច បរិគ្គហេត្វា វុដ្ឋាបេត្វា នានាគេសដ្ឋានិ នយាបេសិ ។ អថ ខលុ ភោ បុណ្ណមុខស្ស ផុស្សកោកិលស្ស សោ អាពាធោ បដិប្បស្សម្ភីតិ ។

[៣០០] អថ ខលុ ភោ កុណាលោ សកុណោ តំ បុណ្ណមុខំ ផុស្សកោកិលំ គិលានា វុដ្ឋិតំ អចិរវុដ្ឋិតំ គេលញ្ញា ឯតទវោច ទិដ្ឋា មយា សម្ម បុណ្ណមុខ កណ្ហា ទ្វេបិតិកា បញ្ចបតិកាយ ឆដ្ឋេ បុរិសេ ចិត្តំ បដិពទ្ធន្តិយា យទិទំ កពន្ធេ បីឋសប្បិម្ហិ ។ ភវតិ ច បនុត្តរេត្ថ ភាស្យំ

អថជ្ជុនោ នកុលោ ភីមសេនោ
យុធិដ្ឋិលោ សហទេវោ ច រាជា
ឯតេ បតី បញ្ចមតិច្ច នារី
អកាសិ ខុជ្ជវាមនកេន បាបន្តិ ។

ទិដ្ឋា មយា សម្ម បុណ្ណមុខ សច្ចតបាវី(១) នាម សមណី

១ ខ. សច្ចតបារី នាម ។ ម. សច្ចកបារី នាម ។

តាពេសឆ្លើយថា ឱកុណាលៈសំឡាញ់ ។ គ្រានោះ កុណាលសកុណៈ ជួយគ្រាហ៍តាពេស ឈ្មោះបុណ្ណមុខៈនោះ ដោយស្លាបទាំងឡាយផង ដោយចំពុះផង ឲ្យក្រោកឡើង ទើបឲ្យផឹកថ្នាំផ្សេង ៗ ។ គ្រានោះ ជម្ងឺរបស់តាពេស ឈ្មោះបុណ្ណមុខៈនោះ ក៏ជាសះស្បើយ ។

(៣០០) គ្រានោះ កុណាលសកុណៈ បាននិយាយពាក្យនេះនឹងតាពេស ឈ្មោះបុណ្ណមុខៈ ដែលសះស្បើយចាកជម្ងឺ ដែលស្រាកស្រាន្តចាកភាពនៃខ្លួនជាអ្នកឈឺ មិនយូរប៉ុន្មានថា នៃបុណ្ណមុខៈសំឡាញ់ កុមារីឈ្មោះនាងកណ្ហា មានបិតាពីរ មានប្តី ៥ នាក់ ជាប់ចំពាក់ចិត្តក្នុងបុរសទី ៦ គឺក្នុងបុរសខ្វិនគម (ដូចខ្ទោចកំបុតក) ក៏ខ្ញុំបានឃើញហើយ ។ ពាក្យក្នុងរឿងនោះ មានដូចតទៅនេះ

ស្ត្រីប្រព្រឹត្តកន្លងប្តីទាំង ៥ នាក់នុ៎ះគឺ អជ្ជុនរាជកុមារ ១
នកុលរាជកុមារ ១ ភីមសេនរាជកុមារ ១ យុធិដ្ឋិលរាជកុមារ១
សហទេវរាជកុមារ១ ធ្វើនូវអំពើដ៏លាមកគឺ សេពមេថុនធម្ម
ជាមួយបុរសគមទាបតឿ ។

នៃបុណ្ណមុខៈសំឡាញ់ នាងសមណីឈ្មោះបញ្ចតបាវី កាលនៅកណ្តាលព្រៃ

សុសានមជ្ឈេ វសន្តី ចតុត្ថភត្តំ បរិណាមយមានា សុរា-ធុត្តកេន(១) បាបមកាសិ ។ ទិដ្ឋា មយា សម្ម បុណ្ណមុខ កាកាតី នាម ទេវី សមុទ្ទមជ្ឈេ វសន្តី ភរិយា វេន-តេយ្យស្ស នដកុវេរេន បាបមកាសិ ។ ទិដ្ឋា មយា សម្ម បុណ្ណមុខ កុរុង្គទេវី នាម លោមសុទ្ទរី ឯឡក-កុមារំ កាមយមានា ឆឡង្គកុមារធនន្តេវាសិនា បាប-មកាសិ ។ ឯវញ្ហេតំ មយា ញាតំ ព្រហ្មទត្តស្ស មាតុកា ឱហាយ កោសលរាជំ បញ្ចាលចណ្ឌេន បាបមកាសិ ។

ឯតា ច អញ្ញា ច អកំសុ បាបំ
តស្មាហំ ឥត្ថីនំ ន វិស្សសេ នប្បសំសេ
មហី យថា ជគតិសមានរត្តា
វសុន្ធរា ឥតរីតរានំ បតិដ្ឋា
សព្វស្សហា អផន្ទនា អកុប្បា
តថិត្ថិយោ តាយោ ន វិស្សសេ នរោ
សីហោ យថា លោហិតមំសភោជនោ
វាឡមិគោ បញ្ចាវុធោ សុរុទ្ធោ

១ ឱ. សា គុណាបុត្តកេន ។ ម. សា សុភធុត្តកេត ។

ស្មសាន រំលងពេលនូវបាយ ៤ ដង បានធ្វើនូវអំពើដ៏លាមកជាមួយនឹង អ្នកលេងស្រា ខ្ញុំបានឃើញហើយ ៗ នៃបុណ្ណមុខៈសំឡាញ់ នាងទេវី ឈ្មោះកាកាតី កាលនៅកណ្ដាលសមុទ្រ ជាភរិយារបស់វេនតេយ្យ បានធ្វើនូវអំពើដ៏លាមក ជាមួយនឹងបុរសឈ្មោះនដកុវេរៈ ខ្ញុំក៏បានឃើញ ហើយ ៗ នៃបុណ្ណមុខៈសំឡាញ់ ព្រះអគ្គមហេសីមានព្រះលោមាល្អ ព្រះនាមកុរង្គទេវី កាលបង់បានឯឡកកុមារ ធ្វើនូវអំពើដ៏លាមកជាមួយនឹង បុរសអ្នកនៅជាយទ្រព្យ ( បុរសខ្ញុំគេ ) ឈ្មោះឆឡង្គកុមារ ខ្ញុំក៏បាន ឃើញហើយ ៗ សេចក្ដីពិត រឿងដូចគ្នានេះ ខ្ញុំដឹងហើយយ៉ាងនេះថា ព្រះវរមាតារបស់ព្រះបាទព្រហ្មទត្ត លះបង់ព្រះបាទកោសល ទៅធ្វើ អំពើដ៏លាមកជាមួយនឹងព្រាហ្មណកុមារ ឈ្មោះបញ្ចាលចណ្ឌៈ ៗ

ពួកស្ត្រីទាំងនុ៎ះក្ដី ពួកស្ត្រីឯទៀតក្ដី បានធ្វើនូវអំពើដ៏លាមកព្រោះ ហេតុនោះ ទើបខ្ញុំមិនទុកចិត្ត មិនសរសើរស្ត្រីទាំងឡាយទេ ពួក ស្ត្រីដូចផែនដីជាទីដើរទៅ ជាទីទ្រទ្រង់ មានសេចក្ដីត្រេកអរស្មើជា ទីតំកល់ទុកនៃវត្ថុគ្រប់យ៉ាង អត់ធន់ចំពោះអារម្មណ៍ទាំងពួង មិន ញាប់ញ័រ មិនកម្រើក នរជនមិនគប្បីទុកចិត្តស្ត្រីទាំងនោះទេ សីហៈជាម្រឹគសាហាវ ជាសត្វស៊ីឈាមនឹងសាច់ មានអាវុធ ៥

បសយ្ហ ខាទី បរហឹសនេ រតោ

តថិត្ថិយោ តាយោ ន វិស្សសេ នរោ ។

ន ខលុ សម្ម បុណ្ណមុខ វេសិយោ នារិយោ គម-
និយោ នហេតា ពន្ធកិយោ នាម វធិកាយោ នាម
ឯតាយោ យទិទំ វេសិយោ នារិយោ គមនិយោតិ ។
ចោរា វិយ វេណិកតា មទិរា វិយ វិសទុដ្ឋា វាណិជោ
វិយ វាចាសន្ថុតិយោ ឥស្សសិង្គមិវ វិបរីវត្តាយោ
ឧរគមិវ ទុជ្ជិវ្ហាយោ សោព្ភមិវ បដិច្ឆន្នា បាតាលមិវ
ទុប្បូរា រក្ខសី វិយ ទុត្តោសា យមោវេកន្តហារិយោ
សិខីរិវ សព្ពភក្ខា នទីរិវ សព្ពវាហិនី អនិលោ វិយ
យេនកាមំចរា នេរុ វិយ អវិសេសករា វិសរុក្ខោ
វិយ និច្ចផលិតាយោ ។ ភវតិ ច បនេត្ថ វាក្យំ

យថា ចោរោ យថា ទុដ្ឋោ វាណិជោវ វិកត្ថនី

ឥស្សសិង្គមិវ បរិវត្តា ទុជ្ជិវ្ហា ឧរគោ យថា ។

សោព្ភមិវ បដិច្ឆន្នា បាតាលមិវ ទុប្បូរា

រក្ខសី វិយ ទុត្តោសា យមោវេកន្តហារិយោ ។

សាហាវក្រៃលែង ត្រេកអរក្នុងការបៀតបៀនសត្វដទៃ កំហែង
ខាំស៊ីយ៉ាងណាមិញ ពួកស្ត្រីទាំងនោះក៏ដូច្នោះដែរ នរជនមិន
គួរទុកចិត្តឡើយ ។

នៃបុណ្ណមុខៈសំឡាញ់ ស្រីទាំងឡាយមិនមែនឈ្មោះថា ពេស្យា ជានារី ជាជាទីគប់រកទេ ស្រីទាំងនុ៎ះ មិនមែនគ្រាន់តែឈ្មោះថា អ្នកកោងកាច អ្នកបង់ទុក (នូវបុរស)ទេ ស្រីទាំងនុ៎ះ គឺស្រីពេស្យា នារី ជាទីគប់រក ឈ្មោះថា ស្រីសម្លាប់ (ប្ដី) ៗ ពួកស្រីស្អិតស្អាងផ្ទង់សក់ ដូចចោរ ដូចគ្រឿងស្រវឹងដែលលាយដោយថ្នាំពិស បិទបាំងដោយវាចា ដូចពាណិជ មានអាការប្រែប្រួល ដូចកុយមាស មានអណ្ដាតពីរដូចពស់ បិទបាំង (នូវកាយ) ដូចជាគេបិទបាំងរណ្ដៅ បំពេញបានដោយក្រដូចសមុទ្រ ត្រេកអរបានដោយក្រដូចអារក្សទឹក នាំទៅដោយដាច់ខាតដូចយមបាល ស៊ីនូវវត្ថុគ្រប់មុខដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង ប្រព្រឹត្តរហើរហាចដូចខ្យល់ ធ្វើនូវវត្ថុមិនឲ្យប្លែកគ្នាដូចភ្នំនេរុ ផ្ទៃជានិច្ចដូចឈើមានពិសពុល ៗ ពាក្យក្នុងរឿងនេះ មានតទៅទៀតថា

ពួកស្រីមានកលមាយាដូចចោរ មានពិសខ្លាំងដូចសុរាដែលលាយ
ថ្នាំពិស និយាយបិទបាំងទោសដូចពាណិជ មានអាការប្រែប្រួលដូច
កុយមាស មានអណ្ដាតពីរដូចពស់ៗ ពួកស្រីបិទបាំង(នូវកាយ)ដូច
ជាគេបិទបាំងរណ្ដៅ បំពេញបានដោយក្រដូចសមុទ្រ ត្រេកអរបាន
ដោយក្រដូចអារក្សទឹក នាំយកទៅដោយដាច់ខាតដូចយមបាល ៗ

យថា សិរី ធនី ភោគោ(១) អធិរោ កាមទារភិ
នេរុ អភិសេកា(២) ច វិសុក្ខោរ ធិច្ចដលី
ធាសយន្តិ យរេ គោកំ រតនានន្តការិត្ថុយោតិ ។

[៣០១] ចត្តារិមានិ សម្ម បុណ្ណមុខ យានិ បរកុលេ ន វាសេតព្ពានិ គោណំ ធេនុំ យានំ ភរិយា ចត្តារិ ឋានានិ បណ្ឌិតោ យានិ(៣) ឃរា ន វិប្បវាសយេ ។

គោណំ ធេនុញ្ច យានញ្ច
ភរិយំ ញាតិកុលេ ន វាសយេ
ភញ្ជន្តិ រថំ អយានកា
អតិភារេន វហន្តិ ធុរំ
ទោហេន ហនន្តិ វច្ឆកំ
ភរិយា ញាតិកុលេ បទុស្សតីតិ ។

[៣០២] ឆ ឥមានិ សម្ម បុណ្ណមុខ យានិ វត្ថូនិ កិច្ចេ ជាតេ អនត្ថចរានិ ភវន្តិ

អគុណំ ធនុ ញាតិកុលេ ច ភរិយា

---

ឱ. ម. ភាគោ ។ ២ ឱ. នេរុ នាវិសមាគមា ។ ម. នេរុ នាបសមាគមា ។ ៣ ម. ឯតានិ បណ្ឌិតោ ឆនានីតិ ទិស្សន្តិ ។

ពួកស្រីដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង មានអាការរហើរហាចក្នុងកាមដូចខ្យល់ មិនឲ្យមានបែកដូចភ្នំនេរុ មានផ្លែជានិច្ចដូចឈើមានពិសពុល ពួកស្រីតែងញ៉ាំងភោគៈ ក្នុងផ្ទះឲ្យវិនាស ធ្វើសេចក្ដីអន្តរាយនូវរតនវត្ថុទាំងឡាយ ។

(៣០១) នៃបុណ្ណមុខៈសំឡាញ់ ទ្រព្យណា ដែលបុគ្គល មិនត្រូវឲ្យនៅក្នុងត្រកូលនៃជនដទៃ ទ្រព្យទាំងនេះ មាន ៤ យ៉ាងគឺ គោឈ្មោល១ មេគោ ១ យាន១ ភរិយា ១ បណ្ឌិតមិនត្រូវញ៉ាំងទ្រព្យទាំង ៤ យ៉ាងនេះ ឲ្យនៅប្រាសចាកផ្ទះឡើយ ។

បុគ្គលមិនគប្បីញ៉ាំងគោឈ្មោល ១ គោញី ១ យាន ១ ភរិយា ១ ឲ្យនៅក្នុងត្រកូលញាតិទេ (ព្រោះថា) ពួកបុគ្គល មិនមានរទេះ រមែងប្រើប្រាស់រទេះ បៀតបៀននូវគោឈ្មោល ដោយការដឹកនាំហួសកម្លាំង បៀតបៀនមេគោ ដោយការរូតទឹកដោះ ភរិយារមែងប្រព្រឹត្តខូច (ក្បត់ចិត្តប្ដី) ក្នុងត្រកូលនៃញាតិ ។

(៣០២) នៃបុណ្ណមុខៈសំឡាញ់ វត្ថុ ៦ យ៉ាងនេះ រមែងមិនបានជាប្រយោជន៍ចំពោះកិច្ចការ ដែលកើតឡើងទេ (វត្ថុ ៦ យ៉ាង) គឺ ធ្នូគ្មានបន្ទោះ ១ ភរិយា (ដែលនៅ) ក្នុងត្រកូលញាតិ ១

បាវំ ភវំ អក្ខកតញ្ញូ យាតំ
ទូរេ មិត្តោ បាបសហាយកោ ច
កិច្ចេ ជាតេ អនត្ថចរា ភវន្តិ ។

(៣០៣) អដ្ឋហិ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី សាមិកំ អវជានាតិ ទលិទ្ទតា អាតុរតា ជិណ្ណកតា សុរាសោណ្ឌតា មុទ្ធតា បមត្តតា សព្វកិច្ចេសុ អនុវត្តនតា សព្វធនមនុប្បទានេន ឥមេហិ ខលុ សម្ម បុណ្ណមុខ អដ្ឋហិ ឋានេហិ ឥត្ថី សាមិកំ អវជានាតិ ។ ភវតិ ច បនុត្តរេត្ថ វាក្យំ

ទលិទ្ទំ អាតុរញ្ចាបិ ជិណ្ណកំ សុរសោណ្ឌកំ
បមត្តំ មុទ្ធបត្តញ្ច រត្តំ កិច្ចេសុ ហាបនំ
សព្វកាមប្បទានេន អវជានាតិ សាមិកន្តិ ។

(៣០៤) នវហិ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី បទោសមាហរតិ អារាមគមនសីលា ច ហោតិ ឧយ្យានគមនសីលា ច ហោតិ នទីតិត្ថគមនសីលា ច ហោតិ ញាតិកុលគមនសីលា ច ហោតិ បរកុលគមនសីលា ច ហោតិ អាទាសទុស្សមណ្ឌនានុយោគមនុយុត្តសីលា ច ហោតិ មជ្ជបាយិនី ច ហោតិ

ទូកនៅឯត្រើយម្ខាង ១ រទេះបាក់ក្ដៅ ១ មិត្តនៅក្នុងទីឆ្ងាយ ១ សំឡាញ់ដំណាមក ១ (ទាំងនេះ) រមែងមិនបានជាប្រយោជន៍បំពោះកិច្ចការ ដែលកើតឡើងទេ ។

(៣០៣) នៃបុណ្ណមុខៈសំឡាញ់ ស្រីរមែងមើលងាយប្ដីដោយហេតុ ៨ យ៉ាងគឺ សេចក្ដីទលក្រ ១ សេចក្ដីឈឺចាប់ជានិច្ច ១ សេចក្ដីចាស់គ្រាំគ្រា ១ ភាពជាអ្នកលេងផឹកសុរា ១ ភាពល្ងង់ខ្លៅ ១ សេចក្ដីធ្វេសប្រហែស ១ ការមិនប្រព្រឹត្តធ្វើរឿយ ៗ ក្នុងកិច្ចការទាំងពួង ១ ការមិនញ៉ាំងទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យកើតមាន ១ នៃបុណ្ណមុខៈសំឡាញ់ ស្រីរមែងមើលងាយប្ដីដោយហេតុ ៨ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ស្រីមើលងាយប្ដី (ដោយហេតុ ៨ យ៉ាង) គឺ ប្ដីទលក្រ ១ ប្ដីឈឺជានិច្ច ១ ប្ដីចាស់គ្រាំគ្រា ១ ប្ដីជាអ្នកលេងផឹកសុរា ១ ប្ដីធ្វេសប្រហែស ១ ប្ដីដល់នូវភាពល្ងង់ខ្លៅ ១ ប្ដីខ្ជិលច្រអូសក្នុងកិច្ចការ ១ ប្ដីញ៉ាំងសេចក្ដីប្រាថ្នាក្នុងវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងឲ្យវិនាស ១ ។

(៣០៤) នៃបុណ្ណមុខៈសំឡាញ់ ស្រីរមែងនាំមកនូវការប្រព្រឹត្តខូច ដោយហេតុ ៩ យ៉ាងគឺ ស្រីទៅកាន់សួនច្បាររឿយ ៗ ១ ទៅកាន់ឧទ្យានរឿយៗ ១ ទៅកាន់កំពង់ស្ទឹងរឿយៗ ១ ទៅកាន់ត្រកូលញាតិរឿយៗ ១ ទៅកាន់ត្រកូលដទៃរឿយ ៗ ១ ប្រកបរឿយ ៗ ក្នុងការលៃលកតែខាងកញ្ចក់ នឹងសំពត់ នឹងគ្រឿងស្អិតស្អាងជាប្រក្រតី ១ ផឹកនូវទឹកស្រវឹងជាប្រក្រតី ១

និល្លោកនសីលា ច ហោតិ បទ្វារដ្ឋាយិនី ច ហោតិ ឥមេហិ ខលុ សម្ម បុណ្ណមុខ នវហិ ឋានេហិ ឥត្ថី បទោសមាហរតីតិ ។ ភវតិ ច បនុត្តរេត្ថ វាក្យំ

អារាមគមនសីលា ច ឧយ្យានំ
នទី ញាតិបរកុលំ
ទុស្សមណ្ឌនមនុយុត្តា
យា ចិត្ថី មជ្ជបាយិនី
យា ច និល្លោកនសីលា
យា ច បទ្វារដ្ឋាយិនី
នវហេតេហិ ឋានេហិ
បទោសមាហរន្តិ ឥត្ថិយោ ។

(៣០៥) ចត្តាឡីសាយ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី បុរិសំ អច្ចាវទតិ វិជម្ភតិ វិនមតិ វិលាសតិ វិលជ្ជតិ នខេន នខំ ឃដ្ដេតិ បាទេន បាទំ អក្កមតិ កដ្ឋេន បឋវឹ វិលេខតិ ទារកំ ឧល្លង្ឃតិ ឧល្លង្ឃាបេតិ កីឡតិ កីឡាបេតិ ចុម្ពតិ ចុម្ពាបេតិ ភុញ្ជតិ ភុញ្ជាបេតិ ទទាតិ យាចតិ អាយាចតិ

មានការលេបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងនាំមកនូវការខូចកាចដោយហេតុ ៩ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ពួកស្រី តែងនាំមកនូវការខូច ដោយហេតុ ៩ យ៉ាងគឺ ជាអ្នកទៅកាន់សួនច្បាររឿយ ៗ ១ ទៅកាន់ឧទ្យាន ១ ទៅកាន់ស្ទឹង ១ ទៅកាន់ត្រកូលញាតិ ១ ទៅកាន់ត្រកូលដទៃ ១ ប្រកបរឿយ ៗ តែខាងសំពត់និងគ្រឿងស្អិតស្អាង ១ ជាស្រីផឹកទឹកស្រវឹង ជាប្រក្រតី ១ មានការលេបមើលបុរស មិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ ។

[៣០៩] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងចែចង់បុរសដោយហេតុ ៤០ យ៉ាងគឺ កាច់កាង ១ បន្ទន់ខ្លួន ១ កែក្រាយ ១ ក្រអឺមក្រអៀម ១ យកក្រចកផ្ទាត់ក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសផែនដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យថើបវិញ ១ ស៊ីខ្លួនឯង ១ ញុំាងកូនក្មេង ឲ្យស៊ី ១ ឲ្យវត្ថុទៅកូនក្មេង ១ សុំលួងលោមយកមកវិញ ១

កាឡមុក្ខកោកិ ឧទ្ធំ កាសតិ ឥតិ កាសតិ អារទ្ធំ កាសតិ វិវិទ្ធំ កាសតិ ឧច្ចេន តិខេន ភិន្នេន ភេទេន វិលា-សិតេន វិក្កសិតេន ជគ្ឃិតេ(ន) បេក្ខិតេ(ន) កាម៉ ចាលេតិ គុយ្ហ-កណ្ណាតិ សញ្ញាលេតិ ឱរុំ វិវរតិ ឱរុំ បិទហតិ ថនេ ទស្សេតិ កច្ឆំ ទស្សេតិ នាភិំ ទស្សេតិ អក្ខឹ និក្ខនតិ ភមុកំ ឧក្ខិបតិ ឱដ្ឋំ បលិក្ខតិ ជិវ្ហំ និល្លាលេតិ ទុស្សំ មុញ្ចតិ ទុស្សំ បដិពន្ធតិ សិរសំ មុញ្ចតិ សិរសំ ពន្ធតិ ន មេតំ ១លាសម្ពុ បុណ្ណមុខ បត្តាឡ្ហសាយ ឋានេហិ ឥត្ថី បុរិសំ អច្ចាវទតិ ។

(៣០៦) បញ្ចាសាយ ១លាសម្ពុ បុណ្ណមុខ ឋានេហិ ឥត្ថី បទុដ្ឋា វេទិតព្វា ករតិ សាមិកស្ស ឱមានំ វណ្ណតិ បត្ថេ ន សរតិ អាគតំ នាភិនន្ទតិ អវណ្ណំ តស្ស ភណតិ វណ្ណំ តស្ស ន ភណតិ អនត្ថំ តស្ស ចរតិ អត្ថំ តស្ស ន ចរតិ អកិច្ចំ តស្ស ករោតិ កិច្ចំ តស្ស ន ករោតិ បរិទហិត្វា សយតិ បរម្មុខី និបជ្ជតិ បរិវត្តកជាតា ហោតិ កុម្មុមិយជាតា ទីឃំ អស្សាសតិ ទុក្ខំ វេទយតិ ឧច្ចារបស្សាវំ អភិណ្ហំ គច្ឆតិ វិលោមមាចរតិ

ធ្វើត្រាប់តាម (ក្មេង) ដែលរាំធ្វើ ១ និយាយខ្លាំង ១ និយាយតិច ១ និយាយបើកបិទមាត់ ១ និយាយលាក់លៀម ១ (ធ្វើនូវនិមិត្ត) ដោយអាការកះប្រៀងប្រគំ យំរាប់រៀបមុំគម៉ក់ស្អិតស្អាង ១ សើចក្អាកក្អាយ ១ សំឡេងសំឡក់ ១ ញាក់បង្អេះ ១ ញុំាងទ្រព្យកំបាំងឲ្យកំរើក ១ បើកបង្ហាញភ្លៅ ១ បិទភ្លៅទៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់បំពើម ១ ខាំបបូរមាត់ ១ លៀនអណ្តាត ១ ប្រូតសំពត់ ១ ស្លៀកសំពត់វិញ ១ រំសាយសក់ ១ បួងសក់វិញ ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងបែចង់បុរសដោយហេតុ ៤០ យ៉ាងនេះឯង ៗ

(៣០៦) នែបុណ្ណមុខៈសំឡាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាង គឺស្រីសរសើរការទៅឃាតអំពីប្តី ១ មិនរឭកប្តីដែលទៅឃាតគ្នា ១ មិនត្រេកអរនឹងប្តី ដែលទើបមកដល់ ១ ពោលទោសប្តីនោះ ១ មិននិយាយសរសើរគុណប្តីនោះ ១ ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ មិនប្រព្រឹត្តសេចក្តីចំរើនដល់ប្តីនោះ ១ ធ្វើតែអំពើ ដែលមិនគួរធ្វើ ដល់ប្តីនោះ ១ មិនធ្វើអំពើដែលគួរធ្វើដល់ប្តីនោះ ១ ស្លៀកដាប់មាំបួនដេក ១ លបដេកកំបាំងមុខ ១ ដេកបម្រះននៀល ១ បង្កដម្លោះ ១ ដកដង្ហើមចេញវែង (ដូចជា) រង់ទុក្ខ ១ ទៅកាន់ទ្វារៈ បស្សាវៈ រឿយ ៗ ១ ប្រព្រឹត្តទទឹងទាស់ ១

បរបុរិសសទ្ទំ សុត្វា កណ្ណសោតំ វិទហតិ(១) នីហត-ភោគា ខោ បន ហោតិ បដិវិស្សកេហិ សន្ថវំ ករោតិ និក្ខន្តបាទា ខោ បន ហោតិ វិសិខានុចារិនី អតិចារិនី ខោ បន ហោតិ សាមិកេ អគារវា បទុដ្ឋមនសង្កប្បា អភិណ្ហំ ទ្វារេ តិដ្ឋតិ កច្ឆានិ អង្គានិ ថនានិ ទស្សេតិ ទិសោទិសំ គន្ត្វា បេក្ខតិ ឯវមេវ ខលុ សម្ម បុណ្ណមុខ បញ្ចវីសាយ ឋានេហិ ឥត្ថី បទុដ្ឋា វេទិតព្វា ភវតិ ។ ភវតិ ច បនុត្តរេត្ថ វាក្យំ

បកាសំ តស្ស វណ្ណេតិ
គតំ តស្ស ន សោចតិ
ទិស្វាន បតិមាគតំ
នាភិនន្ទតិ ភត្តរំ
វណ្ណំ ន កទាចិ ភាសតិ
ឯតេ បទុដ្ឋាយ ភវន្តិ លក្ខណា ។
អនត្ថំ តស្ស ចរតិ អសញ្ញតា
អត្ថញ្ច ហាបេតិ អកិច្ចការិនី
បរិទហិត្វា សយតិ បរម្មុខី

១ ម. វិវរមោទហតិ ។

ពួសម្ងន់ប្រុសឯទៀត ខំផ្ទៀងត្រចៀកស្តាប់ ១ ជាស្រីបំផ្លាញទ្រព្យ ១ ធ្វើនូវសន្ថវកិច្ចនឹងប្រុសទាំងឡាយ ដែលស្និទ្ធស្នាល ១ បានតែខាងដើរចេញដើរ ១ ជាស្រីប្រព្រឹត្តដើរលេងរឿយៗ ក្នុងវេលាយប់ ប្រព្រឹត្តកន្លងបិតុប្តី ១ មិនគោរពប្តី ១ មានចិត្តគិតគិតខូចកាច ១ ឈរទៀបមាត់ទ្វារញយៗ ១ បង្ហាញក្លៀក ពងកាយ ដោះ ដើរទៅកាន់ទិសទាំងពួងហើយក្រឡេកមើល ១ នៃបុណ្ណមុខៈសំឡាញ់ ស្រីដែលខូចបណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនុ៎ះ ដូចមានតទៅទៀត

ស្រីសរសើរនូវការនៅឃ្លាតអំពីប្តីនោះ ១ មិននឹកស្រណោះរកប្តីដែលទៅហើយ ១ ឃើញប្តីមកដល់ មិនត្រេកអរ ១ មិនពោលសរសើរគុណប្តី ក្នុងកាលណាមួយ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីជាអ្នកមិនសង្រួម ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ ញុំាងប្រយោជន៍ឲ្យវិនាស ១ ជាអ្នកធ្វើនូវកិច្ច ដែលមិនគួរធ្វើ ១ ស្លៀកដាប់មាំមួនដេក ១ ដេកក្នុងទីកំបាំងមុខ ១

អសីតិនិបាតេ បតុត្ថំ កុណាលជាតកំ

ឯតេ បទុដ្ឋាយ ភវន្តិ លក្ខណា ។
បរិត្តជាតា ច ភវតិ ភត្តុម្ហី
និយញ្ចុ អស្សាសតិ ទុក្ខវេទិនី
ឧច្ចារបស្សាវមភិណ្ហ គច្ឆតិ
ឯតេ បទុដ្ឋាយ ភវន្តិ លក្ខណា ។
វិលោមមាចរតិ អកិច្ចការិនី
សទ្ទំ និសាមេតិ បរស្ស ភាសតោ
និហតភោគា ច ករោតិ សន្ថវំ
ឯតេ បទុដ្ឋាយ ភវន្តិ លក្ខណា ។
កិច្ឆេន លទ្ធំ កសិរាភតំ ធនំ
វិត្តំ វិនាសេតិ ទុក្ខេន សម្ភតំ ។
បដិវិស្សកេហិ ច ករោតិ សន្ថវំ
ឯតេ បទុដ្ឋាយ ភវន្តិ លក្ខណា ។
និក្ខន្តទារា វិសិខានុចារិនី
និច្ចញ្ច សាមិម្ហិ បទុដ្ឋមានសា
អតិចារិនី ហោតិ អបេតគារវា
ឯតេ បទុដ្ឋាយ ភវន្តិ លក្ខណា ។
អភិក្ខណំ តិដ្ឋតិ ទ្វារមូលេ

ទាំងនេះជាលក្ខណៈរបស់ស្រីខូច ៗ ស្រីដេកបម្រះនទៀល ១ បន្ត ជះម្នាះ ១ ដកដង្ហើមវែង (ហាក់ដូចជា) រងទុក្ខវេទនា ១ ទៅកាន់ទីឧច្ចារៈ បស្សាវៈរឿយៗ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ៗ ស្រីជាអ្នកមិនធ្វើ ការងារ តែងប្រព្រឹត្តទទឹងទាស់ ១ ផ្ទៀងស្តាប់សម្លេងរបស់បុរសដទៃ និយាយ ១ បំផ្លាញទ្រព្យ ១ ធ្វើសន្ថវកិច្ច (នឹងបុរសដទៃ) ១ ទាំងនេះជា លក្ខណៈរបស់ស្រីខូច ៗ បំផ្លាញទ្រព្យសម្បត្តិដែលប្តីបានមកដោយក្រ នាំមកដោយលំបាក បានមកដោយទុក្ខ ១ ធ្វើសន្ថវកិច្ចនឹងពួកបុរស អ្នកស្និទ្ធស្នាល ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ៗ ស្រីបានតែខាង ដើងចេញដើរ ១ ដើរលេងរឿយ ៗ ក្នុងវេលាយប់ ១ មានចិត្តប្រទូស្ត ចំពោះប្តីជានិច្ច ១ ប្រព្រឹត្តកន្លងចិត្តប្តី ១ ប្រាសចាកសេចក្តីគោរព ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ៗ ស្រីឈរទៀបមាត់ទ្វារញយៗ ១

ធជានិ កដ្ឋានិ ច ឧស្សយន្តិ
ទិសោទិសំ បេក្ខតិ ភន្តចិត្តា
ឃាតេ បទុដ្ឋាយ ករន្តិ លក្ខណា ។
សព្វា នទី វង្កគតី[១] សព្វេ កដ្ឋមយា វនា
សព្វិត្ថិយោ ករេ បាបំ លភមានេ និវាតកេ ។
សចេ លភេថ ខណំ វា រហោ វា
និវាតកំ វាបិ លភេថ តាទិសំ
សព្វាវ ឥត្ថី កយិរុំ នុ បាបំ
អញ្ញំ អលទ្ធា បីឋសប្បិនា សទ្ធឹ ។
នរានមារាមករាសុ នារិសុ
អនេកចិត្តាសុ អនិគ្គហាសុ ច
សព្វត្ថតា បីតិករាបិ ចេ សិយុំ
ន វិស្សសេ តិត្ថសមា ហិ នារិយោតិ ។
[៣០៧] យញ្ច ទិស្វា កិន្នរកិន្នរីនំ
សព្វិត្ថិយោ ន រមន្តិ អគារេ
តំ តាទិសំ មច្ចំ ចជិត្វា ភរិយា
អញ្ញំ ទិស្វា បុរិសំ បីឋសប្បឹ ។
[៣០៨] ពកស្ស ច ពាវរិយស្ស រញ្ញោ

១ ម. វង្កនទី ។

បង្ហាញដោះនឹងភ្នែក ១ មានចិត្តភ្ញាក់ផ្អើលក្រឡេកមើលទិសទាំងពួង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្ទឹងទាំងអស់មានដំណើរវៀច ព្រៃទាំងអស់សម្រេចអំពីឈើ (យ៉ាងណាមិញ) ពួកស្រីទាំងអស់ (វៀរលែងតែស្រីដែលមានកិលេសស្តើង) កាលបើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏តែងធ្វើនូវអំពើលាមកបាន (យ៉ាងនោះដែរ) ។ ពួកស្រី បាននូវឱកាស ឬទីកំបាំង ឬក៏បាននូវបុគ្គលខ្សឹបខ្សៀវ ប្រាកដដូច្នោះ ពួកស្រីទាំងអស់ មិនបាននូវបុរសដទៃ ក៏គប្បីធ្វើនូវអំពើលាមក ជាមួយបុរសខ្វិនបាន ។ ពួកបុរស ទោះបីធ្វើនូវអំណរបំពោះនារីទាំងឡាយ ជាអ្នកធ្វើនូវសេចក្តីត្រេកអរដល់ពួកបុរស ជាស្រីមានចិត្តច្រើន ដែលគេផ្ចញ់ផ្ចាល់មិនបាន ដោយប្រការទាំងពួង បុគ្គលមិនត្រូវស្និទ្ធស្នាលទេ ព្រោះថា ស្រីទាំងឡាយ ស្មើដោយកំពង់ទឹក ។

(៣០៧) បុគ្គលឃើញ (នូវហេតុនៃសេចក្តីនឿយណាយ) របស់ព្រះរាជាព្រះនាមកិន្នរៈនឹងព្រះនាងកិន្នរី (គប្បីដឹងចុះ ;) ពួកស្រីទាំងអស់រមែងមិនត្រេកអរ ក្នុងផ្ទះ (របស់ស្វាមីទេ) ដូចជាភរិយា(របស់ព្រះរាជាកិន្នរៈ) លះបង់នូវសត្វគឹ (ស្វាមី) បែបនោះ ព្រោះឃើញនូវបុរសផ្តេសផ្តាសដទៃជាបុរសខ្វិន ។

(៣០៨) ភរិយា របស់ព្រះបាទពកៈ នឹងព្រះបាទ ពាវរិយៈ

អច្ចន្តកាមានុគតស្ស ភរិយា
អជ្ឈាចរី បដ្ឋវសានុគតស្ស
កំ វា ឥត្ថី នាតិចរេ តទញ្ញំ ។
(៣០៩) ពិង្គិយានី សព្វលោកិស្សរស្ស
រញ្ញោ បិយា ព្រហ្មទត្តស្ស ភរិយា
អជ្ឈាចរី បដ្ឋវសានុគតស្ស
តំ វាបិ សា នាជ្ឈគា កាមកាមិនី ។
(៣១០) លុទ្ធានំ លហុចិត្តានំ អកតញ្ញូន ទុព្ភិនំ
នាទេវសត្តោ បុរិសោ ថីនំ សទ្ធាតុមរហតិ ។
ន តា បជានន្តិ កតំ ន កិច្ចំ
ន មាតរំ បិតរំ ភាតរំ វា
អនរិយា សមតិក្កន្តធម្មា
សស្សេវ ចិត្តស្ស វសំ វជន្តិ ។
ចិរានុវុត្ថំបិ បិយំ មនាបំ
អនុកម្បកំ បាណសមំបិ សន្តំ
អាបាសុ កិច្ចេសុ ច នំ ជហន្តិ
តស្មាហំ ឥត្ថីនំ ន វិស្សសាមិ ។

ជាព្រះរាជាលោភកាម ដ៏ក្រៃលែង បានប្រព្រឹត្តក្បត់ចំពោះបុរស អ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា ស្រីមិនប្រព្រឹត្តកន្លងស្វាមី នឹងបុរសដទៃនោះ ឯណាកើត ។

(៣០៩) នាងបិង្គិយានី ជាភរិយា ជាទីស្រឡាញ់នៃព្រះបាទព្រហ្មទត្ត ព្រះអគ្គជាធំ ក្នុងលោកទាំងមូល បានប្រព្រឹត្តក្បត់ចំពោះបុរស អ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា នាងបិយង្គិយានី ជាអ្នកលោភ ក្នុងកាមនោះ មិនបាននូវបុរសគង្វាលសេះនោះផង (នូវទីអគ្គមហេសីផង) ។

(៣១០) បុរសដែលមិនមែនខ្លោចបូល មិនគួរជឿពួកស្រីដែលអាក្រក់ មានចិត្តរហ័ស ជាស្រីមិនដឹងគុណ ដែលគេធ្វើដល់ខ្លួន ជាស្រីប្រទូស្ត (ប្តី) ទេ ។ ពួកស្រីទាំងនោះ មិនដឹងនូវឧបការៈដែលគេធ្វើហើយ (ដល់ខ្លួន) មិនដឹងនូវកិច្ចការដែលគួរធ្វើ មិនស្គាល់ម្តាយ មិនស្គាល់ឪពុក មិនស្គាល់បងប្អូន មិនមានអរិយធម៌ មានការប្រព្រឹត្តកន្លងធម្មតា តែងលុះអំណាចចិត្តរបស់ខ្លួន ។ ពួកស្រីតែងលះបង់ប្តីជាទីស្រឡាញ់ ជាទីពេញចិត្ត ជាអ្នកអនុគ្រោះស្មើដោយជីវិត ដែលគប់ប្រុសព្យអស់កាលដ៏យូរ ឬលះបង់នូវប្តី ក្នុងកិច្ចមានអន្តរាយ ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។

ជីនំ ហិ ចិត្តំ យថា វានរស្ស
កន្ធប្បកន្ធំ យថា រុក្ខឆាយា
ចលាចលំ ហទយំ ឥត្ថិយានំ
ចក្កស្ស នេមិ វិយ បរិវត្តតិ ។
យទា តា បស្សន្តិ សមេក្ខមានា
អាទេយ្យរូបំ បុរិសស្ស វិត្តំ
សណ្ហាហិ វាចាហិ នយន្តិមេនំ
កម្ពោជកា ជលជេនេវ អស្សំ ។
យទា ន បស្សន្តិ សមេក្ខមានា
អាទេយ្យរូបំ បុរិសស្ស វិត្តំ
សមន្តតោ នំ បរិវជ្ជយន្តិ
តិណ្ណោ នទីបារគតោវ កុល្លំ ។
សិលេសូបមា សិខិរិវ សព្វភក្ខា
តិក្ខមាយា នទីរិវ សីឃសោតា
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកុលំ បរញ្ច ។

ន តា ឯកស្ស ន ទ្វិន្នំ អាបណោវ បសារិតោ
យោ តា មយ្ហន្តិ មញ្ញេយ្យ វាតំ ជាលេន ពន្ធយេ ។

ព្រោះថាចិត្តរបស់ស្រីដូចគ្នានឹងចិត្តពានរ ហឫទ័យរបស់ពួកស្រីចុះឡើងញាប់ញ័រដូចជាម្លប់ឈើ តែងវិលទៅ ដូចកង់រទេះ ។ ពួកស្រីទាំងនោះ កាលក្រឡេកមើលឃើញទ្រព្យរបស់ប្រុស ដែលគួរកាន់យកក្នុងកាលណា ក៏កៀរគរប្រុសនោះ ដោយសំដីផ្អែមល្ហែមក្នុងកាលណោះ ដូចពួកជនអ្នកកម្ពោជៈ បញ្ឆោតចាប់សេះដោយសារាយ ។ ពួកស្រីកាលបើក្រឡេកមើល មិនឃើញទ្រព្យរបស់ប្រុសដែលគួរកាន់យកក្នុងកាលណា ក៏វៀរប្រុសនោះដោយជុំវិញ ក្នុងកាលណោះ ដូចគេឆ្លងទៅដល់ត្រើយស្ទឹង ហើយលះបង់នូវក្បូន ។ ពួកស្រីឧបមាដូចជ័រ (ជាទីជាប់ស្អិតនៃចិត្តបុរស) ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង មានមាយាដ៏រហ័ស ដូចស្ទឹងមានខ្សែទឹកដ៏រហ័ស ពួកស្រីទាំងនេះ តែងសេពគប់បុរស ទាំងជាទីស្រឡាញ់ទាំងមិនជាទីស្រឡាញ់ ដូចទូកតែងចូលប្រទះទាំងច្រាំងខាងអាយនឹងច្រាំងខាងនាយ ។ ពួកស្រីទាំងនោះ មិនមែនជារបស់ប្រុសម្នាក់ ឬពីរនាក់ទេ ដូចជារានផ្សារដែលបើកហើយ បុគ្គលណា សំគាល់នូវពួកស្រីទាំងនោះ ថាជារបស់អញ បុគ្គលនោះ ដូចគេយកសំណាញ់ ខ្ទប់ខ្យល់ ។

អសីតិនិបាតេ  ចតុត្ថំ  កុណាលជាតកំ

យថា នទី ច បន្ថោ ច  បានាគារំ សភា បបា
ឯវំ លោកិត្ថិយោ នាម  វេលា តាសំ ន វិជ្ជតិ ។
ឃតាសនសមា ឯតា  កណ្ហសប្បសិរូបមា
គាវោ ពហិ តិណស្សេវ  ឱមសន្តិ វរំ វរំ ។

ឃតាសនំ កុញ្ជរំ កណ្ហសប្បំ
មុទ្ធាភិសិត្តំ បមទា ច សព្វា
ឯតេ នរោ និច្ចយតោ ភជេថ
តេសំ ហវេ ទុព្ពិទុ សព្វភាវោ ។
នាច្ចន្តវណ្ណា ន ពហូន កន្តា
ន ទក្ខិណា បមទា សេវិតព្វា
ន បរស្ស ភរិយា ន ធនស្ស ហេតុ
ឯតិត្ថិយោ បញ្ច ន សេវិតព្វា ។

[៣៨១] អថ ខលុ ភោ អានន្ទោ គិជ្ឈរាជា កុណាលស្ស សកុណស្ស អាទិមជ្ឈកថាបរិយោសានំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

ស្ទឹង ផ្លូវ រោងសុរា រោងជាទីប្រជុំ និងអណ្តូងទឹក យ៉ាងណា ធម្មតាពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា (នៃសេចក្តីស្រើបក្នុងកាម) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរទេ ។ ពួកស្រីទាំងនេះ ស្មើដោយអណ្តាតភ្លើង មានឧបមាដូចក្បាលពស់វែក ដូចពួកគោស៊ីនូវស្មៅដ៏ល្អ ៗ ខាងក្រៅ ៗ នរៈគប្បីគប់រកដោយការប្រយ័ត្ននូវវត្ថុទាំងនេះ គឺភ្លើង១ ដំរី១ ពស់វែក១ ព្រះរាជាដែលគេអភិសេកហើយ១ ពួកស្រីទាំងអស់១ ព្រោះភាពទៀងទាត់នៃវត្ថុទាំងនោះដឹងបានដោយក្រណាស់ ៗ ពួកស្រីមានពណ៌សម្បុរដ៏ល្អលើសលុបពេក បុគ្គលមិនត្រូវសេពគប់ ១ ស្រីជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនច្រើន បុគ្គលមិនត្រូវសេពគប់១ ស្រីឆ្មៀវឆ្លាសក្នុងការរាំនឹងច្រៀង បុគ្គលមិនត្រូវសេពគប់ ១ ប្រពន្ធអ្នកដទៃ បុគ្គលមិនត្រូវសេពគប់ ១ ស្រី (សេពគប់) ព្រោះហេតុនៃទ្រព្យ បុគ្គលក៏មិនត្រូវសេពគប់ ១ ស្រី ៥ ពួកនេះ បុគ្គលមិនត្រូវសេពគប់ទេ ៗ

[៣១១] ដំណាលថា គ្រានោះ ស្តេចត្មាតឈ្មោះអានន្ទ បានដឹងនូវគាថាជាខាងដើម កណ្តាល និងខាងចុង របស់កុណាលសកុណៈ ហើយបានពោលគាថានេះ ក្នុងវេលានោះថា

បុណ្ណម្បិ ចេមំ បឋវឹ ធនេន
ទជ្ជិត្ថិយា បុរិសោ សម្មតាយ
លទ្ធា ខណំ អតិមញ្ញេយ្យ តំបិ
តាសំ វសំ អសតីនំ ន គច្ឆេ ។
ឧដ្ឋាហកញ្ចេវ អលីនវុត្តឹ
កោមារភត្តារំ បិយំ មនាបំ
អាបាសុ កិច្ចេសុ ច នំ ជហន្តិ
តស្មាហំ ឥត្ថីនំ ន វិស្សសាមិ ។
ន វិស្សសេ ឥច្ឆតិ មន្តិ បោសោ
ន វិស្សសេ រោទតិ មេ សកាសេ
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកុលំ បរញ្ច ។
ន វិស្សសេ សាខបុរាណសន្ថតំ
ន វិស្សសេ មិត្តបោរាណចោរំ
ន វិស្សសេ រាជ សខា មមន្តិ
ន វិស្សសេ ឥត្ថិ ទសន្ន មាតរំ ។
ន វិស្សសេ រាមករាសុ តាសុ
អច្ចន្តសីលាសុ អសញ្ញតាសុ

បុរសនោះបើឲ្យនូវផែនដី ដែលពេញដោយទ្រព្យ ដល់ស្ត្រីដែលសន្មតហើយ ស្រីនោះលុះបានឱកាស រមែងមើលងាយបុរសនោះវិញ (ព្រោះហេតុនោះ) បុរសមិនត្រូវលុះអំណាចនៃស្រីទាំងនោះឡើយ ។ ពួកស្រីរមែងលះបង់នូវប្តីក្មេង ដែលជាអ្នកមានព្យាយាមក្រោកឡើងមានការប្រព្រឹត្តមិនរួញរា គួរជាទីស្រឡាញ់ពេញចិត្តផងលះបង់នូវប្តីនោះ ព្រោះកិច្ចដែលមានអន្តរាយផង ព្រោះហេតុនោះខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។ បុរសមិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះបង់បានអញ មិនត្រូវទុកចិត្តស្រីដោយគិតថាស្រីនោះ យំរំដែចំពោះអញ (ដូច្នេះទេ) ព្រោះថា ស្រីទាំងនោះរមែងគប់រកនូវបុរស ទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ដូចទូកជួបប្រទះ ទាំងត្រាំងខាងអាយនិងត្រាំងខាងនាយ ។ បុគ្គលមិនត្រូវទុកចិត្តមែកឈើចាស់ ដែលគេក្រាលទុកទេ មិនត្រូវទុកចិត្តចោរដើមចាស់ជាមិត្តទេ មិនត្រូវទុកចិត្តថា ព្រះរាជា ជាសំឡាញ់របស់អញដូច្នេះទេ មិនត្រូវទុកចិត្តស្រីជាមាតារបស់បុត្ត ១០ នាក់ (យាយចាស់) ទេ ។ បុគ្គលមិនត្រូវទុកចិត្ត ចំពោះពួកនារីអ្នកធ្វើនូវសេចក្តីត្រេកអរ អ្នកកន្លងសីលធម៌ មិនសង្រួមទេ

## អសីតិនិបាតេ ចតុត្ថំ កុណាលជាតកំ

អច្ចន្តបេមានុគតស្ស ភរិយា
ន វិស្សសេ តិត្ថសមា ហិ នារិយោ ។
ហនេយ្យុំបិ ឆិន្ទេយ្យុំបិ ឆេទាបេយ្យុំបិ
កណ្ឋេបិ ឆេត្វា រុធិរំ បិវេយ្យុំ
មា ធីនកាមាសុ អសញ្ញតាសុ
ភាវង្ករេ គង្គតិត្ថូបមាសុ ។

មុសា តាសំ យថា សច្ចំ សច្ចំ តាសំ យថា មុសា
គាវោ ពហិ តិណស្សេវ ឱមសន្តិ វរំ វរំ ។
គតេន តា បលោភេន្តិ បេក្ខិតេន ហសិតេន ច
អថោបិ ទុន្និវត្ថេន មញ្ជុនា ភណិតេន ច ។
ចោរិយោ កឋិនា ហេតា វាឡា ច លបសក្ខរា
ន តា កិញ្ចិ ន ជានន្តិ យំ មនុស្សេសុ វញ្ចនំ ។
អសា លោកិត្ថិយោ នាម វេលា តាសំ ន វិជ្ជតិ
សារត្តា ច បគព្ភា ច សិខី សព្វឃសោ យថា ។

មិនត្រូវទុកចិត្តភរិយា ដែលមានសេចក្តីស្រឡាញ់ក្រៃពេក ព្រោះជា នារីទាំងឡាយទុកស្មើកំពង់ទឹក ៗ ពួកស្រី រមែងសម្លាប់ (ប្រុស) ខ្លះ កាត់ (កប្រុស) ខ្លួនឯងខ្លះ ប្រើគេឲ្យកាត់ខ្លះ កាត់កហើយ ផឹកឈាមខ្លះ បុគ្គលកុំធ្វើសេចក្តីស្នេហាចំពោះពួកស្រី ដែលមាន សេចក្តីប្រាថ្នាថោកទាប ជាអ្នកមិនសង្រួម មានចិត្តដូចកំពង់ទឹក ៗ ពាក្យកុហក របស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យ ពិត របស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក (ពួកស្រី) ដូចគោ ស៊ីប្លិចតែស្មៅល្អ ៗ ខាងក្រៅ ៗ ពួកស្រីទាំងនោះ តែងប្រឡោម (ប្រុស) ដោយដំណើរផង ដោយអាការដែល ក្រឡេកមើលផង ដោយសំណើចផង ឬដោយសំពត់ដែលស្លៀក អាក្រក់ផង ដោយពាក្យពីរោះផង ៗ ពិតណាស់ ស្រីទាំងនេះដូច ចោរ មានចិត្តរឹងត្អឹង ខូចកាច តែមានសំដីផ្អែមដូចស្ករ ការ បញ្ឆោតណាក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការ បញ្ឆោតណាមួយ (នោះ) ទេ ៗ ធម្មតា ពួកស្រីក្នុងលោក (ច្រើនតែ) លាមក វេលារបស់ពួកស្រីទាំងនោះ មិនមានទេ ពួកស្រីជាអ្នក ស្រើបស្រាលផង ឃ្លើសឃ្លងផង ដូចភ្លើងស៊ីវត្ថុគ្រប់យ៉ាង ៗ

នត្ថិត្ថីនំ បិយោ នាម អប្បិយោបិ ន វិជ្ជតិ
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកុលំ បរញ្ច ៗ
នត្ថិត្ថីនំ បិយោ នាម អប្បិយោបិ ន វិជ្ជតិ
ធនត្ថា បដិវល្លន្តិ លតាវ ទុមនិស្សិតា ៗ
ហត្ថិពន្ធំ អស្សពន្ធំ គោបុរិសញ្ច ចណ្ឌាលំ
ឆវដាហកំ បុប្ផឆឌ្ឌកំ សធនំ អនុបតន្តិ នារិយោ ៗ
កុលបុត្តំបិ ជហន្តិ អកិញ្ចនំ ឆវកសមំ
សទិសំ អនុបតន្តិ ធនហេតុ ច នារិយោតិ ៗ

(៣១២) អថ ខលុ ភោ នារទោ ទេវព្រាហ្មណោ អានន្ទស្ស គិជ្ឈរាជស្ស អាទិមជ្ឈកថាបរិយោសានំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

ចត្តារោមេ ន បូរេន្តិ តេ មេ សុណាថ ភាសតោ
សមុទ្ទោ ព្រាហ្មណោ រាជា ឥត្ថី ចាបិ ទិជម្បតិ ៗ
សរិតា សាគរំ យន្តិ យា កាចិ បថវិស្សិតា
តា សមុទ្ទំ ន បូរេន្តិ ឩនត្តា ហិ ន បូរតិ ៗ

ប្រុសឈ្មោះថាជាទីស្រឡាញ់ របស់ពួកស្រី មិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ព្រោះថាពួកស្រីទាំងនេះ តែងគប់រកបុរសជាទីស្រឡាញ់ទាំងមិនស្រឡាញ់ ដូចទូក តែងចូលប្រទះទាំងត្រាំងខាងអាយនិងត្រាំងខាងនាយ ។ ប្រុសឈ្មោះថាជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ពួកស្រីតែងរួបព័ន្ធ (ប្រុស) ដើម្បីទ្រព្យសម្បត្តិ ដូចវល្លិ៍តោងដើមឈើ ។ ស្រីទាំងឡាយ តែងរត់តាមប្រុសឃ្វាលដំរី ឃ្វាលសេះ ឃ្វាលគោ ប្រុសចណ្ឌាល អ្នកដុតខ្មោច និងអ្នកចោលសម្រាម ដែលមានទ្រព្យ ។ ស្រីទាំងឡាយតែងលះបង់នូវកូនអ្នកមានត្រកូល ដែលមិនមានទ្រព្យតិចតួច ទុកស្មើសាកសព នារីទាំងឡាយ (ច្រើនតែ) គប់រកប្រុស ព្រោះហេតុតែទ្រព្យ ។

[៣១២] សេចក្តីដំណាលថា គ្រានោះ ទេវព្រាហ្មណ៍ ឈ្មោះនារទៈ បានដឹងនូវគាថាជាខាងដើម កណ្តាល និងទីបំផុត របស់ស្តេចត្មាតឈ្មោះអានន្ទហើយ ក៏ពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

បពិត្រលោកជាម្ចាស់នៃបក្សី សូមលោកស្តាប់ពាក្យ ដែលខ្ញុំនឹងនិយាយដូចតទៅនេះ ជន ៤ ពួកនេះគឺ សមុទ្រ ១ ព្រាហ្មណ៍ ១ ព្រះរាជា ១ ស្រី ១ រមែងមិនពេញ ។ ស្ទឹងណាមួយដែលអាស្រ័យនូវប្រឹថពីដែលហូរទៅកាន់សាគរ ស្ទឹងទាំងនោះ ក៏ញុំាងសមុទ្រឲ្យពេញមិនបាន ព្រោះថា សមុទ្ររមែងមិនពេញ ចេះតែនៅខ្វះខាត ។

## អសីតិនិបាតេ បឋមំ កុណាលជាតកំ

ព្រាហ្មណោ ច អធិយាន វេទមក្ខានបញ្ចមំ
ភិយ្យោបិ សុតមិច្ឆេយ្យ ឥច្ឆា ហិ ន បូរតិ ។
រាជា ច បថវី សព្វំ សសមុទ្ទំ សបព្វតំ
អជ្ឈាវសំ វិជិនិត្វា អនន្តរតនោចិតំ
បារំ សមុទ្ទំ បត្ថេតិ ឥច្ឆា ហិ ន បូរតិ ។
យញ្ចេកាយ ឥត្ថិយា អដ្ឋ បតយោ សិយុំ
សូរា ច ពលវន្តោ ច សព្វកាមរសាហរា
ករេយ្យ នវមេ ឆន្ទំ ឥច្ឆា ហិ ន បូរតិ ។

សព្វិត្ថិយោ សិខីរិវ សព្វភក្ខា
សព្វិត្ថិយោ នទីរិវ សព្វវាហី
សព្វិត្ថិយោ កណ្ដកានំវ សាខា
សព្វិត្ថិយោ ធនហេតុ វជន្តិ ។
វាតញ្ច ជាលេន នរោ បរាមសេ
ឱសិញ្ចយេ សាគរមេកបាណិនា
សកេន ហត្ថេន ករេយ្យ ឃោសំ
យោ សព្វភាវំ បមទាសុ ឱស្សជេ ។

ចោរីនំ ពហុពុទ្ធីនំ យាសុ សច្ចំ សុទុល្លភំ

ព្រាហ្មណ៍រៀននូវវេទមានគម្ពីរឈ្មោះឥតិហាសៈ ជាគំរប់ ៤ ហើយ តែងប្រាថ្នានូវការចេះដឹងឲ្យក្រៃលែង ព្រោះថា ព្រាហ្មណ៍នោះ រមែងមិនពេញ ចេះតែខ្វះខាត ៗ ចំណែកព្រះរាជាឈ្នះគ្រប់គ្រង ផែនដីទាំងអស់ ព្រមទាំងសមុទ្រនឹងភ្នំហើយ តែងប្រាថ្នារកច្រាំង សមុទ្រ នឹងផ្ទៃសមុទ្រ ដែលសម្បូរដោយរតនៈ មិនមានទីបំផុត ព្រោះថាព្រះរាជានោះ រមែងមិនគ្រប់គ្រាន់ ចេះតែខ្វះខាត ៗ ស្រី ម្នាក់ ៗ មានប្តីប្រាំបី ៗ ហើយប្តីនោះ ជាអ្នកក្លៀវក្លាផង មានកម្លាំង ផង នាំមកនូវរសនៃសេចក្តីប្រាថ្នាគ្រប់យ៉ាង ក៏គង់ធ្វើនូវសេចក្តី ប្រាថ្នាក្នុងប្តីទី ៩ ទៀត ព្រោះថា ស្រីនោះ រមែងមិនគ្រប់គ្រាន់ ចេះតែខ្វះខាត ៗ ពួកស្រីទាំងអស់ ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចស្ទឹងនាំទៅនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចមែកឈើមានបន្លា ពួកស្រីទាំងអស់ គប់រក (ប្តី) ព្រោះ ហេតុតែទ្រព្យ ៗ នរជនណា ផ្តុកផ្តាក់នូវភាព គឺការជោរ ទាំងពួងលើពួកស្រី នរជននោះ ទុកដូចគេយកបណ្តាញចាប់ ខ្យល់ ឬដូចគេបាចទឹកសមុទ្រ ដោយដៃម្ខាង ពុំនោះដូច គេយកដៃមួយ ទះឲ្យឮសូរគឹកកង ៗ ពួកស្រីដែលដូចជាចោរ មានពុតត្បុតច្រើន មានពាក្យសច្ចៈ គេរកបានដោយកម្រណាស់

ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ ។
អនលា មុទុសម្ភាសា ទុប្បូរា តា នទីសមា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។
អាវដ្ដនី មហាមាយា ព្រហ្មចរិយវិកោបនា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។
យេ ឯតា ឧបសេវន្តិ ឆន្ទសា វា ធនេន វា
ជាតវេទោវ សណ្ឋានំ ខិប្បំ អនុទហន្តិ នំ ។

(៣១៣) អថ ខលុ ភោ កុណាលោ សកុណោ នារទស្ស ទេវព្រាហ្មណស្ស អាទិមជ្ឈគាថាបរិយោសានំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

សល្លបេ និសិតខគ្គបាណិនា
បណ្ឌិតោ អបិ បិសាចទោសិនា
ឧគ្គតេជំ ឧរគំបិ អាសិទេ
ឯកោ ឯកាយ បមុទាយ នាលបេ ។
លោកចិត្តមថនា ហិ នារិយោ

ភាពនៃស្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។ ពួកស្រីទាំងនោះ មានមារយាទបិញរបុញ មានសំដីទន់ទុកស្មើដោយស្ទឹង បំពេញបានដោយក្រ តែងលិចចុះ(ក្នុងអបាយព្រោះហេតុតែកាម ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីវៀរឲ្យឆ្ងាយចេញ ។ ពួកស្រីជាអ្នកញុំាងចិត្តប្រុសឲ្យត្រឡប់ត្រឡិនមានមាយាច្រើន ញុំាងព្រហ្មចរិយធម៌ ឲ្យកម្រើក តែងលិចចុះ( ក្នុងអបាយ ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីចៀសឲ្យឆ្ងាយចេញ ។ ពួកស្រីទាំងនោះ ចូលទៅគប់រកប្រុសណាដោយសេចក្ដីប្រាថ្នា ឬដោយទ្រព្យសម្បត្តិ រមែងដុតកំដៅប្រុសនោះដោយឆាប់រហ័ស ដូចភ្លើងឆេះនូវទីរបស់ខ្លួន ។

[៣១៣] សេចក្ដីដំណាលថា គ្រានោះ កុណាលសកុណៈ ដឹងនូវគាថាជាខាងដើម កណ្ដាល និងទីបំផុត នៃទេវព្រាហ្មណ៍ឈ្មោះនារទៈហើយក៏ពោលគាថានេះ ក្នុងវេលានោះថា

បណ្ឌិត គួរចរចា ( ជាមួយ ) នឹងបុគ្គលមានដៃកាន់ដាវ
សម្លៀងហើយ ( ជាមួយ ) នឹងបុគ្គលប្រទូស្តដូចជាបិសាច
ឬក៏ចូលទៅរកពស់ ដែលមានពិសដ៏ពន្លឹក ( ប្រសើរជាង )
ប្រុសម្នាក់ឯង មិនគួរនិយាយចរចា ចំពោះស្រីម្នាក់ឯងទេ ។
ព្រោះថា នារីទាំងឡាយ ជាអ្នកញុំាញីនូវចិត្តនៃមនុស្សលោក

## អសីតិនិបាត បត្តុំ កុណាលជាតកំ

នច្ចគីតភណិតម្ហិតាវរា
ពាធយន្តិ អនុបដ្ឋិតស្សតិំ
ទីបេ រក្ខសិគណាវ វាណិជេ ៗ
នត្ថិ តាសំ វិនយោ ន សំវរោ
មជ្ជមំសនិរតា អសញ្ញតា
តា គិលន្តិ បុរិសស្ស បាភតំ
សាគរេវ មករំ តិមិង្គលោ ៗ
បញ្ចកាមគុណសាតគោចរា
ឧទ្ធតា អនិយតា អសញ្ញតា
ឱសរន្តិ បមុទា បមាទិនំ
លោណំ លោណតោយវតិយំវ អាបគា ៗ
យំ នរំ ឧបលាបេន្តិ នារិយោ
ឆន្ទសា វា រតិយា វា ធនេន វា
ជាតវេទសទិសំបិ តាទិសំ
រាគទោសវធិយោ ទហន្តិ នំ ៗ
អឌ្ឍំ ញត្វា បុរិសំ មហទ្ធនំ
ឱសរន្តិ សធនំ សហត្តនា

ជាអ្នកមានការពា ប្រៀន និយាយ សើច ញញឹម ជាអាវុធ តែង បៀតបៀននូវប្រុសដែលមិនបានតម្កល់ស្មារតី ដូចពួកស្រីអារក្សទឹក ក្នុងកោះបៀតបៀនពួកពាណិជ ។ ពួកស្រីទាំងនោះមិនមានវិន័យ មិនមានសំវរៈ ពួកស្រីទាំងនោះ ជាអ្នកល្មោភទឹកស្រវឹង និងសាច់ ជាអ្នកមិនសង្រួម តែងលេបទ្រព្យសម្បត្តិរបស់បុរស ដូចត្រីធំឈ្មោះតិមិង្គល លេបនូវមករក្នុងសាគរ ។ ពួកស្រីមានសេចក្ដីត្រេកអរក្នុងបញ្ចកាម-គុណជាអារម្មណ៍ មានអាការឆ្មើងឆ្មៃ មិនទៀង មិនសង្រួម ឃុំរកតែបុរសអ្នកប្រមាទ ដូចទឹកស្ទឹង តែងហូរចុះទៅរកទីមានទឹកប្រៃ (សមុទ្រ) ។ នារីទាំងឡាយ រមែងនិយាយស្រស់ស្រាយរកជនណា ដោយសេចក្ដីស្រឡាញ់ ឬដោយតម្រេក ឬក៏ដោយទ្រព្យ ជាស្រីសម្លាប់ប្រុសដោយរាគៈនឹងទោសៈ រមែងដុតពេលនរជននោះសូម្បីប្រុសរុងរឿងដូចភ្លើងជាអ្នកទីងទួន ។ ពួកស្រីដឹងថាបុរសអ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន រមែងក្រវែលរកប្រុសដែលមានទ្រព្យ ដោយខ្លួនឯង

រត្តចិត្តំ អតិវេឋយន្តិ នំ

សាលំ មាលុវលតាវ កាននេ ។

តា ឧបេន្តិ វិវិធេន ឆន្ទសា

ចិត្រពិម្ពមុខិយោ អលង្កតា

ឱហសន្តិ បហសន្តិ នារិយោ

សំពរោវ សតមាយកោវិទា ។

ជាតរូបមណិមុត្តភូសិតា

សក្កតា បតិកុលេសុ នារិយោ

រក្ខិតា អតិចរន្តិ សាមិកំ

ទានវំវ ហទយន្តរនិស្សិតា ។

តេជវាបិ ហិ នរោ វិចក្ខណោ

សក្កតោ ពហុជនស្ស បូជិតោ

នារីនំ វសង្គតោ ន ភាសតិ

រាហុនា ឧបហតោវ ចន្ទិមា ។

យំ ករេយ្យ កុបិតោ ទិសោ ទិសំ

ទុដ្ឋចិត្តោវ សមាគតំ អរី

រូបបុរសដែលមានចិត្តត្រេកអរ ដូចព្ធជ្រៃក្នុងព្រៃរួបព័ន្ធដើមរាំង ៗ នារីទាំងឡាយនោះ មានខ្លួនទន់មុខដ៏វិចិត្រតាក់តែងហើយ ផ្គាប់ផ្គុន (បុរស) ដោយសេចក្តីប្រាថ្នាផ្សេង ៗ ជាអ្នកយល់កលមាយាទាំងរយ រមែងសើច រមែងញញឹម តែហាក់ដូចជាសង្រ្លឹម ៗ នារីទាំងឡាយ ស្អិតស្អាងខ្លួនដោយមាស កែវមណី នឹងកែវមុក្តា ដែលគេធ្វើសក្ការៈ ក្នុងត្រកូលរបស់ប្តី ដែលគេរក្សាហើយ ក៏នៅតែប្រព្រឹត្តក្បត់ស្វាមីបាន ដូចជាប្រពន្ធដែលអាស្រ័យនៅក្នុងបន្ទោះហឫទ័យ ប្រព្រឹត្តក្បត់អសុរិញបាន ៗ នរជន សូម្បីមានតេជះ មានប្រាជ្ញាវាងវៃ ដែលអ្នកផងច្រើនគ្នាធ្វើសក្ការបូជា លុះក្នុងអំណាចនៃស្រីទាំងឡាយហើយ រមែងមិនរុងរឿង ដូចព្រះចន្ទ្រដែលត្រូវរាហូចាប់ ៗ ចោរអ្នកក្រោធមានចិត្តអាក្រក់ (ឃើញ) ចោរជាសត្រូវ (នឹងខ្លួន) មកប្រទះគ្នាហើយ ធ្វើនូវសេចក្តីវិនាសណា

អសីតិនិបាតេ ចតុត្ថំ កុណាលជាតកំ

តេន ហិយ្យោ ព្យសនំ និគច្ឆតិ
នារីនំ វសង្គតោ អបេក្ខវា ។
កេសលូននខឆិន្នតជ្ជិតា
បាទបាណិកសទណ្ឌតាឡិតា
ហីនមេវុបគតា ហិ នារិយោ
តា រមន្តិ កុណបេវ មក្ខិកា ។
តា កុលេសុ វិសិខន្តរេសុ វា
រាជធានីសុ និគមេសុ វា បន
ឱឌ្ឌិតំ នមុចិបាសវាគុរំ
ចក្ខុមា បរិវជ្ជេយ្យ សុខត្ថិកោ ។
ឱស្សជិត្វា កុសលំ តបោគុណំ
យោ អនរិយចរិតានិ មា ចរិ
ទេវតាហិ និរយំ និមិស្សតិ
ឆេទគាមិមណិយំវ វណិជោ ។
សោ ឥធ គរហិតោ បរត្ថ ច
ទុម្មតី ឧបហតោ សកម្មុនា
គច្ឆតិ អនិយតោ គឡាគឡំ

បុគ្គលអ្នកមានតណ្ហា លុះក្នុងអំណាច នៃស្រីទាំងឡាយ រមែងដល់នូវសេចក្ដីវិនាសក្រៃលែង ជាងសេចក្ដីវិនាសនោះទៅទៀត ៗ នារីទាំងឡាយ ដែលមានសក់របោច មានស្នាមដាច់ដោយក្រចក ដែលត្រូវ គេវាយ គេដាក់ ដោយជើង ដៃ នឹងដំបង ក៏នៅតែចូលទៅកាន់អាការថោកទាបវិញ នៅតែត្រេកអរ (ក្នុងកាមទៀត) ដូចរុយត្រេកអរនឹងសាកសព ៗ បុរសអ្នកមានបញ្ញាចក្ខុ ត្រូវការដោយសេចក្ដីសុខ គប្បីវៀរស្រីទាំងឡាយនោះ ( ដែលនៅ ) ក្នុងត្រកូលទាំងឡាយក្ដី ក្នុងចន្លោះប្រកក្ដី ក្នុងរាជធានីក្ដី ក្នុងនិគមក្ដី ឬក៏វៀរនូវអារម្មណ៍ដូចជាអន្ទាក់នឹងបង្កាត់របស់មារ ដែលកិលេស-មារដាក់ហើយក្ដី ៗ បុគ្គលណា លះបង់នូវតបោគុណ ( គុណគឺសេចក្ដីព្យាយាម ) ជាកុសលហើយ ប្រព្រឹត្តនូវចរិតមិនប្រសើរ បុគ្គលនោះ ( លុះច្យុត ) ចាកទេវតាហើយ នឹងមកកាន់នរកវិញ ដូចពាណិជ ( មានទ្រព្យច្រើនដូរយក ) ក្អមកំបែក ៗ ប្រុស (ដែលលុះក្នុងអំណាចស្រី) នោះ ត្រូវគេតិះដៀលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ជាមនុស្សមានគំនិតអាក្រក់ ត្រូវកម្មរបស់ខ្លួនបៀតបៀន ជាបុគ្គលមិនទៀង តែងធ្លាក់ទៅកាន់អបាយភូមិ

ទុដ្ឋគព្ភករោចាវ ឱប្បជេ ។

សោ ឧបេតិ និរយំ បតាបនំ

សត្តិសិម្ពលិវនញ្ច អាយសំ

អាវសិត្វាន តិរច្ឆានយោនិយំ

បេតរាជវិសយំ ន មុញ្ចតិ ។

ទិព្យ ខិឌ្ឌា រតិយោ ច នន្ទនេ

ចក្កវត្តិចរិតញ្ច មានុសេ

នាសយន្តិ បមុទា បមាទិនំ

ទុគ្គតិញ្ច បដិបាទយន្តិ នំ ។

ទិព្យ ខិឌ្ឌា រតិយោ ន ទុល្លភា

ចក្កវត្តិចរិតញ្ច មានុសេ

សោវណ្ណព្យម្ហនិលយា ច អច្ឆរា

យេ ចរន្តិ បមុទាហានត្ថិកា ។

កាមធាតុសមតិក្កមា គតិ

រូបធាតុសម្ភវោ ន ទុល្លភោ

វីតរាគវិសយូបបត្តិ យា

យេ ចរន្តិ បមុទាហានត្ថិកា ។

ដូចរថដែលទឹមលាកាច ដើរទៅក្នុងទីខុសផ្លូវ ។ ប្រុសនោះរមែងចូលទៅកាន់នរក ជាទីញុំាងសត្វឲ្យក្តៅ នៅអាស្រ័យនឹងព្រៃរកាមានបន្លាដូចលំពែងធ្វើអំពីដែកផង កំណើតតិរច្ឆានផង វិស័យនៃប្រេត នឹងអសុរកាយផង រមែងមិនអាចរួចបានទេ ។ ស្រីទាំងឡាយ រមែងញុំាងល្បែងជាទិព្វ ឬញុំាងតម្រេក ក្នុងទីជាទីរីករាយ ឬញុំាងសម្បត្តិចក្រពត្តិ ក្នុងទីជារបស់មនុស្សនៃបុគ្គលអ្នកប្រមាទ ឲ្យវិនាស ពួកស្រីរមែងញុំាងប្រុសនោះ ឲ្យដល់នូវទុគ្គតិ ។ ល្បែងជាតម្រេកទិព្វ សម្បត្តិស្តេចចក្រពត្តិ ក្នុងទីជារបស់មនុស្ស នឹងពួកស្រីអប្សរមានពិមានមាសជាលំនៅ ជាសម្បត្តិដែលបុគ្គលមិនត្រូវការដោយពួកស្ត្រី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) មិនមែនបានដោយក្រទេ ។ គតិជាទីកន្លងផុតចាកកាមធាតុ គឺការកើតក្នុងរូបធាតុ នឹងការកើតក្នុងសុទ្ធាវាស ជាវិស័យរបស់អ្នកប្រាសចាករាគៈ ជាសម្បត្តិដែលបុគ្គលមិនត្រូវការ ដោយពួកស្ត្រី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) មិនមែនបានដោយក្រទេ ។

សព្វទុក្ខសមតិក្កមំ សិវំ
អច្ចុតំ អចលិតំ អសង្ខតំ
និព្វុតេហិ សុចីហិ ន ទុល្លភំ
យេ ចរន្តិ បមុទាហានន្ទិកាតិ ។

(៣១៤) កុណាលោហំ តទា អាសឹ ឧទាយី បុស្សកោកិលោ
អានន្ទោ គិជ្ឈរាជាសិ សារីបុត្តោ ច នារទោ
បរិសា ពុទ្ធបរិសា ឯវំ ធារេថ ជាតកន្តិ ។

កុណាលជាតកំ ចតុត្ថំ ។

# មហាសុតសោមជាតកំ

(៣១៥) កស្មា តុវំ រសក ឯទិសានិ
ករោសិ កម្មានិ សុទារុណានិ
ហនាសិ ឥត្ថី បុរិសេ ច មុឡ្ហេ
មំសស្ស ហេតុ អាទុ ធនស្ស ការណា ។

កុណា ជាតិដ៏ក្សេមក្សាន្ត គឺព្រះនិព្វាន ជាទីកន្លងផុតចាកទុក្ខទាំងពួង ជាអច្ចន្តសុខ មិនកម្រើក មិនមានបច្ច័យតាក់តែង បុគ្គលមិនត្រូវការដោយស្រី ហើយប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) ជាអ្នកស្អាត មានកិលេសរលត់ មិនមែនបានដោយក្រទេ ។

(៣១៨) ( ព្រះសាស្ដា ទ្រង់ប្រជុំជាតកនេះថា ) ក្នុងកាលណោះ កុណាលបក្សី បានមកជាតថាគត បុស្សកោកិលបក្សី បានមកជាឧទាយិភិក្ខុ ស្ដេចត្មាត បានមកជាអានន្ទ នារទព្រាហ្មណ៍ បានមកជាសារីបុត្ត ពួកបរិស័ទបានមកជាពុទ្ធបរិស័ទ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះ ។

ចប់ កុណាលជាតក ទី ៤ ។

# មហាសុតសោមជាតក

(៣១៩) ( សេនាបតី សួរថា ) ម្នាលសេកៈ ( នាយពិសេស ) ព្រោះហេតុអ្វី អ្នកធ្វើនូវអំពើដ៏លាមកក្រៃលែង ប្រាកដដូច្នេះ អ្នកជាបុគ្គលវង្វេង សម្លាប់ពួកស្រីនិងប្រុស ព្រោះហេតុសាច់ ឬព្រោះហេតុទ្រព្យ ។

(៣១៦) ន អត្តហេតុ ន ធនស្ស ការណា
ន បុត្តទារស្ស សហាយញាតិនំ
ភត្តា ច មេ ភគវា ភូមិបាលោ
សោ ខាទតិ មំសំ ភទន្តេ ឯទិសំ ។

(៣១៧) សចេ តុវំ ភត្តុរត្ថេ បយុត្តោ
ករោសិ កម្មានិ សុទារុណានិ
បាតោវ អន្តេបុរំ បាបុណិត្វា
លបេយ្យាសិ មេ រាជិនោ សម្មុខេ តំ ។

(៣១៨) តថា ករិស្សាមិ អហំ ភទន្តេ
យថា តុវំ ភាសសិ កាឡហត្ថិ
បាតោវ អន្តេបុរំ បាបុណិត្វា
វក្ខាមិ តេ រាជិនោ សម្មុខេ តំ ។

(៣១៩) តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
កាឡោ រសកមាទាយ រាជានំ ឧបសង្កមិ
ឧបសង្កមិត្វា រាជានំ ឥទំ វចនមព្រវិ ។
សច្ចំ កិរ មហារាជ រសកោ បេសិតោ តយា
ហនតិ ឥត្ថិបុរិសេ តុវំ មំសានិ ខាទសិ ។

[៣១៦] (នាយពិសេស ជំរាបថា) ខ្ញុំសម្លាប់ មិនមែនព្រោះហេតុខ្លួនឯង មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុកូនប្រពន្ធ ឬសំឡាញ់និងញាតិទេ បពិត្រលោកដ៏ចំរើន ព្រោះថាព្រះភូមិបាលអ្នកមានបុណ្យ ជាម្ចាស់នៃខ្ញុំ ទ្រង់សោយនូវសាច់ប្រាកដដូច្នេះ ។

[៣១៧] (សេនាបតី...) បើអ្នកឯងខ្វល់ខ្វាយ ក្នុងកិច្ចរបស់ព្រះរាជាជាម្ចាស់ ហើយធ្វើនូវអំពើដ៏លាមកក្រៃលែង អ្នកឯង លុះព្រឹកឡើង ចូលទៅខាងក្នុងព្រះរាជវាំងហើយ គប្បីនិយាយនូវដំណើរនោះប្រាប់ខ្ញុំ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។

[៣១៨] (នាយពិសេស...) បពិត្រសេនាបតីឈ្មោះកាឡហត្ថីដ៏ចំរើន លោកនិយាយយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ព្រឹកឡើងខ្ញុំនឹងចូលទៅខាងក្នុងព្រះរាជវាំង ហើយថ្លែងសេចក្តីនោះ ជំរាបលោក ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។

[៣១៩] (អភិសម្ពុទ្ធគាថា) គ្រានោះ កាលដែលវេលារាត្រីភ្លឺច្បាស់ ព្រះអាទិត្យរះឡើងប្រាកដ សេនាបតីឈ្មោះកាឡហត្ថី បាននាំសេកៈចូលទៅគាល់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គប្រើសេកៈឲ្យទៅសម្លាប់ស្រីប្រុស ព្រះអង្គទ្រង់សោយសាច់មនុស្ស ។

## អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

[៣២០] ឯវមេវ តថា កាឡ រសកោ បេសិតោ មយា
មម អត្ថំ កាកេន្តស្ស កិមេតំ បរិភាសសិ ៗ

[៣២១] អានន្ទោ សព្វមច្ឆានំ ខាទិត្វា រសគិទ្ធិមា
បរិក្ខីណាយ បរិសាយ អត្តានំ ខាទិយា មតោ ៗ
ឯវំ បមត្តោ រសគារវេ រតោ
ពាលោ យទី អាយតិ នាវពុជ្ឈសិ(១)
វិធម្ម បុត្តេ ចជិ(២) ញាតកេ ច
បរិវត្តិយ អត្តានញ្ញេវ ខាទតិ ៗ
ឥទំ តេ សុត្វាន វិគេតុ ឆន្ទោ
មា ភក្ខយិ រាជ មនុស្សមំសំ
មា ត្វំ ឥមំ កេវលំ វារិជោវ
ទ្វិបទាធិប សុញ្ញមកាសិ រដ្ឋំ ៗ

[៣២២] សុជាតោ នាម នាមេន ឱរសោ តស្ស អត្រជោ
ជម្ពុបេសី អលទ្ធាន មតោ សោ តស្ស សង្ខយេ
ឯវមេវ អហំ កាឡ ភុត្វា ភក្ខំ រសុត្តមំ
អលទ្ធា មានុសំ មំសំ មញ្ញេ ហេស្សាមិ ជីវិតំ ៗ

---

១ ម. នាវពុជ្ឈតិ ។ ឱ. អាយតី នាវពុជ្ឈតិ ។ ២ ម. ចជិត្វា ។

(៣២០) ( ព្រះរាជា... ) ម្នាលកាឡហត្ថិ ខ្ញុំបានប្រើសកៈដូច្នោះមែន ហេតុអ្វីអ្នកជេរប្រទេចសកបុរស ដែលធ្វើប្រយោជន៍ឲ្យខ្ញុំនុះ ។

(៣២១) ( កាឡហត្ថិ... ) ត្រីឈ្មោះអានន្ទ ជាប់ចិត្តនឹងរស ស៊ីនូវពួកត្រីទាំងពួង កាលបើត្រីជាបរិវារអស់ហើយ ក៏ខាំស៊ីកន្ទុយខ្លួនឯងស្លាប់ទៅ ។ ព្រះអង្គជាអ្នកប្រមាទ ត្រេកអរក្នុងរសដែលគួរគោរព បើព្រះអង្គនៅជាបុគ្គលពាល មិនយល់ហេតុអ្វីតទៅយ៉ាងនេះទេ ព្រះអង្គនឹងឃាតបោះបង់នូវបុត្រទាំងឡាយផង នូវពួកញាតិផង ដូចត្រីឈ្មោះអានន្ទត្រឡប់ស៊ីខ្លួនឯង ។ បពិត្រព្រះរាជា សូមសេចក្ដីប្រាថ្នារបស់ព្រះអង្គប្រាសចេញទៅ ព្រោះបានទ្រង់ព្រះសណ្ដាប់នូវពាក្យនេះ សូមព្រះអង្គកុំសោយសាច់មនុស្ស បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ សូមព្រះអង្គកុំធ្វើដែននេះឲ្យសោះសូន្យ ដូចត្រីឈ្មោះអានន្ទ ធ្វើមហាសមុទ្រទាំងមូលនេះឲ្យសូន្យ ( ពាកត្រី ) ។

(៣២២) ( ព្រះរាជា .. ) កូនបង្កើតរបស់សុជាតកុដុម្ពីនោះ ឈ្មោះសុជាតដោយឈ្មោះ មិនបានសាច់ព្រីងហើយស្លាប់ទៅ ព្រោះអស់សាច់ព្រីងនោះ ( យ៉ាងណា ) ម្នាលកាឡហត្ថិ ខ្ញុំបរិភោគនូវអាហារមានរសជាឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជានឹងលះបង់នូវជីវិត ក៏យ៉ាងនោះដែរ ។

(៣២៣) មាណវ អភិរូបោសិ កុលេ ជាតោសិ សោត្ថិយេ
ន ត្វំ អរហសិ តាត អភក្ខំ ភក្ខយេតវេ ។

(៣២៤) រសានញ្ញតរំ ឯតំ កស្មា មំ ត្វំ និវារយេ
សោហំ តត្ថ គមិស្សាមិ យត្ថ លច្ឆាមិ ឯទិសំ ។
សោវាហំ និប្បតិស្សាមិ ន តេ វច្ឆាមិ សន្តិកេ
យស្ស មេ ទស្សនេន ត្វំ នាភិនន្ទសិ ព្រាហ្មណ ។

(៣២៥) អទ្ធា អញ្ញេបិ ទាយាទេ បុត្តេ លច្ឆាម មាណវ
ត្វញ្ច ជម្ម វិនស្សស្សុ យត្ថ បត្តំ ន តំ សុណេ ។

(៣២៦) ឯវមេវ តុវំ រាជ ទិបទិន្ទ[១] សុណោហិ មេ
បព្វាជិស្សន្តិ តំ រដ្ឋា សោណ្ឌំ មាណវកំ យថា ។

(៣២៧) សុជាតោ នាម នាមេន ភាវិតត្តាន សាវកោ
អច្ឆរំ កាមយន្តោវ ន សោ ភុញ្ជិ ន សោ បិវិ ។

---

១ ម. ទ្វិបទិន្ទ ។

(៣៤៣) (កាឡហត្ថីនាំពៀនព្រាហ្មណ៍ថា) ម្នាលមាណពកូន អ្នកមានរូបស្រស់បស់ កើតក្នុងត្រកូលសោត្ថិយៈ ម្នាលកូន អ្នកមិនគួរស៊ីនូវអាហារ ដែលមិនគួរស៊ីទេ ។

(៣៤៤) (មាណព...) បណ្តារសទាំងឡាយ ទឹកស្រានេះ រាប់ថាជាទឹកមានរសមួយដែរ ព្រោះហេតុអ្វី ទើបលោកឪពុកឃាត់ខ្ញុំ ខ្ញុំបាននូវទឹកស្រានេះក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ។ បពិត្រព្រាហ្មណ៍ឪពុក បើលោកឪពុកមិនត្រេកអរនឹងការឃើញខ្ញុំណា ខ្ញុំនោះនឹងគេចចេញ (អំពីស្រុក) ខ្ញុំមិននៅក្នុងសំណាក់លោកឪពុកទេ ។

(៣៤៥) (ព្រាហ្មណ៍...) នែមាណពកូន យើងនឹងបាននូវកូនទាំងឡាយឯទៀត ទទួលមត៌កដោយពិត នៃកូនជួជាតិ ឯងចូរវិនាសរបុះ លំនៅដែលកូនទៅដល់ក្នុងទីណា សូមកុំឲ្យអញឮនូវទីនោះ ។

(៣៤៦) (កាឡហត្ថី...) បពិត្រព្រះមហាក្សត្រិយ៍ ជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ ពួកប្រជាជន នឹងបណ្តេញព្រះអង្គចាកដែន ដូចមាណពអ្នកលេងស៊ីផឹកដូច្នោះ ។

(៣៤៧) (ព្រះរាជា...) សាវ័ក របស់ពួកឥសី អ្នកមានខ្លួនអប់រំហើយ ជាសាវ័កឈ្មោះសុជាតៈ ប្រាថ្នានូវស្រីអប្សរ ទើបសាវ័កនោះ មិនស៊ី មិនផឹកទេ ។

## អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

កុសគ្គេនុទកមាទាយ សមុទ្ទេ ឧទកំ មិនេ
ឯវំ មានុសិកា កាមា ទិព្វកាមាន សន្តិកេ ។
ឯវមេវ អហំ កាឡ ភុត្វា ភក្ខំ រសុត្តមំ
អលទ្ធា មានុសំ មំសំ មញ្ញេ ហេស្សាមិ ជីវិតំ ។
[៣២៨] យេ ចាបិ តេ ធតរដ្ឋា ហំសា វេហាយសង្គមា
អយុត្តបរិភោគេន សព្វេ អព្ភត្ថំ គតា ។
ឯវមេវ តុវំ រាជ ទិបទិន្ទ សុណោហិ មេ
អភក្ខំ រាជ ភក្ខេសិ តស្មា បព្វាជិស្សន្តិ (១) តំ ។
[៣២៩] តិដ្ឋាហីតិ មយា វុត្តោ សោ ត្វំ គច្ឆសិ បម្មុខោ
អដ្ឋិតោ ត្វំ ឋិតោម្ហីតិ លបសិ ព្រហ្មចារិនិ
ឥទំ តេ សមណាយុត្តំ អសិញ្ច មេ មញ្ញសិ កង្កបត្តំ

១ ម. បព្វាជិហន្តិ ។

បុគ្គលយកទឹកដោយចុងស្មៅមកប្រៀបផ្ទឹមនឹងទឹកក្នុងសមុទ្រ យ៉ាងណា កាមទាំងឡាយជារបស់មនុស្ស (ប្រៀបផ្ទឹម) ក្នុងសំណាក់នៃកាមជាទិព្វក៏យ៉ាងនោះដែរ ។ ម្នាលកាឡហត្ថិ ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជាលះបង់ជីវិត យ៉ាងនោះឯង ។

(៣២៨) (កាឡហត្ថិ...) ដូចយ៉ាងពួកបក្សីហង្សឈ្មោះធតរដ្ឋៈទាំងនោះ ជាសត្វហើរព្ធដ៏អាកាស ដល់នូវសេចក្ដីវិនាសទាំងអស់គ្នា ព្រោះស៊ីនូវចំណីមិនគួរ ។ បពិត្រព្រះរាជាជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ខ្ញុំ បពិត្រព្រះរាជា ព្រះអង្គកុំសោយអាហារ ដែលមិនគួរសោយ ក៏យ៉ាងនោះឯង ពួកប្រជាជននឹងបណ្ដេញព្រះអង្គ (ចាកដែន) ក៏យ៉ាងនោះដែរ ។

(៣២៩) (ព្រះរាជា...) អ្នកកាលដែលខ្ញុំនិយាយថា អ្នកឈប់សិន ហើយចេះតែដើរទៅមុខ ម្នាលអ្នកជាព្រហ្មចារិនី អ្នកមិនឈប់តែនិយាយថា ខ្ញុំឈប់ហើយ ពាក្យនេះមិនគួរដល់អ្នកជាសមណៈទេ អ្នកសំគាល់នូវដាវរបស់ខ្ញុំ គួរដល់សេចក្ដីសង្ស័យដែរឬ ។

(៣៣០) បិតោ ហមស្មិ សន្ធម្ហេសុ រាជ

ន ឆាមតោត្តុំ បរិវត្តយាមិ

ហោរញ្ញុ លោកេ អបិតំ វទន្តិ

អាចាយិតំ នេរយិតំ វតោ ចុតំ ។

សចេ ត្វំ សន្ធហសិ រាជ សុតំ គណ្ហាហិ ខត្តិយំ

តេន យញ្ញំ យជិត្វាន ឯវំ សគ្គំ គមិស្សសិ ។

(៣៣១) កិស្មិំ នុ រដ្ឋេ តវ ជាតិភូមិ

អថ កេន អត្ថេន ឥធានុបត្តោ

អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ

កិមិច្ឆសិ ទេមិ តយជ្ជ បត្ថិតំ ។

(៣៣២) គាថា ចតស្សោ ធរណីមហិស្សរ

សុគម្ភីរត្ថា វរសាគរូបមា

តវេវ អត្ថាយ ឥធាគតោស្មិ

សុណោហិ គាថា បរមត្ថសញ្ហិតា ។

[៣៣០] (ទេវតា...) បពិត្រព្រះរាជា អាត្មាជាអ្នកឈប់ ក្នុងព្រះសទ្ធម្មទាំងឡាយ មិនត្រឡប់ប្រែនាមនឹងគោត្រទេ អ្នកប្រាជ្ញទាំងឡាយ តែងពោលនូវចោរថាមិនឈប់ក្នុងលោក ដែលច្យុតអំពីលោកនេះទៅជាអ្នកទៅកាន់អបាយ កាន់នរក ។ បពិត្រព្រះរាជា បើព្រះអង្គជឿ ចូរព្រះអង្គចាប់សុតសោមជាក្សត្រិយ៍មកបូជាយញ្ញ ព្រះអង្គនឹងទៅកាន់ឋានសួគ៌ ដោយការបូជានោះ ។

[៣៣១] (ព្រះរាជាសុតសោម...) ជាតិភូមិរបស់អ្នក ក្នុងដែនណាមួយទៀត អ្នកមកដល់ក្នុងទីនេះ ដោយប្រយោជន៍ ដូចម្តេច ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ អ្នកប្រាថ្នារបស់អ្វី ខ្ញុំនឹងឲ្យនូវរបស់នោះ តាមដែលអ្នកប្រាថ្នា ក្នុងថ្ងៃនេះ ។

[៣៣២] (នន្ទព្រាហ្មណ៍...) បពិត្រព្រះអង្គជាមហិស្សរៈលើផែនដី គាថាទាំងឡាយ ៤ បទ មានអត្ថដ៏ជ្រៅ ប្រសើរក្រៃលែង ប្រៀបដូចជាសាគរ ខ្ញុំមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ព្រះអង្គតែម្យ៉ាង សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវគាថា ដែលប្រកបដោយប្រយោជន៍ដ៏ប្រសើរ ។

# អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

(៣៣៣) ន វេ រុទន្តិ មតិមន្តោ សបញ្ញា
ពហុស្សុតា យេ ពហុដ្ឋានចិន្តិនោ
ទីបំ ហិ ឯតំ បរមំ នរានំ
យំ បណ្ឌិតា សោកនុទា ភវន្តិ ។
អត្តាន ញាតី ឧទាហុ បុត្តទារំ
ធញ្ញំ ធនំ រជតំ ជាតរូបំ
កិមេវ ត្វំ សុតសោមានុតប្បេ
កោរព្យសេដ្ឋ វចនំ សុណោម តេ ។
(៣៣៤) ន ចាហមត្តានមនុត្ថុនាមិ(១)
ន បុត្តទារំ ន ធនំ ន រដ្ឋំ
សតញ្ច ធម្មោ ចរិតោ បុរាណោ
តំ សង្គរំ ព្រាហ្មណស្សានុតប្បេ ។
កតោ មយា សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាវជិស្សំ ។

---

១ ម. នោហមត្តា ន មនុត្ថុនាមិ ។

(៣៣៣) ( ព្រះបាទពោរិសាទ... ) បណ្ឌិតទាំងឡាយណា ជាអ្នកមានយោបល់ ប្រកបដោយបញ្ញា ជាពហុស្សូត្រ គិតនូវហេតុបានច្រើនយ៉ាង រមែងមិនយំទេ បណ្ឌិតទាំងឡាយនោះ ជាអ្នកបន្ទោបង់នូវសេចក្ដីសោក ដោយហេតុណាពិត ហេតុនុ៎ះជាទីពឹងដ៏ក្រៃលែង របស់ជនទាំងឡាយ ។ បពិត្រព្រះបាទសុតសោម ព្រះអង្គសោកស្ដាយចំពោះខ្លួន ញាតិ ឬកូនប្រពន្ធ ស្រូវ ទ្រព្យ ប្រាក់ មាស ឬអ្វី បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ យើងនឹងស្ដាប់ពាក្យរបស់លោក ។

(៣៣៤) ( ព្រះបាទសុតសោម... ) ខ្ញុំមិនសោកស្ដាយចំពោះខ្លួន មិនសោកស្ដាយចំពោះកូនប្រពន្ធ មិនសោកស្ដាយចំពោះទ្រព្យ មិនសោកស្ដាយចំពោះដែនទេ ( មាន ) បុរាណធម៌ ជាចរិតរបស់សប្បុរសទាំងឡាយ ខ្ញុំសោកស្ដាយនឹងការប្ដេជ្ញានោះ ចំពោះព្រាហ្មណ៍ ។ ការប្ដេជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរ-ភាពក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សាខ្ជាប់ នូវសច្ចៈ នឹងដោះនូវការប្ដេជ្ញានោះ របស់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញ ។

[៣៣៥] ន វាយមេតំ អភិសទ្ទហាមិ
សុខី នរោ មច្ចុមុខា បមុត្តោ
អមិត្តហត្ថំ បុនរាវជេយ្យ
កោរព្យ សេដ្ឋ ន ហិ មំ ឧបេសិ ។
មុត្តោ តុវំ បោរិសាទស្ស ហត្ថា
គន្ត្វា សកំ មន្ទិរំ កាមកាមី
មធុរំ បិយំ ជីវិតំ លទ្ធ រាជ
កុតោ តុវំ ឯហិសិ មេ សកាសំ ។

[៣៣៦] មតំ វរេយ្យ បរិសុទ្ធសីលោ
ន ជីវិតំ គរហិតោ បាបធម្មោ
ន ហិ តំ នរំ តាយតេ ទុគ្គតីហិ
យស្សាបិ ហេតុ អលិកំ ភណេយ្យ ។
សចេបិ វាតោ គិរិមាវហេយ្យ
ចន្ទោ ច សុរិយោ ច ឆមា បតេយ្យុំ
សព្វា ច នជ្ជោ បដិសោតំ វជេយ្យុំ
ន ត្វេវហំ រាជ មុសា ភណេយ្យំ ។

[៣៣៥] (ព្រះបាទបោរិសាទ...) ខ្ញុំមិនជឿនូវពាក្យនុ៎ះថា ជនមានសេចក្ដីសុខ បានរួចអំពីមាត់នៃមច្ចុហើយ ត្រឡប់មករកដៃនៃសត្រូវវិញដូច្នេះទេ បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ ទ្រង់នឹងមិនមករកខ្ញុំទេ ។ បពិត្រព្រះរាជា ទ្រង់បានរួចអំពីដៃនៃព្រះបាទបោរិសាទហើយ មានប្រាថ្នា ទៅកាន់មន្ទីររបស់ខ្លួនហើយបាននូវជីវិត ជាទីស្រឡាញ់ពេញចិត្ត កាលណាទ្រង់នឹងមកកាន់សំណាក់របស់ខ្ញុំវិញ ។

[៣៣៦] (ព្រះបាទសុតសោម...) បុគ្គលអ្នកមានសីលបរិសុទ្ធ រមែងប្រាថ្នានូវសេចក្ដីស្លាប់ ឯបុគ្គលអ្នកមានធម៌លាមក ដែលគួរអ្នកផងតិះដៀល មិនគួរចង់រស់ឡើយ បុគ្គលទ្រុស្ដសីលពោលនូវពាក្យមិនពិត ព្រោះហេតុខ្លួនណា ខ្លួននោះ រមែងមិនរក្សានូវជននោះចាកទុគ្គតិបានឡើយ ។ បើទុកជាខ្យល់បក់កើបភ្នំបានក្ដី ព្រះចន្ទ្រនឹងព្រះអាទិត្យ ធ្លាក់មកលើផែនដីក្ដី ទឹកស្ទឹងទាំងអស់ ហូរច្រាសខ្សែទឹកក្ដី បពិត្រព្រះរាជា ខ្ញុំក៏មិនពោលពាក្យកុហកទេ ។

[៣៣៧] នភំ ផលេយ្យ ឧទធិ បិសុស្សេ
សំវដ្ដេយ្យ ភូតធរា វសុន្ធរា
សិលុច្ចយោ មេរុ សមូលមុប្បតេយ្យ
ន ត្វេវហំ រាជ មុសា ភណេយ្យំ ។

[៣៣៨] អសិញ្ច សត្តិញ្ច បរាមសាមិ
សបថំបិ តេ សម្ម អហំ ករោមិ
តយា បមុត្តោ អនណោ ភវិត្វា
សច្ចានុរក្ខី បុនរាវជិស្សំ ។

[៣៣៩] យោ តេ កតោ សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាវជស្សុ ។

[៣៤០] យោ មេ កតោ សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាវជិស្សំ ។

[៣៤១] មុត្តោ ច សោ បោរិសាទស្ស ហត្ថា
គន្ត្វាន តំ ព្រាហ្មណំ ឯតទវោច

(៣៣៧) មេឃបែកធ្លាយ ទឹកសមុទ្ររីងស្ងួត ឬផែនដីជាទីទ្រទ្រង់ នូវសត្វប្រែត្រឡប់ ឬភ្នំឈ្មោះមេរុរលើងទាំងឫស ខ្ញុំក៏មិន ពោលពាក្យកុហកទេ ។

(៣៣៨) ខ្ញុំចាប់ដាវនឹងលំពែង បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំនឹងធ្វើ នូវសម្បថបំពោះទ្រង់ ខ្ញុំរួចចេញអំពីទ្រង់ ជាអ្នកមិនមាន បំណុល រក្សានូវសច្ចៈ នឹងត្រឡប់មកវិញ ។

(៣៣៩) (ព្រះបាទពោរិសាទ...) ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលព្រះអង្គឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើ ហើយ សូមព្រះអង្គជាអ្នករក្សានូវសច្ចៈ ដោះនូវការប្តេជ្ញានោះ នឹងព្រាហ្មណ៍ហើយ ចូរត្រឡប់មកវិញ ។

(៣៤០) (ព្រះបាទសុតសោម...) ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅ ក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បាន ធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ នឹងដោះនូវការប្តេជ្ញានោះ នឹងព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ ។

(៣៤១) (អភិសម្ពុទ្ធគាថា) ព្រះបាទសុតសោមនោះ រួចពីព្រះហស្ថនៃ ព្រះបាទពោរិសាទ ហើយទៅ បានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថា

សុណោមិ គាថាយោ សតារហាយោ
យា មេ សុតា អស្សុ ហិតាយ ព្រហ្មេ ។
(៣៤២) សកិទេវ សុតសោម សព្ភិ ហោតិ សមាគមោ
សា នំ សង្គតិ បាលេតិ នាសព្ភិ ពហុសង្គមោ ។
សព្ភិរេវ សមាសេថ សព្ភិ កុព្ពេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។
ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។
នភញ្ច ទូរេ បថវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មោ អសតញ្ច រាជ ។

ម្នាលព្រាហ្មណ៍ ខ្ញុំសូមស្តាប់នូវគាថាទាំងឡាយ ដែលគួរដល់ថ្លៃ ១០០ កហាបណៈ ជាគាថាដែលខ្ញុំស្តាប់ហើយមានប្រយោជន៍ ។

(៣៨២) (ព្រាហ្មណ៍... ) បពិត្រព្រះបាទសុតសោម ការជួបប្រទះដោយសប្បុរសទាំងឡាយ អស់វារៈតែម្តង ការជួបប្រទះនោះរមែងរក្សា នូវបុគ្គលនោះបាន ឯការជួបជុំដោយពួកអសប្បុរសជាច្រើនដង រមែងមិនរក្សានូវបុគ្គលនោះបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាល នឹងពួកសប្បុរស គុណធម៌ដ៏ប្រសើរ រមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកឡើយ ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រាទៅវិញ សូម្បីសរីរៈ (នៃពួកសត្វ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្តីគ្រាំគ្រាទេ ពួកសប្បុរស រមែងចរហាដោយពួកសប្បុរស ។ អាកាសនឹងដី ឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវច្រាំងសមុទ្រថាឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវធម៌ របស់ពួកសប្បុរស នឹងពួកអសប្បុរសថា ឆ្ងាយជាងនោះទៅទៀត ។

(៣៤៣) សាហស្សិយោ ឥមា គាថា នយិមា គាថា សតារហា
ចត្តារិ ត្វំ សហស្សានិ ខិប្បំ គណ្ហាហិ ព្រាហ្មណា ។

(៣៤៤) អាសីតិយា នាវុតិយា ច គាថា
សតារហា ចាបិ ភវេយ្យ គាថា
បច្ចត្តមេវ សុតសោម ជានាហិ
សាហស្សិយា នាម កា អត្ថិ គាថា ។

(៣៤៥) ឥច្ឆាមិ វោហំ សុតវុឌ្ឍិមត្តនោ
សន្តោ មំ សប្បុរិសា ភជេយ្យុំ
អហំ សវន្តីហិ មហោទធីវ
ន ហិ តាត តប្បាមិ សុភាសិតេន ។
អគ្គិ យថា តិណកដ្ឋំ ទហន្តោ
ន តប្បតិ សាគរោវ នទីហិ
ឯវំបិ តេ បណ្ឌិតា រាជសេដ្ឋ
សុត្វា ន តប្បន្តិ សុភាសិតេន ។

(៣៤៣) (ព្រះបាទសុតសោម...) គាថាទាំងនេះ គួរដល់ថ្លៃ ១ ពាន់កហាបណៈ គាថាទាំងនេះ មិនគួរដល់ថ្លៃត្រឹម ១០០ កហាបណៈទេ ម្នាលព្រាហ្មណ៍ លោកចូរទទួលយកកហាបណៈ ៤ ពាន់ ជាប្រញាប់ចុះ ។

(៣៤៤) (ព្រះវរបិតា...) គាថាមានថ្លៃ ៨០ កហាបណៈ ៩០ កហាបណៈ នឹងគាថាគួរដល់ថ្លៃ ១០០ កហាបណៈ ម្នាលសុតសោម អ្នកចូរដឹងដោយខ្លួនឯងចុះ គាថាដូចម្តេចដែលឈ្មោះថាគួរដល់ថ្លៃ ១ ពាន់កហាបណៈ ។

(៣៤៥) (ព្រះបាទសុតសោម...) ខ្ញុំព្រះអង្គប្រាថ្នានូវសេចក្តីចំរើនដោយសុតៈគឺការរៀនដឹង ដើម្បីខ្លួន សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់ គប្បីគប់រកនូវខ្ញុំព្រះអង្គ បពិត្រព្រះបិតា ខ្ញុំព្រះអង្គ មិនឆ្អែតដោយសុភាសិត ដូចជាមហាសមុទ្រមិនឆ្អែតដោយទឹកស្ទឹងដែលហូរចូលទៅ ។ ភ្លើងកាលឆេះស្មៅនឹងឈើ រមែងមិនឆ្អែត សាគររមែងមិនឆ្អែតដោយទឹកស្ទឹងយ៉ាងណា បពិត្រព្រះរាជាដ៏ប្រសើរ បណ្ឌិតទាំងឡាយនោះបានស្តាប់ហើយ ក៏មិនឆ្អែតដោយសុភាសិតក៏យ៉ាងនោះដែរ ។

សខស្ស នាសស្ស យថា សុណោមិ
កថំ អហំ អត្តវធី ជនិន្ទ
ឥមេវ សក្កច្ច និសាមយាមិ
ន ហិ តាត ធម្មេសុ មមត្ថិ តិត្តិ ។

(៣៤៦) ឥទន្តេ រដ្ឋំ សជនំ សយោគ្គំ
សកាយុរំ សព្វកាមូបបន្នំ
កឹ កាមហេតុ បរិភាសសេ មំ
គច្ឆាមហំ បោរិសាទស្ស ញត្តេ(១) ។

(៣៤៧) អត្តានុរក្ខាយ ភវន្តិ ហេតេ
ហត្ថារោហា រថិកា បត្តិកា ច
អស្សារោហា យេ ច ធនុគ្គហាសេ
សេនំ បយុញ្ជាម ហនាម សត្តុំ ។

(៣៤៨) សុទុក្ករំ បោរិសាទោ អកាសិ
ជីវំ គហេត្វាន អវស្សជី មំ
តំ តាទិសំ បុព្វកិច្ចំ សរន្តោ
ទុព្ភេ អហំ តស្ស កថំ ជនិន្ទ ។

---

១ ម. បោរិសាទស្ស បន្តេ ។

បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គស្តាប់នូវគាថា ដែលមានប្រយោជន៍របស់ទាសៈនៃខ្លួន ក្នុងកាលណា ក្នុងកាលណោះ ខ្ញុំព្រះអង្គតែងផ្ទៀងស្តាប់នូវគាថានោះឯងដោយគោរព បពិត្រព្រះបិតា ខ្ញុំព្រះអង្គមិនមានសេចក្តីឆ្អែត ក្នុងធម៌ទាំងឡាយទេ ។

(៣៨៦) ផែនរបស់ព្រះអង្គនេះ ព្រមទាំងទ្រព្យ ព្រមទាំងយាន ព្រមទាំងគ្រឿងប្រដាប់កាយ បរិបូណ៌ដោយវត្ថុ គួរប្រាថ្នាគ្រប់យ៉ាង ព្រះអង្គដេរប្រទេចខ្ញុំព្រះអង្គ ព្រោះហេតុនៃសេចក្តីប្រាថ្នាដូចម្តេច ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់នៃព្រះបាទពោរិសាទ ។

(៣៨៧) (ព្រះបិតា...) ដ្បិតពួកពលទាំងនុ៎ះ គឺពលដំរី ពលរថ ពលថ្មើរជើង ពលសេះ នឹងខ្លាន់ខ្លួ ក៏មានសម្រាប់រក្សាខ្លួន យើងនឹងលើកពលសេនាទៅសម្លាប់សត្រូវ ។

(៣៨៨) (ព្រះបាទសុតសោម...) ព្រះបាទពោរិសាទ បានធ្វើនូវអំពើដ៏កម្រក្រៃលែង ចាប់ខ្ញុំព្រះអង្គទាំងរស់ ហើយលែងវិញ បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ រឭកឃើញនូវឧបការគុណក្នុងកាលមុនប្រាកដដូច្នោះ ខ្ញុំនឹងប្រទូស្តចំពោះស្តេចពោរិសាទនោះដូចម្តេចកើត ។

## អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

(៣៨៩) វន្ទិត្វា សោ បិតរំ មាតរញ្ច
អនុសាសេត្វា នេគមញ្ច ពលញ្ច
សច្ចវាទី សច្ចានុរក្ខមានោ
អគមាសិ សោ យត្ថ ពោរិសាទោ ។

(៣៩០) កតោ មយា សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាគតោស្មិ
យជស្សុ យញ្ញំ ខាទ មំ ពោរិសាទ ។

(៣៩១) ន ហាយតេ ខាទិតុំ មយ្ហំ បច្ឆា
ចិតកា អយំ តាវ សធូមកា ច
និទ្ធូមកេ បចិតំ សាធុ បក្កំ
សុណោម គាថាយោ សតារហាយោ ។

(៣៩២) អធម្មិកោ ត្វំ បោរិសាទកាសិ
រដ្ឋា ច ភដ្ឋោ ឧទរស្ស ហេតុ
ធម្មញ្ចិមា អភិវទន្តិ គាថា
ធម្មោ អធម្មោ ច កុហឹ សមេតិ ។

(៣៨៩) ( អភិសម្ពុទ្ធគាថា ) ព្រះបាទសុតសោម ក្រាបថ្វាយបង្គំលាព្រះបិតាមាតា ប្រៀនប្រដៅអ្នកនិគមនិងពលសេនា ព្រះអង្គពោលនូវពាក្យសច្ចៈ រក្សានូវពាក្យសច្ចៈ ហើយក៏ទៅកាន់សំណាក់នៃព្រះបាទពោរិសាទ ។

(៣៩០) ( ព្រះបាទសុតសោម... ) ការប្តេជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ ដោះប្តេជ្ញានឹងព្រាហ្មណ៍ហើយត្រឡប់មកវិញ បពិត្រព្រះបាទពោរិសាទ ចូរព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ។

(៣៩១) ( ព្រះបាទពោរិសាទ... ) ទ្រង់មិនបាត់ទេ ចាំខ្ញុំស៊ីជាខាងក្រោយចុះ ព្រោះជើងក្ករនេះ ប្រកបដោយផ្សែងនៅឡើយ សាច់ដែលចំអិន លើភ្លើងឥតផ្សែង ជាសាច់ឆ្អិនល្អ យើងនឹងស្តាប់នូវគាថារបស់ទ្រង់ ដែលគួរដល់ថ្លៃ ១០០ កហាបណៈ សិន ។

(៣៩២) ( ព្រះបាទសុតសោម... ) ព្រះអង្គជាអធម្មិករាជ ជាអ្នកស៊ីនូវបុរសខ្ចាត់ក្ចាត់អំពីដែន ព្រោះហេតុតែពោះ គាថាទាំងឡាយនេះ រមែងប្រកាសសុចរិតធម៌ ចំណែកធម៌នឹងអធម៌ ស្របគ្នាក្នុងទីណាកើត ។

អធម្មិកស្ស លុទ្ទស្ស ចិត្តំ លោហិតបាណិនោ
នត្ថិ សច្ចំ កុតោ ធម្មោ កឹ សុតេន ករិស្សសិ ។

(៣៩៣) យោ មំសហេតុ មិគវំ ចរេយ្យ(១)
យោ វា ហនេ(២) បុរិសមត្តហេតុ
ឧភោបិ តេ បេច្ច សមា ភវន្តិ
កស្មា នោ អធម្មិកំ ព្រូសិ មំ ត្វំ ។

(៣៩៤) បញ្ច បញ្ច នខា ភក្ខា ខត្តិយេន បជានតា
អភក្ខំ រាជ ភក្ខេសិ តស្មា អធម្មិកោ តុវំ ។

(៣៩៥) មុត្តោ តុវំ ពោរិសាទស្ស ហត្ថា
គន្ត្វា សកំ មន្ទិរំ កាមកាមី
អមិត្តហត្ថំ បុនរាគតោសិ
ន ខត្តធម្មេ កុសលោសិ រាជ ។

(៣៩៦) យេ ខត្តធម្មេ កុសលា ភវន្តិ
បាយេន តេ នេរយិកា ភវន្តិ

---

១–២ ហនេយ្យ ។ អដ្ឋកថា ។

ព្រះអង្គជាអធម្មិករាជ ព្រះហស្តប្រឡាក់ឈាមជានិច្ច មិនមានសច្ចៈ ធម៌នឹងមានមកអំពីណា ព្រះអង្គនឹងធ្វើអ្វីដោយការស្តាប់ ។

(៣៩៣) (ព្រះបាទពោរិសាទ...) បុគ្គលណាត្រាច់ទៅកាន់ទីសម្លាប់ម្រឹគព្រោះហេតុតែសាច់ ឬសម្លាប់បុរសព្រោះហេតុតែខ្លួន បុគ្គលទាំងពីរនោះ ស្មើគ្នាក្នុងលោកខាងមុខ ហេតុអ្វីព្រះអង្គហៅខ្ញុំថាជាអធម្មិករាជ ។

(៣៩៤) (ព្រះបាទសុតសោម...) ក្សត្រិយ៍ជាអ្នកចេះដឹង មិនគួរសោយនូវពួកសត្វ ៥ នឹង ៥ ទេ បពិត្រព្រះរាជា ព្រះអង្គសោយនូវសាច់ដែលមិនគួរសោយ ព្រោះហេតុនោះ ទើបព្រះអង្គឈ្មោះថាជាអធម្មិករាជ ។

(៣៩៥) (ព្រះបាទពោរិសាទ...) លោកបានរួចអំពីដៃពោរិសាទហើយ ទៅកាន់មន្ទីររបស់ខ្លួនតាមសេចក្តីប្រាថ្នា ហើយត្រឡប់មករកដៃរបស់សត្រូវវិញ បពិត្រព្រះរាជា ព្រះអង្គជាបុគ្គលមិនឈ្លាសក្នុងខត្តិយធម៌ទេ ។

(៣៩៦) (ព្រះបាទសុតសោម...) ពួកបុគ្គលណា ជាអ្នកឈ្លាសក្នុងខត្តិយធម៌ ពួកបុគ្គលនោះ ច្រើនតែធ្លាក់ទៅក្នុងនរក

តស្មា អហំ ខត្យធម្មំ បហាយ
សច្ចានុរក្ខី បុនរាគតោស្មិ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
(៣៨៧) បាសាទវាសា បថវីគតស្មា
កាមិត្ថិយោ កាសិកចន្ទនញ្ច
សព្វំ តហឹ លភសិ សាមិតាយ
សច្ចេន កឹ បស្សសិ អានិសំសំ ។
(៣៨៨) យេ កេចិមេ អត្ថិ រសា បថព្យា
សច្ចំ តេសំ សាធុតរំ រសានំ
សច្ចេ ឋិតា សមណព្រាហ្មណា ច
តរន្តិ ជាតិមរណស្ស បារំ ។
(៣៨៩) មុត្តោ តុវំ បោរិសាទស្ស ហត្ថា
គន្ត្វា សកំ មន្ទិរំ កាមកាមី
អមិត្តហត្ថំ បុនរាគតោសិ
នហិ នូន តេ មរណភយំ ជនិន្ទ
អលីនចិត្តោ ចសិ សច្ចវាទី ។

ព្រោះហេតុនោះ បានជាខ្ញុំលះបង់នូវខត្តិយធម៌ ជាអ្នករក្សានូវសច្ចៈ ត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ។

[៣៩៧] (ព្រះបាទបោរិសាទ...) ប្រាសាទជាទីនៅលើផែនដី គោនិងសេះ ពួកស្រីដែលគួរប្រាថ្នា និងខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រង់បាននូវវត្ថុទាំងអស់ ក្នុងទីនោះ ដោយភាពជាម្ចាស់ ចុះទ្រង់ឃើញនូវអានិសង្សនៃពាក្យសច្ចៈ ដូចម្តេច ។

[៣៩៨] (ព្រះបាទសុតសោម...) រសឯណានីមួយ មាននៅលើផែនដី សច្ចៈ ជារសល្អក្រៃលែងជាងរសទាំងឡាយនោះ ពួកសមណៈនិងព្រាហ្មណ៍ ដែលតាំងនៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិនិងមរណៈបាន ។

[៣៩៩] (ព្រះបាទបោរិសាទ...) ទ្រង់បានរួចអំពីដៃបោរិសាទហើយ បានទៅកាន់មន្ទីរ របស់ខ្លួនវិញ តាមសេចក្តីប្រាថ្នា ត្រឡប់មករកដៃសត្រូវវិញ បពិត្រទ្រង់ជាធំជាងជន ភ័យអំពីសេចក្តីស្លាប់ មិនមានដល់ទ្រង់ដោយពិត ទ្រង់ជាអ្នកពោលនូវពាក្យសច្ចៈ ទាំងមានចិត្តក៏មិនរួញរា ។

[១៦០] កតា មេ កល្យាណា អនេករូបា
យញ្ញា យិដ្ឋា យេ វិបុលា បសត្ថា
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
កតា មេ កល្យាណា អនេករូបា
យញ្ញា យិដ្ឋា យេ វិបុលា បសត្ថា
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
បិតា ច មាតា ច ឧបដ្ឋិតា មេ
ធម្មេន មេ ឥស្សរិយំ បសត្ថំ
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
បិតា ច មាតា ច ឧបដ្ឋិតា មេ
ធម្មេន មេ ឥស្សរិយំ បសត្ថំ
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
ញាតីសុ មិត្តេសុ កតូបការោ

[៣៦០] (ព្រះបាទសុតសោម...) យ័ញ្ញ (ការបូជា) មានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញ តែងសរសើរ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅ ក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ យ័ញ្ញមានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញតែងសរសើរ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ មាតានឹងបិតា ខ្ញុំបានបំរើហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅ ក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ បិតានឹងមាតា ខ្ញុំក៏បានបម្រើហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅបរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ខ្ញុំបានធ្វើឧបការកិច្ចចំពោះពួកញាតិនឹងមិត្តហើយ

## អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

ធម្មេន មេ ឥស្សរិយំ បសត្ថំ
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
ញាតីសុ មិត្តេសុ កតូបការោ
ធម្មេន មេ ឥស្សរិយំ បសត្ថំ
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
ទិន្នំ មេ ទានំ ពហុធា ពហូនំ
សន្តប្បិតា សមណព្រាហ្មណា ច
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
ទិន្នំ មេ ទានំ ពហុធា ពហូនំ
សន្តប្បិតា សមណព្រាហ្មណា ច
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។

ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្ដីស្លាប់ ។ ខ្ញុំបានធ្វើឧបការកិច្ច បំពោះពួកញាតិនឹងមិត្តហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្ដៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទពោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងពួកសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គត់ផ្គង់ហើយ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្ដីស្លាប់ ។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គត់ផ្គង់ហើយ ខ្ញុំមិនក្ដៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទពោរិសាទ សូមទ្រង់បូជាយ័ញ្ញ សូមទ្រង់សោយខ្ញុំចុះ ។

(៣៦១) វិសំ បជានំ បុរិសោ អទេយ្យ
អាសីវិសំ ជលិតំ ឧគ្គតេជំ
មុទ្ធាបិ តស្ស វិផលេយ្យ សត្តធា
យោ តាទិសំ សច្ចភាណី អទេយ្យ ។

(៣៦២) សុត្វា ធម្មំ វិជានន្តិ នរា កល្យាណបាបកំ
អបិ គាថា សុណិត្វាន ធម្មេ មេ រមតេ មនោ ។

(៣៦៣) សកិទេវ មហារាជ សព្ភិ ហោតិ សមាគមោ
សា នំ សង្គតិ បាលេតិ នាសព្ភិ ពហុសង្គមោ ។
សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។
ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។

(៣៦១) (ព្រះបាទបោរិសាទ...) បុគ្គលណា ស៊ីនូវជនអ្នកពោលពាក្យសច្ចៈប្រាកដដូច្នោះ ក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ភាគ ដូចបុរសស្គាល់នូវថ្នាំពិស ហើយស៊ីនូវថ្នាំពិស (ឬដូចគេចាប់) ពស់អាសិរពិសដែលមានពិសកាចមានតេជះខ្លាំង ។

(៣៦២) ជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងដឹងច្បាស់នូវបុណ្យនិងបាប ប៉ុនអម្បាលចិត្តរបស់ខ្ញុំ គង់ត្រេកអរក្នុងធម៌ ព្រោះបានស្តាប់នូវគាថាទាំងឡាយ ។

(៣៦៣) (ព្រះបាទសុតសោម...) បពិត្រមហារាជ ការចួបប្រទះដោយសប្បុរសទាំងឡាយអស់វារៈតែម្តង ការជួបប្រទះនោះរមែងរក្សានូវបុគ្គលនោះបាន ការចួបជុំដោយពួកអសប្បុរស ច្រើនដងរមែងមិនរក្សាបុគ្គលបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកទេ ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រា សូម្បីសរីរៈ (របស់ពួកសត្វ) ក៏មែនដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរស មិនដល់នូវសេចក្តីគ្រាំគ្រាទេ សប្បុរសទាំងឡាយ រមែងបរទាដោយពួកសប្បុរសបាន ។

## អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

នភញ្ច ទូរេ បថវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មោ អសតញ្ច រាជ ។

(៣៦៤) គាថា ឥមា អត្ថវតី សុព្យញ្ជនា
សុភាសិតា តុយ្ហ ជនិន្ទ សុត្វា
អានន្ទិ វិត្តោ សុមនោ បតីតោ
ចត្តារិ តេ សម្ម វរេ ទទាមិ ។

(៣៦៥) យោ នត្តនោ មរណំ ពុជ្ឈសេ(១) តុវំ
ហិតាហិតំ វិនិបាតញ្ច សគ្គំ
គិទ្ធោ រសេ ទុច្ចរិតេ និវិដ្ឋោ
កឹ ត្វំ វរំ ទស្សសិ បាបធម្ម ។
អហញ្ច តំ ទេហិ វរន្តិ វជ្ជំ
ត្វញ្ចាបិ ទត្វា ន អវាករេយ្យ
សន្ទិដ្ឋិកំ កលហមិមំ វិវាទំ
កោ បណ្ឌិតោ ជានមុបព្វជេយ្យ ។

(៣៦៦) ន តំ វរំ អរហតិ ជន្តុ ទាតុំ
យំ វាបិ ទត្វា ន អវាករេយ្យ

---
១ ម. ពុជ្ឈតិ ។

អាកាសនឹងដី ឋិតនៅ ក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយបាន ពោលនូវច្រាំងសមុទ្រនោះថាឆ្ងាយ បពិត្រព្រះរាជា បណ្ឌិតទាំងឡាយ រមែងពោលថា ធម៌របស់ពួកសប្បុរស នឹងពួកអសប្បុរស ឆ្ងាយជាងនោះទៅទៀត ។

(៣៦៤) (ព្រះបាទពោរិសាទ...) បពិត្រទ្រង់ជាធំជាងជន គាថាទាំងឡាយ នេះមានអត្ថ មានព្យញ្ជនៈដ៏ល្អ ទ្រង់សំដែងពីរោះណាស់ ខ្ញុំបានស្តាប់ហើយ ក៏ត្រេកអរ រីករាយ មានចិត្តល្អជ្រះថ្លា បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំសូមថ្វាយពរ ៤ ប្រការដល់ទ្រង់ ។

(៣៦៥) (ព្រះបាទសុតសោម...) ទ្រង់មិនដឹងនូវសេចក្តីស្លាប់របស់ខ្លួន ទាំងអំពើមានប្រយោជន៍នឹងឥតប្រយោជន៍ ទាំងនរកនឹងឋានសួគ៌ទេ បពិត្រព្រះអង្គមានធម៌ដ៏លាមក ព្រះអង្គជាប់ចំពាក់ក្នុងរស (នៃសាច់មនុស្ស) តាំងនៅស៊ប់ក្នុងទុច្ចរិតធម៌ ធ្វើម្តេចនឹងឲ្យពរកើត ។ បើខ្ញុំពោលថាសូមព្រះអង្គប្រទានពរនោះ ព្រះអង្គប្រទានហើយត្រឡប់ជាមិនប្រទានវិញ តើបណ្ឌិតណាកាលដឹង នឹងហ៊ានចូលទៅរកជំលោះនឹងវិវាទដ៏ជាក់ស្តែងនេះ ។

(៣៦៦) (ព្រះបាទពោរិសាទ...) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសម្លាញ់

វស្សុ សម្ម អវិកម្បមានោ
ឆាណំ ចជិត្វានបិ ឧស្សមេវ ។

[៣៦៧] អរិយស្ស អរិយេន សមេតិ សក្ខិ[១]
បញ្ញស្ស បញ្ញាណវតា សមេតិ
បស្សេយ្យ តំ វស្សសតំ អរោគំ
ឯតំ វរានំ បឋមំ វរាមិ ។

[៣៦៨] អរិយស្ស អរិយេន សមេតិ សក្ខិ
បញ្ញស្ស បញ្ញាណវតា សមេតិ
បស្សេសិ មំ វស្សសតំ អរោគំ
ឯវំ វរានំ បឋមំ ទទាមិ ។

[៣៦៩] យេ ខត្តិយាសេ ឥធ ភូមិបាលា
មុទ្ធាភិសិត្តា កតនាមធេយ្យា
ន តាទិសេ ភូមិបតី អទេសិ
ឯតំ វរានំ ទុតិយំ វរាមិ ។

[៣៧០] យេ ខត្តិយាសេ ឥធ ភូមិបាលា
មុទ្ធាភិសិត្តា កតនាមធេយ្យា
ន តាទិសេ ភូមិបតី អទេមិ
ឯតំ វរានំ ទុតិយំ ទទាមិ ។

---

១ ម. សខ្យំ ។

សូមទ្រង់កុំញាប់ញ័រ សូមទទួល (ពរ) ចុះ ខ្ញុំសូមលះបង់ជីវិត ក៏នៅតែថ្វាយទ្រង់ ។

(៣៦៧) (ព្រះបាទសុតសោម...) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ខ្ញុំសូមឃើញព្រះអង្គមានជន្មាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ១ នុះ ។

(៣៦៨) (ព្រះបាទពោរិសាទ...) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ទ្រង់សូមឃើញនូវខ្ញុំមានអាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ១ នេះ ។

(៣៦៩) (ព្រះបាទសុតសោម...) ពួកក្សត្រិយ៍ណា រក្សាផែនដី ក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ព្រះអង្គជាម្ចាស់ផែនដី កុំសោយនូវពួកក្សត្រិយ៍ទាំងនោះឡើយ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ២ នេះ ។

(៣៧០) (ព្រះបាទពោរិសាទ...) ពួកក្សត្រិយ៍ណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ខ្ញុំជាម្ចាស់ផែនដី ក៏លែងស៊ីនូវពួកក្សត្រិយ៍ទាំងនោះដែរ បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយនូវពរទី ២ នេះ ។

## អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ

(៣៧១) បរោសតំ ខត្តិយា តេ គហីតា
តលាវុតា អស្សុមុខា រុទន្តា
សកេ តេ រដ្ឋេ បដិបាទយាហិ
ឯតំ វរានំ តតិយំ វរាមិ ។

(៣៧២) បរោសតំ ខត្តិយា មេ គហីតា
តលាវុតា អស្សុមុខា រុទន្តា
សកេ តេ រដ្ឋេ បដិបាទយាមិ
ឯតំ វរានំ តតិយំ ទទាមិ ។

(៣៧៣) ឆិទ្ទំ តេ រដ្ឋំ ព្យថិតា ភយា ហិ
បុថូ នរា លេណមនុប្បវិដ្ឋា
មនុស្សមំសំ វិរមាហិ រាជ
ឯតំ វរានំ ចតុត្ថំ វរាមិ ។

(៣៧៤) អទ្ធា ហិ សោ ភក្ខោ មមំ មនាបោ
ឯតស្ស ហេតុម្ហិ វនំ បវិដ្ឋោ
សោហំ កថំ ឯត្តោ ឧបារមេយ្យំ
អញ្ញំ វរានំ ចតុត្ថំ វរស្សុ ។

(៣៧១) (ព្រះបាទសុតសោម...) ពួកក្សត្រិយ៍ជាងរយនាក់ ដែលព្រះអង្គចាប់ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងយំ សូមព្រះអង្គឲ្យក្សត្រិយ៍ទាំងនោះ ត្រឡប់ទៅកាន់ដែនរបស់ខ្លួនវិញ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៣ នេះ ។

(៣៧២) (ព្រះបាទបោរិសាទ...) ពួកក្សត្រិយ៍ជាងរយនាក់ ដែលខ្ញុំចាប់ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងយំ ខ្ញុំនឹងឲ្យពួកក្សត្រិយ៍ទាំងនោះ ត្រឡប់ទៅកាន់ដែន របស់ខ្លួនវិញ បណ្ដាពរទាំងឡាយ ខ្ញុំនឹងឲ្យពរទី ៣ នេះ ។

(៣៧៣) (ព្រះបាទសុតសោម...) ដែនរបស់ព្រះអង្គ ជាដែនប្រហោង (មិនសូវមានប្រជាជន) ព្រោះពួកប្រជាជន ជាច្រើនញាប់ញ័រហើយ ព្រោះភ័យគ្របសង្កត់ ហើយរត់ចូលទៅកាន់ទីពឹងពួន បពិត្រព្រះរាជា សូមព្រះអង្គវៀរសាច់មនុស្សទៅ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៤ នេះ ។

(៣៧៤) (ព្រះបាទបោរិសាទ...) អាហារនោះ ជាទីពេញចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះឯង នឹងវៀរចាកសាច់មនុស្សនុ៎ះ ដូចម្ដេចបាន បណ្ដាពរទាំងឡាយ សូមទ្រង់ប្រាថ្នានូវពរទី ៤ ដទៃវិញ ។

(១៧៥) ន វេ បិយំ មេតិ ជនិន្ទ តាទិសោ
អត្តំ និរង្កត្វា បិយានិ សេវតិ
អត្តាវ សេយ្យោ បរមាវ សេយ្យោ
លព្ភា បិយា ឱចិតត្ថេន បច្ឆា ។

(១៧៦) បិយំ មេ មានុសំ មំសំ សុតសោម វិជានហិ
នម្ហិ សក្កា និវារេតុំ អញ្ញំ តុវំ សម្ម វរំ វរស្សុ ។

(១៧៧) យោ វេ បិយំ មេតិ បិយានុរក្ខី
អត្តំ និរង្កត្វា បិយានិ សេវតិ
សោណ្ឌោវ បិត្វា វិសមិស្សបានំ
តេនេវ សោ ហោតិ ទុក្ខី បរត្ថ ។
យោ ចីធ សង្ខាយ បិយានិ ហិត្វា
កិច្ឆេនបិ សេវតិ អរិយធម្មេ
ទុក្ខិតោវ បិត្វាន យថោសធានិ
តេនេវ សោ ហោតិ សុខី បរត្ថ ។

(៣៧៥) ( ព្រះបាទសុតសោម... ) បពិត្រព្រះអង្គ ជាធំជាងជន បុគ្គលប្រហែលដូចព្រះអង្គ លះបង់នូវខ្លួនពោលដោយគិតថា នេះជាទីស្រឡាញ់របស់អញដូច្នេះ រមែងមិនបានគប់រកនូវវត្ថុជាទីស្រឡាញ់ទេ ខ្លួនហ្នឹងហើយ ជាសភាវៈប្រសើរ ឈ្មោះថាប្រសើរក្រៃលែង បុគ្គលអ្នកមានចិត្តសន្សំហើយ គប្បីបាននូវគុណជាទីស្រឡាញ់ ក្នុងកាលជាខាងក្រោយ ។

(៣៧៦) (ព្រះបាទពោរិសាទ...) បពិត្រព្រះបាទសុតសោម សូមទ្រង់ជ្រាបនូវសាច់មនុស្សថាជាទីស្រឡាញ់របស់ខ្ញុំ ទ្រង់មិនអាចឃាត់ខ្ញុំបានទេ បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់ប្រាថ្នាពរឯទៀតវិញ ។

(៣៧៧) ( ព្រះបាទសុតសោម... ) បុគ្គលណាជាអ្នករក្សានូវវត្ថុជាទីស្រឡាញ់ ដោយគិតថា វត្ថុនេះជាទីស្រឡាញ់របស់អញដូច្នេះ លះបង់ខ្លួន ហើយនៅសេពគប់វត្ថុ ជាទីស្រឡាញ់ បុគ្គលនោះរមែងជាទុក្ខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចជាអ្នកលេងស្រា ផឹកទឹកស្រាដែលលាយដោយថ្នាំពិស ។ បំណែកខាងបុគ្គលណា ក្នុងលោកនេះ បានពិចារណា លះបង់នូវវត្ថុជាទីស្រឡាញ់ ហើយបែរមកគប់រកនូវអរិយធម៌ សូម្បីដោយលំបាក បុគ្គលនោះ រមែងបានសុខ ក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចបុគ្គលដល់នូវសេចក្តីទុក្ខ ព្រោះផឹកនូវឱសថ ។

(៣៧៨) ឱហាយហំ បិតរំ មាតរញ្ច
មនាបិកេ កាមគុណេហិ បញ្ច
ឯតស្ស ហេតុម្ហិ វនំ បវិដ្ឋោ
តន្តេ វរំ កិន្តិមហំ ទទាមិ ។

(៣៧៩) ន បណ្ឌិតា ទិគុណមាហុ វាក្យំ
សច្ចប្បដិញ្ញាវ ភវន្តិ សន្តោ
វរស្សុ សម្ម ឥតិ មំ អវោច
ឥច្ចព្រវី ត្វំ ន ហិ តេ សមេតិ ។

(៣៨០) អបុញ្ញលាភំ អយសំ អកិត្តិំ
បាបំ ពហុំ ទុច្ចរិតំ កិលេសំ
មនុស្សមំសស្ស កតេ ឧបាគា
តន្តេ វរំ កិន្តិមហំ ទទេយ្យំ ។

(៣៨១) ន តំ វរំ អរហតិ ជន្តុ ទាតុំ
យំ ចាបិ ទត្វា ន អវាករេយ្យ
វរស្សុ សម្ម អវិកម្បមានោ
បាណំ ចជិត្វាន បិ ទស្សមេវ ។

(៣៧៨) (ព្រះបាទពោរិសាទ...) ខ្ញុំលះបង់បិតាមាតា នឹងបញ្ចកាមគុណ ជាទីពេញចិត្ត ហើយបួសព្រៃ ព្រោះហេតុតែសាច់មនុស្សនោះ ខ្ញុំនឹងថ្វាយនូវពរនោះ ដល់ទ្រង់ ដូចម្ដេចបាន ។

(៣៧៩) (ព្រះបាទសុតសោម...) បណ្ឌិតទាំងឡាយជាសប្បុរស ជាអ្នកប្រាជ្ញ ដោយពាក្យសច្ចៈ មិនពោលនូវពាក្យពីរជាន់ទេ ព្រះអង្គបានពោលនឹងខ្ញុំថា បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់ទទួលពរចុះ ព្រះអង្គបានពោលដូច្នេះហើយ (តែពាក្យនោះ) របស់ព្រះអង្គ មិនស្របគ្នាទេ ។

(៣៨០) (ព្រះបាទពោរិសាទ...) ខ្ញុំដល់នូវភាពជាអ្នកមិនមានបុណ្យ មិនមានយស មិនមានកេរ្តិ៍ឈ្មោះ មានបាប មានទុច្ចរិត សៅហ្មងជាច្រើន ក៏ព្រោះហេតុតែសាច់មនុស្ស ខ្ញុំនឹងថ្វាយនូវពរនោះ ដល់ទ្រង់ ដូចម្ដេចកើត ។

(៣៨១) (ព្រះបាទសុតសោម...) (ទ្រង់មានបន្ទូលហើយថា) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់កុំញាប់ញ័រ សូមទទួលយក (ពរ)ចុះ ខ្ញុំសូម្បីលះបង់ជីវិត ក៏នៅតែថ្វាយទ្រង់ដែរ ។

(៣៨២) បាណំ ចជន្តិ សតានេស ធម្មោ
សច្ចប្បដិញ្ញាវ ភវន្តិ សន្តោ
ទត្វា វរំ ខិប្បមវាករោហិ
ឯតេន សម្បជ្ជស្សុ រាជសេដ្ឋ ។
ចជេ ធនំ អង្គវរស្ស ហេតុ
អង្គំ ចជេ ជីវិតំ រក្ខមានោ
អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ
ចជេ នរោ ធម្មមនុស្សរន្តោ ។
(៣៨៣) យស្មា ហិ ធម្មំ បុរិសោ វិជញ្ញា
យេ ចស្ស កង្ខំ វិនយន្តិ សន្តោ
តញ្ហិស្ស ទីបញ្ច បរាយនញ្ច
ន តេន មេត្តិំ ជិរយេថ បញ្ញោ ។
(៣៨៤) អទ្ធា ហិ សោ ភក្ខោ មម មនាបោ
ឯតស្ស ហេតុម្ហិ វនំ បវិដ្ឋោ
សចេ ច មំ យាចសិ ឯតមត្ថំ
ឯតំបិ តេ សម្ម វរំ ទទាមិ ។

១ ម. សន្តោ នាបិ ធម្មំ ។

(៣៨២) នុ៎ះជាធម៌ របស់ពួកសប្បុរស ធម្មតាពួកសប្បុរស ជាអ្នកប្តេជ្ញាដោយពាក្យសច្ចៈ តែងលះបង់នូវជីវិត ព្រះអង្គឲ្យពរហើយ ចូរឲ្យរហ័ស បពិត្រព្រះរាជដ៏ប្រសើរ សូមព្រះអង្គសម្រេចដោយធម៌នឹងពាក្យសច្ចៈនុ៎ះចុះ ។ ជនគប្បីលះបង់នូវទ្រព្យ ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលបើរក្សានូវជីវិតក៏គប្បីលះបង់នូវអវយវៈ កាលបើរឭកឃើញនូវធម៌ គប្បីលះបង់ទាំងអវយវៈទ្រព្យនឹងជីវិតទាំងអស់ ។

(៣៨៣) បុរសចេះដឹង នូវធម៌អំពីបុគ្គលណា ឬក៏ពួកសប្បុរសណា បន្ទោបង់នូវសេចក្តីសង្ស័យ របស់បុគ្គលនោះបាន ដំណើរនោះ ឈ្មោះថាជាទីពឹង ជាទីពំនាក់ របស់បុគ្គលនោះ បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវបំបាត់មេត្រីចិត្តអំពីបុគ្គលនោះទេ ។

(៣៨៤) (ព្រះបាទបោរិសាទ...) អាហារនោះ ជាទីគាប់ចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះ បើទ្រង់ទទួលសូមសេចក្តីនុ៎ះនឹងខ្ញុំ បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំក៏ឲ្យពរនោះ ដល់ទ្រង់ ។

(៣៨៥) សត្តា ច មេ ហោសិ សខា ច មេសិ
វចនំបិ តេ សម្ម អហំ អកាសឹ
តុវំបិ មេ សម្ម ករោហិ វាក្យំ
ឧភោបិ គន្ត្វាន បមោចយាម ។
(៣៨៦) សត្តា ច តេ ហោមិ សខា ច ត្យម្ហិ
វចនំបិ មេ សម្ម តុវំ អកាសិ
អហំបិ តេ សម្ម ករោមិ វាក្យំ
ឧភោបិ គន្ត្វាន បមោចយាម ។
(៣៨៧) កម្មាសបាទេន វិហេឋិតម្ហា
តលាវុតា អស្សុមុខា រុទន្តា
ន ជាតុ ទុព្ភេថ ឥមស្ស រញ្ញោ
សច្ចប្បដិញ្ញំ មេ បដិស្សុណាថ ។
(៣៨៨) កម្មាសបាទេន វិហេឋិតម្ហា
តលាវុតា អស្សុមុខា រុទន្តា
ន ជាតុ ទុព្ភេម ឥមស្ស រញ្ញោ
សច្ចប្បដិញ្ញំ តេ បដិស្សុណាម ។

(៣៨៥) ព្រះអង្គជាសាស្តា របស់ខ្ញុំផង ជាសំឡាញ់ របស់ខ្ញុំផង បពិត្រព្រះអង្គជាសំឡាញ់ ខ្ញុំនឹងធ្វើតាមព្រះឱង្ការ របស់ព្រះអង្គ ព្រះអង្គក៏ចូរធ្វើតាមពាក្យរបស់ខ្ញុំដែរ យើងទាំងពីរនាក់ ទៅដោះលែង (ពួកក្សត្រិយ៍ទាំងនោះជាមួយគ្នា) ។

(៣៨៦) (ព្រះបាទសុតសោម...) ខ្ញុំជាសាស្តារបស់ព្រះអង្គផង ជាសំឡាញ់របស់ព្រះអង្គផង បពិត្រព្រះអង្គជាសំឡាញ់ បើព្រះអង្គធ្វើតាមពាក្យខ្ញុំ ទាំងខ្ញុំក៏ធ្វើតាមពាក្យព្រះអង្គដែរ យើងទាំងពីរនាក់ទៅដោះលែង (ពួកក្សត្រិយ៍ទាំងនោះជាមួយគ្នា) ។

(៣៨៧) ពួកយើងដែលត្រូវព្រះរាជាជើងពពាល បៀតបៀនដោតបាតដៃ មានមុខជោកដោយទឹកភ្នែក ស្រែកយំ (ឥឡូវនេះ) អ្នកទាំងឡាយ លែងប្រទូស្តនឹងព្រះរាជានេះចុះ អ្នកទាំងឡាយចូរទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់ របស់ខ្ញុំចុះ ។

(៣៨៨) (ពួកក្សត្រិយ៍...) ពួកយើងដែលត្រូវព្រះរាជាជើងពពាល បៀតបៀនដោតបាតដៃ មានមុខជោកដោយទឹកភ្នែក ស្រែកយំ (ឥឡូវនេះ) ពួកយើងមិនប្រទូស្ត ចំពោះព្រះរាជានេះទេ ពួកយើងនឹងទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់ របស់ព្រះអង្គ ។

(៣៨៩) យថា បិតា វា អថវាបិ មាតា
អនុកម្បកា អត្ថកាមា បជានំ
ឯវម្បិ វោ ហោតុ អយញ្ច រាជា
តុម្ហេ ច វោ ហោថ យថេវ បុត្តា ។

(៣៩០) យថា បិតា វា អថវាបិ មាតា
អនុកម្បកា អត្ថកាមា បជានំ
ឯវម្បិ នោ ហោតុ អយញ្ច រាជា
មយម្បិ ហេស្សាម យថេវ បុត្តា ។

(៣៩១) ចតុប្បទំ សកុណញ្ចាបិ មំសំ
សូទេហិ រន្ធំ សុកតំ សុនិដ្ឋិតំ
សុធំវ ឥន្ទោ បរិភុញ្ជិយានោ
ហិត្វា កថេកោ រមសី អរញ្ញេ ។
តា ខត្តិយា វេល្លិវិលាកមជ្ឈា
អលង្កតា សម្បរិវារយិត្វា
ឥន្ទំវ ទេវេសុ បមោទយិំសុ
ហិត្វា កថេកោ រមសី អរញ្ញេ ។

[៣៨៩] (ព្រះបាទសុតសោម...) បិតា ឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចំរើន ដល់បុត្រទាំងឡាយ យ៉ាងណាមិញ បំណែកព្រះរាជានេះ ចូរមានដល់លោកទាំងឡាយ ក៏យ៉ាងនោះដែរ ទាំងលោកទាំងឡាយ ក៏សូមដូចជាបុត្ត ។

[៣៩០] (ពួកក្សត្រិយ៍...) បិតា ឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចំរើន ដល់បុត្តទាំងឡាយ យ៉ាងណាមិញ បំណែកខាងព្រះរាជានេះ ចូរមានដល់យើងទាំងឡាយ យ៉ាងនោះដែរ ទាំងពួកយើងក៏ដូចបុត្តដែរ ។

[៣៩១] (ព្រះបាទសុតសោម...) ព្រះអង្គធ្លាប់សោយនូវសាច់នៃសត្វជើង ៤ ឬសត្វបក្សី ដែលពួកនាយពិសេសបាត់ចែងល្អ សម្រេចដោយល្អ ជាទីត្រេកអរ ដូចព្រះឥន្ទ្រ សោយនូវសុធាភោជន ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្តេចកើត ។ ពួកនាងខត្តិយានីនោះ មានគ្រឿងប្រដាប់ភ្លឺផ្លេក និងចង្កេះដំរៀវ ពាក់តែងខ្លួនគាល់គ្រៀបគ្រា ញុំាងព្រះអង្គឲ្យរីករាយ ដូចជាស្រីអប្សរ បំរើព្រះឥន្ទ្រក្នុងទេវលោក ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្តេចកើត ។

តម្ហិ ជាតេ ពហុកោណាកម្ហិ
សុកម្ហិ សព្វសយនម្ហិលង្គេ(១)
សយេនស្ស មជ្ឈម្ហិ សុខំ សយិត្វា
ហិត្វា កថេកោ រមសិ អរញ្ញេ ។
ឆាណិស្សរំ កុម្ភថូណំ និសីថេ
អថោបិ វេ និប្បុរិសំបិ តូរិយំ
ពហុំ សុគីតញ្ច សុវាទិតញ្ច
ហិត្វា កថេកោ រមសិ អរញ្ញេ ។
ឧយ្យានសម្បន្នបហូតមាល្យំ
មិគាជិនូបេតបុរំ សុរម្មំ
ហយេហិ នាគេហិ រថេហុបេតំ
ហិត្វា កថេកោ រមសិ អរញ្ញេ ។

(៣៩២) កាឡបក្ខេ យថា ចន្ទោ ហាយតេវ សុវេ សុវេ
កាឡបក្ខូបមោ រាជ អសតំ ហោតិ សមាគមោ ។
យថាហំ រសកមាគម្ម សូទំ កាបុរិសាធមំ
អកាសឹ ឆាបកំ ជម្មំ(២) យេន គច្ឆាមិ ទុគ្គតឹ ។

---

១ ម. សព្វស្សយនម្ហិសង្គោ ។ ២ ម. ឃាបកំ កម្មំ ។

ព្រះអគ្គីផុំលើព្រះបន្ទំ មានខ្នើយពណ៌ក្រហម មានព្រំមានពេម ច្រើន ដែលគាក់តែងក្នុងទីព្រះបន្ទំទាំងអស់ ដ៏ល្អជាសុខសប្បាយ ក្នុងទីពាក់កណ្ដាលនៃព្រះបន្ទំ ហើយលះបង់ចោល ត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត ។ ក្នុងវេលារាត្រី មានសូរសំឡេងគងនឹងស្គរ ទាំងតូរ្យតន្ត្រី ឥតមានបុរសនៅលាយ មានទាំងចម្រៀងដ៏ពីរោះ នឹងប្រគំក៏ពីរោះជាច្រើនយ៉ាង ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត ។ ឧទ្យាន (ឈ្មោះមិគាជិន) ក៏មានផ្កាច្រើនបរិបូណ៌ បុរីប្រកបដោយឈ្មោះតាមឧទ្យានមិគាជិន ជាបុរីគួរជាទីសប្បាយក្រៃពេក សម្បូរដោយពាហណៈ សេះ ដំរី រថ ព្រះអង្គលះបង់ចោលបេ ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្ដេចកើត ។

[៣៩២] (ព្រះបាទពោរិសាទ...) ព្រះចន្ទក្នុងកាឡបក្ខ (រនោច) រមែងអស់ទៅកល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការសមាគមនឹងពួកអសប្បុរស ឧបមាដូចព្រះចន្ទ្រ ក្នុងកាឡបក្ខ ។ ដូចយ៉ាងខ្ញុំ អាស្រ័យសេកៈអ្នកស្លដណ្ដាំ ជាបុរសអាក្រក់លាមក ហើយបានធ្វើនូវកម្មអាក្រក់ ជាហេតុទៅកាន់ទុគ្គតិ ។

សុក្កបក្ខេ យថា ចន្ទោ    វឌ្ឍតេ សុវេ សុវេ
សុក្កបក្ខូបមោ រាជ    សតំ ហោតិ សមាគមោ ។
យថាហំ តុម្ហមាគម្ម    សុតសោម វិជានហិ
កាហាមិ កុសលំ កម្មំ    យេន គច្ឆាមិ សុគ្គតឹ ។

ថលេ យថា វារិ ជនិន្ទ វុដ្ឋំ
អនទ្ធនេយ្យំ ន ចិរដ្ឋិតីកំ
ឯវំបិ មេ ហោតិ អសតំ សមាគមោ
អនទ្ធនេយ្យោ ឧទកំ ថលេវ ។
សរេ យថា វារិ ជនិន្ទ វុដ្ឋំ
ចិរដ្ឋិតីកំ នរវីរសេដ្ឋ
ឯវំបិ មេ ហោតិ សតំ សមាគមោ
ចិរដ្ឋិតីកោ ឧទកំ សរេវ ។
អព្យាយិកោ ហោតិ សតំ សមាគមោ
យាវម្បិ តិដ្ឋេយ្យ តថេវ ហោតិ
ខិប្បំ ហិ វេតិ អសតំ សមាគមោ
តស្មា សតំ ធម្មោ អសព្ភិ អារកា ។

ព្រះចន្ទ្រក្នុងសុក្កបក្ខ រមែងចំរើនឡើងរាល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការជួបប្រទះនឹងពួកសប្បុរស ក៏ឧបមាដូចជាព្រះចន្ទ្រក្នុងសុក្កបក្ខ ។ បពិត្រព្រះបាទសុតសោម សូមព្រះអង្គជ្រាបចុះ ដូចយ៉ាងខ្ញុំ អាស្រ័យព្រះអង្គ ហើយធ្វើការកុសល ជាហេតុទៅកាន់សុគតិ ។

បពិត្រព្រះអង្គជាធំជាងជន ទឹកដែលបង្អុរចុះលើទីទួល មិនដក់នៅ មិនឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកអសប្បុរសរបស់ខ្ញុំ មិនតាំងនៅអស់កាលយូរ ដូចទឹកលើទីទួលយ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រសើរជាងជន ទឹកដែលបង្អុរចុះក្នុងស្រះ ឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកសប្បុរសរបស់ខ្ញុំ ឋិតនៅអស់កាលយូរ ដូចទឹកក្នុងស្រះ យ៉ាងនោះដែរ ។ សមាគមនឹងពួកសប្បុរស រមែងមិនឃ្លាតចេញទេ គប្បីឋិតនៅដរាបអស់ជីវិត ការសមាគមនឹងពួកអសប្បុរស រមែងវិនាសទៅឆាប់ ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស រមែងឆ្ងាយអំពីពួកអសប្បុរស ។

(៣៩៣) ន សោ រាជា យោ អជេយ្យំ ជិនាតិ
ន សោ សខា យោ សខារំ ជិនាតិ
ន សា ភរិយា យា បតិនោ វិភេតិ
ន តេ បុត្តា យេ ន ភរន្តិ ជិណ្ណំ ។
ន សា សភា យត្ថ ន សន្តិ សន្តោ
ន តេ សន្តោ យេ ន ភណន្តិ ធម្មំ
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ ភណន្តាវ ភវន្តិ សន្តោ ។

នាភាសមានំ ជានន្តិ    មិស្សំ ពាលេហិ បណ្ឌិតំ
ភាសមានញ្ច ជានន្តិ    ទេសេន្តំ អមតំ បទំ ។
ភាសយេ ជោតយេ ធម្មំ    បគ្គណ្ហេ ឥសិនំ ធជំ
សុភាសិតទ្ធជា ឥសយោ    ធម្មោ ហិ ឥសិនំ ធជោតិ ។

សុតសោមជាតកំ បញ្ចមំ ។

(៣៩៣) (ព្រះបាទសុតសោម...) ព្រះរាជាណា ផ្ចាញ់នូវបុគ្គល មិនគួរផ្ចាញ់ (មាតាបិតា) ព្រះរាជានោះ មិនមែនជាព្រះរាជាទេ សំឡាញ់ណា ផ្ចាញ់នូវសំឡាញ់ សំឡាញ់នោះ មិនមែនជាសំឡាញ់ទេ ភរិយាណា មិនខ្លាចប្ដី ភរិយានោះមិនមែនជាភរិយាទេ ពួកបុត្រណា មិនចិញ្ចឹមមាតាបិតា ជាបុគ្គលចាស់ទុំ ពួកបុត្រនោះ មិនមែនជាកូនទេ ។ ពួកសប្បុរសមិនមានក្នុងទីប្រជុំណា ទីនោះ មិនមែនទីប្រជុំទេ ពួកជនណាមិនពោលនូវធម៌ ពួកជននោះ មិនមែនជាសប្បុរសទេ លុះតែពួកជន លះបង់នូវរាគៈ ទោសៈ និងមោហៈ ហើយពោលនូវធម៌ទើបឈ្មោះថា សប្បុរស ។

បណ្ឌិតកាលបើមិនពោល (នូវធម៌) ជាអ្នកច្រឡូកច្រឡំ ដោយពួកជនពាល ពួកអ្នកផងរមែងស្គាល់មិនបាន លុះតែពោលសំដែងនូវអមតបទ ទើបពួកអ្នកផងស្គាល់បាន ។ បណ្ឌិតគប្បីពោលបំភ្លឺនូវធម៌ ផ្គងឡើងនូវធម៌ ជាទង់ជ័យនៃពួកឥសី ពួកឥសីមានសុភាសិតជាទង់ជ័យ ព្រោះជាធម៌ទុកដូចជាទង់ជ័យនៃពួកឥសី ។

ចប់ សុតសោមជាតក ទី ៥ ។

## តស្សុទ្ទានំ

សុមុខោ បន ហំសវរោ ច មហា
សុធភោជនិកោ ច បរោ បវរោ
សកុណាលទិជាធិបតិវ្ហយនោ
សុតសោមវរុត្តមសវ្ហយនោ ។

អសីតិនិបាតំ និដ្ឋិតំ ។

# ឧទ្ទាននៃជាតកនោះគឺ

ចុល្លហង្សឈ្មោះសុមុខៈ ១ មហាហង្សដ៏ប្រសើរ ១ តាបសឲ្យនូវសុធាភោជនដ៏ប្រសើរដទៃ ១ ស្តេចបក្សីឈ្មោះកុណាល ១ ព្រះរាជាដ៏ប្រសើរព្រះនាមសុតសោម ១ ។

ចប់ អសីតិនិបាត ។

# សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស

## ជាតកំ

## ទសមោ ភាគោ


| | បញ្ញាសនិបាតជាតកំ | អង្កេ |
| --- | --- | --- |
| បញ្ញាសនិបាតេ | បឋមំ និឡិនិកាជាតកំ . . . . . . . | ១ |
| | ទុតិយំ ឧម្មាទន្តីជាតកំ . . . . . . . | ១៤ |
| | តតិយំ មហាពោធិជាតកំ . . . . . . | ៣០ |
| | **សដ្ឋិនិបាតជាតកំ** | |
| សដ្ឋិនិបាតេ | បឋមំ សោណកជាតកំ . . . . . . | ៤២ |
| | ទុតិយំ សង្កិច្ចជាតកំ . . . . . . | ៥៤ |
| | **សត្តតិនិបាតជាតកំ** | |
| សត្តតិនិបាតេ | បឋមំ កុសជាតកំ . . . . . . | ៦៤ |
| | ទុតិយំ សោណនន្ទជាតកំ . . . . . . | ៨១ |
| | **អសីតិនិបាតជាតកំ** | |
| អសីតិនិបាតេ | បឋមំ ចុល្លហំសជាតកំ . . . . . | ៩៧ |
| | ទុតិយំ មហាហំសជាតកំ . . . . . | ១១២ |
| | តតិយំ សុធាភោជនជាតកំ . . . . | ១៣១ |
| | ចតុត្ថំ កុណាលជាតកំ . . . . . | ១៥៤ |
| | បញ្ចមំ មហាសុតសោមជាតកំ . . . | ១៨៥ |

# សុត្តន្តបិដក ខុទ្ទកនិកាយ

# ជាតក

# ទសមភាគ


| | បញ្ញាសនិបាតជាតក | លេខទំព័រ |
|---|---|---|
| បញ្ញាសនិបាត | នឡិនិកាជាតក ទី ១ . . . . . . . | ១ |
| | ឧម្មាទន្តីជាតក ទី ២ . . . . . . . | ១៤ |
| | មហាពោធិជាតក ទី ៣ . . . . . | ៣០ |
| | **សដ្ឋិនិបាតជាតក** | |
| សដ្ឋិនិបាត | សោណកជាតក ទី ១ . . . . . . . | ៤២ |
| | សង្កិច្ចជាតក ទី ២ . . . . . . . . | ៥៤ |
| | **សត្តតិនិបាតជាតក** | |
| សត្តតិនិបាត | កុសជាតក ទី ១ . . . . . . . . | ៦៤ |
| | សោណនន្ទជាតក ទី ២ . . . . . . | ៨១ |
| | **អសីតិនិបាតជាតក** | |
| អសីតិនិបាត | ចុល្លហំសជាតក ទី ១ . . . . . . | ៩៧ |
| | មហាហំសជាតក ទី ២ . . . . . . | ១១២ |
| | សុធាភោជនជាតក ទី ៣ . . . . . | ១៣១ |
| | កុណាលជាតក ទី ៤ . . . . . . | ១៥៤ |
| | មហាសុតសោមជាតក ទី ៥ . . . . | ១៨៩ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រដ្ឋុលេខាយំ |
|---|---|---|---|
| ភិន្ទានិ | ភិន្នានិ | ៦ | ១២ |
| សុត្តន្តបិដកេ ខុទ្ទក- | បញ្ញាសនិបាតេ ទុតិយំ | | |
| និកាយស្ស ជាតកំ | ទម្មាទន្តី ជាតកំ | ១៥ | ១ |
| ពីជព្ទស្ស | ពីជព្ហស្ស | ៣៩ | ១៥ |
| នយ្យាទយាមិ | និយ្យាទយាមិ | ៤៨ | ១១ |
| សុសេស្យាណ | សុសេស្យាណ៍ | ៦៥ | ៣ |
| លកាមំ | សកាមំ | ″ | ៦ |
| សុត្តន្តបិដកេ ខុទ្ទក- | សត្តតិនិបាតេ បឋមំ | | |
| និកាយស្ស ជាតកំ | កុសជាតកំ | ៧១ | ១ |
| សត្តតីនិបាតេ | សត្តតិនិបាតេ | ៨៣ | ១ |
| សំសយ | សំសយំ | ១១៩ | ៥ |
| កុ លេ | កុសលេ | ១២៨ | ១០ |
| មិតី | មិគី | ១៤២ | ១៨ |
| មសា | មុសា | ១៤៥ | ៤ |
| ហាកេ | ហោកេ | ១៤៥ | ៥ |
| សម្ពោជ្ឈា | សម្ពុជ្ឈា | ១៥៤ | ២ |

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | បត្តេ | រជ្ជុលេខាយំ |
|---|---|---|---|
| លម្ភមានេ | លព្ភមានេ | ១៧២ | ៦ |
| ចណាចលំ | ចលាចលំ | ១៧៨ | ៨ |
| ករេយ្យ | ករេយ្យុ | ១៩៥ | ៥ |
| បចត្តមេវ | បច្ចត្តមេវ | ១៩៥ | ៦ |
| ទុតិយ | ទុតិយំ | ២០៨ | ១៩ |
| អនទ្ឋនេយ្យំ | អនទ្ធនេយ្យំ | ២១២ | ៧ |
| អសីតិនិបាតេ បញ្ចមំ មហាសុតសោមជាតកំ | សុត្តន្តបិដកេ ខុទ្ទក- និកាយស្ស ជាតកំ | ២១៨ | ១ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ឬទ្ធិ | ឫទ្ធិ | ២ | ៩ |
| ការស្វាធ្យាយ | ការស្វាយធ្យាយន៍ | ១០ | ៧ |
| ពុំមុន | ពីមុន | ,, | ៨ |
| សរីរៈកាយ | សរីរកាយ | ,, | ១២ |
| បញ្ញាសនិបាត នឡិកាជាតក ទី ១ | បញ្ញាសនិបាត ឧម្មាទន្តីជាតក ទី ២ | ១៥ | ១ |
| ប្រសារ | ប្រសា | ,, | ៣ |
| តិរិធិ | តិរីធិ | ១៧ | ៤ |
| ពូជ្រៃ | ពូរជ្រៃ | ,, | ៦ |
| ប៉ូរ | ប៉ុះ | ១៨ | ១៤ |
| ឬទ្ធិ | ឫទ្ធិ | ,, | ១៨ |
| ហឬទ័យ | ហឫទ័យ | ២២ | ៦ |
| សិរិ | សិរី | ,, | ១៧ |
| សួរស្តី | សួស្តី | ២៥ | ៨ |
| ចាត់ចងនូវឬទ្ធិ | ចាត់ចែងនូវឫទ្ធិ | ៣៤ | ៤ |
| គ្រប់គ្រង់ | គ្រប់គ្រង | ៤០ | ២ |
| តោះក | តោះក៏ | ,, | ៤ |
| ធំនិល | ធំនែល | ,, | ៥ |
| មាទ្រព្យ | មានទ្រព្យ | ៤៤ | ១៣ |
| ទុំនិក | ទុំនិក់ | ៤៥ | ១០ |
| សម្លាប | សម្លាប់ | ៦០ | ១១ |
| ហប្ទ័យ | ហឫទ័យ | ៦៨ | ៤ |
| ស្លែម | ស្លេម | ៧០ | ៥ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សត្តន្តបិដក | សុត្តន្តបិដក | ៧២ | ១ |
| មានណ្ណៈ | មានវណ្ណៈ | ៧៣ | ៤ |
| សម្បូណ៌ | សម្បូណ៌ | ៨២ | ៨ |
| បពិតគ្រ | បពិត្រ | ៨៤ | ១៧ |
| ពួកកត | ពួកភូត | ៨៩ | ១៥ |
| ទាំង នោះ | ទាំង ៤ នុ៎ះ | ៨៥ | ១៤ |
| ពិតាណា | ពិតារណា | ៩៨ | ១៦ |
| ហឫទ័យ | ហឫទ័យ | ១០៤ | ៣ |
| ព្រះអង | ព្រះអង្គ | ១១០ | ៦ |
| បង់ | បង្គំ | ១១១ | ៨ |
| ហើរចល | ហើរចូល | ១១២ | ៤ |
| ស្មើគា | ស្មើគ្នា | ១១៣ | ២ |
| បុគល | បុគ្គល | ១១៥ | ១៦ |
| ឫស្សី | ឫស្សី | ១១៩ | ៤ |
| ជិវិត | ជីវិត | ១១៩ | ៦ |
| (២ ៧) | (២៤៧) | ១៣១ | ២ |
| យ៉ាង | យ៉ាំង | ១៣៩ | ១០ |
| បរទារិក– | បរទារក– | ១៤០ | ៩ |
| អសិតិនិបាត | អសីតិនិបាត | ១៤៣ | ១ |
| មាស់ | ម្ចាស់ | ១៤៣ | ១៧ |
| បជាមិត្ត | បច្ចាមិត្ត | ១៤៣ | ១៩ |
| គ្រកល | ត្រកូល | ៦៤៥ | ៨ |
| ហារិ | ហារី | ១៥២ | ៣ |
| ហារិ | ហារី | ,, | ១០ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ហិរិទេវធីតា | ហិរីទេវធីតា | ១៤៣ | ១៧ |
| ឈ | ឈរ | ១៦៨ | ២ |
| សារក | សារ៉ក | ១៨៨ | ១៦ |
| ខ្ញំ | ខ្ញុំ | ១៩៦ | ១៤ |
| កំ មែង | កំរមែង | ២០២ | ១៦ |
| ឃ្លាត | ឃ្លាត | ២១២ | ១៤ |
| | សុត្តន្តបិដក | | |
| | ខុទ្ទកនិកាយ ជាតក | ២១៤ | ១ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ :

Printing costs were met through the gift of

**Wat. Sotoshu Fukusenji Temple**
The Rev. Seikyo Muchaku・Toki Muchaku
292 Hitokuwada, Tako-Machi, Katori-Gun, Chiba Prefecture 289-22
Japan

この本は次の方によって復刻されました。

宗教法人 曹洞宗 福泉寺 住職　無着成恭・無着とき
〒289-22　日本国千葉県香取郡多古町一鍬田292
☎0479-75-0894

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 61 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第61巻スッタンタピタカ（経部）

発　　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　　行：1994年12月８日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE